# ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ ទីក្រុងនិរន្តរភាព ២០២០-២០៣០

## សម្រាប់ក្រុងគោលដៅ ៧



*ចំណាំ៖*

រូបភាពនៅក្នុងរបាយការណ៍ជាភាសាអង់គ្លេស របស់ «ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ទីក្រុងនិរន្តរភាព ២០២០-២០៣០ សម្រាប់ក្រុងគោលដៅ ៧» ត្រូវបានរៀបចំឡើងអោយសមស្របទៅនឹងទម្រង់ភាសាអង់គ្លេស។ ដូច្នេះរូបភាពមួយចំនួនមានទ្រង់ទ្រាយនិងទីតាំងមិនដូចទាំងស្រុង តាមរូបភាពដែលមាននៅក្នុងអត្ថបទជាភាសាខ្មែរ ប៉ុន្តែរាល់អត្ថន័យទាំងអស់នៅតែរក្សាខ្លឹមសារដើមជានិច្ច។

# ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍
# ទីក្រុងនិរន្តរភាព ២០២០-២០៣០
## សម្រាប់ក្រុងគោលដៅ ៧



ក្រុងព្រះសីហនុ

# សារគន្លឹះ
# របស់សម្ដេចក្រឡាហោម ស ខេង
# ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ទីក្រុងនិរន្តរភាពឆ្នាំ២០២០-២០៣០ សម្រាប់ក្រុងគោលដៅទាំងប្រាំពីរ ដែលបានតាក់តែងឡើងនេះ គឺជាឯកសារគោលនយោបាយ និងជាឧបករណ៍ជំនួយដល់រដ្ឋបាលក្រុងសម្រាប់ប្រើប្រាស់ក្នុងការដោះស្រាយបញ្ហាប្រឈមនានាពាក់ព័ន្ធនឹងការអភិវឌ្ឍវិស័យនគរូបនីយកម្ម ការធានាបាននូវអភិបាលកិច្ចល្អ និងជាផែនទីបង្ហាញផ្លូវសម្រាប់ឆ្លើយតបទៅនឹងតម្រូវការរបស់ប្រជាជននៅមូលដ្ឋានក្នុងក្រុងគោលដៅ។ ម្យ៉ាងវិញទៀត ការរៀបចំឱ្យមានផែនការយុទ្ធសាស្ត្រនេះ ក៏ជាការបញ្ជាក់ពីការប្ដេជ្ញាចិត្តយ៉ាងមុតមាំរបស់រាជរដ្ឋាភិបាលកម្ពុជា ចំពោះចក្ខុវិស័យ និងគោលដៅអភិវឌ្ឍន៍របស់ខ្លួនដែលបានលើកឡើងនៅក្នុងយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៤ ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ ២០១៩-២០២៣ និងកម្មវិធីជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ នឹងឆ្លុះបញ្ចាំងអំពីការប្ដេជ្ញាចិត្តរបស់ក្រសួងមហាផ្ទៃ ក្នុងការអនុវត្តច្បាប់ស្ដីពី ការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ និងច្បាប់ស្ដីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់។

ខ្ញុំសង្ឃឹមថា ផែនការយុទ្ធសាស្ត្រនេះនឹងក្លាយជាឯកសារគោលនយោបាយដ៏មានតម្លៃមួយសម្រាប់រដ្ឋបាលក្រុង ក្នុងការបន្តអភិវឌ្ឍន៍ក្រុងរបស់ខ្លួនប្រកបដោយនិរន្តរភាព ដើម្បីសម្រេចបានតាមចក្ខុវិស័យ និងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ។ ជាមួយគ្នានេះ ខ្ញុំសូមស្នើឱ្យរដ្ឋបាលក្រុង ពិនិត្យលទ្ធភាពដើម្បីដាក់បញ្ចូលផែនការយុទ្ធសាស្ត្រនេះ ចូលទៅក្នុងផែនការអភិវឌ្ឍន៍ និងផែនការវិនិយោគរបស់ខ្លួន ដោយរៀបចំឱ្យបានសមស្របតាមគោលការណ៍ច្បាប់ និងលិខិតបទដ្ឋានគតិយុត្តនានាដែលមានស្រាប់របស់រាជរដ្ឋាភិបាលកម្ពុជា។

ខ្ញុំសូមថ្លែងអំណរគុណដល់ក្រសួងបរិស្ថាន អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាជាតិអភិវឌ្ឍន៍ដោយចីរភាព អគ្គនាយកដ្ឋានរដ្ឋបាលនៃក្រសួងមហាផ្ទៃ និងវិទ្យាស្ថានអភិវឌ្ឍន៍បៃតងសកល ដែលបានដឹកនាំកិច្ចខិតខំប្រឹងប្រែងនេះ ព្រមទាំងមន្ត្រីរាជការនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិទាំងអស់ដែលបានចូលរួមចំណែកក្នុងដំណើរការរៀបចំផែនការយុទ្ធសាស្ត្រនេះឡើង។ ខ្ញុំសង្ឃឹម និងជឿជាក់ថាភាគីពាក់ព័ន្ធទាំងអស់ ទាំងស្ថាប័នរាជរដ្ឋាភិបាល និងមិនមែនរដ្ឋាភិបាល ព្រមទាំងដៃគូអភិវឌ្ឍន៍ទាំងអស់នឹងបន្តចូលរួមយ៉ាងសកម្មក្នុងការអនុវត្តផែនការនេះ និងការត្រួតពិនិត្យវឌ្ឍនភាព ដើម្បីទទួលបាននូវប្រសិទ្ធភាព និងប្រសិទ្ធផល នាពេលខាងមុខ៕

ថ្ងៃ អង្គារ ០៣កើត ខែ ចេត្រ ឆ្នាំជូត ទោស័ក ព.ស.២៥៦៤

រាជធានីភ្នំពេញ ថ្ងៃទី ១៦ ខែ មីនា ឆ្នាំ២០២១

**ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ**

**សម្ដេចក្រឡាហោម ស ខេង**

# អារម្ភកថា

រាជធានី និងបណ្តាខេត្តនានា នៅកម្ពុជាបាន និងកំពុងមានការអភិវឌ្ឍយ៉ាងឆាប់រហ័ស ហើយការអភិវឌ្ឍរាជធានី និងក្រុង គឺជាកាតាលីករដ៏សំខាន់ក្នុងការអភិវឌ្ឍសេដ្ឋកិច្ចជាតិ។ ការរីកចម្រើនលើវិស័យនគរូបនីយកម្ម បានបង្កើតឱកាសការងារនិងភាពរស់នៅ និងការអភិវឌ្ឍសេដ្ឋកិច្ច។ ថ្វីបើដូច្នេះក៏ដោយ ការអភិវឌ្ឍយ៉ាងឆាប់រហ័សក្នុងរាជធានី និងក្រុង ដែលពុំទាន់មានការគ្រប់គ្រងច្បាស់លាស់ អាចនាំមកនូវបញ្ហាជាច្រើនដល់សេដ្ឋកិច្ច សង្គម បរិស្ថាន និងវប្បធម៌។ បញ្ហាទាំងនេះ គឺជាកត្តាប្រឈមដែលសព្វថ្ងៃបាន និងកំពុងកើតមាននៅតាមក្រុងមួយចំនួននៅកម្ពុជា ជាពិសេសក្នុងវិស័យសំខាន់ៗមួយចំនួនដូចជា៖ ថាមពល ទឹក និងអនាម័យ ការដឹកជញ្ជូន សំណង់អគារនិងលំនៅឋាន ការគ្រប់គ្រងសំរាមសំណល់រឹង និងប្រព័ន្ធលូទឹកកខ្វក់ និងប្រព័ន្ធបង្ហូរទឹកភ្លៀង។

ភ្នំពេញ គឺជារាជធានីនៃព្រះរាជាណាចក្រកម្ពុជា ដែលបានទទួលការចាប់អារម្មណ៍ និងយកចិត្តទុកដាក់យ៉ាងខ្លាំងចំពោះបញ្ហាទាំងនេះ ប៉ុន្តែក្រៅពីរាជធានីភ្នំពេញ យើងក៏ត្រូវផ្តោតការយកចិត្តទុកដាក់ជាសំខាន់ទៅលើការអភិវឌ្ឍប្រកបដោយចីរភាពសម្រាប់បណ្តាក្រុងផ្សេងៗទៀតផងដែរ។ កម្ពុជាបាន និងកំពុងជំរុញ ការអភិវឌ្ឍវិស័យនគរូបនីយកម្មមួយប្រកបដោយចីរភាពបរិស្ថាន និងកំណើនសេដ្ឋកិច្ចដែលមានលក្ខណៈបរិយាបន្ន។ ក្នុងន័យនេះ ខ្ញុំសូមអបអរសាទរ និងវាយតម្លៃខ្ពស់ចំពោះអគ្គលេខាធិការដ្ឋាននៃក្រុមប្រឹក្សាជាតិអភិវឌ្ឍន៍ដោយចីរភាព អគ្គនាយកដ្ឋានរដ្ឋបាលនៃក្រសួងមហាផ្ទៃ និងវិទ្យាស្ថានអភិវឌ្ឍន៍បៃតងសកល ដែលបានបង្កើត និងអនុវត្តកម្មវិធីអភិវឌ្ឍន៍ទីក្រុងនិរន្តរភាព ជាពិសេសការរៀបចំផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ទីក្រុងនិរន្តរភាព ឆ្នាំ២០២០-២០៣០ សម្រាប់ក្រុងគោលដៅទាំងចំនួន៧ ដើម្បីរួមចំណែកសម្រេចឱ្យបាននូវ ចក្ខុវិស័យក្នុងការអភិវឌ្ឍក្រុងឱ្យមានភាពធន់ទៅនឹងការប្រែប្រួលអាកាសធាតុ ការប្រើប្រាស់ធនធានប្រកបដោយប្រសិទ្ធភាព ផ្តល់គុណភាពជីវិតរស់នៅល្អប្រសើរ និងភាពសុខដុមរមនាក្នុងសង្គម។

ខ្ញុំជឿជាក់ថាផែនការយុទ្ធសាស្ត្រនេះ នឹងក្លាយជាឯកសារបង្ហាញផ្លូវដ៏មានសារៈសំខាន់មួយសម្រាប់រដ្ឋបាលថ្នាក់ក្រោមជាតិ ជាពិសេសរដ្ឋបាលក្រុង និងដៃគូអភិវឌ្ឍន៍នានា ក្នុងការគ្រប់គ្រងការអភិវឌ្ឍក្រុងប្រកបដោយនិរន្តរភាព។ ខ្ញុំសូមគាំទ្រសារគន្លឹះដ៏មានសារៈសំខាន់របស់ **សម្តេចក្រឡាហោម ស ខេង** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ក្នុងការជំរុញ និងលើកទឹកចិត្តឱ្យរដ្ឋបាលក្រុង និងស្ថាប័នពាក់ព័ន្ធគិតគូរពីការដាក់បញ្ចូលផែនការយុទ្ធសាស្ត្រ និងគម្រោងអាទិភាពចូលទៅក្នុងដំណើរការរៀបចំផែនការអភិវឌ្ឍន៍ និងផែនការវិនិយោគក្នុងដែនសមត្ថកិច្ចរបស់ខ្លួន។ ការអភិវឌ្ឍបៃតងតាមបណ្តាក្រុងនានានឹងជំរុញការអភិវឌ្ឍវិស័យនគរូបនីយកម្មប្រកបដោយតុល្យភាព និងនិរន្តរភាពនៅទូទាំងប្រទេស ដើម្បីបញ្ចៀសការប្រមូលផ្តុំកំណើននគរូបនីយកម្មដ៏ច្រើននៅតែក្នុងរាជធានីភ្នំពេញ។ ផែនការយុទ្ធសាស្ត្រនេះ នឹងក្លាយជាឧបករណ៍គោលនយោបាយដ៏សំខាន់សម្រាប់ក្រុងទាំងឡាយ ក្នុងការរួមចំណែកដល់គោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាពរបស់កម្ពុជា ជាពិសេសការឆ្លើយតបទៅនឹងការប្រែប្រួលអាកាសធាតុដែលប្រទេសកម្ពុជាជាប្រទេសមួយងាយរងគ្រោះ។

លើសពីនេះទៀត ផែនការយុទ្ធសាស្ត្រនេះ បង្កើតការយល់ដឹងរួម និងផ្ដល់ផែនទីបង្ហាញផ្លូវសម្រាប់ការអភិវឌ្ឍក្រុងប្រកបដោយនិរន្តរភាពតាមរយៈការកំណត់បានអាទិភាពរួម របស់ក្រុងនីមួយៗ ដោយសម្រិតសម្រាំងយកជាអាទិភាពចម្បងៗរបស់ខ្លួន ក្នុងការជំរុញការអភិវឌ្ឍក្រុងគោលដៅទាំង៧នេះ។ ផ្អែកលើស្មារតីនេះ ខ្ញុំសូមលើកទឹកចិត្តឱ្យបណ្ដារដ្ឋបាលក្រុងនានា និងអ្នកពាក់ព័ន្ធសំខាន់ៗដទៃទៀត បង្កើនភាពជាដៃគូក្នុងការអនុវត្តផែនការ និងការតាមដានត្រួតពិនិត្យវឌ្ឍនភាពលើការងារអភិវឌ្ឍន៍ក្រុងប្រកបដោយនិរន្តរភាព។

ខ្ញុំសូមថ្លែងអំណរគុណដល់ថ្នាក់ដឹកនាំ និងមន្ត្រីនៃអគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាជាតិអភិវឌ្ឍន៍ដោយចីរភាព អគ្គនាយកដ្ឋានរដ្ឋបាលនៃក្រសួងមហាផ្ទៃ និងវិទ្យាស្ថានអភិវឌ្ឍន៍បៃតងសកល ដែលបានរៀបចំផែនការយុទ្ធសាស្ត្រមានលក្ខណៈគ្រប់ជ្រុងជ្រោយនេះឡើង និងសូមអរគុណចំពោះការចូលរួមចំណែករបស់រដ្ឋបាលក្រុងទាំង៧ និងអ្នកពាក់ព័ន្ធដទៃទៀត នៅក្នុងអំឡុងពេលនៃដំណើរការរៀបចំផែនការយុទ្ធសាស្ត្រនេះសម្រេចបានដោយជោគជ័យ៕

ថ្ងៃ អង្គារ ៤ រោច ខែ ជេស្ឋ ឆ្នាំឆ្លូវ ត្រីស័ក ព.ស. ២៥៦៥

រាជធានីភ្នំពេញ ថ្ងៃទី ២៩ ខែ ០៦ ឆ្នាំ២០២១

**ប្រធានក្រុមប្រឹក្សាជាតិអភិវឌ្ឍន៍ដោយចីរភាព**

**និងជារដ្ឋមន្ត្រីក្រសួងបរិស្ថាន**

**សាយ សំអាល់**

# សេចក្តីថ្លែងអំណរគុណ

ការសម្រេចបាននូវផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ទីក្រុងនិរន្តរភាព ឆ្នាំ២០២០-២០៣០ សម្រាប់ក្រុងគោលដៅទាំង ៧ គឺជាលទ្ធផលនៃកិច្ចសហការរវាងក្រុមប្រឹក្សាជាតិអភិវឌ្ឍន៍ដោយចីរភាព (ក.ជ.អ.ច.) ក្រសួងមហាផ្ទៃ តាមរយៈអគ្គនាយកដ្ឋានរដ្ឋបាល និងវិទ្យាស្ថានអភិវឌ្ឍន៍បៃតងសកល (GGGI) ដោយមានការគាំទ្រផ្នែកបច្ចេកទេសពីក្រុមជំនាញការមកពីហ្គ្រូភ្លើសហនស្ត្រាផ អេអែស (Grue+Hornstrup A/S) ដែលមានទីតាំងនៅប្រទេសដាណឺម៉ាក។

ការរៀបចំផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ទីក្រុងនិរន្តរភាព ឆ្នាំ២០២០-២០៣០ សម្រាប់ក្រុងគោលដៅទាំង ៧ ដែលបានលេចចេញជារូបរាងឡើងគឺ ដោយមានការចូលរួមពីក្រសួងស្ថាប័ន រដ្ឋបាលខេត្តក្រុង មន្ទីរជំនាញពាក់ព័ន្ធ នៃខេត្តក្រុងគោលដៅ ដៃគូអភិវឌ្ឍន៍ សហគមន៍មូលដ្ឋាន អង្គការមិនមែនរដ្ឋាភិបាល ស្ថាប័នសិក្សាស្រាវជ្រាវ និងវិស័យឯកជន ដែលមានទស្សនវិស័យស្របតាមរាជរដ្ឋាភិបាល ដែលសម្លឹងឃើញអនាគតទីក្រុងរបស់យើងទាំងអស់គ្នាក្លាយជាទីក្រុង និរន្តរភាព។

សូមថ្លែងអំណរគុណដល់មន្ត្រីថ្នាក់ដឹកនាំ នៃអគ្គលេខាធិការដ្ឋាន ក.ជ.អ.ច. ក្រសួងបរិស្ថាននិងអគ្គនាយកដ្ឋានរដ្ឋបាល ក្រសួងមហាផ្ទៃ ដែលបានដឹកនាំនិងផ្តល់យោបល់ជាយុទ្ធសាស្ត្រដល់ការសិក្សា និងរៀបចំផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ទីក្រុងនិរន្តរភាព ឆ្នាំ២០២០-២០៣០ សម្រាប់ក្រុងគោលដៅទាំង ៧ ដូចខាងក្រោម៖

- **ឯកឧត្តម ទិន ពន្លក** រដ្ឋលេខាធិការក្រសួងបរិស្ថាន (អតីតអគ្គលេខាធិការ ក.ជ.អ.ច.)
- **ឯកឧត្តម វ៉ាន់ មុនីនាថ** អគ្គលេខាធិការ ក.ជ.អ.ច.
- **ឯកឧត្តម ឯ វុឌ្ឍី** អនុរដ្ឋលេខាធិការក្រសួងមហាផ្ទៃ (អតីតអគ្គលេខាធិការរង ក.ជ.អ.ច.)
- **ឯកឧត្តម កែន សេរីរដ្ឋា** អគ្គលេខាធិការរង ក.ជ.អ.ច.
- **ឯកឧត្តម ប្រាក់ សំអឿន** អគ្គនាយក នៃអគ្គនាយកដ្ឋានរដ្ឋបាល ក្រសួងមហាផ្ទៃ
- **ឯកឧត្តម ជា ប៊ុនហេង** អគ្គនាយករង នៃអគ្គនាយដ្ឋានរដ្ឋបាល ក្រសួងមហាផ្ទៃ
- **ឯកឧត្តម អ៊ឹង ផៃ** អគ្គាធិការរង នៃអគ្គាធិការដ្ឋាន ក្រសួងមហាផ្ទៃ (អតីត អនុប្រធាននាយកដ្ឋានកិច្ចការរដ្ឋបាល ក្រុង ស្រុក ឃុំ សង្កាត់)

សមាជិកក្រុមការងារអនុវត្តគម្រោងដែលបានដើរតួនាទីសំខាន់ក្នុងការសម្របសម្រួលរៀបចំនូវផែនការយុទ្ធសាស្ត្រទីក្រុងនិរន្តរភាព ឆ្នាំ២០១៩-២០៣០ សម្រាប់ក្រុងគោលដៅទាំង ៧ រួមមាន៖

- **លោក តាំង ម៉េងអៀង** ប្រធាននាយកដ្ឋានសេដ្ឋកិច្ចបៃតង នៃអគ្គលេខាធិការដ្ឋាន ក.ជ.អ.ច.
- **លោក ណុប សុខៃ** អនុប្រធាននាយកដ្ឋានសេដ្ឋកិច្ចបៃតង នៃអគ្គលេខាធិការដ្ឋាន ក.ជ.អ.ច.
- **លោក មាស ឈីវហ៊ុន** អនុប្រធាននាយកដ្ឋានកិច្ចការរដ្ឋបាលក្រុង ស្រុក ឃុំ សង្កាត់ ក្រសួងមហាផ្ទៃ
- **លោក យឹម សណ្តាប់** ប្រធានការិយាល័យ នៃនាយកដ្ឋានសេដ្ឋកិច្ចបៃតង នៃអគ្គលេខាធិការដ្ឋាន ក.ជ.អ.ច.
- **លោក សាត ស៊ីតាក់** អនុប្រធានការិយាល័យ នៃនាយកដ្ឋានសេដ្ឋកិច្ចបៃតង នៃអគ្គលេខាធិការដ្ឋាន ក.ជ.អ.ច.
- **លោកស្រី សឿង លីលី** មន្ត្រីការិយាល័យ នៃនាយកដ្ឋានសេដ្ឋកិច្ចបៃតង នៃអគ្គលេខាធិការដ្ឋាន ក.ជ.អ.ច.
- **លោក តាំង ពន្លឺ** មន្ត្រីការិយាល័យ នៃនាយកដ្ឋានសេដ្ឋកិច្ចបៃតង នៃអគ្គលេខាធិការដ្ឋាន ក.ជ.អ.ច.
- **លោក ហែម សារិន** ប្រធានការិយាល័យ នៃនាយកដ្ឋានកិច្ចការរដ្ឋបាលក្រុង ស្រុក ឃុំ សង្កាត់ ក្រសួងមហាផ្ទៃ
- **លោក សារូ រដ្ឋជាតិ** ប្រធានការិយាល័យ នៃនាយកដ្ឋានកិច្ចការរដ្ឋបាលក្រុង ស្រុក ឃុំ សង្កាត់ ក្រសួងមហាផ្ទៃ
- **លោក ហេង សេងគីម** អនុប្រធានការិយាល័យ នៃនាយកដ្ឋានកិច្ចការរដ្ឋបាលក្រុង ស្រុក ឃុំ សង្កាត់ ក្រសួងមហាផ្ទៃ

មន្ត្រី បង្គោលមកពីក្រុងគោលដៅទាំង ៧ ដែលបានដើរតួនាទីយ៉ាងសំខាន់ក្នុងការផ្តល់ទំនាក់ទំនង និងសម្របសម្រួល ក្នុងកំឡុងពេលដំណើរការរៀបចំបង្កើត និងប្រឹក្សាយោបល់សម្រាប់ផែនការយុទ្ធសាស្ត្រ នៅតាមក្រុងរបស់ខ្លួន រួមមាន៖

| ក្រុងគោលដៅ | មន្ត្រីបង្គោល |
|---|---|
| ក្រុងបាវិត | លោក សេង សិលា អភិបាលរងខេត្តស្វាយរៀង (អតីតអភិបាលក្រុងបាវិត) |
| ក្រុងសួង | លោក ជា ណារ៉ុន អភិបាលក្រុង |
| ក្រុងសៀមរាប | លោកស្រី លឹម ផល្លីកា អភិបាលរងក្រុង |
| ក្រុងកែប | លោក យន វុឌ្ឍី អភិបាលរងក្រុង |
| ក្រុងកំពង់ចាម | លោក ហ៊ាន លីណា អភិបាលរងក្រុង |
| ក្រុងបាត់ដំបង | លោក ហឿន ឌឿ អភិបាលរងក្រុង |
| ក្រុងព្រះសីហនុ | លោក អែម សារិន អភិបាលរងក្រុង |

# មាតិកា


ទំព័រ

សារគន្លឹះរបស់សម្តេចក្រឡាហោម ស ខេង III

អារម្ភកថា IV

សេចក្តីថ្លែងអំណរគុណ VI

បញ្ជីពាក្យបង្រួញ X

បញ្ជីតារាង XIII

បញ្ជីរូបភាព XIV

មូលន័យសង្ខេប XV

## ១ ការរៀបចំផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ទីក្រុងនិរន្តរភាព ១

១.១ សេចក្តីផ្តើម ១

១.២ ចក្ខុវិស័យ និងគោលដៅ ៣

១.៣ ក្របខ័ណ្ឌជាយុទ្ធសាស្ត្រ ៤

១.៣.១ ការវិភាគជាយុទ្ធសាស្ត្រ ៤

១.៣.២ ការកំណត់កម្មវត្ថុជាយុទ្ធសាស្ត្រ ៣១

១.៤ សកម្មភាពអាទិភាព ៣២

១.៥ ស្ថាប័នអនុវត្តន៍ និងយន្តការគាំទ្រ ៤៣

១.៦ ធនធានហិរញ្ញវត្ថុ ៤៦

១.៦.១ ថវិកាជាតិសម្រាប់ការអនុវត្តរបស់រដ្ឋបាលក្រុង ៤៦

១.៦.២ ជំនួយការអភិវឌ្ឍន៍ផ្លូវការ ៥៣

១.៦.៣ ការវិនិយោគពីវិស័យឯកជន ៥៥

១.៧ ការរាយការណ៍ ការតាមដាន និងវាយតម្លៃ ៥៧

## ២ ការវិភាគទិដ្ឋភាពទូទៅរបស់ក្រុងគោលដៅទាំង ៧ សម្រាប់ការអភិវឌ្ឍទីក្រុងនិរន្តរភាព ៦១

ក្រុងសៀមរាប ៦១

ក្រុងបាត់ដំបង ៦៩

ក្រុងព្រះសីហនុ ៧៧

ក្រុងកែប ៨៧

ក្រុងកំពង់ចាម ៩៥

ក្រុងបាវិត ១០៣

ក្រុងសួង ១១១

## វិធីសាស្រ្តនៃការសិក្សាស្រាវជ្រាវ និងវិភាគទិន្នន័យ ១១៧

## ពាក្យបច្ចេកទេស និងនិយមន័យ ១២៣

# បញ្ជីពាក្យបំព្រួញ

| | |
|---|---|
| ADB | : ធនាគារអភិវឌ្ឍន៍អាស៊ី |
| ASEAN | : សមាគមប្រជាជាតិអាស៊ីអាគ្នេយ៍ |
| CBT | : ទេសចរណ៍បែបសហគមន៍ |
| CBET | : អេកូទេសចរណ៍បែបសហគមន៍ |
| CCCA | : កម្មវិធីសម្ព័ន្ធភាពប្រែប្រួលអាកាសធាតុកម្ពុជា |
| CDC | : ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា |
| CS | : ឃុំសង្កាត់ |
| D&D | : វិមជ្ឈការ និងវិសហមជ្ឈការ |
| DEWATS | : ប្រព័ន្ធប្រព្រឹត្តិកម្មទឹកកខ្វក់ខ្នាតតូច |
| DM | : ស្រុកក្រុង |
| EDC | : អគ្គិសនីកម្ពុជា |
| GCF | : មូលនិធិអាកាសធាតុបៃតង |
| GDP | : ផលិតផលក្នុងស្រុកសរុប |
| GEF | : មូលនិធិបរិស្ថានសកល |
| GGGI | : វិទ្យាស្ថានអភិវឌ្ឍន៍បៃតងសកល |
| GNP | : ផលិតផលជាតិសរុប |
| GNI | : កំណើនចំណូលជាតិសរុប |
| HHs | : ចំនួនគ្រួសារ |
| IDP | : គោលនយោបាយអភិវឌ្ឍន៍ឧស្សាហកម្ម |
| IFC | : សាជីវកម្មហិរញ្ញវត្ថុអន្តរជាតិ |

| | |
|---|---|
| **LDCF** | : មូលនិធិសម្រាប់ប្រទេសមានការអភិវឌ្ឍតិចតួចបំផុត |
| **MEF** | : ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ |
| **MoEYS** | : ក្រសួងអប់រំ យុវជន និងកីឡា |
| **MISTI** | : ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ |
| **MLMUPC** | : ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ |
| **MME** | : ក្រសួងរ៉ែ និងថាមពល |
| **MOE** | : ក្រសួងបរិស្ថាន |
| **MOI** | : ក្រសួងមហាផ្ទៃ |
| **MOT** | : ក្រសួងទេសចរណ៍ |
| **MPWT** | : ក្រសួងសាធារណការ និងដឹកជញ្ជូន |
| **MSMEs** | : សហគ្រាសធុនតូចបំផុត តូច និងមធ្យម |
| **NCDD** | : គណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ |
| **NCDM** | : គណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយ |
| **NCSD** | : ក្រុមប្រឹក្សាជាតិអភិវឌ្ឍន៍ដោយចីរភាព (ក.ជ.អ.ច.) |
| **NDC** | : ការចូលរួមចំណែកដើម្បីអនុវត្តអនុសញ្ញាសហប្រជាជាតិស្តីពីការប្រែប្រួលអាកាសធាតុ |
| **NGOs** | : អង្គការមិនមែនរដ្ឋាភិបាល |
| **NIE** | : ស្ថាប័នអនុវត្តជាតិ |
| **NP-SNDD** | : កម្មវិធីជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ |
| **PPCR** | : កម្មវិធីសាកល្បងភាពធន់ទៅនឹងការប្រែប្រួលអាកាសធាតុ |
| **PPP** | : យន្តការភាពជាដៃគូរវាងរដ្ឋ និងឯកជន |

**PWGCCA** : ក្រុមការងារថ្នាក់ខេត្តវាយតម្លៃទីក្រុងស្អាត

**RGC** : រាជរដ្ឋាភិបាលកម្ពុជា

**SCCF** : មូលនិធិពិសេសសម្រាប់ការងារប្រែប្រួលអាកាសធាតុ

**SCSP** : ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ទីក្រុងនិរន្តរភាព

**SEZ** : តំបន់សេដ្ឋកិច្ចពិសេស

**SDGs** : គោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាព

**SGP** : កម្មវិធីជំនួយខ្នាតតូច

**SNAs** : រដ្ឋបាលថ្នាក់ក្រោមជាតិ

**SNIF** : មូលនិធិវិនិយោគរដ្ឋបាលថ្នាក់ក្រោមជាតិ

**TWG** : ក្រុមការងារបច្ចេកទេស

**UNDP** : កម្មវិធីអភិវឌ្ឍន៍សហប្រជាជាតិ

**UNEP** : កម្មវិធីបរិស្ថានសហប្រជាជាតិ

**UNESCO** : កម្មវិធីអប់រំ វិទ្យាសាស្ត្រ និងវប្បធម៌នៃអង្គការសហប្រជាជាតិ (អង្គការយូណេស្កូ)

**UNFCCC** : អនុសញ្ញាក្របខ័ណ្ឌសហប្រជាជាតិស្តីពីការប្រែប្រួលអាកាសធាតុ

**WB** : ធនាគារពិភពលោក

# បញ្ជីតារាង


ទំព័រ

តារាង ១.១. លក្ខណៈវិនិច្ឆ័យជ្រើសរើសទីក្រុង ៨

តារាង ១.២. គោលដៅរៀបចំផែនការប្រើប្រាស់ដី ពីឆ្នាំ២០១៩-២០២៣ ១០

តារាង ១.៣. ថវិកាសម្រាប់សេវាសម្អាតបរិស្ថាន ឆ្នាំ២០១៧ ១៤

តារាង ១.៤. សក្តានុពលនៃការធ្វើឱ្យប្រសើរឡើងនៃការប្រើប្រាស់ថាមពល ក្នុងវិស័យឧស្សាហកម្មប្រកបដោយប្រសិទ្ធភាព ២០

តារាង ១.៥. តំបន់សេដ្ឋកិច្ចពិសេស នៅក្នុងប្រទេសកម្ពុជា ឆ្នាំ២០១៤ ២១

តារាង ១.៦. លទ្ធភាពទទួលបានសេវាសាធារណៈ ២៥

តារាង ១.៧. តួនាទីស្ត្រី ក្នុងការធ្វើសេចក្តីសម្រេចចិត្ត ២៦

តារាង ១.៨. ថវិកាសម្រាប់រដ្ឋបាលថ្នាក់ក្រោមជាតិ ៣០

តារាង ១.៩. តួនាទីរបស់រដ្ឋបាលមូលដ្ឋានក្នុងដំណើរការរៀបចំថវិកាប្រចាំឆ្នាំ ៤៧

តារាង ១.១០. មូលនិធិក្រុង ស្រុក (លានរៀល) ៥១

តារាង ១.១១. ប្រភេទនៃហានិភ័យសម្រាប់ការវិនិយោគពីវិស័យឯកជន ៥៦

តារាង ១.១២. សូចនាករដែលស្នើឡើងសម្រាប់ការតាមដាន និងវាយតម្លៃ ៥៨

# បញ្ជីរូបភាព

ទំព័រ


រូបភាព ១.១. និន្នាការនៃចំនួនប្រជាជននៅប្រទេសកម្ពុជាពីឆ្នាំ១៩៦២-២០១៩ (លាននាក់) ១

រូបភាព ១.២. ទំនាក់ទំនងរវាងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ទីក្រុងនិរន្តរភាព និងផែនការអភិវឌ្ឍន៍ក្រុងដែលមានស្រាប់ ៣

រូបភាព ១.៣. ផែនទីប្រទេសកម្ពុជាបង្ហាញពីក្រុងទាំង ៧ដែលត្រូវបានជ្រើសរើស ៩

រូបភាព ១.៤. រចនាសម្ព័ន្ធរដ្ឋបាលថ្នាក់ក្រោមជាតិ របស់ប្រទេសកម្ពុជា ២៩

រូបភាព ១.៥. ការរៀបចំស្ថាប័នអនុវត្ត និងយន្តការគាំទ្រ (ទម្រង់គម្រូរចនាសម្ព័ន្ធដែលអាចបង្កើតឡើងតាមរយៈការពិគ្រោះយោបល់ជាមួយភាគីពាក់ព័ន្ធ) ៤៤

រូបភាព ១.៦. ចំនួនមូលនិធិឃុំ សង្កាត់ តាមឆ្នាំ (ជាលានដុល្លារសហរដ្ឋអាមេរិក) ៥០

រូបភាព ១.៧. យន្តការហិរញ្ញប្បទានដែលមានសក្ដានុពលខ្ពស់ ៥៧

# មូលន័យសង្ខេប

### អ្វីទៅជាផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ទីក្រុងនិរន្តរភាព?

ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ទីក្រុងនិរន្តរភាព ឆ្នាំ២០២០-២០៣០ គឺជាយុទ្ធសាស្ត្ររយៈពេលវែង ដែលមានទិសដៅលើកកម្ពស់ការអភិវឌ្ឍនិរន្តរភាពក្នុងក្រុងគោលដៅ ដែលមានសក្តានុពលមួយចំនួននៅក្នុងប្រទេសកម្ពុជា ដែលត្រូវបានជ្រើសរើសជាក្រុងអាទិភាពដោយរដ្ឋបាលថ្នាក់ជាតិសម្រាប់ជាគំរូនៃការអភិវឌ្ឍទីក្រុងនិរន្តរភាព។ ក្រុងអាទិភាព ៧ ត្រូវបានជ្រើសរើសជាករណីសិក្សាតំណាង ក្រុងនៅតំបន់៣ផ្សេងគ្នា៖ តំបន់ឆ្នេរសមុទ្រ (ក្រុងព្រះសីហនុ និងក្រុងកែប) តំបន់ទំនាប(ក្រុងកំពង់ចាម ក្រុងសួង និងក្រុងបាវិត) និងតំបន់ជុំវិញបឹងទន្លេសាប (ក្រុងសៀមរាប និងក្រុងបាត់ដំបង)។

ផែនការយុទ្ធសាស្ត្រនេះ បង្ហាញផ្លូវដល់រដ្ឋបាលថ្នាក់ជាតិ ថ្នាក់ក្រោមជាតិ និងដៃគូអភិវឌ្ឍន៍ក្នុងការធ្វើផែនការ និងការសម្រេចចិត្តពាក់ព័ន្ធនឹងការគ្រប់គ្រង និងការវិនិយោគ ដើម្បីធានាការអភិវឌ្ឍទីក្រុងប្រកបដោយនិរន្តរភាព រក្សាតុល្យភាពកំណើនសេដ្ឋកិច្ច សង្គម និងបរិស្ថាន។ ការអភិវឌ្ឍបៃតងក្នុងក្រុងទាំងនេះ នឹងលើកកម្ពស់ការអភិវឌ្ឍវិស័យនគរូបនីយកម្មរបស់ប្រទេសកម្ពុជាប្រកបដោយតុល្យភាព និងនិរន្តរភាព។ ផែនការយុទ្ធសាស្ត្រនេះ រៀបចំឡើងដើម្បីលើកកម្ពស់ការយល់ដឹងការអភិវឌ្ឍទីក្រុងនិរន្តរភាព និងរបៀបអនុវត្តផែនការផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ទីក្រុងនិរន្តរភាពនេះ ឱ្យកាន់តែមានប្រសិទ្ធភាព និងអាចអនុវត្តបាន។ ផែនការយុទ្ធសាស្ត្រនេះ នឹងជួយគាំទ្រទៅដល់ក្រុងគោលដៅនីមួយៗក្នុងការដាក់បញ្ចូលគោលការណ៍អភិវឌ្ឍន៍បៃតង ទៅក្នុងការអនុវត្តផែនការមេ ផែនការអភិវឌ្ឍន៍រយៈពេល៥ឆ្នាំ និងកម្មវិធីវិនិយោគរយៈពេល៣ឆ្នាំរំកិល ក៏ដូចជាផែនការអភិវឌ្ឍតាមវិស័យរបស់ទីក្រុងនីមួយៗ។

ផែនការយុទ្ធសាស្ត្រនេះកំណត់ទិសដៅធំៗចំនួន ៤ មានគោលដៅជាក់លាក់ចំនួន ១២ និងសកម្មភាពអាទិភាពចំនួន៩៨ ដែលមានការពិភាក្សាលម្អិតជាមួយក្រសួង/ស្ថាប័ន និងរដ្ឋបាលថ្នាក់ក្រោមជាតិ។ គោលដៅនៃផែនការយុទ្ធសាស្ត្រនេះត្រូវបានបង្កើតឡើងស្របទៅនឹងប្រធានបទ ៤ គឺ៖ (១) ការរៀបចំផែនការនគរូបនីយកម្មទីក្រុង និងការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធបៃតងគ្រប់វិស័យ (២) ការអភិវឌ្ឍសេដ្ឋកិច្ចបៃតងក្នុងទីក្រុង (៣) ការលើកកម្ពស់បរិយាបន្នសង្គម និង (៤) ការរៀបចំអភិបាលកិច្ចទីក្រុងនិរន្តរភាព។

### ហេតុអ្វីត្រូវគិតគូរពីនិរន្តរភាពនៃការអភិវឌ្ឍនគរូបនីយកម្មនៅក្នុងប្រទេសកម្ពុជា?

ប្រទេសកម្ពុជា ជាប្រទេសមួយដែលមានកំណើនប្រជាជនក្នុងទីក្រុងដ៏លឿនជាងគេមួយក្នុងចំណោមប្រទេសក្នុងតំបន់អាស៊ីអាគ្នេយ៍ ហើយក្រុងធំៗភាគច្រើននៅក្នុងប្រទេសកម្ពុជា កំពុងតែមានការរីកលូតលាស់តំបន់ទីប្រជុំជនក្រុងយ៉ាងឆាប់រហ័ស ដែលភាគច្រើនជាតំបន់មិនទាន់មានផែនការហេដ្ឋារចនាសម្ព័ន្ធក្រុងច្បាស់លាស់។ កត្តានេះបង្កឱ្យមានបញ្ហាប្រឈមផ្នែកបរិស្ថាន និងសង្គមជាច្រើនរួមមានការប្រើប្រាស់តំបន់ក្រុងមិនមានប្រសិទ្ធភាព ការផ្តល់សេវាហេដ្ឋារចនាសម្ព័ន្ធមិនគ្រប់គ្រាន់ ការបាត់បង់ធនធានធម្មជាតិ ការកើនឡើងការស្ទះចរាចរណ៍ ការបំពុលបរិយាកាស ភាពគ្មានការងារធ្វើ និងវិសមភាពសង្គម។ បើមិនមានផែនការរៀបចំទីក្រុងសមស្របនោះទេ បញ្ហាប្រឈម និងវិសមភាពពីការអភិវឌ្ឍទាំងនេះនឹងកើនឡើង ដែលវានឹងក្លាយទៅជាឧបសគ្គ និងកត្តាគំរាមកំហែងក្នុងការអភិវឌ្ឍនៅថ្ងៃអនាគត ដែលនឹងតម្រូវឱ្យមានការចំណាយធនធាននិងពេលវេលាជាច្រើនក្នុងការដោះស្រាយ។

លើសពីនេះទៅទៀត នៅក្នុងក្រុងនានានៅទូទាំងប្រទេស ជាពិសេសនៅរាជធានីភ្នំពេញ ការអភិវឌ្ឍប្រមូលផ្តុំនៅតែតាមទីក្រុង ដែលធ្វើឱ្យឱកាស និងការទទួលបានសេវាកម្មផ្នែកឧស្សាហកម្ម និងសេដ្ឋកិច្ចមិនមានភាពស្មើគ្នា។ ប្រទេសកម្ពុជា ត្រូវការធ្វើនគរូបនីយកម្មទីក្រុងឱ្យមាននិរន្តរភាពបរិស្ថានមានភាពទាក់ទាញ និងតុល្យភាពសេដ្ឋកិច្ចនៅតាមគ្រប់បណ្តាក្រុងទូទាំងប្រទេស ដើម្បីកាត់បន្ថយសម្ពាធ និងបញ្ចៀសការប្រមូលផ្តុំធនធានសម្រាប់តែការអភិវឌ្ឍក្នុងរាជធានីភ្នំពេញ និងដើម្បីបង្កើនការអភិវឌ្ឍនៅតាមបណ្តាក្រុងតូចធំផ្សេងៗទៀត។

បច្ចុប្បន្ននេះ ទីក្រុងទីប្រជុំជនត្រូវបានគេចាត់ទុកថាជាយន្តការនៃកំណើនសេដ្ឋកិច្ចជាតិ។ បើសិនជាមានផែនការអភិវឌ្ឍន៍ច្បាស់លាស់ ក្រុងទាំងនោះ នឹងក្លាយជាក្រុងប្រើប្រាស់ធនធានប្រកបដោយប្រសិទ្ធភាព មានភាពធន់នឹងការប្រែប្រួលអាកាសធាតុ មានសមធម៌ និងបរិយាបន្នសង្គម។ បើទីក្រុងទាំងនោះមិនមានការរៀបចំផែនការ និងការគ្រប់គ្រងច្បាស់លាស់ទេនោះ កំណើនសេដ្ឋកិច្ចទាំងមូលនៅតែមានកម្រិតទាប ហើយប្រមូលផ្តុំតែនៅក្នុងបណ្តាក្រុងធំៗមួយចំនួនប៉ុណ្ណោះ។ ការអភិវឌ្ឍបៃតងក្នុងទីក្រុង នាំឱ្យមានសក្តានុពលក្នុងការទទួលបាននូវអត្ថប្រយោជន៍ជាច្រើនដូចជាការបង្កើតការងារបៃតង ផ្សាភ្ជាប់ទំនាក់ទំនងការអភិវឌ្ឍទីក្រុងទៅនឹងទីផ្សារវិនិយោគ ការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធ ការផ្តល់សេវាបរិយាបន្នសង្គម ការបន្ស៊ាំនឹងវឌ្ឍនភាពនគរូបនីយកម្ម ប្រសិទ្ធភាពធនធាន និងការអភិវឌ្ឍដែលបំភាយកាបូនតិច។

ការអភិវឌ្ឍទីក្រុងបៃតង មានសារៈសំខាន់ក្នុងការចូលរួមសម្រេចបានឱ្យនូវការប្តេជ្ញាចិត្តជាអន្តរជាតិរបស់ប្រទេសកម្ពុជា រួមមានគោលដៅអភិវឌ្ឍប្រកបដោយចីរភាព (SDGs) ការរួមចំណែករបស់ប្រទេសកម្ពុជាអនុវត្តអនុសញ្ញាក្របខ័ណ្ឌសហប្រជាជាតិស្តីពីការប្រែប្រួលអាកាសធាតុ (NDC) និងសេចក្តីប្រកាសទីក្រុងគីតូ (Quito Declaration) ស្តីពីទីក្រុងនិរន្តរភាព និងការតាំងទីលំនៅសម្រាប់ទាំងអស់គ្នា។ គោលគំនិតទីក្រុងនិរន្តរភាព/បៃតង បង្កើតឡើងដោយផ្អែកលើសក្តានុពលដែលមានស្រាប់នៅតំបន់ក្រុងនៅទូទាំងប្រទេស ដើម្បីអភិវឌ្ឍទីក្រុង តាមរយៈការប្រមូលផ្តុំសកម្មភាពសេដ្ឋកិច្ច នវានុវត្តន៍ និងការបង្កើតការងារ ហើយទាញយកសក្តានុពលទាំងនេះសម្រេចឱ្យបាននូវសង្គមមួយដែលមានីការប្រមូលផ្តុំវប្បធម៌កម្រិតខ្ពស់ ហេដ្ឋារចនាសម្ព័ន្ធ សំណង់អគារ សមត្ថភាពពង្រឹងទំនាក់ទំនងរវាងទីក្រុង និងជនបទក្នុងគោលបំណងអភិឌ្ឍន៍តំបន់ជនបទ ដោយទាញយកអត្ថប្រយោជន៍ចេញពីការអភិវឌ្ឍនៅទីក្រុង។

**តើអ្វីជាបញ្ហាប្រឈម និងឱកាសនៃការអភិវឌ្ឍបៃតងនៅក្នុងក្រុងនៃប្រទេសកម្ពុជា?**

- ការរៀបចំផែនការទីក្រុង និងការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធបៃតង

ការរីកចម្រើននៃក្រុង ត្រូវការការគ្រប់គ្រង និងត្រួតពិនិត្យឱ្យបានគ្រប់ជ្រុងជ្រោយ និងដោយយកចិត្តទុកដាក់។ មកដល់ពេលបច្ចុប្បន្ន វិស័យនគរូបនីយកម្មមិនសូវបានរៀបចំផែនការច្បាស់លាស់ និងមិនមានការត្រួតពិនិត្យត្រឹមត្រូវនៅឡើយទេ។ រដ្ឋបាលក្រុងជាច្រើននៃប្រទេសកម្ពុជា កំពុងប្រឈមការខ្វះខាតទាំងសមត្ថភាព និងលទ្ធភាពរៀបចំផែនការកំណត់តំបន់ជាប្រព័ន្ធ និងកង្វះធនធានហិរញ្ញវត្ថុសម្រាប់ហេដ្ឋារចនាសម្ព័ន្ធទីក្រុង និងសេវាកម្មសាធារណៈដែលមានចីរភាព។ បញ្ហាទាំងនេះបណ្តាលឱ្យមានការមកតាំងទីលំនៅដែលមិនរៀបរយ ការសាងសង់អគារដែលមិនមានការតាមដាន និងត្រួតពិនិត្យបទដ្ឋាន ការបែងចែកតំបន់សម្រាប់ពាណិជ្ជកម្មនិងតំបន់អភិវឌ្ឍន៍និវាសដ្ឋានដែលមិនមានការគ្រប់គ្រងឱ្យបានត្រឹមត្រូវ និងហានិភ័យនៃការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធក្រុងដែលមិនចំទិសដៅ។ ដើម្បីឱ្យការអភិវឌ្ឍទីក្រុងមានរចនាសម្ព័ន្ធច្បាស់លាស់ ការធ្វើផែនការតំបន់ទីក្រុង គឺជាបុរេលក្ខខណ្ឌដែលត្រូវតែមានជាចាំបាច់ មុនការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធទីក្រុងដើម្បីធានាបាននិរន្តរភាព។ ផលប៉ះពាល់ពីការប្រែប្រួលអាកាសធាតុ ក៏ជាកត្តាចាំបាច់មួយដែលត្រូវគិតគូរពិចារណាឱ្យបានល្អិតល្អន់នៅក្នុងការរៀបចំផែនការទីក្រុងនិរន្តរភាព/បៃតង។ ប្រទេសកម្ពុជា ជាប្រទេសដែលងាយរងគ្រោះបំផុតពីការប្រែប្រួលអាកាសធាតុ។

ការគ្រប់គ្រងសំរាម គឺជាបញ្ហារួមសម្រាប់ក្រុងទាំងឡាយនៅកម្ពុជា។ បរិមាណសំរាមក្រុង មានការកើនឡើងយ៉ាងខ្លាំង។ កង្វះការគ្រប់គ្រងសំរាមប្រកបដោយគុណភាព កង្វះការចូលរួមពីសហគមន៍ បូកផ្សំនឹងការគ្រប់គ្រងទីលានចាក់សំរាមមិនមានបទដ្ឋានត្រឹមត្រូវ គឺជាបញ្ហាប្រឈមដ៏ធ្ងន់ធ្ងរមួយនៃការអភិវឌ្ឍក្រុង។ សេវាប្រមូលសំរាមមិនអាចឆ្លើយតបទាន់ពេលវេលា ហើយការដុតសំរាមនៅទីសាធារណៈ និងការចោលសំរាម នៅតាមបឹង តាមអូរ និងប្រឡាយនានានៅតែកើតមានជាធម្មតា។ ទស្សនវិស័យ និងវិធានការល្អៗនៃការកាត់បន្ថយបរិមាណសំរាម និងការកែច្នៃសំរាមដែលអាចរួមចំណែកក្នុងការបង្កើតការងារ និងកំណើនសេដ្ឋកិច្ច កំពុងតែត្រូវបានបញ្ជ្រាបចូលក្នុងបរិបទប្រទេសកម្ពុជា ប៉ុន្តែមិនទាន់ត្រូវបានគេយកមកអនុវត្តពេញលេញ និងប្រកបដោយប្រសិទ្ធភាពនៅឡើយទេ ហើយទស្សនវិស័យ និងវិធានការទាំងនោះ មិនទាន់មានគេស្គាល់ច្បាស់ឱ្យបានទូលំទូលាយនៅឡើយ។

ការគ្រប់គ្រងបណ្តាញលូទឹក និងទឹកកខ្វក់ គឺជាបញ្ហាប្រឈមធំមួយផ្សេងទៀតនៃការអភិវឌ្ឍទីក្រុង។ សមត្ថភាព និងលទ្ធភាពក្នុងការធ្វើប្រព្រឹត្តិកម្មទឹកកខ្វក់នៅមានកម្រិតទាបនៅក្នុងប្រទេសកម្ពុជា ហើយទឹកកខ្វក់ដែលមិនបានធ្វើប្រព្រឹត្តិកម្មត្រូវបានបង្ហូរចូលដោយផ្ទាល់ទៅក្នុងបរិស្ថាន។ កង្វះធនធានហិរញ្ញវត្ថុ ធនធានមនុស្ស និងកង្វះការពង្រឹងសិទ្ធិអំណាចពេញលេញដល់ថ្នាក់ក្រុង គឺជាឧបសគ្គដ៏សំខាន់សម្រាប់ការអភិវឌ្ឍ និងការគ្រប់គ្រងប្រព័ន្ធលូនិងទឹកកខ្វក់។

ផលប៉ះពាល់ពីការប្រែប្រួលអាកាសធាតុទាមទារអោយមានការយកចិត្តទុកដាក់ខ្លាំងនិងកាតាលីករសំខាន់មួយក្នុងការរៀបចំផែនការអភិវឌ្ឍន៍ទីក្រុងនិរន្តរភាព។ ប្រទេសកម្ពុជាជាប្រទេសមួយក្នុងចំណោមប្រទេសដែលងាយរងគ្រោះពីការប្រែប្រួលអាកាសធាតុ ហើយផលប៉ះពាល់ដែលអាចកើតមាននៅប្រទេសកម្ពុជា រួមមាន៖ ទឹកជំនន់ គ្រោះរាំងស្ងួត ខ្យល់កន្ត្រាក់ ការកើនឡើងកំពស់ទឹកសមុទ្រ ការសឹករេចរឹលនៃតំបន់ឆ្នេរការបាត់បង់ធនធានបាតសមុទ្រដែលនាំអោយមានការថយចុះចំនួនភ្ញៀវទេសចរ។

- សេដ្ឋកិច្ចបៃតងទីក្រុង

“ការអភិវឌ្ឍបៃតង” គឺជាវិធីសាស្ត្រអភិវឌ្ឍន៍សេដ្ឋកិច្ចមួយ ដែលនឹងនាំឱ្យមាននិរន្តរភាពបរិស្ថាន និងបរិយាបន្នសង្គម។ គោលដៅនៃការអភិវឌ្ឍសេដ្ឋកិច្ចបៃតងគឺ ដើម្បីបង្កើតសុខុមាលភាព និងសមធម៌សង្គម និងស្របពេលជាមួយគ្នានេះ រួមចំណែកដល់ការកាត់បន្ថយផលប៉ះពាល់លើបរិស្ថាន និងពង្រឹងធនធានអេកូឡូស៊ីដែលកំពុងខ្វះខាត។

វិស័យទេសចរណ៍ គឺជាកាតាលីករដ៏សំខាន់ក្នុងការអភិវឌ្ឍសេដ្ឋកិច្ចបៃតងសម្រាប់ក្រុងនានានៅកម្ពុជា និងអាចដើរតួនាទីយ៉ាងសំខាន់ក្នុងការបង្កើតការងារបន្ថែម។ ទោះបីជាវិស័យនេះមានតួនាទីសំខាន់យ៉ាងណាក្តី វាត្រូវការការគ្រប់គ្រងយ៉ាងប្រុងប្រយ័ត្ន ហើយជំរុញឱ្យមានអេកូទេសចរណ៍ ដើម្បីបញ្ចៀសផលវិបាកមិនល្អពីវិស័យទេសចរណ៍មកលើសង្គម វប្បធម៌ និងបរិស្ថាន។ ការកើនឡើងនៃចំនួនភ្ញៀវទេសចរដ៏ច្រើន ក៏អាចមានផលប៉ះពាល់អវិជ្ជមានមកលើធនធានវប្បធម៌ និងធនធានធម្មជាតិផងដែរ ជាពិសេសបែបបទនៃការប្រើប្រាស់សម្ភារការទុកដាក់សំរាមរបស់អ្នកទេសចរ និងកត្តាផ្សេងទៀត។ ការពង្រីកហេដ្ឋារចនាសម្ព័ន្ធ ដើម្បីឆ្លើយតបនឹងតម្រូវការកំណើនវិស័យទេសចរណ៍ដែលកំពុងរីកលូតលាស់នេះ ត្រូវតែស្របទៅតាមគោលការណ៍និរន្តរភាព ដូចជាតាមរយៈការបង្កើតប្រព័ន្ធហេដ្ឋារចនាសម្ព័ន្ធបៃតង អគារបៃតង និងប្រព័ន្ធដឹកជញ្ជូនបៃតង។

ជាតុដ៏សំខាន់មួយផ្សេងទៀតដែលជាកាតាលីករនៃសេដ្ឋកិច្ចទីក្រុង គឺវិស័យឧស្សាហកម្ម។ វិស័យឧស្សាហកម្មនៅក្នុងប្រទេសកម្ពុជាត្រូវបានគេមើលឃើញថា មានការរីកលូតលាស់យ៉ាងឆាប់រហ័សក្នុងរយៈពេល ២ទសវត្សន៍ចុងក្រោយនេះ ពោលគឺវិស័យនេះបានកើនឡើងពី ១៧% នៃការរួមចំណែកក្នុងផលិតផលក្នុងស្រុកសរុប (GDP) កាលពីឆ្នាំ១៩៩៨ មកដល់៣២% នៅឆ្នាំ២០១៨ នេះបើតាមទិន្នន័យរបស់ធនាគារពិភពលោក[១]។ ទោះបីជាវិស័យនេះមានការរីកលូតលាស់ខ្លាំងក្នុងរយៈពេល ១៥ឆ្នាំចុងក្រោយ ក៏វិស័យឧស្សាហកម្មត្រូវបានគេមើលឃើញថាកំពុងបាត់បង់នូវសក្តានុពលប្រកួតប្រជែងរបស់ខ្លួនដោយសារការចំណាយលើធនធានថាមពលខ្ពស់ការកើនឡើងនៃប្រាក់ឈ្នួលអប្បបរមាថ្មីៗនេះ ការខ្វះខាតហេដ្ឋារចនាសម្ព័ន្ធគាំទ្រ ផលិតភាព និងភស្តុភារ។ វិធីសាស្ត្រក្នុងខ្សែសង្វាក់ផលិតកម្មភាគច្រើនប្រើប្រាស់ធនធានមិនទាន់មានប្រសិទ្ធភាពដែលជាកត្តារាំងស្ទះដល់សមត្ថភាពប្រកួតប្រជែងក្នុងទីផ្សារអន្តរជាតិ។ ដូច្នេះហើយវាជាកត្តាសំខាន់ និងចាំបាច់ក្នុងការពិចារណា និងចាប់យកទស្សនទាននៃការអភិវឌ្ឍឧស្សាហកម្មបៃតង ក្នុងនោះផ្តោតជាសំខាន់ទៅលើការបង្កើត និងប្រើប្រាស់ថាមពល បច្ចេកវិទ្យាបៃតង និងដំណើរការផលិតកម្មដែលមានប្រសិទ្ធភាពធនធានជាងមុន។

[1] World Bank, World Bank Database, (Washington, D.C.: The World Bank Group, 2018). Accessed June 06, 2019. https://data.worldbank.org/country/cambodia?view=chart

ចំណុចសំខាន់នៃការអភិវឌ្ឍឧស្សាហកម្មបៃតង គឺការប្រើប្រាស់ថាមពលកកើតឡើងវិញ។ បណ្ដាក្រុងមួយចំនួនធំនៅក្នុងប្រទេសកម្ពុជា ទទួលបានថាមពលអគ្គិសនីប្រើប្រាស់តាមរយៈបណ្ដាញអគ្គិសនីជាតិ ដែលប្រភពដើមសម្រាប់ការផ្គត់ផ្គង់យកចេញពីថាមពលកកើតឡើងវិញមានមិនដល់មួយភាគបីផង (មិនរាប់បញ្ចូលថាមពលកកើតឡើងវិញដែលមានប្រភពពីវារីអគ្គិសនី)។ តាមផ្ទះប្រជាពលរដ្ឋ និងតាមក្រុមហ៊ុនអាជីវកម្ម បានជួបប្រទះបញ្ហាប្រឈមមួយចំនួន ដោយសារតម្លៃអគ្គិសនីនៅថ្លៃ និងការផ្គត់ផ្គង់ថាមពលមិនគ្រប់គ្រាន់តាមតម្រូវការ។ ដូចបានជួបប្រទះនូវការផ្ដាច់ចរន្តអគ្គិសនីប្រើប្រាស់ក្នុងរដូវប្រាំងក្នុងឆ្នាំ ២០១៩ ដោយសារភាពរាំងស្ងួត ដូច្នេះវាជាកត្តាចាំបាច់បំផុតដែលរដ្ឋាភិបាលគួរតែពិចារណាលើការបន្ថែមសមត្ថភាពនាំការផ្គត់ផ្គង់ថាមពល តាមរយៈថាមពលពន្លឺព្រះអាទិត្យ និងប្រភពថាមពលកកើតឡើងវិញផ្សេងទៀត ដើម្បីបំពេញបន្ថែមទៅលើប្រភពថាមពលវារីអគ្គិសនីនៅពេលជួបភាពរាំងស្ងួត។ កិច្ចខិតខំប្រឹងប្រែងរបស់រដ្ឋាភិបាលក្នុងការលើកកម្ពស់ការអភិវឌ្ឍវិស័យថាមពលកកើតឡើងវិញ នឹងនាំឱ្យមានផលប្រយោជន៍ទាំងផ្នែកសេដ្ឋកិច្ច និងបរិស្ថាន។

វិធានការប្រសិទ្ធភាពថាមពល ក៏អាចជួយដល់ការបង្កើនផលិតភាពក្នុងសេដ្ឋកិច្ចបានច្រើនផងដែរ ហើយក៏អាចជួយកាត់បន្ថយតម្រូវការថាមពល និងការកាត់បន្ថយការបំភាយឧស្ម័នកាបូនិច ($CO_2$)។ ផ្អែកលើការវាយតម្លៃពីសក្ដានុពលប្រសិទ្ធភាពថាមពលក្នុងវិស័យសំណង់អគារ ឧស្សាហកម្ម និងដឹកជញ្ជូន គោលដៅរួមដែលបានដាក់នៅក្នុងសេចក្ដីព្រាងគោលនយោបាយជាតិស្ដីពីប្រសិទ្ធភាពថាមពល គឺការកាត់បន្ថយតម្រូវការថាមពលឱ្យបាន២០%ក្នុងឆ្នាំ២០៣៥បើធៀបទៅនឹងសេណារីយ៉ូនៃការអនុវត្តតាមទម្លាប់ធម្មតា(Business As Usual – BAU)។ បើប្រទេសកម្ពុជា សម្រេចបាននូវគោលដៅនេះ វានឹងជួយដល់ការសន្សំថាមពលពីចន្លោះ ១៩០ ទៅ ៣០៧ ម៉េកាវ៉ាត់។

- បរិយាបន្នសង្គម

ការអភិវឌ្ឍទីក្រុងបៃតង ជាកាតាលីករដ៏សំខាន់មួយនៃការជំរុញឱ្យមានបរិយាបន្នសង្គមក្នុងក្រុង តាមរយៈការគាំទ្រឱ្យមានសហគ្រិនភាពបែបថ្មី ពោលគឺការវិនិយោគ និងការបង្កើតការងារ ក្នុងការអភិវឌ្ឍធុរកិច្ចបៃតងសម្រាប់អនាគត។ បញ្ហាប្រឈមនៃបរិយាបន្នសង្គមក្នុងក្រុង រួមមាន ភាពក្រីក្រក្នុងក្រុង និងលទ្ធភាពទទួលបានហេដ្ឋារចនាសម្ព័ន្ធ និងសេវាសាធារណៈប្រកបដោយនិរន្តរភាព លទ្ធភាពទទួលបានលំនៅឋាន ការធ្វើដំណើរដែលមានតម្លៃសមរម្យ សមភាពយេនឌ័រ និងការចូលរួមរបស់ពលរដ្ឋនៅក្នុងការធ្វើសេចក្ដីសម្រេចចិត្តរៀបចំផែនការអភិវឌ្ឍន៍ទីក្រុង។

- អភិបាលកិច្ចទីក្រុង

អាជ្ញាធរដែនដី និងរដ្ឋបាលក្រុង មានតួនាទីស្នូលក្នុងការលើកកម្ពស់ការអភិវឌ្ឍទីក្រុងនិរន្តរភាព/បៃតង។ រដ្ឋបាលក្រុង និងអាជ្ញាធរដែនដី គឺជាអ្នកកំណត់ទិសដៅរួមសម្រាប់អភិវឌ្ឍន៍ក្រុងរបស់ខ្លួន និងទទួលខុសត្រូវក្នុងការគ្រប់គ្រងនិងផ្ដល់សេវាសាធារណៈ។

រដ្ឋបាលថ្នាក់ក្រោមជាតិ នៅតែប្រឈមមុខនឹងឧបសគ្គកង្វះធនធានមនុស្ស និងធនធានហិរញ្ញវត្ថុ ជាពិសេសសម្រាប់ផ្ដល់សេវាសាធារណៈ និងហេដ្ឋារចនាសម្ព័ន្ធ។ សមត្ថភាពស្ថាប័ននៅតែមានកម្រិតក្នុងការដោះស្រាយបញ្ហាទីក្រុងដែលកំពុងកើតឡើងថ្មីៗ ការធ្វើកំណែទម្រង់ និងកង្វះបុគ្គលិក នៅតែជាបញ្ហា។ ការពង្រឹងសមត្ថភាពស្ថាប័ន និងរចនាសម្ព័ន្ធអភិបាលកិច្ច គឺជាភាពចាំបាច់ ដូចជាការរៀបចំឱ្យមានប្រព័ន្ធបំពេញគុណភាពការងារ បរិក្ខារប្រើប្រាស់ និងប្រព័ន្ធឌីជីថលឱ្យបានប្រសើរជាងមុន។ ក្រៅពីនេះ យន្តការសម្របសម្រួល និងទំនាក់ទំនងស្ថាប័ននៅថ្នាក់ក្រោមជាតិ ក៏ជាកង្វះខាតមួយផងដែរ។

## តើផែនការយុទ្ធសាស្ត្រនឹងត្រូវអនុវត្តយ៉ាងដូចម្ដេច?

យន្តការនៃការអនុវត្តផែនការយុទ្ធសាស្ត្រ គឺការបង្កើតឱ្យមានក្រុមការងារអភិវឌ្ឍន៍ទីក្រុងនិរន្តរភាពនៅថ្នាក់ក្រោមជាតិ (កម្រិតខេត្ត) ដែលមានប្រធានក្រុមការងារជាអភិបាលខេត្ត និងមានសមាជិកពីមន្ទីរ / អង្គភាពពាក់ព័ន្ធ។ តួនាទី និងការទទួលខុសត្រូវរបស់ក្រុមការងារ គឺការរៀបចំផែនការ និងធ្វើសមាហរណកម្មគម្រោងក្នុង ឬកម្មវិធីវិនិយោគបៃតង អនុវត្ត ការតាមដាននិងការវាយតម្លៃ កៀរគរធនធាន

និងជំរុញឱ្យមានការចូលរួមពីប្រជាពលរដ្ឋ និងដៃគូអភិវឌ្ឍន៍។ ឱកាសល្អមួយនៃការអនុវត្តផែនការយុទ្ធសាស្ត្រនេះ គឺតាមរយៈការប្រើប្រាស់យន្តការសម្របសម្រួលដែលមានស្រាប់ ដូចជាក្រុមការងារថ្នាក់ខេត្តសម្រាប់វាយតម្លៃទីក្រុងស្អាត ឬគណៈកម្មការថ្នាក់ក្រោមជាតិសម្រាប់ការងារដែនដី និងនគរូបនីយកម្ម។

ដើម្បីគាំទ្រដល់ការអនុវត្ត ក្រុមការងារអនុវត្តផែនការទីក្រុងនិរន្តរភាពនេះ នឹងធ្វើរបាយការណ៍ប្រចាំឆ្នាំស្តីពីវឌ្ឍនភាពនៃការអនុវត្តផែនការយុទ្ធសាស្ត្រទីក្រុងនិរន្តរភាព ដែលនឹងត្រូវដាក់ជូនក្រុមការងារបច្ចេកទេសទីក្រុងនិរន្តរភាព (SCTWG) ដែលស្ថិតក្រោមរចនាសម្ព័ន្ធក្រុមប្រឹក្សាជាតិអភិវឌ្ឍន៍ដោយចីរភាព។ សមាជិកក្រុមការងារស្តីពីទីក្រុងនិរន្តរភាពដែលបានបង្កើតឡើងក្នុងឆ្នាំ ២០១៩ គឺមានតំណាងមកពីក្រសួង ស្ថាប័ននិងរដ្ឋបាលខេត្តពាក់ព័ន្ធ។ ក្រុមការងារ SCTWG មានទំនួលខុសត្រូវចំពោះការអភិវឌ្ឍ និងការលើកកម្ពស់គោលនយោបាយ និងក្របខ័ណ្ឌគតិយុត្តិសម្រាប់ការអភិវឌ្ឍបៃតង បញ្ជ្រាបការអភិវឌ្ឍទីក្រុងបៃតងចូលទៅក្នុងក្របខ័ណ្ឌច្បាប់ ឬផែនការយុទ្ធសាស្ត្ររបស់ប្រទេសកម្ពុជា។



ក្រុងកែប

# ១. ការរៀបចំផែនការយុទ្ធសាស្ត្រ សម្រាប់អភិវឌ្ឍន៍ទីក្រុងនិរន្តរភាព

## ១.១. សេចក្តីផ្តើម

យោងតាមលទ្ធផលជំរឿនប្រជាជនកាលពីពេលថ្មីៗនេះ ប្រទេសកម្ពុជាមានចំនួនប្រជាជនសរុបប្រមាណ ១៥,២៩លាននាក់។ អត្រាកំណើនប្រជាជនប្រចាំឆ្នាំជាមធ្យមគឺ ១,២% ចន្លោះពីឆ្នាំ ២០០៨-២០១៩[២]។ នៅក្នុងការរៀបចំផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ (NSDP) ២០១៩-២០២៣ រាជរដ្ឋាភិបាលបានប៉ាន់ស្មាន ឃើញថាចំនួនប្រជាជនក្នុងទីប្រជុំជនមាន ២៤,៩% នៃចំនួនប្រជាជនសរុបក្នុងឆ្នាំ ២០១៩ និងព្យាករថានឹងកើនឡើងដល់ ២៦,៧% នៅឆ្នាំ ២០២៣។ តាមរបាយការណ៍ឆ្នាំ ២០១៥ របស់ធនាគារពិភពលោក ប្រទេសកម្ពុជាមានអត្រាពង្រីកទីក្រុងជាមធ្យម ៤,៣% ក្នុងមួយឆ្នាំ ដែលជាអត្រាកំណើនដ៏លឿនជាងគេលំដាប់ទី២នៅក្នុងតំបន់អាស៊ីអាគ្នេយ៍បន្ទាប់ពីប្រទេសឡាវ[៣]។ ការរីកសាយតំបន់ក្រុង បង្ហាញឱ្យឃើញទាំងឱកាស និងបញ្ហាប្រឈម ពោលគឺវាអាចបង្កើតឱកាសនៃការអភិវឌ្ឍសេដ្ឋកិច្ច ការវិនិយោគ និងឱកាសការងារថ្មីៗ។ ប៉ុន្តែបើការអភិវឌ្ឍក្នុងវិស័យនគរូបនីយកម្មមិនមានរចនាសម្ព័ន្ធ និងមិនមានផែនការច្បាស់លាស់ទេ វាអាចបង្កើតឱ្យមានបញ្ហាប្រឈមផ្នែកសេដ្ឋកិច្ច សង្គម និងបរិស្ថានធ្ងន់ធ្ងរទៅវិញ ដូចជាការរីករាលដាលទីក្រុងទៅដល់ជាយក្រុងកាន់តែខ្លាំង ការផ្តល់សេវាកម្ម និងហេដ្ឋារចនាសម្ព័ន្ធក្រុងជាមូលដ្ឋានមិនគ្រប់គ្រាន់ទៅតាមតម្រូវការ (ការផ្តល់លំនៅឋានសមរម្យ សេវាដឹកជញ្ជូន ថាមពល ការផ្គត់ផ្គង់ទឹក និងអនាម័យ) និងការកើនឡើងនៃការស្ទះចរាចរណ៍ ការបំពុលបរិស្ថាន កង្វះការងារ និងវិសមភាពសង្គម។

រូបភាព ១.១. និន្នាការនៃចំនួនប្រជាជននៅប្រទេសកម្ពុជាពីឆ្នាំ ១៩៦២-២០១៩ (លាននាក់)[៤]




[2] The General Population Census of the Kingdom of Cambodia 2019, conducted by the National Institute of Statistics (NIS) of the Ministry of Planning (MOP). It is the fourth census in subsequent censuses conducted in Cambodia every 10 years, including 1962, 1998, and 2008.

[3] World Population Review, "Total Population by Country 2019," accessed August 05, 2019, http://worldpopulationreview.com/countries/

[4] Ministry of Planning. "The General Population Census of the Kingdom of Cambodia 2019," accessed September 20, 2019, http://www.nis.gov.kh/nis/Census2019/Provisional%20Population%20Census%202019_English_FINAL.pdf

ការរីកលូតលាស់នៃវិស័យនគរូបនីយកម្មក្នុងពេលបច្ចុប្បន្ននេះ ប្រមូលផ្តុំខ្លាំងតែនៅរាជធានីភ្នំពេញ និងតំបន់ជុំវិញរាជធានី ដែលបច្ចុប្បន្នជាមជ្ឈមណ្ឌលសម្រាប់ការអភិវឌ្ឍសេដ្ឋកិច្ចរបស់ប្រទេស និងបានបង្កើតការងារជាច្រើនជាពិសេសនៅក្នុងវិស័យឧស្សាហកម្ម និងផលិតកម្មទាំងមូល។ ប៉ុន្តែប្រទេសកម្ពុជា ត្រូវការការអភិវឌ្ឍវិស័យនគរូបនីយកម្មដែលអាចធានានិរន្តរភាពបរិស្ថាន និងការអភិវឌ្ឍកំណើនសេដ្ឋកិច្ចនៅទូទាំងប្រទេស ដើម្បីបញ្ចៀសការប្រមូលផ្តុំការអភិវឌ្ឍតែនៅក្នុងរាជធានីភ្នំពេញ។ ក្នុងឆ្នាំ ២០១១ រាជរដ្ឋាភិបាលកម្ពុជា បានរៀបចំគោលនយោបាយជាតិស្តីពីការរៀបចំដែនដី សំដៅធានាដល់ការប្រើប្រាស់ដី និងធនធានធម្មជាតិប្រកបដោយប្រសិទ្ធភាព ចីរភាព និងសមធម៌នៅទូទាំងព្រះរាជាណាចក្រកម្ពុជា ដើម្បីគាំទ្រដល់ការអភិវឌ្ឍសេដ្ឋកិច្ច សង្គម និងការធានាសន្តិសុខស្បៀង និងកិច្ចការពារលំនឹងធម្មជាតិ[៥]។

ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ទីក្រុងនិរន្តរភាព ឆ្នាំ២០២០-២០៣០ (ចាប់ពីនេះទៅ នៅក្នុងអត្ថបទនេះ ហៅថា "ផែនការយុទ្ធសាស្ត្រ") ត្រូវបានបង្កើតឡើងដើម្បីសម្រេចបានគោលដៅអភិវឌ្ឍន៍នគរូបនីយកម្មប្រកបដោយនិរន្តរភាព ដោយបង្ហាញពីទិសដៅជាយុទ្ធសាស្ត្រដល់រដ្ឋបាលក្រុងនីមួយៗ ដើម្បីរួមបញ្ចូលគោលការណ៍ទីក្រុងនិរន្តរភាពនៅក្នុងផែនការអភិវឌ្ឍន៍ និងផែនការវិនិយោគរបស់ក្រុងនីមួយៗ។ ក្រុងដែលបានចូលរួមនៅក្នុងការសិក្សារៀបចំផែនការយុទ្ធសាស្ត្រនេះរួមមាន បាវិត កំពង់ចាម ស្ទួង សៀមរាប បាត់ដំបង កែប និងព្រះសីហនុ។ ការអនុវត្តផែនការយុទ្ធសាស្ត្រនេះប្រកបដោយប្រសិទ្ធភាព និងចូលរួមចំណែកសម្រេចបាននូវគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាពរបស់កម្ពុជា (CSDGs)[៦] ការចូលរួមចំណែកដើម្បីអនុវត្តអនុសញ្ញាសហប្រជាជាតិស្តីពីការប្រែប្រួលអាកាសធាតុ[៧] និងការអនុវត្តរបស់ប្រទេសកម្ពុជាទៅតាម "គំរូនៃការអភិវឌ្ឍទីក្រុង (Urban Paradigm Shift)" ដែលបានកំណត់នៅក្នុងរបៀបវារៈនៃការអភិវឌ្ឍទីក្រុងថ្មីរបស់អង្គការសហប្រជាជាតិស្តីពីលំនៅឋានលើកទី ៣ (New Urban Agenda at Habitat 3)[៨]។

ផែនការយុទ្ធសាស្ត្រនេះ ត្រូវបានបង្កើតឡើងដោយមានការចូលរួមសហការជាដៃគូរវាងក្រុមប្រឹក្សាជាតិអភិវឌ្ឍន៍ដោយចីរភាព ក្រសួងមហាផ្ទៃ និងវិទ្យាស្ថានអភិវឌ្ឍន៍បៃតងសកល បន្ទាប់ពីបានធ្វើការប្រឹក្សាយោបល់យ៉ាងទូលំទូលាយ ទាំងនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិជាមួយបណ្តាក្រសួង មន្ទីរពាក់ព័ន្ធសំខាន់ៗ រដ្ឋបាលក្រុងទាំងប្រាំពីរ ដៃគូអភិវឌ្ឍន៍ អង្គការក្រៅរដ្ឋាភិបាលជាតិ និងអន្តរជាតិ វិស័យឯកជន វិស័យសិក្សាធិការ និងស្ថាប័នស្រាវជ្រាវ។ ដំណើរការនៃការប្រមូលទិន្នន័យ សិក្សាស្រាវជ្រាវ ពិភាក្សា និងសិក្ខាសាលាពិគ្រោះយោបល់មានរយៈពេលជាងមួយឆ្នាំ ក្នុងនោះរួមមានការចុះទៅដល់ក្រុងទាំង៧ ដើម្បីប្រមូលទិន្នន័យ សិក្សាពីស្ថានភាពភូមិសាស្ត្រ និងពិភាក្សាជាមួយអាជ្ញាធរក្រុង និងស្ថាប័នដែលពាក់ព័ន្ធ និងសិក្ខាសាលាពិគ្រោះយោបល់ចំនួន ៣លើក ដែលរួមបញ្ចូលនូវវគ្គបណ្តុះបណ្តាលខ្លីៗ ស្តីពីការអភិវឌ្ឍបៃតង និងវិធីសាស្ត្ររៀបចំផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍បៃតងនៅតាមក្រុង។

ផែនការយុទ្ធសាស្ត្រនេះជាផែនការមួយដែលបង្កើតឡើងស្របទៅនឹងចក្ខុវិស័យ និងទិសដៅជាតិសម្រាប់ការអភិវឌ្ឍវិស័យនគរូបនីយកម្មប្រកបដោយចីរភាព និងបរិយាបន្ន។ ផែនការយុទ្ធសាស្ត្រនឹងរួមចំណែកដល់ការអនុវត្តគោលនយោបាយ និងផែនការយុទ្ធសាស្ត្រជាតិស្តីពី ការអភិវឌ្ឍបៃតង (២០១៣ - ២០៣០) និងបំពេញដល់ការបង្កើតក្របខ័ណ្ឌជាតិសម្រាប់ការអភិវឌ្ឍវិស័យនគរូបនីយកម្ម។ ផែនការយុទ្ធសាស្ត្រនេះ ក៏បានបង្កើតឡើងឱ្យស្របទៅនឹងកម្មវិធីជាតិស្តីពីការប្រកួតប្រជែងទីក្រុងស្អាត និងគោលនយោបាយរាជរដ្ឋាភិបាល កម្មវិធីកំណែទម្រង់ និងដំណើរការវិមជ្ឈការ និងវិសហមជ្ឈការ (D&D) ផងដែរ។ មិនតែប៉ុណ្ណោះ វាក៏ជាផែនការយុទ្ធសាស្ត្រ ដែលស្របទៅនឹងច្បាប់ស្តីពី ការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក និងខណ្ឌ ឆ្នាំ២០០៨ ទៀតផង។[៩]

[5] Ministry of Land Management Urban Planning, and Construction (MLMUPC), National Policy on Land Use in Cambodia, April 2011.

[6] UNIDO, "Background on the SDGs," accessed September 20, 2019, http://www.undp.org/content/undp/en/home/sustainable-development-goals/background.html

[7] United Nations Climate Change, "National Determined Contributions (NDCs)," accessed September 20, 2019, http://unfccc.int/focus/items/10240.php

[8] UNIHABITAT, "New Urban Agenda Adopted at Habitat III," last modified October 21, 2016, https://unhabitat.org/new-urban-agenda-adopted-at-habitat-iii/

[9] The Organic Law, 2008

ផែនការយុទ្ធសាស្ត្រនេះ នឹងបង្កើនការយល់ដឹងជាមូលដ្ឋានបន្ថែមទៅក្នុងវិធីសាស្ត្ររៀបចំផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ទីក្រុងនិរន្តរភាព។ ផែនការយុទ្ធសាស្ត្រនេះ បង្ហាញពីការដាក់បញ្ចូលគោលការណ៍អភិវឌ្ឍន៍បៃតងទៅក្នុងការរៀបចំផែនការអភិវឌ្ឍ និងវិនិយោគក្រុងរបស់រាជរដ្ឋាភិបាល ដើម្បីធានាដល់និរន្តរភាពបរិស្ថាន បរិយាបន្នសង្គម និងការអភិវឌ្ឍសេដ្ឋកិច្ចទីក្រុង។

ក្រៅពីការបង្កើតគោលនយោបាយ ផែនការយុទ្ធសាស្ត្រ និងកម្មវិធីវិនិយោគសាធារណៈសម្រាប់ការអភិវឌ្ឍទីក្រុង រាជរដ្ឋាភិបាលក៏បានដាក់ចេញនូវកម្មវិធីថ្នាក់ជាតិ និងចូលរួមក្នុងកម្មវិធីថ្នាក់តំបន់មួយចំនួនដែលជាយន្តការជួយគាំទ្រ និងតម្រង់ទិស ដល់ការអនុវត្តនូវផែនការទាំងនោះតាមស្តង់ដារអន្តរជាតិ ក្នុងនោះមានដូចជាកម្មវិធីថ្នាក់ជាតិស្តី ពីការប្រកួតប្រជែងទីក្រុងស្អាតដែលដឹកនាំដោយក្រសួងទេសចរណ៍ សម្រាប់ការចូលរួមក្នុងការប្រកួតប្រជែងទីក្រុងទេសចរណ៍ស្អាតថ្នាក់តំបន់របស់អាស៊ាន និងកម្មវិធីថ្នាក់តំបន់ស្តីពី ទីក្រុងឆ្លាតវៃអាស៊ានផងដែរ។ ជាក់ស្តែងកាលពីឆ្នាំ ២០១៨ ក្រុង ៣ របស់ប្រទេសកម្ពុជា (ក្រុងកែប ក្រុងបាត់ដំបង និងក្រុងសៀមរាប) ដែលមានលក្ខណៈសម្បត្តិគ្រប់គ្រាន់តាមស្តង់ដារសូចនាករអាស៊ាន បានទទួលជ័យលាភីជាទីក្រុងទេសចរណ៍ស្អាតរបស់អាស៊ាន[១០]។ រាជធានីភ្នំពេញ ក្រុងបាត់ដំបង និងក្រុងសៀមរាប ក៏ត្រូវបានជ្រើសរើសឱ្យចូលរួមនៅក្នុងកម្មវិធីទីក្រុងឆ្លាតវៃអាស៊ាន ដែលជាកម្មវិធីថ្នាក់តំបន់ទទួលបានការគាំទ្រពីរដ្ឋាភិបាលជប៉ុន ដើម្បីជំរុញវិនិយោគឯកជនជប៉ុនក្នុងការអភិវឌ្ឍទីក្រុងនិរន្តរភាព និងមានភាពឆ្លាតវៃនៅតំបន់អាស៊ាន។ ក្នុងនោះទីក្រុងទាំង ៣ របស់ប្រទេសកម្ពុជា តាមរយៈក្របខ័ណ្ឌសហប្រតិបត្តិការរវាងវិស័យឯកជន និងសាធារណៈសម្រាប់ការអភិវឌ្ឍទីក្រុងនឹងទទួលបានការគាំទ្រពីវិនិយោគិនជប៉ុនសម្រាប់ការចូលរួមក្នុងកម្មវិធីថ្នាក់តំបន់អាស៊ាននេះ[១១]។

## ១.២. ចក្ខុវិស័យ និងគោលដៅ

### ចក្ខុវិស័យ

នៅត្រឹមឆ្នាំ ២០៣០ ក្រុងគោលដៅសក្តានុពលទាំង ៧ ក្នុងប្រទេសកម្ពុជា នឹងមានការអភិវឌ្ឍក្លាយជាទីក្រុងនិរន្តរភាព ដែលមានភាពធន់ទៅនឹងការប្រែប្រួលអាកាសធាតុ មានការប្រើប្រាស់ធនធានប្រកបដោយប្រសិទ្ធភាព ផ្តល់គុណភាពជីវិតរស់នៅល្អប្រសើរ និងភាពសុខដុមរមនាក្នុងសង្គមប្រសើរជាងមុន។

រូបភាព ១.២. ទំនាក់ទំនងរវាងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ទីក្រុងនិរន្តរភាព និងផែនការអភិវឌ្ឍន៍ក្រុងដែលមានស្រាប់




[10] FreshNewsAsia, “Three cities from Cambodia received Awards from ASEAN’s Clean Tourism City Contest,” last modified January 29, 2018, http://freshnewsasia.com/index.php/en/localnews/ 77226-2018-01-29-02-44-04.html

[11] Khmer Times, “Three Cambodian cities chosen for Asean urban planning scheme,” last modified February 2, 2019, https://www.khmertimeskh.com/582486/three-cambodian-cities-chosen-for-asean-urban-planning-scheme/

### គោលដៅ

១. អភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធទីក្រុងនិរន្តរភាព តាមរយៈការរៀបចំប្លង់គោល/ផែនការប្រើប្រាស់ដី ដែលមានបរិយាបន្ន និងពង្រឹងការគ្រប់គ្រងបរិស្ថានក្នុងក្រុង ដើម្បីផ្តល់សេវាសាធារណៈ ដែលមានគុណភាពខ្ពស់ ការរក្សាធនធានធម្មជាតិ និងការកាត់បន្ថយការបំពុលបរិស្ថាន និងផលប៉ះពាល់នៃការប្រែប្រួលអាកាសធាតុក្នុងទីក្រុង

២. ធ្វើឱ្យប្រសើរឡើងនូវសេដ្ឋកិច្ចមូលដ្ឋាន តាមរយៈការពង្រឹងលទ្ធភាពប្រកួតប្រជែងរបស់ទីក្រុង ការស្វែងរកឱកាសលើកកម្ពស់សេដ្ឋកិច្ចក្រៅ ភាពជាដៃគូវិស័យសាធារណៈនិងឯកជន និងការប្រើប្រាស់បច្ចេកវិទ្យាបៃតង

៣. លើកកម្ពស់បរិយាបន្នភាពសង្គម តាមរយៈការពង្រឹងលទ្ធភាពទទួលបានសេវាសាធារណៈ និងឱកាសការងារសម្រាប់ទាំងអស់គ្នា

៤. ពង្រឹងអភិបាលកិច្ចទីក្រុង តាមរយៈការកសាងស្ថាប័នដែលរឹងមាំ និងមានគណនេយ្យភាពខ្ពស់ ការអភិវឌ្ឍធនធានមនុស្សនៅមូលដ្ឋាន និងការលើកកម្ពស់ការចែករំលែកចំណេះដឹង និងបទពិសោធន៍រវាងក្រុងនិងក្រុង។

## ១.៣. ក្របខ័ណ្ឌយុទ្ធសាស្ត្រ

ផ្នែកក្របខ័ណ្ឌយុទ្ធសាស្ត្រនេះ គឺជាការសិក្សាគ្រប់ជ្រុងជ្រោយ និងការវិភាគអំពីការអភិវឌ្ឍនិរន្តរភាពក្នុងវិស័យនគរូបនីយកម្ម លើបរិបទនិងស្ថានភាពបច្ចុប្បន្នរបស់ក្រុងគោលដៅ ដោយរាប់បញ្ចូលទាំងបញ្ហាប្រឈម និងឱកាសអភិវឌ្ឍន៍ ជាពិសេសនៅក្នុងវិស័យសំខាន់ៗដូចជាការគ្រប់គ្រងសំណល់ ការគ្រប់គ្រងទឹកកខ្វក់ និងអនាម័យ ប្រព័ន្ធដឹកជញ្ជូនក្នុងទីក្រុង ថាមពល វិស័យសំណង់ និងទេសចរណ៍។ល។ ផ្អែកលើការវិភាគលើក្រុងសក្តានុពលទាំង ៧ (ផ្នែកទី ២ នៃផែនការនេះ បង្ហាញលម្អិតអំពីទិដ្ឋភាពរួមនៃការអភិវឌ្ឍក្រុងនីមួយៗ) យើងកំណត់បានសកម្មភាពអាទិភាពដែលអាចឆ្លើយតបបានទៅនឹងគោលដៅ និងចក្ខុវិស័យនៃការអភិវឌ្ឍទីក្រុងនិរន្តរភាព។

### ១.៣.១. ការវិភាគជាយុទ្ធសាស្ត្រ

**តម្រូវការនៃការអភិវឌ្ឍនិរន្តរភាពក្នុងវិស័យនគរូបនីយកម្មនៅក្នុងប្រទេសកម្ពុជា**

តាមរយៈការវិភាគស្ថានភាពនៅតាមបណ្តាក្រុងដែលមានសក្តានុពលមួយចំនួននៃប្រទេសកម្ពុជា យើងសង្កេតឃើញថា ទោះបីជាខណៈពេលនេះចំនួនប្រជាជនរស់នៅក្នុងតំបន់ទីក្រុងនៅមានចំនួនតិច បើធៀបទៅនឹងចំនួនប្រជាជនរស់នៅតំបន់ជនបទក៏ដោយ ក៏រាជធានី ក្រុងធំៗ និងទីប្រជុំជនសំខាន់ៗនៅក្នុងប្រទេសកម្ពុជាកំពុងតែជួបនូវបញ្ហាប្រឈមជាច្រើនពីការរីកលូតលាស់យ៉ាងឆាប់រហ័សនៃទីក្រុង ដោយសារការអភិវឌ្ឍវិស័យនគរូបនីយកម្មមិនទាន់មានផែនការអភិវឌ្ឍន៍ដែលប្រកបដោយនិរន្តរភាពច្បាស់លាស់នៅឡើយ ជាពិសេសហេដ្ឋារចនាសម្ព័ន្ធសាធារណៈដែលទ្រទ្រង់នៅក្នុងវិស័យនេះ។ កត្តានេះនឹងធ្វើឱ្យទីក្រុង និងទីប្រជុំជនទាំងនោះប្រឈមនឹងបញ្ហាសង្គម និងបរិស្ថានជាច្រើនដូចជាការប្រើប្រាស់ដីនៅមិនទាន់មានប្រសិទ្ធភាព ការផ្តល់សេវានិងហេដ្ឋារចនាសម្ព័ន្ធសាធារណៈមូលដ្ឋានមិនបានគ្រប់ជ្រុងជ្រោយ ការបាត់បង់ធនធានធម្មជាតិ ការកើនឡើងនូវការស្ទះចរាចរណ៍ ការបំពុលបរិយាកាស កង្វះការងារធ្វើ និងវិសមភាពក្នុងទីក្រុង។ បើមិនមានផែនការរៀបចំនគរូបនីយកម្មក្រុង និងទីប្រជុំជនបានសមស្របទេនោះ វិសមភាពនៃការអភិវឌ្ឍតាមតំបន់ក្រុងនឹងមានការកើនឡើង ដែលជាកត្តាមួយនាំឱ្យមានវិសមភាពនៃប្រាក់ចំណូលក្នុងចំណោមប្រជាជនរស់នៅក្នុងទីក្រុងនិងក្រុងកាន់តែខ្លាំង។

បញ្ហាទាំងនេះ ក៏អាចបណ្តាលមកពីការគ្រប់គ្រងវិស័យនគរូបនីយកម្មទីក្រុងនៅមានលក្ខណៈខ្វះខាតនៅឡើយ ការធ្វើផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ក្រុងនៅមានកម្រិត ការផ្សារភ្ជាប់រវាងការធ្វើផែនការ និងការគ្រប់គ្រងបរិស្ថាននៅមានកម្រិត និងការវិនិយោគទៅលើសេវាកម្ម និងហេដ្ឋារចនាសម្ព័ន្ធសាធារណៈ មិនទាន់គ្រប់គ្រាន់ជាដើម។ ការរៀបចំនគរូបនីយកម្មនាពេលបច្ចុប្បន្ន គឺកំពុងប្រមូលផ្តុំយ៉ាងខ្លាំងនៅក្នុងរាជធានីភ្នំពេញ និងតំបន់ជុំវិញរាជធានីតាមតំបន់ទីប្រជុំជនខ្លះនៅភាគពាយព្យជុំវិញបឹងទន្លេសាប និងតំបន់វាលទំនាប។

ការប្រមូលផ្តុំនៃវិស័យឧស្សាហកម្ម ការបង្កើតការងារ និងការផ្តល់សេវាសាធារណៈ គឺផ្តោតសំខាន់នៅតាមបណ្តាក្រុងសក្តានុពលធំៗ ជាពិសេសនៅរាជធានីភ្នំពេញ។ ឧទាហរណ៍ការផ្តល់សេវាសាធារណៈដែលមានគុណភាព ដូចជាការផ្គត់ផ្គង់ទឹកស្អាត ការគ្រប់គ្រង និងការប្រមូលសំរាមជាដើម គឺនៅមានលក្ខណៈមិនស្មើគ្នា ដែលយើងអាចមើលឃើញថាលក្ខខណ្ឌ និងឱកាសនៃការវិនិយោគលើហេដ្ឋារចនាសម្ព័ន្ធនៅរាជធានីភ្នំពេញ គឺមានលក្ខណៈល្អប្រសើរខ្ពស់ដាច់ឆ្ងាយ បើធៀបជាមួយការផ្តល់សេវាសាធារណៈនៅតាមបណ្តាក្រុង ទីប្រជុំជនតូចៗ និងនៅតំបន់ជនបទ។

ការអភិវឌ្ឍទីក្រុង អាចជាកាតាលីករសំខាន់មួយនៃការអភិវឌ្ឍសេដ្ឋកិច្ចរបស់ប្រទេស។ ប៉ុន្តែការអភិវឌ្ឍទីក្រុងនៅប្រទេសកម្ពុជា គឺបានតែបណ្តាក្រុងធំៗ មួយចំនួនតូចប៉ុណ្ណោះ គឺមិនទាន់មានលក្ខណៈទូលំទូលាយនៅឡើយ។ ដរាបណាការរៀបចំផែនការអភិវឌ្ឍន៍ និងការគ្រប់គ្រងទីក្រុង និងទីប្រជុំជនដទៃទៀតនៅមិនទាន់មានលក្ខណៈច្បាស់លាស់ និងមានបរិយាបន្ន ការអភិវឌ្ឍសេដ្ឋកិច្ចគឺនៅមានលក្ខណៈប្រមូលផ្តុំតាមតំបន់។ ការធ្វើឱ្យប្រសើរឡើងនៃដំណើរការរៀបចំផែនការទីក្រុង ការអភិវឌ្ឍ និងការគ្រប់គ្រង (អភិបាលកិច្ចទីក្រុង) គឺជាតម្រូវការចាំបាច់ និងកំពុងក្លាយជាកត្តាសំខាន់ ប្រសិនបើចង់ឱ្យទីក្រុងដែលកំពុងមានការរីកលូតលាស់ "គួរអោយចង់រស់នៅ" ប្រកបដោយនិរន្តរភាពបរិស្ថាន និងការអភិវឌ្ឍសេដ្ឋកិច្ចក្នុង រយៈពេលពីមធ្យមទៅវែង។

បើការអនុវត្តប្រកបដោយប្រសិទ្ធភាព នោះការអភិវឌ្ឍទីក្រុងនិរន្តរភាព គឺជាវិធីសាស្ត្រមួយដែលអាចជួយឱ្យសម្រេចបាននូវទិសដៅនោះ។ ទីក្រុងនិរន្តរភាព គឺជាការអភិវឌ្ឍរយៈពេលវែងដែលការពារដល់បរិស្ថាន ធានាបានបរិយាបន្នសង្គមនិងនិរន្តរភាពកំណើនសេដ្ឋកិច្ច។ កាន់តែច្បាស់ជាងនេះទៀត ទីក្រុងនិរន្តរភាព គឺជាទីក្រុងដែលប្រើប្រាស់ធនធានប្រកបដោយប្រសិទ្ធភាព ធន់ទៅនឹងការប្រែប្រួលអាកាសធាតុ ធានាបាននូវបរិយាបន្នសង្គម និងសមភាព។ ការអភិវឌ្ឍបៃតង គឺជាកត្តាសំខាន់សម្រាប់ទីក្រុងនិរន្តរភាព ដែលវាមានសក្តានុពលផ្តល់ផលប្រយោជន៍ជាច្រើនដូចជាការបង្កើតការងារបៃតង បង្កើនការផ្សារភ្ជាប់រវាងទីក្រុង និងទីផ្សារ ការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធ ការផ្តល់នូវសេវាសាធារណៈបានគ្រប់ជ្រុងជ្រោយ ការបន្សាំនឹងការប្រែប្រួលអាកាសធាតុរបស់ទីក្រុង និងការអភិវឌ្ឍដែលមានការបំភាយកាបូនតិច។

## បរិបទគោលនយោបាយ

លក្ខខណ្ឌទូទៅនៃការអភិវឌ្ឍទីក្រុងនិរន្តរភាព មានលក្ខណៈស្របទៅនឹងក្របខ័ណ្ឌគោលនយោបាយជាតិរបស់រាជរដ្ឋាភិបាលកម្ពុជា។ ផែនទីបង្ហាញផ្លូវជាតិស្តីពី ការអភិវឌ្ឍបៃតង (២០០៩) គោលនយោបាយជាតិស្តីពី ការអភិវឌ្ឍបៃតង និងផែនការយុទ្ធសាស្ត្រជាតិស្តីពីការអភិវឌ្ឍបៃតង ឆ្នាំ២០១៣-២០៣០ ផ្តោតសំខាន់ទៅលើកត្តាជាច្រើនដែលជាគន្លឹះសំខាន់សម្រាប់ការអភិវឌ្ឍបៃតងនៅតាមបណ្តាក្រុងដែលមានសក្តានុពល។ កត្តាទាំងនេះរួមមានការវិនិយោគបៃតង និងការងារបៃតង ការអភិវឌ្ឍសេដ្ឋកិច្ចបៃតង ការគ្រប់គ្រងបច្ចេកវិទ្យាបៃតង សុវត្ថិភាពសង្គម ការរក្សាអត្តសញ្ញាណជាតិ និងបេតិកភណ្ឌវប្បធម៌ដែលមានលក្ខណៈបៃតង និងអភិបាល-កិច្ចល្អក្នុងការអភិវឌ្ឍបៃតង។ វិស័យអាទិភាពមួយចំនួនដែលសំខាន់សម្រាប់បណ្តាក្រុងដែលមានសក្តានុពល រួមមាន៖ ការប្រើប្រាស់ដីធ្លីប្រកបដោយនិរន្តរភាព ការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធបៃតងវិស័យដឹកជញ្ជូន និងទេសចរណ៍ ការគ្រប់គ្រងថាមពលប្រកបដោយប្រសិទ្ធភាព រួមទាំងថាមពលកកើតឡើងវិញ និងការគ្រប់គ្រងធនធានទឹក។

អនុក្រឹត្យស្តីពីនគរូបនីយកម្ម រាជធានី ក្រុង និងទីប្រជុំជនដែលបានអនុម័តឆ្នាំ ២០១៥ និងសេចក្តីព្រាងក្របខ័ណ្ឌជាតិអភិវឌ្ឍន៍ទីប្រជុំជន ដែលដឹកនាំដោយក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ក៏មានទស្សនវិស័យដូចគ្នាដែរ គឺសំដៅលើការអភិវឌ្ឍនគរូបនីយកម្មរាជធានី ក្រុង និងទីប្រជុំជនប្រកបដោយនិរន្តរភាព និងបរិយាបន្នសង្គម។ នៅក្នុងសេចក្តីព្រាងក្របខ័ណ្ឌយុទ្ធសាស្ត្រជាតិអភិវឌ្ឍន៍ទីប្រជុំជនបានកំណត់ចក្ខុវិស័យសម្រាប់ការអភិវឌ្ឍតំបន់ក្រុងទាំងអស់ ពោលគឺ

> "ទីក្រុង និងទីប្រជុំជននៅទូទាំងប្រទេស នឹងត្រូវបានអភិវឌ្ឍន៍យ៉ាងល្អជាបន្តបន្ទាប់ក្នុងលក្ខណៈប្រកបដោយនិរន្តរភាព និងមានភាពធន់ទៅនឹងការប្រែប្រួលអាកាសធាតុ ផ្តល់ឱកាសឱ្យមានការអភិវឌ្ឍសេដ្ឋកិច្ចដែលមានតុល្យភាព រក្សាបាននូវបរិយាកាសល្អ និងគុណភាពនៃសេវាកម្មដែលបម្រើដល់ប្រជាជនក្នុងទីក្រុង និងទីប្រជុំជនក្រុង ដែលនឹងនាំឱ្យមានការរស់នៅល្អប្រសើរ និងបរិយាបន្នសង្គម ហើយអាចរួមចំណែកដល់ការកាត់បន្ថយភាពក្រីក្រ កែលម្អជីវភាពរស់នៅ និងសុខុមាលភាព មានកំណើន

សេដ្ឋកិច្ច និងមានតុល្យភាពនៃការអភិវឌ្ឍទីក្រុង និងទីប្រជុំជនសម្រាប់វប្បធម៌ សង្គម និងនិរន្តរភាពបរិស្ថាន។”[១២]

គោលនយោបាយអភិវឌ្ឍន៍ឧស្សាហកម្ម បានបញ្ជាក់ពីភាពចាំបាច់ក្នុងការពិចារណាពីសេដ្ឋកិច្ចដែលមានលក្ខណៈពិពិធកម្ម និងមានការផ្លាស់ប្តូរយ៉ាងឆាប់រហ័សមួយនៅក្នុងប្រទេសកម្ពុជា។ គោលនយោបាយនេះមានបំណងជំរុញកំណើនវិស័យឧស្សាហកម្មឱ្យបាន ៣០% នៃផលិតផលក្នុងស្រុកសរុប (ផសស) នៅឆ្នាំ ២០២៥ ដោយបង្កើតនូវបរិយាកាសទាក់ទាញវិនិយោគិនបរទេសតាមរយៈការកាត់បន្ថយនូវបែបបទរដ្ឋបាលស្មុគស្មាញ បង្កើតនូវរបបពន្ធដែលមានតុល្យភាព និងការកែលម្អហេដ្ឋារចនាសម្ព័ន្ធ។ គោលនយោបាយនេះ កំណត់នូវកាតាលីករដែលអាចមានសម្រាប់ការអភិវឌ្ឍវិស័យឧស្សាហកម្ម ហើយដែលផ្សាភ្ជាប់ទៅនឹងការពង្រីកទំនាក់ទំនងរវាងតំបន់ដែលមានការអភិវឌ្ឍខ្ពស់ទៅនឹងតំបន់សំខាន់ៗផ្សេងទៀត (ខេត្តដែលជាច្រករបៀង) ហើយវានឹងដើរតួនាទីសំខាន់ក្នុងការពង្រីក និងអភិវឌ្ឍន៍តំបន់ទីប្រជុំជនផងដែរ។ ឧទាហរណ៍ ក្រុងព្រះសីហនុត្រូវបានកំណត់ជាក្រុងអាទិភាពសម្រាប់ការអភិវឌ្ឍទីក្រុងនិរន្តរភាពរបស់អាស៊ានដែលស្ថិតនៅក្រោមគោលនយោបាយអភិវឌ្ឍន៍វិស័យឧស្សាហកម្ម។ ថ្មីៗនេះ រាជរដ្ឋាភិបាលកម្ពុជា តាមរយៈក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជាបាននឹងកំពុងរៀបចំបញ្ចប់សេចក្តីព្រាងច្បាប់វិនិយោគថ្មីៗ និងសេចក្តីព្រាងច្បាប់ស្តីពី តំបន់សេដ្ឋកិច្ចពិសេស។ ច្បាប់ថ្មីៗទាំងនេះ នឹងផ្តល់តម្លាភាព ភាពអំណោយផលដល់បរិយាកាសវិនិយោគ និងការលើកទឹកចិត្តប្រកបដោយភាពទាក់ទាញសំដៅចូលរួមចំណែកដល់ការធ្វើពិពិធកម្មសេដ្ឋកិច្ច និងបង្កើនផលិតភាពឧស្សាហកម្ម ឆ្លើយតបនឹងគោលនយោបាយអភិវឌ្ឍន៍វិស័យឧស្សាហកម្មកម្ពុជា ២០១៥-២០២៥ និងវិធានការកែទម្រង់ដ៏ត្រឹមត្រូវរបស់រាជរដ្ឋាភិបាល ដែលបានដាក់ចេញកាលពីខែមីនាឆ្នាំ២០១៩កន្លងមក។ ច្បាប់វិនិយោគថ្មី ច្បាប់ស្តីពីតំបន់សេដ្ឋកិច្ចពិសេស នឹងមានការលើកទឹកចិត្តដល់ក្រុមហ៊ុនដែលគិតគូរយូរអង្វែងពីទំនួលខុសត្រូវសង្គម ពោលគឺផ្តោតសំខាន់លើ ៣ចំនុចធំៗ គឺទី១ យកចិត្តទុកដាក់ចំពោះបរិស្ថាន ទី២ យកចិត្តទុកដាក់ចំពោះបុគ្គលិក និងទី៣ យកចិត្តទុកដាក់ចំពោះបរិយាបន្នសង្គម។ កត្តានេះនឹងជួយជំរុញបន្ថែមដល់រដ្ឋបាលក្រុង និងស្ថាប័នពាក់ព័ន្ធក្នុងការជំរុញគម្រោងវិនិយោគហេដ្ឋារចនាសម្ព័ន្ធបៃតងសម្រាប់អភិវឌ្ឍន៍ក្រុង[១៣]។

ការអភិវឌ្ឍទីក្រុងនិរន្តរភាព ក៏ត្រូវបានផ្សាភ្ជាប់យ៉ាងល្អជាមួយកម្មវិធីទីក្រុងស្អាតរបស់រាជរដ្ឋាភិបាល ដើម្បីលើកកម្ពស់សម្រស់អនាម័យ បរិស្ថានល្អ និងជីវភាពរស់នៅក្នុងក្រុង និងទាក់ទាញភ្ញៀវទេសចរថែមទៀត។ ដោយប្រើប្រាស់លក្ខណៈវិនិច្ឆ័យចំនួន ១១៣ និងសូចនាករចំនួន ៤១ប្រភេទ ក្រុងនីមួយៗនឹងត្រូវបានចាត់ថ្នាក់ដោយគណៈកម្មាធិការជាតិវាយតម្លៃទីក្រុងស្អាតទៅតាមវិស័យសំខាន់ៗមានដូចជា ភាពស្អាត (អនាម័យ) ការគ្រប់គ្រងសំណល់ ការផ្តល់សេវាសាធារណៈ ការកសាងហេដ្ឋារចនាសម្ព័ន្ធ និងលើកកម្ពស់ការយល់ដឹង។ ក្រុងដែលមានចំណាត់ថ្នាក់ល្អ និងបន្តបន្ទាប់ គឺជាទីក្រុងដែលមានពិន្ទុ ៧៥% ៦០% និង៤០% នឹងត្រូវបានផ្តល់ជូនដោយផ្ការំដួល ៣ទង ២ទង និង ១ទង ទៅតាមចំណាត់ថ្នាក់[១៤]។

ការអភិវឌ្ឍទីក្រុងនិរន្តរភាព មានសារៈសំខាន់ណាស់ដើម្បីចូលរួមបំពេញកាតព្វកិច្ច និងការប្តេជ្ញាចិត្តនៅលើឆាកអន្តរជាតិរបស់ប្រទេសកម្ពុជាលើការអភិវឌ្ឍប្រកបដោយចីរភាព និងប្រយុទ្ធប្រឆាំងការប្រែប្រួលអាកាសធាតុ។ ការអភិវឌ្ឍទីក្រុងនិរន្តរភាព នឹងជួយរួមចំណែកដល់គោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាព (SDGs) របស់ប្រទេសកម្ពុជា (ជាពិសេសគោលដៅទី ១១ ស្តីពីទីក្រុង និងសហគមន៍ប្រកបដោយនិរន្តរភាព) និងការចូលរួមចំណែកដើម្បីអនុវត្តអនុសញ្ញាក្របខ័ណ្ឌសហប្រជាជាតិស្តីពីការប្រែប្រួលអាកាសធាតុ របស់ប្រទេសកម្ពុជា នៅក្រោមកិច្ចព្រមព្រៀងទីក្រុងប៉ារីស។

ការអភិវឌ្ឍទីក្រុងនិរន្តរភាព មានសក្តានុពលអាចជួយឱ្យមានការប្រែប្រួលក្នុងសង្គម ដោយសារការប្រមូលផ្តុំនៃសកម្មភាពសេដ្ឋកិច្ច ការច្នៃប្រឌិត និងការបង្កើតការងារថ្មីៗ។ តួនាទីរបស់ទីក្រុងនិរន្តរភាព មិនត្រឹមតែមានសារៈសំខាន់ដល់ការសម្រេចបានគោលដៅទី ១១

[12] MLMUPC, Sub-Decree on Urbanization for the Capital City, City and Urban Areas (2015).

[13] Economist, "New Investment Law More Encourage Private Sectors," last modified July 26, 2019, https://cambonomist.com/news/new-investment-law-more-encourage-private-sectors-/

[14] National Committee for Clean City Assessment, "About National Clean City Competition," last modified July 30, 2019, http://www.cambodiacleancity.gov.kh/kh

ស្តីពីទីក្រុង និងសហគមន៍ប្រកបដោយនិរន្តរភាពប៉ុណ្ណោះទេ វាក៏ជួយគាំទ្រដល់គោលដៅទាំង ១៧ ផ្សេងទៀតផងដែរ។ សកម្មភាពនៅថ្នាក់ក្រុងមានសារៈសំខាន់ខ្លាំងណាស់សម្រាប់ភាពជោគជ័យរបស់គោលដៅអភិវឌ្ឍន៍ប្រកបដោយនិរន្តរភាព ( SDGs ) ហេតុដូច្នេះ បណ្តាក្រុងដែលមានសក្តានុពលនៅកម្ពុជា និងមន្ត្រីសាលាក្រុង ក៏ដូចជាមន្ត្រីមូលដ្ឋាន គួរតែមានលទ្ធភាពសមស្របក្នុងការអភិវឌ្ឍ និងអនុវត្តនូវសកម្មភាពទីក្រុងនិរន្តរភាពក្នុងដែនសមត្ថកិច្ចមូលដ្ឋានរបស់ខ្លួន។

ការចូលរួមចំណែកដើម្បីអនុវត្តអនុសញ្ញាក្របខ័ណ្ឌសហប្រជាជាតិស្តីពីការប្រែប្រួលអាកាសធាតុ (NDC) របស់ប្រទេសកម្ពុជា មានផែនការកាត់បន្ថយការបំភាយឧស្ម័នឱ្យបាន ២៧% ធៀបទៅនឹងចំហាកព្យាករណ៍តាមទម្លាប់ធម្មតានៅត្រឹមឆ្នាំ២០៣០ ដែលត្រូវបានគេប៉ាន់ស្មានថាមានចំនួន ១១.៦០០.០០០តោន កាបូនឌីអុកស៊ីត ($tCO_{2e}$)។ វិស័យអាទិភាពដែលបានកំណត់នៅក្រោមសកម្មភាពកាត់បន្ថយការប្រែប្រួលអាកាសធាតុ រួមមានវិស័យថាមពល ការដឹកជញ្ជូន ផលិតកម្ម និងប្រសិទ្ធភាពថាមពល នៅតាមអគារ (ប្រភេទនេះ បានដាក់នៅក្រោមប្រភេទ "ផ្សេងៗ" នៅក្នុង NDC) ដែលទាំងអស់នេះទាក់ទងនឹងការអភិវឌ្ឍទីក្រុងនិរន្តរភាព។ លើសពីនេះទៀត ការចូលរួមចំណែកដើម្បីអនុវត្តអនុសញ្ញាសហប្រជាជាតិស្តីពីការប្រែប្រួលអាកាសធាតុ (NDC) បានកំណត់បញ្ជីនៃសកម្មភាពអាទិភាពសម្រាប់កម្មវិធីបន្សាំ។ ភាគច្រើននៃសកម្មភាពទាំងនេះមានដូចជា "ការបង្កើតទំនប់ការពារទឹកជំនន់សម្រាប់ការអភិវឌ្ឍទីក្រុង" និង "ការបង្កើនហេដ្ឋារចនាសម្ព័ន្ធធន់នឹងការប្រែប្រួលអាកាសធាតុ" និងការបង្ហាញពីឥទ្ធិពលនៃផលប៉ះពាល់ពីការកើនឡើងនៃកម្រិតទឹកសមុទ្រតាមបណ្តាក្រុងជាប់មាត់សមុទ្រ ដូចជាក្រុងកែបនិងក្រុងព្រះសីហនុ។

ចុងក្រោយ ការអភិវឌ្ឍទីក្រុងនិរន្តរភាព ក៏នឹងជួយពន្លឿនប្រទេសកម្ពុជាក្នុងការអនុវត្តរបៀបវារៈថ្មីសម្រាប់ការអភិវឌ្ឍទីក្រុង/ទីប្រជុំជន ដែលបានបង្កើត និងអនុម័តឡើងនៅក្នុងទីក្រុងគីតូ (Quito) ប្រទេសអេក្វាឌ័រ (Ecuador) នៅក្នុងខែតុលា ឆ្នាំ២០១៦ កន្លងមក។ សេចក្តីថ្លែងការណ៍នៃកិច្ចប្រជុំក្រុងគីតូ(Quito) ស្តីពីទីក្រុងនិរន្តរភាព និងការមានលំនៅឋានសម្រាប់ មនុស្សទាំងអស់គ្នា បានអំពាវនាវដូចខាងក្រោម[១៥]៖

- ការអភិវឌ្ឍទីក្រុងនិរន្តរភាព ដើម្បីជានាបរិយាបន្នសង្គមនិងលុបបំបាត់ភាពក្រីក្រ
- បង្កើនវឌ្ឍនភាព និងឱកាសសម្រាប់ទីក្រុងដែលមាននិរន្តរភាព និងបរិយាបន្នភាព សម្រាប់ទាំងអស់គ្នា
- ការអភិវឌ្ឍទីក្រុងប្រកបដោយចីរភាពបរិស្ថាន និងភាពធន់ទៅនឹងការប្រែប្រួលអាកាសធាតុ
- កសាងរចនាសម្ព័ន្ធអភិបាលកិច្ចទីក្រុង៖ បង្កើតក្របខ័ណ្ឌ និងរចនាសម្ព័ន្ធគាំទ្រ
- រៀបចំផែនការ និងគ្រប់គ្រងការអភិវឌ្ឍទីក្រុង។

## ការប៉ាន់ប្រមាណអំពីកត្តាប្រឈម និងកាលានុវត្តភាពក្នុងវិស័យសំខាន់ៗក្នុងទីក្រុង។

ផ្នែកនេះ នឹងពិភាក្សាអំពីកត្តាប្រឈម និងកាលានុវត្តភាពសំខាន់ៗ មួយចំនួនដល់ការអភិវឌ្ឍនិរន្តរភាព នៅតាមបណ្តាទីក្រុង ឬទីប្រជុំជននៃប្រទេសកម្ពុជា ដោយបែងចែកជាបួនផ្នែក (១) ការរៀបចំផែនការក្រុង និងអភិវឌ្ឍន៍ហេដ្ឋារចនាសម្ព័ន្ធ (២) ការអភិវឌ្ឍសេដ្ឋកិច្ចបៃតងក្រុង (៣)បរិយាបន្នសង្គម និង (៤) អភិបាលកិច្ចល្អ។ ការប៉ាន់ប្រមាណនេះ ផ្អែកលើលទ្ធផលពីការប្រមូលទិន្នន័យគ្រប់ជ្រុងជ្រោយ និងការពិគ្រោះយោបល់ជាមួយភាគីពាក់ព័ន្ធនៅតាមបណ្តាទីក្រុងចំនួន៧។ ទីក្រុងទាំង៧ ត្រូវបានជ្រើសរើសដោយរដ្ឋបាលថ្នាក់ជាតិ ដោយប្រើប្រាស់នូវលក្ខណៈវិនិច្ឆ័យ ៧ ចំណុចពាក់ព័ន្ធនឹងការអភិវឌ្ឍនិរន្តរភាព (តារាងទី១.១) ដើម្បីជាតំណាងដល់បណ្តាក្រុងផ្សេងៗតាមតំបន់ ដែលបានបែងចែកជា ៣ តំបន់៖ តំបន់ឆ្នេរ (ក្រុងព្រះសីហនុ និងក្រុងកែប) តំបន់ទំនាប (ក្រុងកំពង់ចាម ក្រុងសួង និងក្រុងបាវិត) និងតំបន់តាមដងទន្លេសាប (ក្រុងសៀមរាប និងក្រុងបាត់ដំបង) (រូបភាពទី៣)។

[15] United Nations, "UN conference agrees new urban development agenda creating sustainable, equitable cities for all," last modified October 20, 2016, http://www.un.org/sustainabledevelopment/blog/2016/10/un-conference-agrees-new-urban-development-agenda-creating-sustainable-equitable-cities-for-all/

## តារាងទី ១.១. លក្ខណៈវិនិច្ឆ័យជ្រើសរើសទីក្រុង

| លក្ខណៈវិនិច្ឆ័យ | ពន្យល់អត្ថន័យ |
|---|---|
| មានសក្តានុពលផ្នែកសេដ្ឋកិច្ចក្នុងការចូលរួមចំណែកដល់ការអភិវឌ្ឍជាតិ | មានសកម្មភាពសេដ្ឋកិច្ចសំខាន់ៗ ដែលរួមចំណែកដល់កំណើនសេដ្ឋកិច្ចជាតិ និងកាត់បន្ថយភាពក្រីក្រ។ |
| សារៈសំខាន់នៃទីតាំងភូមិសាស្ត្រសម្រាប់ តុល្យភាពនៃការបែងចែកតំបន់ | សារៈសំខាន់នៃកំណើនប្រកបដោយចីរភាពនៃក្រុងនេះ នឹងនាំឱ្យមានតុល្យភាពនៃការអភិវឌ្ឍជាតិ និងតាមទីប្រជុំជន។ |
| មានការចាប់អារម្មណ៍ចូលរួម និងការប្តេជ្ញាចិត្តខ្ពស់របស់រដ្ឋបាលនៅមូលដ្ឋាន | ការចាប់អារម្មណ៍ និងការប្តេជ្ញាចិត្តចូលរួមរបស់អាជ្ញាធរមូលដ្ឋានក្នុងការអភិវឌ្ឍទីក្រុងនិរន្តរភាព។ |
| កំណើនប្រជាជន | អត្រាកំណើនប្រជាជនក្នុងក្រុង ដែលបានព្យាករួចពាក់ព័ន្ធនឹងតម្រូវការកើតចេញពីការអភិវឌ្ឍនាពេលខាងមុខ។ |
| វិសាលភាពនៃបញ្ហាសង្គមនិងបរិស្ថាន ដែលតម្រូវឱ្យមានវិធានការបន្ទាន់ | ភាពធ្ងន់ធ្ងរនៃបញ្ហាសង្គម និងបរិស្ថានក្រុងដែលនឹងជះឥទ្ធិពលដល់ការអភិវឌ្ឍទីក្រុងនិរន្តរភាពក្នុងពេលដ៏ឆាប់ខាងមុខ បើមិនមានការដោះស្រាយជាមុនឱ្យបានទាន់ពេលវេលាទេ។ |
| មានគោលនយោបាយ និងការគ្រប់គ្រងស្ថាប័នល្អនៅថ្នាក់ក្រុងដែលអំណោយផលល្អដល់ការអភិវឌ្ឍទីក្រុងនិរន្តរភាព | គោលនយោបាយ និងការគ្រប់គ្រងស្ថាប័ននៅថ្នាក់មូលដ្ឋាន(រដ្ឋបាលក្រុង) ដែលនឹងផ្តល់ភាពងាយស្រួល ឬការលំបាក ដល់ការអនុវត្តគម្រោង។ ការគាំទ្រដល់ការអនុវត្តគម្រោងពីរដ្ឋបាលនានានៅមូលដ្ឋាន មានសារៈសំខាន់ណាស់ដែលអាចធានាភាពជោគជ័យនៃការអភិវឌ្ឍទីក្រុងនិរន្តរភាព។ |
| មានការជួយគាំទ្រពីដៃគូអភិវឌ្ឍន៍ ឬ ស្ថាប័នផ្សេងទៀត | កម្រិតនៃការទទួលបានការគាំទ្រពីដៃគូអភិវឌ្ឍន៍ អង្គការជាតិ និងអន្តរជាតិនៅក្នុងការអភិវឌ្ឍក្រុង។ |

រូបភាពទី១.៣. ផែនទីប្រទេសកម្ពុជាបង្ហាញពីក្រុងទាំង៧ដែលត្រូវបានជ្រើសរើស[១៦]




## ក. ការរៀបចំផែនការអភិវឌ្ឍន៍ទីក្រុងនិរន្តរភាព និង ការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធបៃតង

ក្នុងរយៈពេល ២ទសវត្សរ៍ចុងក្រោយនេះ ប្រទេសកម្ពុជា គឺជាប្រទេសដែលមានកំណើនប្រជាជនរស់នៅក្នុងទីប្រជុំជនលឿនជាងគេមួយនៅក្នុងតំបន់។ នៅក្នុងឆ្នាំ២០០០ ប្រជាជនរស់នៅក្នុងទីប្រជុំជនមានប្រមាណតែ ៩២០.០០០ នាក់ប៉ុណ្ណោះ ហើយចំនួននេះបានកើនឡើងដល់ទៅ ៣,៥លាននាក់ នៅឆ្នាំ២០១៦ (ប្រមាណ ២០,៩% នៃចំនួនប្រជាជនសរុប)[១៧]។ នៅឆ្នាំ២០១៩ប្រជាជនរស់នៅក្នុងទីប្រជុំជនមានប្រមាណ ២៤,៩% ហើយត្រូវបានព្យាករណ៍ថានឹងកើនឡើងដល់ ២៦,៧% នៅឆ្នាំ២០២៣[១៨] និងដល់ ៤៤% នៅឆ្នាំ២០៣០[១៩]។

ការរីកលូតលាស់យ៉ាងឆាប់រហ័សនៃវិស័យនគរូបនីយកម្មក្នុងទីក្រុងនៃប្រទេសកម្ពុជា កំពុងជំរុញឱ្យរាជរដ្ឋាភិបាលខិតខំប្រឹងប្រែងក្នុងការកសាងហេដ្ឋារចនាសម្ព័ន្ធ និងសេវាសាធារណៈឱ្យបានគ្រប់ជ្រុងជ្រោយ និងប្រកបដោយនិរន្តរភាព។ សព្វថ្ងៃនេះ បញ្ហាប្រឈមគឺការរៀបចំនគរូបនីយកម្មទីក្រុងភាគច្រើនមិនមានផែនការជាមុន

[16] Image from Google Maps

[17] Trading Economics, "Cambodia - Urban Population (% of total)," accessed May 10, 2016, https://tradingeconomics.com/cambodia/urban-population-percent-of-total-wb-data.html

[18] Ministry of Planning (MoP). "National Strategic Development Plan 2019-2023,"

[19] Ministry of Planning (MoP). "National Institute of Statistics, Socio-Economic Survey 2016"

និងមិនមានការគ្រប់គ្រងច្បាស់លាស់ ដែលកំពុងបង្កើតជាបញ្ហាយ៉ាងច្រើនដល់សង្គម សេដ្ឋកិច្ច និងបរិស្ថាន។ ក្រុងជាច្រើនក្នុងប្រទេសកម្ពុជា កំពុងប្រឈមនឹងការខ្វះខាតការរៀបចំផែនការក្រុងដែលមានលក្ខណៈជាប្រព័ន្ធ និងការខ្វះខាតធនធានហិរញ្ញវត្ថុសម្រាប់អភិវឌ្ឍន៍ហេដ្ឋារចនាសម្ព័ន្ធ និងផ្តល់សេវាទីក្រុងដែលមាននិរន្តរភាព។

រាជរដ្ឋាភិបាលកម្ពុជា តាមរយៈក្រសួងរៀបចំដែនដី នគរូបនីយកម្មនិងសំណង់ កំពុងបន្តជំរុញការគ្រប់គ្រង និងការរៀបចំផែនការដីធ្លីដែលជាអាទិភាពមួយទាំងនៅថ្នាក់មូលដ្ឋាន ជាតិ និងតំបន់។ ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ ២០១៩-២០២៣ បានដាក់ចេញនូវគោលដៅដូចខាងក្រោម៖

## តារាងទី ១.២. គោលដៅនៃការរៀបចំផែនការប្រើប្រាស់ដី ២០១៩-២០២៣[២០]

| សូចនាករ | ឯកតា | ២០១៨ | ២០១៩ | ២០២០ | ២០២១ | ២០២២ | ២០២៣ |
|---|---|---|---|---|---|---|---|
| ផែនការរៀបចំដែនដីថ្នាក់ជាតិ | ផែនការ | ០ | ០ | ០ | ០ | ០ | ១ |
| ផែនការរៀបចំដែនដីថ្នាក់តំបន់ | ផែនការ | - | ១ | ១ | ២ | ២ | ៣ |
| ផែនការរៀបចំដែនដីថ្នាក់ខេត្ត | ផែនការ | ៣ | ៧ | ៩ | ១១ | ១៣ | ១៥ |
| ប្លង់គោលប្រើប្រាស់ដីថ្នាក់ក្រុង និងទីប្រជុំជន | ប្លង់គោល | ៩ | ២៣ | ២៥ | ២៧ | ២៩ | ៣១ |
| ប្លង់គោលប្រើប្រាស់ដីថ្នាក់ស្រុកខណ្ឌ | ប្លង់គោល | - | ១៩ | ២៥ | ២៩ | ៣៤ | ៣៨ |
| ផែនការប្រើប្រាស់ដីថ្នាក់ឃុំ សង្កាត់ | ផែនការ | ៨០ | ១៧៩ | ១៩៩ | ២១៩ | ២៣៩ | ២៥៩ |

សម្រាប់ការអភិវឌ្ឍទីក្រុងដែលមានរចនាសម្ព័ន្ធច្បាស់លាស់ ការធ្វើផែនការរៀបចំ និងបែងចែកតំបន់ប្រើប្រាស់ដី គឺជាលក្ខខណ្ឌចាំបាច់ដំបូងមុននឹងមានការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធទីក្រុងប្រកបដោយនិរន្តរភាព។ ឯកឧត្តម ប្រាជ្ញ ចន្ទ អតីតអភិបាលខេត្តបាត់ដំបង ធ្លាប់សរសេរអារម្ភកថានៅក្នុងឆ្នាំ២០០៩ ថា "ផែនការប្រើប្រាស់ដីធ្លីនឹងធានាឱ្យមានការអភិវឌ្ឍទីក្រុងប្រកបដោយនិរន្តរភាពនិងរលូន ហើយអាចបញ្ចៀសបញ្ហា និងឧបសគ្គនាពេលអនាគត[...] ការរៀបចំផែនការប្រើប្រាស់ដីនឹងជំរុញឱ្យមានកំណើនសេដ្ឋកិច្ចសង្គម និងរួមចំណែកដល់គោលដៅរួម គឺការកាត់បន្ថយភាពក្រីក្រ" ។ នៅតាមបណ្តាក្រុងនានានៃព្រះរាជាណាចក្រកម្ពុជា ក្រុងបាត់ដំបងបានបញ្ចប់ការរៀបចំផែនការមេប្រើប្រាស់ដីរបស់ខ្លួនសម្រាប់ការអភិវឌ្ឍក្រុងរួចរាល់មុនគេកាលពីឆ្នាំ២០១៥។ ក្រុង២ ទៀត មានក្រុងសៀមរាប និងក្រុងកែប ទើបតែបញ្ចប់ការរៀបចំប្លង់គោលប្រើប្រាស់ដីរបស់ខ្លួនកាលពីឆ្នាំ២០១៨ និងកំពុងរៀបចំផែនការប្រើប្រាស់ដីបន្តទៀត។ ក្រុងផ្សេងៗទៀតនៃប្រទេសកម្ពុជាកំពុងតែស្ថិតនៅក្នុងដំណាក់កាលរៀបចំប្លង់គោល និងផែនការប្រើប្រាស់ដីធ្លី បែងចែកតំបន់ ការធ្វើផែនទីប្រើប្រាស់ដី និងសេចក្តីព្រាងផែនការមេ។ បញ្ហាប្រឈម គឺដំណើរការនៃការរៀបចំផែនការមេ (ប្លង់គោល) ចំណាយពេលយូរខណៈសន្ទុះនៃនគរូបនីយកម្មមានល្បឿនលឿន។

[២០] Ministry of Planning (MoP). “National Strategic Development Plan 2019-2023,” p.356

ដំណើរការយឺតយ៉ាវនេះ នឹងនាំឱ្យមានការមកតាំងលំនៅអនាធិបតេយ្យ ការសាងសង់អគារមិនមានការត្រួតពិនិត្យបានត្រឹមត្រូវ មិនមានការគ្រប់គ្រងលើការបែងចែកតំបន់សម្រាប់អាជីវកម្ម និង/ឬ ការអភិវឌ្ឍលំនៅឋានដែលនឹងអាចឈានទៅរកការរៀបចំហេដ្ឋារចនាសម្ព័ន្ធទីក្រុងមិនត្រូវតាមទិសដៅ។ ឧទាហរណ៍នៅក្រុងកំពង់ចាម ដោយមិនមានផែនការប្រើប្រាស់ដីច្បាស់លាស់ ក្រុងត្រូវដោះស្រាយរាល់ផលប៉ះពាល់ពីការដំឡើងប្រព័ន្ធលូបង្ហូរទឹកកខ្វក់ និងប្រព័ន្ធលូទឹកភ្លៀងថ្មីឡើងវិញ ក្នុងឆ្នាំ២០១៧ ដែលនេះបង្កឱ្យមានការខាតបង់យ៉ាងច្រើនខាងផ្នែកសេដ្ឋកិច្ច និងសង្គម។ សាលាក្រុងត្រូវដោះស្រាយទូទាត់សំណងដល់ម្ចាស់ផ្ទះដែលបានសាងសង់ផ្ទះ អគារ ឬផ្លូវរួចហើយដើម្បីដំឡើងប្រព័ន្ធលូឡើងវិញស្របទៅតាមគោលការណ៍ណែនាំរបស់រដ្ឋាភិបាល។ យើងអាចសង្កេតឃើញថា កាលណាមានការយឺតយ៉ាវក្នុងការរៀបចំផែនការអភិវឌ្ឍន៍ក្រុង នឹងនាំឱ្យមានការយឺតយ៉ាវលើការវិនិយោគហេដ្ឋា-រចនាសម្ព័ន្ធក្រុង ហើយនេះជាកត្តាមួយធ្វើឱ្យកំណើនសេដ្ឋកិច្ចដែលមានសក្តានុពល និងសេវាហេដ្ឋារចនាសម្ព័ន្ធក្រុងកាន់តែយឺតផងដែរ។ សមត្ថភាពក្នុងក្រុងមូលដ្ឋាននៅមានកម្រិត និងកង្វះការគាំទ្រផ្នែកបច្ចេកទេស និងថវិកាពីរដ្ឋបាលថ្នាក់ជាតិ គឺជាបញ្ហាចម្បងមួយដែលបានលើកឡើងដោយរដ្ឋបាលមូលដ្ឋាន ថាវាជាកត្តាដែលនាំឱ្យការរៀបចំផែនការនគរូបនីយកម្មយឺតយ៉ាវ។

តម្រូវការចាំបាច់ក្នុងការរៀបចំផែនការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធក្រុង ដែលតម្រូវឱ្យមានការយកចិត្តទុកដាក់ខ្ពស់ស្រាប់នោះ កាន់តែជួបការលំបាកបន្ថែមដោយសារការប្រែប្រួលអាកាសធាតុ។ ប្រទេសកម្ពុជា គឺជាប្រទេសមួយដែលងាយរងគ្រោះពីការប្រែប្រួលអាកាស-ធាតុ[២១]។ នៅក្នុងការវាយតម្លៃពីហានិភ័យពីការប្រែប្រួលអាកាសធាតុសកលឆ្នាំ២០១៧ (Global Climate Risk Index)ដែលបានវិភាគដោយអង្គការ ជឿរមែនវ៉ចឆ៍ (Germanwatch) បានបង្ហាញថាប្រទេសកម្ពុជាស្ថិតនៅក្នុងក្រុមដែលមានហានិភ័យខ្ពស់ មានចំណាត់ថ្នាក់ទី ១១៥ ក្នុងចំណោមប្រទេស ១៨១ ប្រទេស។ បើប្រៀបធៀបទៅនឹង ២០ឆ្នាំមុន (១៩៩៨-២០១៧) ប្រទេសកម្ពុជាមានចំណាត់ថ្នាក់ទី ១៩ នឹងមានពិន្ទុ ៣៩,៦៧[២២]។ ស្រដៀងគ្នានេះដែរ ការវិភាគរបស់អង្គការម៉ាផលក្រហ្វធ៍ (Maplecroft) នៅក្នុងចំណោម ១៩១ ប្រទេសដែលមានភាពងាយរងគ្រោះពីការប្រែប្រួលអាកាសធាតុ (Climate Change Vulnerability Index) ក្នុងឆ្នាំ២០១៧ មាន៣៣ប្រទេស ស្ថិតនៅក្នុងក្រុមប្រទេសដែលមានហានិភ័យខ្ពស់បំផុត ៤៤ប្រទេសជាក្រុមប្រទេសដែលមានហានិភ័យខ្ពស់ ៧៥ ប្រទេសជាក្រុមប្រទេសមានហានិភ័យមធ្យម និង៣៩ប្រទេសជាក្រុមប្រទេសមានហានិភ័យទាប។ ប្រទេសកម្ពុជា ស្ថិតនៅក្នុងចំណោមប្រទេសដែលមានហានិភ័យខ្ពស់[២៣]។

## ការគ្រប់គ្រងសំរាម

សំរាម គឺជាបញ្ហាទូទៅមួយនៅគ្រប់បណ្តាទីក្រុងនៃប្រទេសកម្ពុជា។ ដោយសារកំណើនប្រជាជន និងកំណើនសកម្មភាពសេដ្ឋកិច្ចជាពិសេសពីវិស័យទេសចរណ៍ សំណង់ និងឧស្សាហកម្ម បាននាំឱ្យបរិមាណសំរាមក្នុងទីក្រុងនៅទូទាំងប្រទេសបានកើនឡើងយ៉ាងខ្លាំងរហូតដល់ជាង ៤លានតោនក្នុងមួយឆ្នាំនៅប៉ុន្មានឆ្នាំចុងក្រោយនេះ។ ក្នុងបរិមាណដ៏ច្រើននេះ សំរាមដែលបានប្រមូលទៅចោលនៅទីលានចាក់សំរាមមានតែ ៣៧%ប៉ុណ្ណោះ ១២%មានការកែច្នៃ និង ៥១% ត្រូវបានទុកចោល ឬដុតចោល ទោះបីជាមានច្បាប់ហាមប្រាមក៏ដោយ[២៤]។ ចំណែកបរិមាណសំរាមនៅទីលានចាក់សំរាមក៏ត្រូវបានមើលឃើញថាមានការកើនឡើងយ៉ាងគំហុកផងដែរ ពីប្រមាណ ៣១៧.៥៥០ តោនក្នុងមួយឆ្នាំអំឡុងឆ្នាំ២០០៤ មកដល់ ១.៥០៣.៧២៣ តោនក្នុងមួយឆ្នាំ ពីអំឡុងឆ្នាំ២០១៧[២៥] និងនៅតែបន្តកើនឡើង។ ការកើនឡើងនៃបរិមាណសំរាមយ៉ាងគំហុកនេះ បូកផ្សំជាមួយការគ្រប់គ្រងនៅមិនទាន់បានល្អប្រសើរ (រួមមានការប្រមូល ការទុកដាក់ និងការដឹកជញ្ជូនសំរាម) និងកង្វះការចូលរួម

[21] MEF & GSSD. "Addressing Climate Change Impacts on Economic Growth in Cambodia," (2019).

[22] Germanwatch, "Global Climate Risk Index 2019," accessed September 10, 2019, https://germanwatch.org/sites/germanwatch .org/files/Global%20Climate%20Risk%20Index%202019_2.pdf

[23] Maplecroft, "Climate Change Vulnerability Index 2017," accessed September 9

[24] Data from Ministry of Environment's page on 27 July 2019 during the awareness campaign in Siem Reap on the use of plastic bags and the environmental-friendly bags. https://www.facebook.com/Ministry-of-Environment-314699302002531/

[25] Presentation by the Department of Waste Management of the Ministry of Environment in August 2017 during the consultative workshop under Green Urban Development Program Phase II, organized by GGGI.

របស់សហគមន៍ បានធ្វើឱ្យបញ្ហាសំរាមក្លាយជាបញ្ហាចម្បងមួយនៃទីក្រុង ដែលត្រូវការការកែលម្អ។ ជាក់ស្តែង ការរីកលូតលាស់យ៉ាងខ្លាំងនៅក្រុងព្រះសីហនុបាននាំឱ្យមានបរិមាណសំរាមកើនឡើងយ៉ាងគំហុករហូតដល់ទៅជាង១.០០០តោនក្នុងមួយថ្ងៃ ក្នុងឆ្នាំ២០១៩នេះ ដែលកាលពីឆ្នាំ២០១៥ សំរាមមានមិនដល់ ២០០តោនផងក្នុងមួយថ្ងៃ។ ជាលទ្ធផល សំរាមជាច្រើនត្រូវបានទុកគរចោលនៅតាមផ្លូវ មួយចំនួនបោះចូលទៅក្នុងសមុទ្រខ្លះបានដុតចោលមិនបានត្រឹមត្រូវ។ រដ្ឋបាលក្រុងព្រះសីហនុមានការពិបាកគ្រប់គ្រងស្ថានការនៃការកើនឡើងគំហុកនេះ បានស្នើដល់ដៃគូអភិវឌ្ឍន៍នានា និងវិស័យឯកជនក្នុងការរួមគ្នាដោះស្រាយ និងគ្រប់គ្រងសំរាមប្រកបដោយនិរន្តរភាព[២៦]។

នៅប្រទេសកម្ពុជា មានតែរាជធានីភ្នំពេញមួយគត់ដែលបានរៀបចំផែនការយុទ្ធសាស្ត្រ និងសកម្មភាពរយៈពេលវែង (២០១៨-២០៣៥) ដើម្បីគ្រប់គ្រងសំរាមក្នុងរាជធានីភ្នំពេញ (បរិមាណដែលប៉ាន់ស្មាន គឺ ៣.០០០ តោនក្នុងមួយថ្ងៃ) ប្រកបដោយនិរន្តរភាព និងដើរទន្ទឹមគ្នាទៅនឹងការរីកលូតលាស់យ៉ាងឆាប់រហ័សនៃតំបន់រាជធានី ក្នុងវិស័យសេដ្ឋកិច្ច និងឧស្សាហកម្ម[២៧]។ ផែនការនេះបានបង្ហាញគម្រូដ៏ល្អមួយសម្រាប់បណ្តាក្រុងនានានៅទូទាំងប្រទេសកម្ពុជាក្នុងការដាក់ចេញនូវចក្ខុវិស័យរយៈពេលវែង ដើម្បីឆ្លើយតបទៅនឹងបញ្ហាសំរាមដែលបន្តកើនឡើងជាលំដាប់ ដែលជាលទ្ធផលនៃការរីកលូតលាស់នៃតំបន់ទីប្រជុំជនក្រុង។

បច្ចុប្បន្នការគ្រប់គ្រងសំរាមនៅតាមបណ្តាក្រុងជាច្រើនត្រូវបានប្រគល់ទៅឱ្យក្រុមហ៊ុនឯកជន ដោយសារដំណើរការសេវាប្រមូលថ្លៃសំរាមមានលក្ខណៈខុសគ្នារវាងទីក្រុង និងក្រុង បានធ្វើឱ្យស្តង់ដារនៃសេវាប្រមូលសំរាមក៏ខុសគ្នាដែរ។ លើសពីនេះទៀត ទីលានចាក់សំរាមដែលកំពុងមានស្រាប់មិនមានគុណភាពល្អនៅឡើយ និងមិនមានការរៀបចំ និងគ្រប់គ្រងតាមស្តង់ដាបច្ចេកទេសដែលនាំឱ្យមានផលប៉ះពាល់ដល់បរិស្ថាន និងសង្គម (សារធាតុក្លិនផ្អូរ ការជ្រាបទឹកចេញពីសំរាម សំបុកសត្វល្អិត ការបំភាយសារធាតុមេតាន និងកំទេចសំរាមរាយប៉ាយ)។

សេវាប្រមូលសំរាមមិនបានគ្របដណ្តប់គ្រប់តំបន់ទាំងអស់នៃក្រុងឬស្រុកទេ ដោយសារតែការខាតបង់ផ្នែកសេដ្ឋកិច្ច (ការចំណាយខ្ពស់ធៀបនឹងទំហំការងារគ្រប់គ្រង) ខ្វះផ្លូវចូលទៅប្រមូលសំរាម និងខ្វះការចូលរួមស្ម័គ្រចិត្តបង់ថ្លៃសេវាប្រមូលសំរាមពីសហគមន៍។ មានការប៉ាន់ស្មានថា ប្រជាជនរស់នៅក្នុងទីក្រុង ទីប្រជុំជនប្រមាណតែ៥៨% ប៉ុណ្ណោះដែលទទួលបានសេវាកម្មប្រមូលសំរាម[២៨]។ ការដុតសំរាមចោលនៅតាមទីវាល គឺជាវិធីសាស្ត្រទូទៅមួយសម្រាប់អ្នកដែលមិនប្រើសេវាកម្មប្រមូលសំរាម ហើយជាទូទៅការដុតសំរាមចោលបានធ្វើឡើងដោយគ្មានការញែកសំរាមជាមុនទេ (ឧទាហរណ៍ការញែកសារធាតុប្លាស្ទិកចេញពីការដុត) ហើយដុតនៅកន្លែងដែលមានសីតុណ្ហភាពទាប ដែលកត្តានេះបណ្តាលឱ្យមានការបញ្ចេញសារធាតុ ឬឧស្ម័នពុលទៅក្នុងបរិយាកាស ការហៀរចេញនៃសារធាតុគ្រោះថ្នាក់ចូលទៅក្នុងដី ដែលអាចប៉ះពាល់ដល់ចរន្តទឹកក្រោមដី។

ការយល់ដឹងជាសាធារណៈទៅលើការទុកដាក់សំរាមឱ្យបានសមស្រប និងជម្រើសឱ្យមានការកែច្នៃសំរាមដើម្បីប្រើប្រាស់ឡើងវិញនៅមានកម្រិតទាបនៅឡើយ។ នៅតាមសហគមន៍មួយចំនួនខ្វះការគាំទ្រដើម្បីអនុវត្តកម្មវិធីផ្លាស់ប្តូរឥរិយាបថ និងពង្រឹងការទទួលខុសត្រូវជាលក្ខណៈបុគ្គលនៅក្នុងការទុកដាក់ និងចោលសំរាមផ្ទាល់ខ្លួនឱ្យបានត្រឹមត្រូវ។ យុទ្ធនាការលើកកម្ពស់ការយល់ដឹងជាសាធារណៈ គឺត្រូវតែមានការអនុវត្តជាចាំបាច់នៅក្នុងវិស័យនេះ។

ទស្សនទាននៃគោលការណ៍ ៤Rs (កាត់បន្ថយ ប្រើប្រាស់ឡើងវិញកែច្នៃឡើងវិញ និងកែច្នៃជាវត្ថុធាតុដើមសម្រាប់ផលិតផលផ្សេង) និងការញែកសំរាម ត្រូវបានយកមកបង្ហាញ និងធ្វើការណែនាំដល់សាធារណជន ប៉ុន្តែមិនទាន់ត្រូវបានអនុវត្តពេញលេញ និងមានប្រសិទ្ធភាពនៅឡើយ ហើយទស្សនទាន និងគោលការណ៍នេះមិនទាន់ជ្រាបច្បាស់ក្នុងការអនុវត្តប្រចាំថ្ងៃរបស់សាធារណជននៅឡើយដែរ។ នៅប្រទេសកម្ពុជា មានតែក្រុងបាត់ដំបងមួយទេ ដែលមានរោងចក្រកែច្នៃធ្វើជីកំប៉ុសតូចមួយ ក្រៅពីនេះការកែច្នៃសំរាមឡើងវិញនៅក្នុងទីក្រុង ឬកន្លែងចាក់សំរាមនៅក្រៅទីក្រុង

[26] B. Sokhean, “Governor seeks World Bank’s help as Sihanoukville rubbish rockets to 1,000 tonnes a day,” The Khmer Times. Last modified October 9, 2019, https://www.khmertimeskh.com/50649191/governor-seeks-world-banks-help-to-tackle-waste-woes/

[27] Phnom Penh Capital Administration (2018). “Phnom Penh Waste Management Strategy and Action Plan 2018-2035”

[28] S. Sethy, C. Sothun and R. Wildblood, “Municipal Solid Waste Management in Cambodia,” in Municipal Solid Waste Management in Asia and the Pacific Islands, ed. A. Pariatamby and M. Tanaka (Singapore: Springer Environmental Science and Engineering, 2014).

នៅតែមិនមានរចនាសម្ព័ន្ធគ្រប់គ្រងល្អទេ។ សំណល់សំរាមមួយចំនួនដែលនៅមានតម្លៃខ្លះ ដូចជាដប សំណប៉ាហាំង កំប៉ុងអាលុយមីញ៉ូម និងដបកែវផ្សេងៗ ត្រូវបានប្រមូល និងលក់ទៅឱ្យក្រុមដើរទិញសំណល់រឹងដែលមិនមានលក្ខណៈផ្លូវការ ហើយក្រៅពីនោះសំរាមដែលនៅសេសសល់គឺប្រមូល និងយកទៅចាក់ចោលនៅតំបន់ជាយក្រុងដោយគ្មានវិធានការណាមួយសម្រាប់ការពារបរិស្ថាន។

ក្នុងគោលបំណងធ្វើវិមជ្ឈការការគ្រប់គ្រងសំណល់ សំរាមទៅថ្នាក់ក្រោមជាតិ រាជរដ្ឋាភិបាលបានអនុម័ត អនុក្រឹត្យលេខ ១១៣ នៅខែសីហា ឆ្នាំ២០១៥ ដើម្បីកំណត់អាណត្តិច្បាស់លាស់ និងល្អប្រសើរជាងមុនស្តីពីការគ្រប់គ្រងសំណល់ សំរាម។ អនុក្រឹត្យនេះមានគោលបំណងដូចខាងក្រោម៖

- ពង្រឹងការទទួលខុសត្រូវរបស់ក្រសួង ស្ថាប័ន អង្គភាពជំនាញរដ្ឋបាលថ្នាក់ក្រោមជាតិ និងភាគីដែលពាក់ព័ន្ធទៅនឹងការគ្រប់គ្រងសំរាម និងសំណល់នៅក្នុងទីក្រុង ទីប្រជុំជន

- ចាត់តាំងភារកិច្ចគ្រប់គ្រងសំរាម និងសំណល់ផ្សេងៗ នៅតាមក្រុងទៅកាន់រដ្ឋបាលក្រុង និងស្រុក

- កំណត់វិធានការចាំបាច់នានាដើម្បីបង្កើនប្រសិទ្ធភាព និងសុវត្ថិភាពក្នុងការគ្រប់គ្រងសំរាម និងសំណល់ផ្សេងៗនៅក្នុងក្រុង

- បង្កើនការយល់ដឹងសាធារណៈ និងការចូលរួមរបស់ប្រជាពលរដ្ឋនៅក្នុងការបង្កើត និងអនុវត្តការគ្រប់គ្រងសំរាម និងសំណល់ផ្សេងៗ នៅតាមមូលដ្ឋាន។

ការអនុវត្តអនុក្រឹត្យនេះ នៅមានកម្រិតនៅឡើយដោយសារតែកង្វះធនធានហិរញ្ញវត្ថុ និងមនុស្សសម្រាប់ធ្វើការតាមដាន និងអនុវត្តន៍។ ជាឧទាហរណ៍ លក្ខខណ្ឌក្នុងការទុកដាក់សំរាម វេចខ្ចប់តាមផ្ទះនិងការហាមប្រាមដុតសំរាម ការចោលសំរាមមិនត្រឹមត្រូវមិនទាន់ត្រូវបានរៀបចំ និងផ្សព្វផ្សាយឱ្យបានទូលំទូលាយ ដូចជាការពិន័យជាប្រាក់ជាដើម។ ការផ្ទេរតួនាទី ទៅរដ្ឋបាលក្រុង ស្រុកខណ្ឌ ឃុំ សង្កាត់ ក៏នៅមានកម្រិតនៅឡើយ នៅឆ្នាំ២០១៧ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុបានផ្តល់ថវិកាចំនួន៨.០០០លានរៀល (ប្រមាណ ២លានដុល្លារសហរដ្ឋអាមេរិក) ទៅដល់២៦ក្រុងនៅទូទាំងប្រទេសដើម្បីបំពេញនូវចន្លោះខ្វះខាតផ្នែកហិរញ្ញវត្ថុក្នុងការគ្រប់គ្រងសំណល់រឹង និងរាវ។ ទោះជាយ៉ាងណាក៏ដោយចំនួននេះនៅតែមិនគ្រប់គ្រាន់ដើម្បីរក្សាទីក្រុងឱ្យស្អាតបានទេ។ កត្តានេះទាមទារចាំបាច់ឱ្យមានបែបបទ ឬគំរូនៃការប្រមូលកម្រៃសេវាប្រមូលសំរាមដែលមានលក្ខណៈតម្លាភាព និងប្រកបដោយនិរន្តរភាពនៅតាមបណ្តាក្រុងនានាដែលទទួលបានការឧបត្ថម្ភធនពីរដ្ឋបាលក្រុង ប្រសិនបើកិច្ចការប្រមូលសំរាមនឹងត្រូវធ្វើជាសេវាសាធារណៈនោះ។

## តារាងទី១.៣. ថវិកាសម្រាប់សេវាសម្អាតបរិស្ថាន ឆ្នាំ២០១៧

| រដ្ឋបាលក្រុង | ថវិកា (លានរៀល) | រដ្ឋបាលក្រុង | ថវិកា (លានរៀល) |
|---|---|---|---|
| សេរីសោភ័ណ្ឌ | ៤០៥ | ព្រៃវែង | ២២២ |
| ប៉ោយប៉ែត | ៤៤៧ | ពោធិ៍សាត់ | ៣៣១ |
| បាត់ដំបង | ៥៦១ | បានលុង | ២៣៥ |
| កំពង់ចាម | ២៦០ | សៀមរាប | ៧៨៣ |
| កំពង់ឆ្នាំង | ២៦៧ | ព្រះសីហនុ | ៣៦១ |
| ច្បារមន | ២៨៥ | ស្ទឹងត្រែង | ២៣៦ |
| ស្ទឹងសែន | ៣០៧ | ស្វាយរៀង | ២៧៨ |
| កំពត | ២៤៩ | បាវិត | ២៥៩ |
| តាខ្មៅ | ៣៥០ | ដូនកែវ | ២៧១ |
| ខេមរភូមិន្ទ | ២៣០ | សំរោង | ៣២០ |
| ក្រចេះ | ២៣៨ | កែប | ២០៩ |
| សែនមនោរម្យ | ១៩២ | ប៉ៃលិន | ២៥២ |
| ព្រះវិហារ | ២១៤ | សួង | ២៥២ |

*ប្រភព៖ ឯកសារបទបង្ហាញពីនាយកដ្ឋានគ្រប់គ្រងសំណល់រឹង នៃក្រសួងបរិស្ថាន*

នៅពាក់កណ្តាលឆ្នាំ២០១៩ ក្រសួងបរិស្ថាន ដែលជាស្ថាប័នដឹកនាំការអនុវត្តអនុក្រឹត្យ លេខ ១១៣ កំពុងពិនិត្យលទ្ធភាពអនុម័តកញ្ចប់ថវិកាសេវាអនាម័យបរិស្ថានឱ្យបានសមស្របផ្តល់ជូនរដ្ឋបាលថ្នាក់ក្រោមជាតិដែលមានរដ្ឋបាលក្រុង-ស្រុកទាំងអស់ដើម្បីបង្កើនភាពងាយស្រួលអនុវត្តការងារគ្រប់គ្រងសំរាម សំណល់រឹង ទីប្រជុំជនឲ្យមានប្រសិទ្ធភាពខ្ពស់ជាងមុន។ ការអនុម័តនេះសបញ្ជាក់ថាក្រសួងត្រៀមលក្ខណៈបច្ចេកទេស និងមូលនិធិដើម្បីគាំទ្រដល់ផែនការសកម្មភាពរបស់រដ្ឋបាលក្រុង ស្រុកទាំងអស់ដែលចូលរួមរៀបចំហេដ្ឋារចនាសម្ព័ន្ធគ្រប់គ្រងសំណល់រឹង សំរាមនៅតាមមូលដ្ឋានរៀងៗខ្លួន ដោយផ្ទាល់ និងមានការសហការជាមួយដៃគូអាជីវកម្ម និងបច្ចេកវិទ្យា សមស្រប ឬរៀបចំគ្រប់គ្រងសំណល់រឹងឱ្យបានល្អ។ នៅថ្ងៃទី២២ ខែកក្កដា ឆ្នាំ២០១៩ ក្រសួងបរិស្ថានបានចេញសេចក្តីប្រកាស និងគោលការណ៍ក្នុងការកែលម្អ និងការអនុវត្តការងារគ្រប់គ្រងសំរាមទីក្រុង។ គោលការណ៍នេះ បានដាក់ចេញនូវយន្តការសម្រាប់ខ្សែសង្វាក់នៃការកកើត និងគ្រប់គ្រងសំរាមមានដូចជា[២៩]៖

[29] MOE, "Prakas No. 249 PRK B.ST on the Implementation of Guideline for the Improvement of Solid Waste and Municipal Waste Management," adopted on July 22, 2019.

[30] MOI, MEF & MOE, "Inter-Ministerial Prakas No. 8682 PRK on the Management and Use of Transitional Money from Penalties for Offenses the Sub-Decree 113," adopted on September 10, 2019.

- យន្តការនៃការប្រមូល និងដឹកជញ្ជូនសំរាម
- យន្តការសម្រាប់ការកំណត់កម្រៃប្រមូលសំរាម
- យន្តការនៃការប្រមូលកម្រៃសេវាប្រមូលសំរាម (១) ដោយរដ្ឋបាលក្រុង (២)ដោយក្រុមហ៊ុនឯកជន
- យន្តការគ្រប់គ្រងទីលានចាក់សំរាម
- យន្តការសម្រាប់ការលើកទឹកចិត្តផ្នែកហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងសំរាម

បន្ថែមលើនេះទៀត កាលពីថ្ងៃទី១០ ខែកញ្ញា ឆ្នាំ២០១៩ ក្រសួងបរិស្ថាន រួមជាមួយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងក្រសួងមហាផ្ទៃបានចេញប្រកាសអន្តរក្រសួងមួយស្តីពីការគ្រប់គ្រង និងប្រើប្រាស់ប្រាក់ពិន័យអន្តរកាល ដែលទទួលបានពីការល្មើសលើអនុក្រឹត្យ១១៣[៣០]។

## អនាម័យ និងទឹកកខ្វក់

ការគ្រប់គ្រងប្រព័ន្ធលូទឹកកខ្វក់ និងលូទឹកភ្លៀង គឺជាបញ្ហាប្រឈមចម្បងមួយទៀតសម្រាប់ទីក្រុង ទីប្រជុំជន។ បច្ចុប្បន្ននេះ នៅទូទាំងប្រទេសកម្ពុជាមានអាងប្រព្រឹត្តិកម្មទឹកកខ្វក់តែ ៣កន្លែងប៉ុណ្ណោះ ដែលកំពុងប្រតិបត្តិការគឺមាននៅក្រុងសៀមរាប ដែលមានសមត្ថភាពប្រព្រឹត្តិកម្មទឹកកខ្វក់បានចំនួន ៣.០០០ម៉ែត្រគូបក្នុងមួយថ្ងៃ នៅក្រុងព្រះសីហនុ បានចំនួន ៦.៩០០ម៉ែត្រគូប និងក្រុងបាត់ដំបង បានចំនួន ១.០០០ម៉ែត្រគូប។ អាងប្រព្រឹត្តិកម្មទាំងនេះ មិនគ្រប់គ្រាន់ដើម្បីឆ្លើយតបទៅនឹងតម្រូវការដែលកំពុងកើនឡើងរបស់ក្រុងនីមួយៗទេ។ ប្រព័ន្ធលូទឹកកខ្វក់នៅក្រុងព្រះសីហនុ បានសាងសង់តាំងពីសម័យបារាំង ហើយត្រូវបានរៀបចំឡើងដើម្បីបម្រើប្រជាពលរដ្ឋត្រឹមតែចំនួន ៣៨.០០០នាក់ប៉ុណ្ណោះកាលពីសម័យកាលនោះ។ ចំណែកអាងប្រព្រឹត្តិកម្មនៅឯក្រុងបាត់ដំបង គឺធ្វើឡើងសម្រាប់បម្រើដល់ប្រជាពលរដ្ឋតែ ១៥.០០០នាក់ប៉ុណ្ណោះ ក្នុងទំហំផ្ទៃដីចំនួន ៨៩ហិកតា ប៉ុន្តែបច្ចុប្បន្ននេះសមត្ថភាពរបស់អាងប្រព្រឹត្តិកម្ម បានត្រឹមតែ ៤៥០ម៉ែត្រគូប ក្នុងមួយថ្ងៃដោយសារតែការសឹករេចរឹលនៃប្រព័ន្ធអាង។ បច្ចុប្បន្ន ក្រុងទាំងនេះកំពុងរៀបចំផែនការដើម្បីកែលម្អអាងប្រព្រឹត្តិកម្មរបស់ខ្លួន ដោយមានការសហការដៃគូជាមួយធនាគារអភិវឌ្ឍន៍អន្តរជាតិនានា។

ទឹកកខ្វក់នៅក្នុងបណ្តាក្រុងផ្សេងទៀត គឺធ្វើការបញ្ចេញចោលទៅក្នុងប្រឡាយ ស្រះ ឬទន្លេ ដោយគ្មានការធ្វើប្រព្រឹត្តិកម្មឡើង។ កត្តានេះបណ្តាលឱ្យមានការបំពុលធ្ងន់ធ្ងរ ការធ្លាក់ចុះនៃបរិស្ថាននិងប៉ះពាល់ទៅលើសុខភាពមនុស្ស។ ជាឧទាហរណ៍នៅក្រុងកំពង់ចាម សំណល់ទឹកកខ្វក់ទាំងអស់នៅក្នុងក្រុងត្រូវបានបញ្ចេញពីប្រព័ន្ធលូបង្ហូរទឹកកខ្វក់ និងលូទឹកភ្លៀង ចូលទៅក្នុងទន្លេមេគង្គដោយគ្មានការធ្វើប្រព្រឹត្តិកម្មជាមុន។ ក្រុងសួងមិនមានប្រព័ន្ធបង្ហូរទឹកកខ្វក់ ឬប្រព័ន្ធលូទឹកភ្លៀងទេ ហើយបច្ចុប្បន្នសំណល់ទឹកកខ្វក់ត្រូវបានបង្ហូរចូលទៅក្នុងស្រះ និងស្ទឹងធម្មជាតិតាមប្រឡាយចាស់ៗ។ ក្រុងបាវិត និងក្រុងកែបក៏ប្រឈមនឹងបញ្ហាស្រដៀងគ្នានេះផងដែរ។

កង្វះធនធានហិរញ្ញវត្ថុ និងធនធានមនុស្ស និងការពង្រឹងអំណាចនិងសមត្ថភាពដល់ក្រុងមិនពេញលេញ ក៏ជាឧបសគ្គចម្បងសម្រាប់ការអភិវឌ្ឍ និងការគ្រប់គ្រងប្រព័ន្ធលូទឹកផងដែរ។ ទោះបីជាអាជ្ញាធរក្រុង បានដឹងពីផលវិបាកយ៉ាងធ្ងន់ធ្ងរនៃបញ្ហាទឹកកខ្វក់ក៏ដោយ ក៏ពួកគេមិនមានជម្រើសអ្វីផ្សេងក្រៅពីការត្រូវរង់ចាំការគាំទ្រផ្នែកបច្ចេកទេស និងហិរញ្ញវត្ថុពីរដ្ឋបាលថ្នាក់ខេត្ត ថ្នាក់ជាតិ និងដៃគូអភិវឌ្ឍន៍។

រាជរដ្ឋាភិបាលកម្ពុជាបានទទួលស្គាល់ពីភាពធ្ងន់ធ្ងរ និងភាពចាំបាច់នៃបញ្ហាទឹកកខ្វក់។ រាជរដ្ឋាភិបាលបានបង្កើតនូវគោលនយោបាយនិងផែនការជាតិសម្រាប់ការដោះស្រាយលើបញ្ហានេះ និងសេវាអនាម័យនៅតាមទីក្រុងនិងក្រុងនានា តាមរយៈការធ្វើយុទ្ធសាស្ត្ររយៈពេលខ្លី មធ្យម និងវែង។ ក្រសួងសាធារណការ និងដឹកជញ្ជូនបានដាក់ចេញអនុក្រឹត្យមួយស្តី ពីការគ្រប់គ្រងប្រព័ន្ធលូបង្ហូរទឹក និងប្រព័ន្ធប្រព្រឹត្តិកម្មទឹកកខ្វក់ ដើម្បីគ្រប់គ្រងលើបញ្ហានៅក្នុងវិស័យនេះឱ្យមាននិរន្តរភាពជាងមុន។ នៅឆ្នាំ២០៣០ ក្រោមយុទ្ធសាស្ត្ររបស់ក្រសួងសាធារណការ និងដឹកជញ្ជូន អាងទឹកកខ្វក់នៅតាមផ្ទះ (Septic Tank) / ប្រព័ន្ធប្រព្រឹត្តិកម្មទឹកកខ្វក់ខ្នាតតូច (DEWATS) នឹងត្រូវបានតភ្ជាប់ទៅនឹងអាងស្តុកទឹកមេ និងនៅត្រឹមឆ្នាំ២០៥០ ការគ្រប់គ្រងទឹកកខ្វក់ និងសេវាអនាម័យនឹងអាចផ្តល់ជូនប្រជាពលរដ្ឋបានទាំងអស់គ្នានៅទូទាំងប្រទេស[៣១]។

[31] MPWT's presentation in a regional policy workshop on wastewater management in Bangkok, Southeast Asia, April 2-3, 2015.

ទោះជាយ៉ាងណាក៏ដោយ ការសម្រេចឱ្យបាននូវគោលដៅទាំងនេះ ត្រូវការយុទ្ធសាស្ត្រអនុវត្ត និងការចូលរួមពីគ្រប់ភាគីពាក់ព័ន្ធ។ កត្តានេះ រួមបញ្ចូលទាំងការកំណត់ឱ្យឃើញស្ថាប័នដឹកនាំការអនុវត្ត ពោលគឺស្ថាប័ននាំមុខ អ្នកធ្វើគោលនយោបាយ បទបញ្ញត្តិនានា និងអ្នកផ្តល់សេវាកម្មនេះ។ អនុក្រុមការងារបច្ចេកទេស ស្តីពីការគ្រប់គ្រងទឹកកខ្វក់ និងអនាម័យ បានសម្របសម្រួលឱ្យមានអ្នកជំនាញការពីគ្រប់ស្ថាប័នពាក់ព័ន្ធនៃរាជរដ្ឋាភិបាលកម្ពុជា ដៃគូអភិវឌ្ឍន៍ ត្រូវបានបង្កើតឡើងនៅក្នុងខែមករា ឆ្នាំ២០១៩ ក្រោមការដឹកនាំរបស់ក្រសួងសាធារណការ និងដឹកជញ្ជូន។

ដើម្បីសម្រេចបានវត្ថុបំណងនៃអនុក្រឹត្យលេខ ២៣៥ យើងត្រូវការបង្កើតនូវក្របខ័ណ្ឌហិរញ្ញប្បទាន និងមូលនិធិប្រកបដោយនិរន្តរភាពមួយ ក៏ដូចជាការជ្រើសរើសនូវបច្ចេកវិទ្យាដែលសមស្របទៅតាមស្ថានភាពជាក់លាក់ និងការលើកកម្ពស់ការយល់ដឹងអំពីសារៈសំខាន់និងផលប្រយោជន៍នៃការធ្វើប្រព្រឹត្តិកម្មទឹកកកខ្វក់ការប្រើប្រាស់ទឹកឡើងវិញ និងសេវាអនាម័យទីក្រុង។ មានគម្រោងការហេដ្ឋារចនាសម្ព័ន្ធធំជាច្រើនក្នុងវិស័យគ្រប់គ្រងទឹកកខ្វក់ និងប្រព័ន្ធប្រព្រឹត្តិកម្មរួម កំពុងត្រូវបានធ្វើការសិក្សា និងវាយតម្លៃដោយមានការគាំទ្រពីដៃគូអភិវឌ្ឍន៍នានាសម្រាប់ដោះស្រាយ បញ្ហាទឹកកខ្វក់នៅក្រុងមួយចំនួនដូចជាក្រុងព្រះសីហនុ ក្រុងសៀមរាប និងក្រុងបាវិត។ ប៉ុន្តែកត្តាសំខាន់គឺសមត្ថភាព និងលទ្ធភាពក្នុងការគ្រប់គ្រងនូវសំណង់ និងប្រព័ន្ធហេដ្ឋារចនាសម្ព័ន្ធធំៗបែបនេះ របស់រាជរដ្ឋាភិបាលជាពិសេសគឺនិរន្តរភាពនៃថវិកាសម្រាប់ការប្រតិបត្តិនិងថែទាំ។ វាក៏ជាកត្តាសំខាន់មួយដែរ សម្រាប់ប្រព័ន្ធគ្រប់គ្រងនិងប្រព្រឹត្តិកម្មទឹកកខ្វក់មេ្សរួម ដែលមានការបំពេញបន្ថែមដោយប្រព្រឹត្តិកម្មខ្នាតតូចដាច់ដោយឡែក ជាពិសេសនៅតាមតំបន់ជាយក្រុងដែលប្រជាជនក្រីក្ររស់នៅប្រមូលផ្តុំ ដែលជារឿយៗតំបន់ទាំងនោះមិនត្រូវបានគ្របដណ្តប់ដោយប្រព័ន្ធមេរួម។ ការរក្សាបឹងធម្មជាតិ និងតំបន់ដីសើមនានាក្នុងក្រុង ក៏ជាកត្តាចាំបាច់ផងដែរសម្រាប់ការគ្រប់គ្រងទឹកជំនន់ និងទឹកកខ្វក់។ ដំណោះស្រាយបញ្ហាទឹកកខ្វក់តាមបែបធម្មជាតិផ្សេងទៀតដូចជា ប្រព័ន្ធជីវៈចម្រុះ ឬព្រៃកោងកាង មិនទាន់មានការប្រើប្រាស់បានពេញសមត្ថភាពនៅឡើយទេ។

បូកផ្សំជាមួយនិងកង្វះខាតលើការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធបៃតង ក្រុងនានាក៏ត្រូវគិតពីផលប៉ះពាល់នៃការប្រែប្រួលអាកាស-ធាតុនិងយកចិត្តទុកដាក់ក្នុងការរៀបចំផែនការទីក្រុងនិរន្តរភាពដែលគិតលើបញ្ហានេះ។ ជាឧទាហរណ៍ជាក់ស្តែង នៅខេត្តបាត់ដំបងមានប្រជាពលរដ្ឋ ៧៥៣នាក់ ដីកសិកម្ម ១.៥៨១ហិកតា និងផ្លូវថ្នល់ប្រវែង ៥៩.៣២៤ម៉ែត្រ បានរងផលប៉ះពាល់ដោយសារទឹកជំនន់កាលពីឆ្នាំ២០១៣[៣២]។ នៅឯខេត្តសៀមរាប មានគ្រួសារចំនួន ១.៩២១គ្រួសារ បានរងផលប៉ះពាល់ពីភាពរាំងស្ងួតកាលពីឆ្នាំ២០១៥ និងផ្លូវប្រវែង ១៤.២០០ម៉ែត្រ រងការខូចខាតពីទឹកជំនន់កាលពីឆ្នាំ២០១៥[៣៣]។ នៅក្រុងកែប ប្រជាពលរដ្ឋ ១៧០នាក់បានរងគ្រោះដោយសារខ្យល់ព្យុះកាលពីឆ្នាំ២០១៦[៣៤]។ នៅខេត្តព្រះសីហនុវិស័យទេសចរណ៍គឺងាយរងគ្រោះបំផុតពីការប្រែប្រួលអាកាសធាតុដោយសារ ជាខេត្តដែលមានស្ថានភាពទាក់ទាញអាកាសធាតុខ្ពស់។ ផលប៉ះពាល់ពីការប្រែប្រួលអាកាសធាតុដែលអាចកើតមាន ដូចជាការសឹករិចរិលនៃតំបន់ឆ្នេរដោយសារការកើនឡើងនីវ៉ូទឹកសមុទ្រ និងព្យុះសមុទ្រកើនឡើង ការបាត់បង់នូវធនធានសមុទ្រ និងការបាត់បង់ចំនួនភ្ញៀវទេសចរនៅក្នុងរដូវភ្លៀង។

ដើម្បីដោះស្រាយបញ្ហាប្រឈមដែលបានលើកឡើង ការធ្វើផែនការអភិវឌ្ឍន៍ទីក្រុងដែលមានបរិយាបន្ន ការបង្កើតហេដ្ឋារចនា-សម្ព័ន្ធទីក្រុងប្រកបដោយនិរន្តរភាព និងការកៀរគរការវិនិយោគដើម្បីផ្តល់សេវាមូលដ្ឋាន ដូចជាការគ្រប់គ្រងសំណល់ សំរាម និងការបង្កើតអាងប្រព្រឹត្តិកម្មទឹកកខ្វក់ គឺជាកត្តាចាំបាច់ និងបន្ទាន់សម្រាប់បណ្តាក្រុងដែលមានសក្តានុពលរបស់ប្រទេសកម្ពុជា។ ការបង្កើត និងការពង្រឹងកិច្ចអន្តរាគមន៍លើការអភិវឌ្ឍទីក្រុងនិរន្តរភាពមានសារៈសំខាន់ខ្លាំងណាស់ក្នុងការគាំទ្រដល់ក្រុងនានារៀបចំធ្វើផែនការការទទួលបានធនធានហិរញ្ញវត្ថុ និងការអនុវត្តការធ្វើនគរូបនីយកម្មរយៈពេលវែងប្រកបដោយចីរភាព។

[31] MPWT's presentation in a regional policy workshop on wastewater management in Bangkok, Southeast Asia, April 2-3, 2015.

[32] Battambang Social Economic Statistics 2017

[33] Siem Reap Social Economic Statistics 2017

[34] Kep Social Economic Statistics 2017

## ខ. សេដ្ឋកិច្ចបៃតងក្នុងទីក្រុង

បណ្ដាក្រុងនានានៅប្រទេសកម្ពុជា មានកាលានុវត្តភាពយ៉ាងច្រើនដើម្បីទទួលបានអត្ថប្រយោជន៍ពីការអភិវឌ្ឍសេដ្ឋកិច្ចបៃតង ជាពិសេសពីការបង្កើតការងារបៃតងថ្មីៗ។ គោលដៅនៃសេដ្ឋកិច្ចបៃតង គឺការធ្វើឱ្យជីវភាពប្រជាពលរដ្ឋកាន់តែប្រសើរឡើង និងមានសមភាពនៅក្នុងសង្គម ព្រមជាមួយនឹងការកាត់បន្ថយផលប៉ះពាល់លើបរិស្ថាន និងដោះស្រាយបញ្ហាកង្វះមុខងារប្រព័ន្ធអេកូឡូស៊ី។ វាគឺជាការអភិវឌ្ឍដែលមានការបញ្ចេញជាតិកាបូនតិច ការប្រើប្រាស់ធនធានមានប្រសិទ្ធភាព និងធានាបរិយាបន្នសង្គម។[៣៥] គំនិតនៃការអភិវឌ្ឍសេដ្ឋកិច្ចបៃតង គឺកើតចេញពីតម្រូវការក្នុងការវាស់ស្ទង់ផលប៉ះពាល់អេកូឡូស៊ីរបស់មនុស្ស ប្រសិទ្ធភាពនៃការអនុវត្តក្នុងវិស័យដឹកជញ្ជូន ថាមពល សំណង់អគារ និងទេសចរណ៍ ក៏ដូចជាតម្រូវការក្នុងការវាស់ស្ទង់លំហូរវិនិយោគនៅក្នុងវិស័យដែលជាគោលដៅដូចជាការវិនិយោគលើថាមពលកកើតឡើងវិញ និងបច្ចេកវិទ្យាស្អាតដែលមានលក្ខណៈច្នៃប្រឌិតថ្មី។ ដោយសារតែជាងពាក់កណ្ដាលនៃផលិតផលក្នុងស្រុកសរុប (ផសស - GDP) របស់ប្រទេសកម្ពុជាបានមកពីសកម្មភាពសេដ្ឋកិច្ចនៅក្នុងទីក្រុង ទីប្រជុំជន ដូច្នេះការអភិវឌ្ឍបៃតងនៅក្នុងប្រព័ន្ធសេដ្ឋកិច្ចក្នុងទីក្រុង ទីប្រជុំជន គឺមានសារៈសំខាន់សម្រាប់ការអភិវឌ្ឍប្រទេសប្រកបដោយចីរភាព។

### ទេសចរណ៍

វិស័យទេសចរណ៍ គឺជាកត្តាជំរុញដ៏សំខាន់មួយនៃសេដ្ឋកិច្ចបៃតងនៅក្នុងទីក្រុង ទីប្រជុំជននៃប្រទេសកម្ពុជា។ នៅឆ្នាំ ២០១៨ ប្រទេសកម្ពុជាទទួលបានភ្ញៀវទេសចរអន្តរជាតិប្រមាណ ៦,២ លាននាក់ កើនឡើងពី ៤,៨លាននាក់នៅឆ្នាំ២០១៥ ដែលការកើនឡើងនេះភាគច្រើនពីភ្ញៀវទេសចរណ៍ចិន។ ប្រទេសកម្ពុជាធ្លាប់បានជាប្រទេសដែលមានការកើនឡើងនូវចំនួនភ្ញៀវទេសចរច្រើនបំផុតទី៣របស់តំបន់អាស៊ាន តាមពីក្រោយប្រទេសវៀតណាម និងឥណ្ឌូនេស៊ី[៣៦]។ ការកើនឡើងនេះបានរួមចំណែក ៤,៣ពាន់លានដុល្លារ ទៅក្នុងថវិកាជាតិ (ក្រសួងទេសចរណ៍ ឆ្នាំ២០១៩)[៣៧]។ រាជរដ្ឋាភិបាលបានព្យាករថា ទេសចរណ៍អន្តរជាតិនឹងកើនឡើងដល់ទៅ ១០លាននាក់ នៅត្រឹមឆ្នាំ ២០២៥ ដែលស្មើនឹង ៦០០% បើធៀបនឹងឆ្នាំ២០០៥[៣៨]។ សម្រាប់ប្រទេសកំពុងអភិវឌ្ឍដូចជាកម្ពុជា វិស័យទេសចរណ៍អាចដើរតួយ៉ាងសំខាន់ក្នុងការបង្កើតការងារបន្ថែមទៀត និងគាំទ្រដល់ការរីកចម្រើននៃអាជីវកម្មទាំងខ្នាតតូចនិងខ្នាតធំ រាប់ចាប់ពីហាងលក់ទំនិញតូចៗតាមដងផ្លូវ សិប្បកម្មអ្នកបើកបរម៉ូតូកង់បី ម៉ូតូរ៉ឺម៉ក ម៉ូតូឌុប រហូតដល់ឧស្សាហកម្មសណ្ឋាគារ។ កត្តានេះបានជួយដោយផ្ទាល់ក្នុងការកាត់បន្ថយភាពក្រីក្រ និងបង្កើននូវកំណើនសេដ្ឋកិច្ចរបស់ប្រទេស។

ទោះបីជាវិស័យទេសចរណ៍មានអត្ថប្រយោជន៍ច្រើនយ៉ាងណាក៏ដោយបើមិនមានការគ្រប់គ្រងបានល្អទេនោះ អាចបណ្ដាលឱ្យមានផលវិបាកដល់សង្គម វប្បធម៌ និងបរិស្ថានផងដែរ។ ដោយសារទេសចរណ៍ជាវិស័យមួយដែលមានការប្រើប្រាស់ធនធានច្រើន ការកើនឡើងនៃចំនួនភ្ញៀវទេសចរនឹងមានផលប៉ះពាល់យ៉ាងខ្លាំងទៅលើធនធានវប្បធម៌ និងធនធានធម្មជាតិរបស់ប្រទេស។ បើតាមការពិភាក្សាជាមួយអាជ្ញាធរមូលដ្ឋាន យើងឃើញថា ឥរិយាបថនៃការប្រើប្រាស់សម្ភារ ការទុកដាក់និងការចោលសំណល់របស់ភ្ញៀវទេសចរ នឹងប៉ះពាល់ទៅលើភាពស្អាតរបស់ទីក្រុង និងសង្គម។ ឧទាហរណ៍ និរន្តរភាពបរិស្ថាននៅតំបន់អង្គរវត្តដ៏ល្បីល្បាញនៅលើពិភពលោកក្នុងក្រុងសៀមរាប កំពុងតែប្រឈមនឹងសម្ពាធកាន់តែខ្លាំងឡើងពីការហូរចូលនៃភ្ញៀវទេសចរដ៏ច្រើន ដែលគំរាមកំហែងដល់និរន្តរភាពយូរអង្វែងរបស់តំបន់អង្គរនេះ។ សំរាមគរចោលនៅតាមដងផ្លូវ ទឹកកខ្វក់បង្ហូរចូលទៅក្នុងស្ទឹងសៀមរាប ការបំពុលខ្យល់ ការជន់លិចដោយទឹកភ្លៀង គឺជាបញ្ហាដែលប្រជាជនក្រុងសៀមរាបមានការទិតៀនដល់អាជ្ញាធរ[៣៩]។ ចំណែកឯក្រុងព្រះសីហនុដែលទទួលបានភ្ញៀវទេសចរប្រមាណ ១,៣លាននាក់នៅត្រឹម

[35] United Nations Environment Program (UNEP) on defining green economy. Accessed October 20, 2019, https://www.cbd.int/doc/meetings/im/wscbteeb-mena-01/other/wscbteeb-mena-01-unep-green-economy-en.pdf

[36] Chea Vannak, "Cambodia 3rd in Asean for tourist growth," Khmer Times, last modified January 22, 2019, https://www.khmertimeskh.com/570963/cambodia-3rd-in-asean-for-tourist-growth/ .

[37] Ministry of Tourism (MoT), "Tourism Statistics Report - February 2019," last modified September 15, 2019, https://amchamcambodia.net/wp-content/uploads/2019/04/CAM022019.pdf

[38] Clean Green Cambodia, "Sustainable tourism in Cambodia," accessed September 15, 2019, https://www.cleangreencambodia.org/sustainable-tourism-in-cambodia/

[39] Long Kimmarita, "Siem Reap waste 'pollutes' river," last modified February 15, 2019, https://www.phnompenhpost.com/national/siem-reap-waste-pollutes-river

ពាក់កណ្តាលឆ្នាំ២០១៨ (១០,១២% កើនឡើងបើធៀបនឹងពាក់កណ្តាលឆ្នាំ២០១៧) ក៏ធ្លាប់ទទួលរងសម្ពាធពីចំនួនភ្ញៀវទេសចរដែលមិនអាចគ្រប់គ្រងលើនិរន្តរភាពបរិស្ថានបាន រួមទាំងសំណង់អគារដែលកំពុងរីកព្រោងព្រាត។ កត្តាទាំងនេះបណ្តាលឱ្យមានការព្រួយបារម្ភដល់បរិស្ថាន សង្គម និងសុវត្ថិភាព។ រដ្ឋមន្ត្រីក្រសួងទេសចរណ៍ បានសង្កត់ធ្ងន់ថាផលវិបាកពីការរីកលូតលាស់នៃសំណង់អគារក្រុងព្រះសីហនុក្នុងប៉ុន្មានឆ្នាំចុងក្រោយនេះ បាននឹងកំពុងជះឥទ្ធិពលអវិជ្ជមានដល់បរិស្ថាន និងឧស្សាហកម្មទេសចរណ៍នៅទីនោះ[៤០]។ កាលពីខែមិថុនា ឆ្នាំ២០១៩ បន្ទាប់ពីមានការបាក់រលំអគារដែលបានសម្លាប់កម្មករចំនួន ២៨នាក់រួចមក រដ្ឋាភិបាលបានបិទការដ្ឋានសាងសង់អគារចំនួន ២២កន្លែងដែលមិនមានលិខិតអនុញ្ញាត។ បើយោងតាមវិទ្យាស្ថានជាតិស្ថិតិ ក្រុងព្រះសីហនុមានប្រជាជនប្រមាណ ៣០០.០០០ នាក់ និងប្រជាជនចិនប្រមាណ ៨០.០០០ នាក់ ដោយសារការកើនឡើងវិស័យទេសចរណ៍នៅទីនោះ។ ស្ទើរតែ ៩០% ទៅហើយនៃអាជីវកម្ម នៅក្រុងព្រះសីហនុជាពិសេសវិស័យបដិសណ្ឋារកិច្ច គឺគ្រប់គ្រងដោយក្រុមហ៊ុនចិន។ ប្រជាពលរដ្ឋក្រីក្រ បានចាកចេញពីក្រុងព្រះសីហនុដោយសារតម្លៃនៃការជួលផ្ទះ មានការឡើងខ្ពស់ខ្លាំង[៤១] ។ បរិមាណសំរាមក្នុងក្រុងបានកើនឡើងយ៉ាងខ្លាំងពីមួយថ្ងៃទៅមួយថ្ងៃ ពីចំនួនប្រមាណតែ ១០០ ទៅ ២០០តោនក្នុងមួយថ្ងៃ កាលពីឆ្នាំ២០១៥ ទៅដល់ប្រមាណ ១០០០តោនក្នុងមួយថ្ងៃក្នុងពេលបច្ចុប្បន្ន[៤២]។

វាគឺជាចំហាកនៃយុទ្ធសាស្ត្រឈ្នះឈ្នះមួយសម្រាប់ក្រុងនានាដើម្បីធ្វើការអភិវឌ្ឍ "ទេសចរណ៍ប្រកបដោយនិរន្តរភាព" បើយោងទៅតាមអង្គការទេសចរណ៍ពិភពលោក (World Tourism Organization) ទីក្រុងទាំងនោះគួរតែ[៤៣] ៖

- ប្រើប្រាស់ធនធានបរិស្ថានឱ្យមានប្រសិទ្ធភាពបំផុតដែលជាធាតុផ្សំដ៏សំខាន់ក្នុងការអភិវឌ្ឍទេសចរណ៍រក្សាដំណើរការប្រព័ន្ធអេកូឡូស៊ីដែលចាំបាច់ និងជួយអភិរក្សបេតិកភណ្ឌធម្មជាតិ និងជីវៈចម្រុះ
- គោរពភាពដើមនៃសង្គម - វប្បធម៌ របស់សហគមន៍ អភិរក្សការរស់នៅ និងបេតិកភណ្ឌវប្បធម៌ ក៏ដូចជាតម្លៃប្រពៃណីរបស់សហគមន៍ ហើយរួមចំណែកដល់ការយល់ដឹងពីគ្នាទៅវិញទៅមកនូវវប្បធម៌ ប្រពៃណីផ្សេងៗគ្នា
- ធានាបាននូវសកម្មភាពសេដ្ឋកិច្ចយូរអង្វែងដែលអាចផ្តល់ផលប្រយោជន៍ដោយស្មើភាពដល់ប្រជាពលរដ្ឋគ្រប់រូប។ ក្នុងនោះរួមបញ្ចូលទាំងស្ថេរភាពការងារ ឱកាសរកប្រាក់ចំណូលសេវាសង្គមទៅដល់សហគមន៍ និងការរួមចំណែកកាត់បន្ថយភាពក្រីក្រ។

គំនិតផ្តួចផ្តើមមួយ ដែលបណ្តាក្រុងនានាអាចអនុវត្តបានគឺការបង្កើត និងលើកកម្ពស់អេកូទេសចរណ៍(ទេសចរណ៍បែបធម្មជាតិ) ដែលអាចជួយការពារនិងអភិរក្សបេតិកភណ្ឌ និងធនធានវប្បធម៌ជាតិរក្សានូវធនធានជីវៈចម្រុះនៅលើដី និងក្នុងសមុទ្រ បង្កើតការងារសមរម្យ បង្កើតទីផ្សារសម្រាប់ផលិតផល និងសេវាកម្មសម្រាប់ប្រជាពលរដ្ឋក្នុងមូលដ្ឋាន និងបង្កើនប្រសិទ្ធភាពធនធាន (ការប្រើប្រាស់ទឹក អគ្គិសនី អាហារ) នៅក្នុងវិស័យទេសចរណ៍។ ជាឧទាហរណ៍មិនដូចជាទេសចរណ៍ទូទៅការអនុវត្តកម្មវិធីទេសចរណ៍បែបសហគមន៍ (CBT) និងអេកូទេសចរណ៍សហគមន៍ (CBET) ត្រូវបានគ្រប់គ្រងដោយសហគមន៍មូលដ្ឋានដោយខ្លួនឯងផ្ទាល់ ឬជាមួយសហគមន៍មូលដ្ឋានដែលបានចូលរួមនៅក្នុងដំណើរការធ្វើការសម្រេចចិត្ត។ ប្រាក់ចំណូលពីកម្មវិធីទេសចរណ៍បែបនេះ បានផ្តល់ផលប្រយោជន៍ដោយផ្ទាល់ទៅដល់សហគមន៍មូលដ្ឋានដើម្បីលើកកម្ពស់ការអភិវឌ្ឍរបស់ពួកគេ។ បច្ចុប្បន្ននេះមានកម្មវិធីទេសចរណ៍សហគមន៍ (CBT) និង អេកូទេសចរណ៍សហគមន៍ (CBET) ចំនួន៦៦ គម្រោងនៅទូទាំងប្រទេសកម្ពុជា។ ក្រុងជាច្រើនដូចជាក្រុងសៀមរាប

[40] Hin Piset, “Sihanoukville tourism First half of 2018 sees 1.3M visitors,” last modified October 3, 2018, https://www.phnompenhpost.com/business/sihanoukville-tourism-first-half-2018-sees-13m-visitors

[41] Kristin Huang, “Sihanoukville’s big gamble: the sleepy beach town in Cambodia that bet its future on Chinese money, last modified September 24, 2019, https://www.scmp.com/news/china/diplomacy/article/3025262/sihanoukvilles-big-gamble-sleepy-beach-town-bet-its-future

[42] Ben Sokhean, “Governor seeks World Bank’s help as Sihanoukville rubbish rockets to 1,000 tonnes a day,” last modified October 9, 2019, https://www.khmertimeskh.com/50649191/governor-seeks-world-banks-help-to-tackle-waste-woes/

[43] United Nations Environment Programme. Division of Technology. Making Tourism More Sustainable - A Guide for Policy Makers (2005) 11-12. World Tourism Organization Publications.

ក្រុងកំពត ក្រុងកែប ក្រុងព្រះសីហនុ និងក្រុងបាត់ដំបង មានសក្តានុពលទេសចរណ៍ធម្មជាតិដ៏ធំធេង។ នៅឆ្នាំ២០១៥ មានតែភ្ញៀវទេសចរប្រមាណពី ១០% ទៅ២០% ប៉ុណ្ណោះដែលបានមកទស្សនាតំបន់ទេសចរណ៍សហគមន៍និងអេកូទេសចរណ៍សហគមន៍[៤៤]។ ហេតុដូច្នេះហើយ បណ្តាក្រុងនីមួយៗមានឱកាសដើម្បីចាត់វិធានការក្នុងការលើកកម្ពស់អេកូទេសចរណ៍នេះបានតាមរយៈការវិនិយោគលើតំបន់អេកូទេសចរណ៍ដែលមានស្រាប់ និងបង្កើតថ្មី ធ្វើការបណ្តុះបណ្តាលប្រជាជនក្នុងតំបន់លើការផ្តល់សេវាកម្មអេកូទេសចរណ៍ និងបង្កើតយុទ្ធសាស្ត្រ អេកូទេសចរណ៍ដើម្បីទាក់ទាញភ្ញៀវទេសចរបន្ថែមទៀតនៅក្នុងវិស័យនេះ។

ក្រុងបាត់ដំបង គឺជាឧទាហរណ៍គំរូល្អមួយសម្រាប់ការគ្រប់គ្រងនិរន្តរភាពទេសចរណ៍បេតិកភណ្ឌ។ ខេត្ត និងក្រុងបាត់ដំបង ដោយមានការគាំទ្រពីក្រសួងទេសចរណ៍ បានបង្កើតនូវគោលការណ៍យុទ្ធសាស្ត្រសម្រាប់ទេសចរណ៍និរន្តរភាពបេតិកភណ្ឌកាលពីឆ្នាំ ២០១៦។ គោលការណ៍យុទ្ធសាស្ត្រនេះ បានដាក់ចេញនូវសេវាកម្ម និងហេដ្ឋារចនាសម្ព័ន្ធគាំទ្រជាមូលដ្ឋាន មានដូចជាការកែលម្អនូវការគ្រប់គ្រងសំណល់ ការកែលម្អ និងពង្រឹងវិស័យដឹកជញ្ជូនតាមទឹក ការថែរក្សាតំបន់កម្សាន្ត ការបន្ថែមនូវការផ្គត់ផ្គង់អគ្គិសនីសម្រាប់ពង្រឹងសុវត្ថិភាពនិងសោភ័ណ និងការបន្ថែមនូវសេវានិងមណ្ឌលសុខភាពជាដើម[៤៥]។

## ឧស្សាហកម្ម

វិស័យដ៏សំខាន់មួយទៀតដែលជំរុញសេដ្ឋកិច្ចទីក្រុង គឺវិស័យឧស្សាហកម្ម។ វិស័យឧស្សាហកម្មនៅប្រទេសកម្ពុជា ក្នុងរយៈពេល ២ទសវត្សរ៍ចុងក្រោយនេះ មានការរីកលូតលាស់យ៉ាងឆាប់រហ័ស ដែលការរួមចំណែកនៅក្នុងផសស កាលពីឆ្នាំ១៩៩៨ មានត្រឹមតែ ១៧% បានកើនឡើងដល់ ៣២% នៅឆ្នាំ២០១៨ នេះបើតាមរបាយការណ៍ធនាគារពិភពលោក[៤៦]។ ប៉ុន្តែទោះបីជាមានការរីកលូតលាស់បែបនេះក្តី ក៏គេសង្កេតឃើញថាវិស័យនេះកំពុងមានការបាត់បង់នូវលទ្ធភាពប្រកួតប្រជែងរបស់ខ្លួនបើធៀបនឹងប្រទេសជិតខាង ដូចជា ប្រទេសបង់ក្លាដេស ភូមា និងវៀតណាម ដោយសារការចំណាយទៅលើថាមពលខ្ពស់ ការកើនឡើងថ្លៃឈ្នួល អប្បបរមាការខ្វះខាតនូវហេដ្ឋារចនាសម្ព័ន្ធគាំទ្រ ផលិតភាពទាប និងកត្តាភស្តុភារ។ សម្រាប់ប្រទេសកម្ពុជា ក្នុងការបន្តអភិវឌ្ឍកំណើនសេដ្ឋកិច្ចតាមបែបចម្រុះ រដ្ឋាភិបាលគួរតែស្វែងរកនូវវិធីសាស្ត្រថ្មីក្នុងការបង្កើនផលិតភាព និងលទ្ធភាពចូលទៅកាន់ទីផ្សារកម្រិតខ្ពស់។ ការវិភាគគំរូសេដ្ឋកិច្ច ដែលបានរៀបចំរួមគ្នាដោយក្រុមប្រឹក្សាជាតិអភិវឌ្ឍន៍ដោយចីរភាព (NCSD) និងវិទ្យាស្ថានអភិវឌ្ឍន៍បៃតងសកល (GGGI) បង្ហាញឱ្យឃើញថា ការចាប់ផ្តើមអនុវត្តដំណើរការផលិតកម្មដែលមានប្រសិទ្ធភាពធនធាន អាចនាំឱ្យមានកំណើន ផ.ស.ស.ដល់ទៅ ២,៧ពាន់លានដុល្លារអាមេរិក នៅត្រឹមឆ្នាំ២០៣០ ឬម៉្យាងទៀត វានាំឱ្យមានផលិតភាពប្រសើរឡើងនៅក្នុងវិស័យកាត់ដេរបានដល់ទៅ ៤៦% វិស័យឡឥដ្ឋ ១៤,៧% វិស័យកែច្នៃម្ហូបអាហារ ៣៣% និងវិស័យឧបករណ៍អេឡិចត្រូនិច ៣៥,៥%។ ការអភិវឌ្ឍបៃតងនៅក្នុងអនុវិស័យទាំងបួននេះ អាចបង្កើតការងារបានទៅដល់ជាងកន្លះលានកន្លែងបន្ថែមទៀត និងកាត់បន្ថយការបំភាយឧស្ម័នផ្ទះកញ្ចក់បាន ៣,៣៧លានតោន ដែលក្នុងនោះ ១៧%កាត់បន្ថយបានពីវិស័យកាត់ដេរ និង ៣០% ពីវិស័យឧបករណ៍អេឡិចត្រូនិច[៤៧]។ បង្កើនប្រសិទ្ធភាពនៃការប្រើប្រាស់ធនធាន គឺមានន័យថាការបន្ថយផលប៉ះពាល់អវិជ្ជមានមកលើបរិស្ថាន និងការកាត់បន្ថយបាននូវសំណល់ឧស្សាហកម្ម។

ដូច្នេះការលើកកម្ពស់ការអភិវឌ្ឍឧស្សាហកម្មបៃតង គឺមានសារៈសំខាន់ណាស់ក្នុងការសម្រេចបាននូវសេដ្ឋកិច្ចបៃតងក្នុងមូលដ្ឋាន។ សេចក្តីព្រាងគោលនយោបាយជាតិស្តីពី ប្រសិទ្ធភាពថាមពលបានកំណត់ពីសក្តានុពលដ៏ធំនៃការសន្សំសំចៃថាមពលនៅក្នុងវិស័យឧស្សាហកម្ម (តារាងទី ១.៤) ។នេះបង្ហាញថាវិស័យឧស្សាហកម្ម

[44] Afore Hsieh, “Cambodia’s Experiment with Responsible Tourism,” last modified December 30, 2016, https://thediplomat.com/2016/12/cambodias-experiment-with-responsible-tourism/

[45] RGC, “Strategic Guidelines for Heritage Tourism in Battambang province, Cambodia,” accessed September 15, 2019, https://www.researchgate.net/publication/303566295_Strategic_Guidelines_for_Heritage_Tourism_in_Battambang_Province_Cambodia#pf16

[46] World Bank, World Bank Database (Washington D.C,: The World Bank, 2018).,

[47] GGGI and NCSD, “The Economic, Social and Environmental Impacts of Greening the Industrial Sector in Cambodia,” 2018.

អាចធ្វើឱ្យមានប្រសិទ្ធភាពធនធាន និងមេត្រីភាពបរិស្ថានល្អប្រសើរ ដោយប្រើប្រាស់បច្ចេកវិទ្យាបៃតងនៅក្នុងប្រតិបត្តិការ និងការគ្រប់គ្រង។ បណ្ដាក្រុងដែលមានតំបន់សេដ្ឋកិច្ចពិសេស ដូចជាទីក្រុងភ្នំពេញ ក្រុងបាវិត ក្រុងព្រះសីហនុ ក្រុងប៉ោយប៉ែត និងក្រុងខេមរភូមិន្ទនៃខេត្តកោះកុង ដើរតួនាទីយ៉ាងសំខាន់ក្នុងការជំរុញការអភិវឌ្ឍបៃតងនៅក្នុងវិស័យឧស្សាហកម្ម។ ការងារនេះទាមទារឱ្យមានកិច្ចខិតខំប្រឹងប្រែងបន្ថែមទៀតដើម្បីលើកទឹកចិត្តឱ្យរោងចក្រឧស្សាហកម្មទាំងនោះអនុវត្តប្រសិទ្ធភាពនិងលើកកម្ពស់ការរក្សាបរិស្ថានរបស់ពួកគេ។

## តារាងទី១.៤. សក្ដានុពលនៃការធ្វើឱ្យប្រសើរឡើងការប្រើប្រាស់ប្រសិទ្ធភាពថាមពល នៅតាមវិស័យឧស្សាហកម្ម[៤៨]

| សក្ដានុពលនៃការលើកកម្ពស់ប្រសិទ្ធភាពថាមពល | | | | |
|---|---|---|---|---|
| (អនុ) វិស័យ | ទាបបំផុត | ខ្ពស់បំផុត | ជាមធ្យម | អនុសាសន៍ |
| រោងចក្រកិនស្រូវ | | ៧០% | ៣៥% | ជំនួសដោយការប្រើប្រាស់ឥន្ធនៈហ្វូស៊ីល ដោយប្រើឧស្ម័នពីអង្កាម |
| ឧស្សាហកម្មកាត់ដេរ | ២០% | ៣៥% | ២៨% | តាមរយៈការប្រើប្រាស់ម៉ាស៊ីនកម្ដៅប្រើអុស និងម៉ាស៊ីនដេរដែលមានប្រសិទ្ធភាពជាងមុខ ការប្រើប្រាស់បំពង់អ៊ីសូឡង់កម្ដៅ |
| រោងចក្រទឹកកក | | | ២៥% | ការប្រើប្រាស់ឧស្ម័នជីវម៉ាស |
| ឧស្សាហកម្មម្ហូបអាហារ | ១៥% | ២០% | ១៨% | ប្ដូរការប្រើប្រាស់អំពូលភ្លើង និងម៉ាស៊ីនបញ្ចូលខ្យល់ដែលមិនមានប្រសិទ្ធភាព |
| រោងចក្រកៅស៊ូ | | | ២៥% | កែលម្អដំណើរការសម្ងួតប្រើប្រាស់ម៉ាស៊ីនអគ្គិសនីដែលមានប្រសិទ្ធភាពជាងមុន |
| រោងចក្រឥដ្ឋ | | ៧០% | ៣៥% | ជំនួសការប្រើប្រាស់បំពង់ឡឥដ្ឋ តាមរយៈការប្រើឡឥដ្ឋ ដែលមានឡៅបញ្ឈរ និងកែលម្អដំណើរការធ្វើឥដ្ឋ |
| អគារពាណិជ្ជកម្ម | ២០% | ៣០% | ២៥% | ផ្អែកលើការប្រៀបធៀបជាមួយបទពិសោធន៍អន្តរជាតិ |
| ផលិតកម្ម ធ្យូង | ៣០% | ៤០% | ៣៥% | តាមរយៈការប្រើប្រាស់ឡដែលមានប្រសិទ្ធភាពជាងមុនដូចជា ឡម៉ាកយូស៊ីម៉ូរ៉ា (Yoshimura) (អង្គការ GERES) |

*ប្រភព៖ : សេចក្ដីព្រាងគោលនយោបាយជាតិស្ដីពីប្រសិទ្ធភាពថាមពល*

ខណៈពេលដែលការអនុវត្តអាជីវកម្មប្រកបដោយនិរន្តរភាពមិនទាន់គ្រប់គ្រាន់ យើងឃើញមានគំនិតផ្ដួចផ្ដើមថ្មីមួយចំនួនដែលអាចជំរុញដោយវិស័យឧស្សាហកម្ម។ ឧទាហរណ៍នៅក្នុងតំបន់សេដ្ឋកិច្ចពិសេសនៅក្រុងព្រះសីហនុ (SSEZ) ដែលគ្របដណ្ដប់លើផ្ទៃដី ១.១១៣ ហិកតា និងមានក្រុមហ៊ុនចំនួន ១០៩ក្រុមហ៊ុន បានបង្កើតការងារក្នុងស្រុកចំនួន ១៤.០០០កន្លែង។ តំបន់សេដ្ឋកិច្ចពិសេសនៅក្រុងព្រះសីហនុ បានវិនិយោគទឹកប្រាក់ ៧លានដុល្លារ ដែលពួកគេបានអះអាងថាជាអាងប្រព្រឹត្តិកម្មទឹកកខ្វក់ដែលមានលក្ខណៈទំនើប និងខ្នាតធំជំបូងគេបង្អស់នៅប្រទេសកម្ពុជា។ ដំណាក់កាលទី ១ ត្រូវបានបញ្ចប់ហើយអាចធ្វើប្រព្រឹត្តិកម្មទឹកសំណល់បាន

[48] Draft of the National Energy Efficiency Policy, checked and approved by Technical Working Group on August 9, 2017.

៥.០០០ម៉ែត្រគូប ក្នុងមួយថ្ងៃ[៤៩]។ តំបន់សេដ្ឋកិច្ចពិសេសខេត្តព្រះសីហនុ មានទីលានចាក់សំរាមរបស់ខ្លួនផ្ទាល់ និងបានគ្រោងវិនិយោគលើការបង្កើតរោងចក្រកែច្នៃសំរាមទៅជាថាមពលសម្រាប់ប្រើប្រាស់ផងដែរ។ តាមរយៈការសម្ភាសជាមួយផ្នែកគ្រប់គ្រងតំបន់សេដ្ឋកិច្ចពិសេសម៉ាន់ហាតាន់ (Manhattan) (MSEZ) នៅក្រុងបាវិត បានឱ្យដឹងថា តំបន់សេដ្ឋកិច្ចពិសេសម៉ាន់ហាតាន់ មានទំហំផ្ទៃដី ៥០០ហិកតា មានរោងចក្រចំនួន ៣៣ និងផ្តល់ការងារដល់ប្រជាពលរដ្ឋប្រហែល ៣០.០០០នាក់។ តំបន់សេដ្ឋកិច្ចពិសេសម៉ាន់ហាតាន់ បានចំណាយប្រាក់ប្រមាណ ១,២លានដុល្លារ សហរដ្ឋអាមេរិកដើម្បីបង្កើតអាងប្រព្រឹត្តិកម្មទឹកកខ្វក់របស់ខ្លួន (ដំណាក់-កាលទី ១) ដែលមានសមត្ថភាពធ្វើប្រព្រឹត្តិកម្មទឹកកខ្វក់បានចំនួន ៥.០០០ម៉ែត្រគូបក្នុងមួយថ្ងៃ។ តំបន់សេដ្ឋកិច្ចពិសេសម៉ាន់ហាតាន់ បច្ចុប្បន្នកំពុងបង្កើនល្បឿនសាងសង់អាងប្រព្រឹត្តិកម្មមួយទៀត (ដំណាក់កាលទី ២) ដែលមានសមត្ថភាពស្រដៀងគ្នានឹងដំណាក់កាលទី១ ផងដែរ[៥០]។

បើគិតពីភាពស៊ាំទៅនឹងអាកាសធាតុនៃវិស័យនេះ ការសិក្សាកាលពីឆ្នាំ ២០១៩ របស់រាជរដ្ឋាភិបាលបានបង្ហាញដល់ម្ចាស់ផលិតកម្មនានា ក្នុងការគិតគូរវិនិយោគទៅក្នុងការបង្កើនផលិតភាពពលកម្ម ដើម្បីសម្របទៅនឹងការប្រែប្រួលអាកាសធាតុ។ ការសិក្សានេះ បានប៉ាន់ប្រមាណថា បើអនុវត្តតាមទម្លាប់ធុរកិច្ចតាមប្រក្រតី (BAU) ត្រឹមឆ្នាំ២០៥០ ការថយចុះនូវផលិតភាពពលកម្មមានដល់ទៅ ៥៧% ដែលជាលទ្ធផលនៃការឡើងកម្តៅ។ ហានិភ័យនេះនឹងប៉ះពាល់គ្រប់វិស័យ ជាពិសេសក្នុងវិស័យកម្មន្តសាល និងសំណង់។ ការសិក្សានេះបានបង្ហាញពីវិធានការដើម្បីដោះស្រាយនូវបញ្ហានេះដូចជាការកាត់បន្ថយនូវការងារប្រើកម្លាំងធ្ងន់ៗ និងកំណត់ពេលវាលាសមស្របសម្រាប់ការងារបែបនេះ ពោលគឺចៀសវាងការធ្វើក្នុងពេលមានការកើនឡើងកម្តៅ វិធានការផ្សេងទៀតមានដូចជាការកែលម្អប្រព័ន្ធខ្យល់ចេញចូល[៥១]។

ឧស្សាហូបនីយកម្មប្រកបដោយនិរន្តរភាព បានផ្សារភ្ជាប់យ៉ាងល្អជាមួយគោលនយោបាយជាតិអភិវឌ្ឍន៍វិស័យឧស្សាហកម្ម (IDP) ២០១៥-២០២៥ ដែលមានគោលដៅជំរុញកែប្រែ និងធ្វើទំនើបកម្មរចនាសម្ព័ន្ធវិស័យឧស្សាហកម្មរបស់កម្ពុជា ពោលគឺពីឧស្សាហកម្មប្រពលកម្មឈានទៅជាឧស្សាហកម្មផ្អែកលើជំនាញនៅត្រឹមឆ្នាំ២០២៥។ វាអាចសម្រេចទៅបានតាមរយៈការផ្សារភ្ជាប់ទៅនឹងខ្សែសង្វាក់តម្លៃនៅក្នុងទីផ្សារសកល និងសមាហរណកម្មទៅក្នុងបណ្តាញផលិតកម្មក្នុងតំបន់ និងទៅក្នុងកម្រងប្រទេសកំពុងអភិវឌ្ឍន៍ ស្របពេលជាមួយនឹងការពង្រឹងភាពប្រកួតប្រជែង និងលើកកម្ពស់ផលិតភាពឧស្សាហកម្មក្នុងស្រុក ហើយបន្តឈានទៅអភិវឌ្ឍវិស័យឧស្សាហកម្មដែលប្រើប្រាស់បច្ចេកវិទ្យាទំនើប និងប្រកបដោយវិជ្ជាជីវៈ។

### តារាងទី១.៥. តំបន់សេដ្ឋកិច្ចពិសេស នៅក្នុងប្រទេសកម្ពុជា ឆ្នាំ២០១៤

| ទីតាំង | ឈ្មោះតំបន់សេដ្ឋកិច្ចពិសេស (SEZ) | ឆ្នាំបង្កើត | ចំនួនក្រុមហ៊ុន | ចំនួនការងារសរុប | ចំនួនបុគ្គលិកក្នុងក្រុមហ៊ុន(ជាមធ្យម) |
|---|---|---|---|---|---|
| រាជធានីភ្នំពេញ | ភ្នំពេញ SEZ | ២០០៨ | ៥០ | ១៧.០០០ | ៣៤០ |
| ក្រុងបាវិត | ម៉ាហាតាន់ SEZ | ២០០៦ | ២៦ | ២៨.០៥១ | ១.០៧៩ |
| | តាយសេង បាវិត SEZ | ២០០៧ | ១៧ | ៧.៩៦៨ | ៤៦៩ |
| | ជ្រាហ្វីន យីង SEZ | ២០១៣ | ២ | ២៨០ | ១៤០ |

[49] Consultation meeting with the management of SSEZ in February 2018.
[50] Consultation meeting with the management of MSEZ in February 2018.
[51] MOE, NCSD, and MEF, “Addressing Climate Change Impacts of Economic Growth in Cambodia,” 2019. Accessed October 30, 2019. https://www.climatefinance-developmenteffectiveness.org/sites/default/files/CEGIM_FullReport.pdf

| | | | | | |
|---|---|---|---|---|---|
| ក្រុងព្រះសីហនុ | ក្រុងព្រះសីហនុ SEZ ១ | ២០០៩ | ២ | ៤២៤ | ២១២ |
| | ក្រុងព្រះសីហនុ SEZ ២ | ២០០៨ | ៤០ | ៨.៩៦៧ | ២២៤ |
| | ផែក្រុងព្រះសីហនុ SEZ | ២០១២ | ២ | ៤១៦ | ២០៨ |
| ក្រុងប៉ោយប៉ែត | ប៉ោយប៉ែត អូនាង SEZ | ២០១១ | ២ | ៨៣០ | ៤១៥ |
| ក្រុងកោះកុង | នាងកុក កោះកុង SEZ | ២០០៥ | ៤ | ៣.៩៥៣ | ៩៨៨ |
| **សរុប** | **SEZ ក្នុងប្រទេសកម្ពុជា** | **២០០៥** | **១៤៥** | **៦៧.៨៨៩** | **៤៦៨** |

*ប្រភព៖ ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា នៃរាជរដ្ឋាភិបាលកម្ពុជា ( http://cambodiainvestment.gov.kh/list-of-sez.html )*

ក្របខ័ណ្ឌគោលនយោបាយអភិវឌ្ឍន៍ឧស្សាហកម្មមានសសរស្តម្ភចំនួនបួន ដែលមានសារៈសំខាន់ក្នុងការលើកកម្ពស់សេដ្ឋកិច្ចបៃតងនៅក្នុងក្រុង។ ទី ១ កៀរគរ និងទាក់ទាញវិនិយោគផ្ទាល់ពីបរទេស និងវិនិយោគឯកជនក្នុងស្រុក សម្រាប់អភិវឌ្ឍន៍វិស័យឧស្សាហកម្ម នាំចេញ ការអភិវឌ្ឍ និងពង្រីកទីផ្សារ និងលើកកម្ពស់ការអភិវឌ្ឍ និងផ្ទេរបច្ចេកវិទ្យា។ ទី២ អភិវឌ្ឍន៍និងធ្វើទំនើបកម្មសហគ្រាសធុនតូច និងមធ្យម តាមរយៈការពង្រីក និងពង្រឹងមូលដ្ឋានឧស្សាហកម្មកម្មន្តសាល លើកកម្ពស់ការអភិវឌ្ឍ និងការផ្ទេរបច្ចេកវិទ្យា និងពង្រឹងការតភ្ជាប់ឧស្សាហកម្មក្នុងស្រុក និងអន្តរជាតិ។ ទី៣ កែលម្អបរិស្ថាននិយ័តកម្មដើម្បីពង្រឹងភាពប្រកួតប្រជែង តាមរយៈការកែលម្អបរិយាកាសវិនិយោគ និងលើកកម្ពស់ឱ្យមានកិច្ចសម្រួលពាណិជ្ជ-កម្ម ការផ្តល់ព័ត៌មានទីផ្សារ និងកាត់បន្ថយចំណាយចម្លងការ។ ទី៤ សម្របសម្រួលគោលនយោបាយគាំទ្រ ដូចជាការអភិវឌ្ឍធនធានមនុស្ស ការបណ្តុះបណ្តាលជំនាញ និងការកែលម្អទំនាក់ទំនងឧស្សាហកម្ម រួមជាមួយការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធ ដូចជាប្រព័ន្ធដឹកជញ្ជូន/ភស្តុភារ និងប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន និងគមនាគមន៍ ការផ្គត់ផ្គង់អគ្គិសនី និងទឹកស្អាត និងសេវាសាធារណៈ សេវាសង្គមកិច្ច និងសេវាហិរញ្ញវត្ថុ។

## ថាមពលស្អាត

កត្តាដែលសំខាន់ក្នុងការអភិវឌ្ឍវិស័យឧស្សាហកម្ម គឺការប្រើប្រាស់ថាមពលកកើតឡើងវិញ។ បើយើងមើលក្នុងវិស័យថាមពលនៅក្នុងឆ្នាំ ២០១៨ ការផ្គត់ផ្គង់ថាមពលអគ្គិសនី គឺ ២.៦៥០,២៦ មេហ្គាវ៉ាត់ ដែលក្នុងនោះ ៦៤,៧៧មេកាវ៉ាត់ គឺទទួលបានពីប្រភពថាមពលកកើតឡើងវិញ នេះបើតាមរបាយការណ៍ប្រចាំឆ្នាំរបស់អាជ្ញាធរអគ្គិសនីកម្ពុជា។ បើតាមទិន្នន័យក្រសួងរ៉ែ និងថាមពលនៅក្នុងឆ្នាំ២០១៨ កម្ពុជាប្រើប្រាស់អគ្គិសនីមានកម្រិត ៩.៣០០ លានគីឡូវ៉ាត់ម៉ោងក្នុងមួយឆ្នាំ ដែលជាមធ្យមគឺស្មើនិង ២៥,៥លានគីឡូវ៉ាត់ម៉ោងក្នុងមួយថ្ងៃ។ ពីខែមករា ដល់ចុងខែកុម្ភៈ ឆ្នាំ២០១៩ ការប្រើប្រាស់ថាមពលមានការកើនឡើងដល់ទៅ ៣១លានគីឡូវ៉ាត់ម៉ោងក្នុងមួយថ្ងៃ ដោយសារការបង្កើតគម្រោងវិនិយោគថ្មីៗនៅក្នុងរាជធានី។ កត្តានេះ នាំឱ្យមានការខ្វះខាតអគ្គិសនីប្រើប្រាស់ដល់ទៅ ៤០០មេហ្គាវ៉ាត់ ទូទាំងប្រទេស ក្នុងរដូវរាំងស្ងួត ២០១៩ និងដាច់ចរន្តអគ្គិសនីរយៈពេលយូរក្នុងមួយថ្ងៃៗ។ ភាពរាំងស្ងួតកាន់តែធ្ងន់ធ្ងរនៅប្រទេសកម្ពុជា ដែលនាំឱ្យប៉ះពាល់ដល់ការផលិតថាមពលពីវារីអគ្គិសនី គឺជាហេតុផលដ៏ល្អផ្នែកសេដ្ឋកិច្ចក្នុងការចាប់ផ្តើមគិតគូរបន្ថែមការផលិតថាមពល តាមរយៈថាមពលពន្លឺព្រះអាទិត្យ។

បើយោងតាមរបាយការណ៍ប្រចាំឆ្នាំរបស់អគ្គិសនីកម្ពុជា ក្នុងការលក់ថាមពលសរុបចំនួន ៦.៩៩៤ ជីកាវ៉ាត់ នៅក្នុងឆ្នាំ២០១៧ មាន ១៨% គឺសម្រាប់វិស័យឧស្សាហកម្ម[៥២]។ គេបានប៉ាន់ប្រមាណថាការប្រើប្រាស់ថាមពលនៅក្នុងវិស័យឧស្សាហកម្មនឹងមានការកើនឡើងជាលំដាប់ផងដែរក្នុងអត្រាកំណើនប្រចាំឆ្នាំ ៣,៩% រហូតដល់ឆ្នាំ២០៣៥[៥៣]។ ប៉ុន្តែតំបន់សេដ្ឋកិច្ចពិសេសទាំងនៅ តំបន់សេដ្ឋកិច្ចពិសេសម៉ាន់ហាតាន់ និងតំបន់សេដ្ឋកិច្ចពិសេសនៅក្រុងព្រះសីហនុ

[52] Electricite Du Cambodge (EDC). Annual Report 2017

[53] Economic Research Institute for ASEAN and East Asia (ERIA), Annual Report 2015

បានប្រតិកម្មទៅនឹងតម្លៃខ្ពស់នៃអគ្គិសនី និងការផ្គត់ផ្គង់មិនគ្រប់គ្រាន់តាមតម្រូវការសម្រាប់ការពង្រីកផលិតកម្ម។ រាជរដ្ឋាភិបាល គួរតែដាក់ចេញនូវគោលនយោបាយដែលលើកទឹកចិត្តដល់តំបន់សេដ្ឋកិច្ចពិសេសក្នុងការវិនិយោគទៅលើថាមពលកកើតឡើងវិញ ដែលវានឹងជួយជំរុញដល់កំណើនសេដ្ឋកិច្ចផង និងផលប្រយោជន៍បរិស្ថានផងក្នុងរយៈពេលវែង។

ដើម្បីឆ្លើយតបទៅនឹងតម្រូវការថាមពលដែលកំពុងមានការកើនឡើង រាជរដ្ឋាភិបាលបានទទួលស្គាល់ពីសក្តានុពលក្នុងការអភិវឌ្ឍវិស័យថាមពលពន្លឺព្រះអាទិត្យ។ កាលពីខែមករា ឆ្នាំ២០១៨ អាជ្ញាធរអគ្គិសនីកម្ពុជា បានចេញនូវសេចក្តីប្រកាសជំបូងស្តីពីលក្ខខណ្ឌទូទៅនៃការតភ្ជាប់ថាមពលពន្លឺព្រះអាទិត្យទៅនឹងប្រព័ន្ធចែកចាយអគ្គិសនីជាតិ ឬប្រព័ន្ធប្រើប្រាស់អគ្គិសនីជាតិ។ សេចក្តីប្រកាសនេះ បានអនុញ្ញាតឱ្យអ្នកប្រើប្រាស់ ក៏ដូចជាវិស័យឧស្សាហកម្មក្នុងលក្ខខណ្ឌកំណត់មួយចំនួន ក្នុងការរៀបចំបង្កើតថាមពលពន្លឺព្រះអាទិត្យសម្រាប់ប្រើប្រាស់ផ្ទាល់ខ្លួន។ ដោយមានការផ្តល់យោបល់ពីវិស័យឧស្សាហកម្ម នៅពេលបច្ចុប្បន្ន សេចក្តីប្រកាសនេះកំពុងមានការកែសម្រួលបន្ថែមទៀត។ លើសពីនេះទៅទៀត នៅក្នុងឆ្នាំ ២០១៩ នេះ រាជរដ្ឋាភិបាលបានអនុម័តឱ្យមានការវិនិយោគលើការអភិវឌ្ឍបន្ទះស្រូបពន្លឺព្រះអាទិត្យ ដែលមានកម្រិតថាមពល ៤១០មេហ្គាវ៉ាត់ត្រឹមឆ្នាំ២០២២ ដែលស្មើនឹង ២០% នៃសមត្ថភាពថាមពលជាតិ។

វិធានការប្រសិទ្ធភាពថាមពល ក៏អាចជួយដល់ការបង្កើនផលិតភាពសេដ្ឋកិច្ចបានច្រើន និងកាត់បន្ថយតម្រូវការ ថាមពល ព្រមទាំងការកាត់បន្ថយឧស្ម័នកាបូនិចទៅក្នុងបរិយាកាស។ ផ្អែកទៅលើការវាយតម្លៃពីសក្តានុពល ប្រសិទ្ធភាពថាមពលនៅក្នុងវិស័យសំណង់ អគារ ឧស្សាហកម្ម និងដឹកជញ្ជូន គោលដៅរួមដែលបានកំណត់នៅក្នុងគោលនយោបាយជាតិស្តីពីប្រសិទ្ធភាពថាមពល គឺការកាត់បន្ថយតម្រូវការថាមពលឱ្យបាន ២០% ក្នុងឆ្នាំ២០៣៥ បើធៀបនឹងការអនុវត្តតាមទម្លាប់ធម្មតា។ បទពិសោធន៍អាស៊ានបង្ហាញថា នេះជាគោលដៅអភិរក្ស ហើយអាចសម្រេចបានទាំងស្រុង។ ប្រសិនបើប្រទេសកម្ពុជាឈានដល់គោលដៅនោះ វានឹងជួយសន្សំសំចៃសមត្ថភាពផលិតថាមពលក្នុងចន្លោះ ១៩០ មេហ្គាវ៉ាត់ដល់ ៣០៧ មេហ្គាវ៉ាត់។ វិស័យដែលមានសក្តានុពលខ្ពស់សម្រាប់ការសន្សំ គឺនៅក្នុងឧស្សាហកម្ម អគារ និងការដឹកជញ្ជូន។ ការឈានដល់គោលដៅបែបនេះមិនចាំបាច់ត្រូវការការវិនិយោគពីរដ្ឋាភិបាលទេ។ ភាគច្រើនអាចត្រូវបានសម្រេចដោយមានបទបញ្ញត្តិរឹងមាំជុំវិញប្រសិទ្ធភាពថាមពល។ ការវិភាគរបស់ក្រុមប្រឹក្សាជាតិអភិវឌ្ឍន៍ដោយចីរភាព និងGGGI បង្ហាញថាអាជីវកម្មដែលវិនិយោគលើដំណើរការផលិតកម្ម ឬអគារប្រកបដោយប្រសិទ្ធភាពថាមពលអាចរំពឹងថានឹងទទួលបានផលល្អពីការវិនិយោគដោយចំណាយពេលវេលាខ្លី។ ជាលទ្ធផលនៃប្រសិទ្ធភាពកាន់តែច្រើនអាជីវកម្មទាំងនេះ មើលឃើញពីផលិតភាព និងការប្រកួតប្រជែងរបស់ពួកគេមានភាពប្រសើរឡើង។ បទពិសោធន៍អន្តរជាតិបង្ហាញថា ការសន្សំថាមពល ២៥ % ឬច្រើនជាងនេះ អាចសម្រេចបាននៅក្នុងអគារដោយគ្រាន់តែប្រើសំភារៈសាងសង់អគារថាមពល បរិក្ខារដែលមានប្រសិទ្ធភាពថាមពល និងគោលការណ៍ passive design (GSA, 2011)។ លើសពីនេះទៀត យោងទៅតាមបទពិសោធន៍អន្តរជាតិ និងអនុវត្តស្លាកសញ្ញាថាមពលសម្រាប់ផលិតផលអ្នកប្រើប្រាស់ឧបករណ៍ប្រើប្រាស់ និងការប្រើប្រាស់ប្រកបដោយប្រសិទ្ធភាព អាចនាំឱ្យមានការសន្សំថាមពលពី ៣២% - ៥០%។[៥៤] នៅប្រទេសកម្ពុជា សហភាពអឺរ៉ុបប៉ាន់ស្មានថា វិស័យឧស្សាហកម្មសំខាន់ៗ (សម្លៀកបំពាក់ ផលិតកម្មកៅស៊ូ ឡឥដ្ឋ ការកែច្នៃ អាហារ ការ៉េម និងរោងម៉ាស៊ីនកិនស្រូវ) ផ្តល់នូវសក្តានុពលសន្សំថាមពលដែលមានចន្លោះពី ២៥-៣៥% ហើយជាពិសេសឡឥដ្ឋអាចសន្សំសំចៃរហូតដល់ ៧០% អាស្រ័យលើអត្រាកំណើនអនាគតរបស់ប្រជាជន និងផលិតផលក្នុងស្រុកសរុប និងផ្អែកលើនិន្នាការដែលបានព្យាករសម្រាប់តម្លៃថាមពលសមិទ្ធផលនៃការកាត់បន្ថយ ២០% នៃតម្រូវការប្រឆាំងនឹង BAU នៅត្រឹមឆ្នាំ២០៣៥ នឹងកាត់បន្ថយចំណាយថាមពលជាតិពី ៥៤០ លានដុល្លារទៅ ៦៩០ លានដុល្លារក្នុងមួយឆ្នាំ។ ការកែលម្អប្រសិទ្ធភាពថាមពលនឹងអនុញ្ញាតឱ្យកម្ពុជាឈានទៅសម្រេចបានគោលដៅអគ្គិសនីភាវូបនីយកម្មដែលបានកំណត់រួចបានឆាប់ និងចំណាយតិច។ ជាលទ្ធផល ការសន្សំសំចៃសេដ្ឋកិច្ចសរុបពីការកែលំអប្រសិទ្ធភាពថាមពល ត្រូវបានគេប៉ាន់ប្រមាណថា នឹងឈានដល់ ៧១០លានដុល្លារ / ឆ្នាំឬស្មើនឹង ១៣ កោដិដុល្លារគិតត្រឹមឆ្នាំ២០៣៥។ ការប្រើប្រាស់ឥន្ទនៈហ្វូស៊ីលអាចនឹងថយចុះ ២៩០.០០០ តោននៃប្រេង (ktoe) មកនៅត្រឹម ៤៦០ គីឡូវ៉ាត់ម៉ោង ជាមធ្យម

[54] International Energy Agency (IEA), 2015. https://www.iea.org/publications/freepublications/publication/WEO2015.pdf

ក្នុងមួយឆ្នាំ។ ការបំភាយឧស្ម័នកាបូនិកត្រូវបានគេរំពឹងថា នឹងធ្លាក់ចុះត្រឹម ១,៧ - ២,៥ លានតោនក្នុងមួយឆ្នាំ។ រដ្ឋាភិបាលទទួលស្គាល់តថភាពនេះហើយបានចាប់ផ្តើមចាត់វិធានការសមស្របលើបញ្ហានេះដោយបង្កើតក្រុមការងារស្តីពីគោលការណ៍ណែនាំ និងវិញ្ញាបនបត្រសម្រាប់អគារបៃតងនៅខែមីនា ឆ្នាំ២០២០ ដោយប្រមូលផ្តុំអ្នកជំនាញមកពីរដ្ឋាភិបាលវិស័យឯកជន និងទីភ្នាក់ងារអភិវឌ្ឍន៍។

## គ. បរិយាបន្នសង្គម

កំណើនសេដ្ឋកិច្ច មិនមែនសុទ្ធតែមានន័យថា ទាំងអស់គ្នាសុទ្ធតែទទួលបានឱកាសអភិវឌ្ឍន៍ស្មើៗគ្នានោះទេ។ ដូច្នេះ បរិយាបន្នសង្គម គឺជាធាតុចាំបាច់មួយក្នុងការធានាការអភិវឌ្ឍសេដ្ឋកិច្ចសង្គមប្រកបដោយនិរន្តរភាព និងសម្រាប់ទាំងអស់គ្នា។ ប្រទេសកម្ពុជាបានចាត់ទុក "បរិយាបន្នភាព" ថាជាផ្នែកដ៏សំខាន់ដើម្បីសម្រេចបាននូវទិសដៅជាសកលក្នុងការលុបបំបាត់ភាពក្រីក្រ និងជំរុញឱ្យមានការរីកចម្រើនទាំងអស់គ្នា។ ជាទូទៅ យើងតែងតែឃើញមានភាពខ្វះចន្លោះនៃការអភិវឌ្ឍទីក្រុង/ទីប្រជុំជន ដែលបង្កើតគម្លាតរវាងក្រុមសមាជិកសង្គម ដូចជាគម្លាតរវាងអ្នកមាន និងអ្នកក្រ និងក្រុមសមាជិកសង្គមតូចដែលមិនត្រូវបានសង្គមរាប់បញ្ចូល ដូចជាក្រុមកុមារ ស្ត្រី មនុស្សចាស់ ជនពិការ និងជនចំណាកស្រុក។

ក្រុមនិប្បរិយាបន្ន ជារឿយៗមិនត្រូវបានគេគិតបញ្ចូលទៅក្នុងការធ្វើផែនការអភិវឌ្ឍន៍ទីក្រុងទេ ដែលកត្តានេះតែងតែឈានទៅដល់ការមិនពេញចិត្តកាន់តែខ្លាំង ហើយចុងក្រោយនឹងអាចក្លាយជាទំនាស់ក្នុងសង្គម[៥៥]។ បើមើលទៅលើការប្រែប្រួលប្រជាសាស្ត្រពេលបច្ចុប្បន្ន និងពេលអនាគត រាជរដ្ឋាភិបាលបានទទួលស្គាល់ពីផលវិបាកនៃការប្រែប្រួលទាំងនេះ ដែលនឹងជះឥទ្ធិពលដល់ប្រជាពលរដ្ឋគ្រប់ៗគ្នា។

## ភាពក្រីក្រ និងលទ្ធភាពទទួលបានសេវា

ភាពក្រីក្រក្នុងទីក្រុង នៅតែមានជាធម្មតានៅប្រទេសកម្ពុជា។ រាជរដ្ឋាភិបាលកម្ពុជា បានដាក់ចេញនូវគោលនយោបាយជាតិស្តីពីប្រជាពលរដ្ឋ រយៈពេលវែង ២០១៦-២០៣០ ដែលបានកំណត់បរិយាបន្នសង្គម ជាធាតុដ៏សំខាន់។ គោលបំណងរួមនៃគោលនយោបាយនេះ គឺការចូលរួមចំណែកក្នុងការលើកកម្ពស់គុណភាពជីវិតរបស់ប្រជាពលរដ្ឋកម្ពុជា និងការកាត់បន្ថយភាពក្រីក្រ ដែលអាចសម្រេចបានតាមរយៈកិច្ចខិតខំប្រឹងប្រែងរួមគ្នាដើម្បីធានាកំណើនសេដ្ឋកិច្ចប្រកបដោយនិរន្តរភាព និងសមធម៌ ការអភិវឌ្ឍសង្គម និងការការពារបរិស្ថាន នៅក្នុងក្របខ័ណ្ឌអភិវឌ្ឍន៍របស់ប្រទេស និងសកលលោក។

យោងទៅតាមរបាយការណ៍វឌ្ឍនភាពនៃការអនុវត្តផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ ២០១៤-២០១៨ និងវឌ្ឍនភាពនៃការសម្រេចបានគោលដៅអភិវឌ្ឍន៍សហស្សវត្សន៍កម្ពុជាក្នុងឆ្នាំ ២០១៤ អត្រាភាពក្រីក្របានធ្លាក់ចុះពី ៤៧,៨% ក្នុងឆ្នាំ ២០០៧ មកនៅត្រឹម ១៤% នៅឆ្នាំ ២០១៤ ហើយបើតាមផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ ២០១៩-២០២៣ ដែលទើបតែបានអនុម័តរួច អត្រាភាពក្រីក្រមានត្រឹមតែ ៩,៥% ក្នុងឆ្នាំ២០១៩ និងត្រូវបានព្យាករថានឹងធ្លាក់ចុះមកត្រឹម ៥,៥% នៅឆ្នាំ២០២៣។ វិសមភាពនៅក្នុងប្រទេសកម្ពុជា ក៏មានការធ្លាក់ចុះផងដែរ។ នៅក្នុងឆ្នាំ២០១៧ សន្ទស្សន៍នៃការអភិវឌ្ឍធនធានមនុស្ស ដែលបានគិតបញ្ចូលកត្តាវិសមភាព (Inequality-Adjusted HDI) បានបង្ហាញថា អត្រាវិសមភាពសង្គម ១៩,៤% នៅប្រទេសកម្ពុជាជាអត្រាមួយដែលមានលក្ខណៈល្អប្រសើរខ្លាំងបើធៀប ជាមួយបណ្តាប្រទេសកំពុងអភិវឌ្ឍន៍និងប្រទេសមានការអភិវឌ្ឍមធ្យមដូចគ្នា[៥៦]។ ទោះបីជាយ៉ាងណាក្តី គុណភាពជីវិតនៃប្រជាពលរដ្ឋនៅប្រទេសកកម្ពុជានៅមានកម្រិតដោយសារការខ្វះលទ្ធភាពទទួលបានសេវាហេដ្ឋារចនាសម្ព័ន្ធ ដូចបានបង្ហាញនៅក្នុងតារាងទី ១.៦ ខាងក្រោម។

[55] J. L. Baker and G.U. Gadgil, Ed. East Asia and Pacific Cities: Expanding Opportunities for the Urban Poor, (The World Bank, 2017).

[56] UNDP, Human Development Indices and Indicators: 2018 Statistical Update. Accessed September 20, 2019. http://hdr.undp.org/en/2018-update

## តារាងទី១.៦. លទ្ធភាពទទួលបានសេវាសាធារណៈ[៥៧]

| ទីក្រុង | ចំនួនគ្រួសាររស់នៅលើដីរដ្ឋ | % នៃគ្រួសារដែលទទួលបានសេវាតភ្ជាប់បណ្តាញទឹក | % នៃគ្រួសារដែលទទួលបានសេវាអនាម័យ | % នៃគ្រួសារដែលទទួលបានសេវា ប្រមូលសំរាម |
|---|---|---|---|---|
| ក្រុងបាត់ដំបង | ២.៦៣១ | ៥៥,៦ | ៨១,១ | ៣៨,៩ |
| ក្រុងសៀមរាប | ២.៩៦២ | ១៨ | ៨២,៦ | ៣២,៨ |
| ក្រុងព្រះសីហនុ | ៩៧២ | ៦៣ | ៨៣,៩ | ៥១,៤ |
| ក្រុងកែប | ១៤ | ៤,៣ | ៣៩,៤ | ០ |
| ក្រុងកំពង់ចាម | ៩២ | ៨៣,៦ | ៨៦,៧ | ៥៦,៤ |
| ក្រុងសួង | ៦០ | ២៨,៨ | ៧០,៦ | ១០,៩ |
| ក្រុងបាវិត | | ៧,៩៣ | ៦២,២ | ៨ |

នៅឆ្នាំ២០១៤ រាជរដ្ឋាភិបាលបានដាក់ចេញនូវផែនការយុទ្ធសាស្ត្រវិស័យអប់រំ ដើម្បីកែលម្អប្រព័ន្ធអប់រំនៅកម្ពុជា ដែលនឹងរួមចំណែកដល់ការអភិវឌ្ឍសេដ្ឋកិច្ច។ ផែនការនេះ ផ្តោតសំខាន់លើការទទួលបានការអប់រំដោយស្មើភាព ការបង្កើនគុណភាពតាមសាលា និងការលើកទឹកចិត្តគ្រូបង្រៀន និងសម្ភារបង្រៀន ដើម្បីជំរុញឱ្យមានភាពប្រសើរឡើង។ ជាមួយនឹងការយកចិត្តទុកដាក់របស់រាជរដ្ឋាភិបាលក្នុងប្រព័ន្ធអប់រំ យើងឃើញមានការអភិវឌ្ឍគួរឱ្យកត់សម្គាល់ក្នុងរយៈពេលមួយទសវត្សន៍ចុងក្រោយនេះ។ នៅឆ្នាំ២០១៦ ចំនួនកុមារចុះឈ្មោះចូលរៀននៅកម្រិតបឋមសិក្សាបានកើនពី ៨២% នៅឆ្នាំ១៩៩៧ មកដល់ ៩៧% នៅក្នុងឆ្នាំសិក្សា ២០១៧/២០១៨។ ប្រទេសកម្ពុជា បានសាងសង់ ១.០០០ សាលាបន្ថែមទៀតក្នុងរយៈពេល ១០ឆ្នាំចុងក្រោយ និងបានប្រើប្រាស់ធនធានយ៉ាងច្រើនទៅក្នុងការពង្រឹង និងពង្រីកគុណភាពអប់រំ។ រាជរដ្ឋាភិបាលបានសន្យា កំណត់ថវិកាជាតិ ១៨,៣១% សម្រាប់វិស័យអប់រំ នៅឆ្នាំ២០១៦។ ក្នុងចន្លោះឆ្នាំ១៩៩០ ដល់២០១៧ ចំនួនឆ្នាំជាមធ្យមនៃសាលា គឺ ២,១ ឆ្នាំ ហើយអត្រានេះនឹងមានការកើនឡើងក្នុងរយៈពេល ៥ឆ្នាំ[៥៨]។ ទោះបីជាយ៉ាងណាក៏ដោយ គុណភាពអប់រំនៅតែជាបញ្ហាប្រឈម។

អត្រាកូនសិស្ស ធៀបនឹងគ្រូបង្រៀនម្នាក់ នៅខ្ពស់នៅឡើយ បើធៀបនឹងប្រទេសជិតខាង ហើយគ្រូមិនទាន់ទទួលបានកម្រៃសមរម្យនៅឡើយ។ ៤៧% នៃសិស្សថ្នាក់ទី ៣ គឺមិនទាន់អាចអានបាននៅកម្រិតទី ៣[៥៩]។

### សមភាពយេនឌ័រ

រាជរដ្ឋាភិបាលបានដាក់ចេញនូវគោលនយោបាយជាតិ និងគោលការណ៍ណែនាំជាច្រើនស្តីពីយេនឌ័រ។ រដ្ឋាភិបាលក៏បានអនុវត្តកម្មវិធីបញ្ជ្រាបយេនឌ័រដើម្បីលើកកម្ពស់សមភាពយេនឌ័រ និងការផ្តល់សិទ្ធិអំណាចដល់ស្ត្រីនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ។ ប្រទេសកម្ពុជាបានពង្រឹងអត្រាស្ត្រីនៅក្នុងវិស័យអប់រំ ដែលក្នុងនោះយើងឃើញថា ៤៨,២% នៃកូនសិស្សក្នុងបឋមសិក្សា គឺជាសិស្សស្រី។ ទោះបីជាយ៉ាងនេះក៏ដោយ ក្នុងការអនុវត្ត ស្ត្រីនៅតែជាក្រុមងាយ

[57] Data compiled from each city's social economic statistics, 2017.

[58] UNDP, Human Development Indices and Indicators: 2018 Statistical Update. Accessed September 20, 2019. http://hdr.undp.org/en/2018-update

[59] Julia McCartney, "Improving access to education in Cambodia," last modified August 14, 2017, https://borgenproject.org/access-education-in-cambodia/

វងគ្រោះ បើធៀបជាមួយបុរសដោយសារតែលទ្ធភាពទទួលបាន ធនធានហិរញ្ញវត្ថុ ដីធ្លី ធនធានធម្មជាតិ ការអប់រំ សុខភាព សិទ្ធិ និង ផលដែលទទួលបានពីការអភិវឌ្ឍមិនសមាមាត្រគ្នា។ ស្ត្រី ក៏ស្ថិតក្នុង ចំណោមក្រុមងាយរងគ្រោះ និងបាត់បង់ឱកាសក្នុងការចូលរួមដំណើរ ការបន្សាំនឹងការប្រែប្រួលអាកាសធាតុ និងការចូលរួមប្រកបដោយ អត្ថន័យក្នុងដំណើរការសម្រេចចិត្ត ដោយសារតែកត្តាសង្គម និង លទ្ធភាពទទួលបានព័ត៌មាន[៦០]។ ដូចដែលបានបង្ហាញក្នុងតារាង ខាងក្រោម មានស្ត្រីតិចតួចណាស់ដែលមានតួនាទីដឹកនាំនៅក្នុង សហគមន៍មូលដ្ឋានរបស់ពួកគេ។

### តារាងទី១.៧. តួនាទីស្ត្រី ក្នុងការធ្វើសេចក្ដីសម្រេចចិត្ត[៦១]

| ទីក្រុង | មេភូមិ | | | ក្រុមប្រឹក្សាឃុំ | | |
|---|---|---|---|---|---|---|
| | បុរស | ស្ត្រី | %ស្ត្រី | បុរស | ស្ត្រី | %ស្ត្រី |
| ក្រុងបាត់ដំបង | ៦២ | ៩ | ១៤,៥ | ១០០ | ១៩ | ១៩ |
| ក្រុងសៀមរាប | ៩៩ | ៦ | ៦,១ | ៩៤ | ២១ | ២២,៣ |
| ក្រុងព្រះសីហនុ | ១៩ | ១ | ៥,៣ | ៤៧ | ៨ | ១៧ |
| ក្រុងកែប | ១១ | ០ | ០ | ១៤ | ២ | ១៤,៣ |
| ក្រុងកំពង់ចាម | ៣២ | ៥ | ១៦,៥ | ៣៦ | ៩ | ២៥ |
| ក្រុងសួង | ៣០ | ១ | ៣,៣ | ២០ | ៦ | ៣០ |
| ក្រុងបាវិត | ៣៥ | ០ | ០ | ២៩ | ៤ | ១៣,៨ |

ធនាគារពិភពលោកបានរាយការណ៍ថា ការរួមចំណែកក្នុង កម្លាំងពលកម្មសេដ្ឋកិច្ចរបស់ស្ត្រីនៅប្រទេសកម្ពុជាដ៏ខ្ពស់នេះ មាន ចំនួនច្រើនជាងប្រទេសដទៃទៀតនៅក្នុងតំបន់។ ប្រមាណជា ៨០% នៃស្ត្រីកម្ពុជាដែលមានអាយុពី ១៥ ទៅ ៦៤ ឆ្នាំបានធ្វើការយ៉ាងហោច ណាស់មួយម៉ោងច្រើនជាង បើប្រៀបធៀបទៅនឹងអត្រាជាមធ្យម ៦៦% សម្រាប់ស្ត្រីនៅអាស៊ីបូព៌ា និងប៉ាស៊ីហ្វិក។ស្ត្រីកម្ពុជាជិត ២៣% បានធ្វើការនៅក្នុងវិស័យផលិតកម្មនៅឆ្នាំ២០១៥។ ស្ត្រី ៤២% ធ្វើការនៅឆ្នាំ២០១៦ បានកាន់កាប់មុខរបរដែលមានចំនួនស្ទើរតែ ពាក់កណ្ដាលនៃវិស័យកាត់ដេរ។ ទោះយ៉ាងនេះក្ដី ស្ត្រីធ្វើការនៅកម្ពុជា ជាច្រើន មិនត្រូវបានគាំពារដោយបទប្បញ្ញត្តិនៃច្បាប់ការងារទេ។ ទោះបីជាស្ត្រីត្រូវបានគេមើលឃើញថា ជាក្បាលម៉ាស៊ីននៃឧស្សាហកម្ម កាត់ដេរសម្លៀកបំពាក់ផ្លូវការក៏ដោយ ក៏ការចូលរួមរបស់ពួកគេកំពុង

[60] Phearanich Hing, "Women in the Face of Climate Change: the Driving Force for Any Solution," last modified March 8, 2016, http://www.kh.undp.org/content/cambodia/en/home/presscenter/articles/2016/03/08/women-in-the-face-of-climate-change-the-driving-force-for-any-solution.html

[61] Data compiled from different sources of each city's social economic statistics.

កើនឡើងនៅក្នុងការងារប្រាក់ឈ្នួលឯកជននៅក្នុងសេវាកម្ម (ដូចជាបដិសណ្ឋារកិច្ច និងការអប់រំ) កសិកម្ម និងសំណង់។ នៅក្នុងវិស័យទាំងនេះ ការចូលរួមរបស់ពួកគេ ភាគច្រើននៅតែមិនទាន់មានលក្ខណៈផ្លូវការនៅឡើយ។ ឧទាហរណ៍ កម្មការនីជាង ៥០០.០០០ នាក់នៅតែស្ថិតក្នុងវិស័យការងារប្រាក់ឈ្នួលក្រៅផ្លូវការនៅក្នុងវិស័យសេវាកម្ម និងសំណង់។ ស្ត្រីនៅក្នុងវិស័យក្រៅផ្លូវការទាំងនេះ ខ្វះការការពារ ដូចដែលកម្មករនិយោជិតក្នុងរោងចក្រកាត់ដេរធំៗត្រូវទទួលបាន ដូចជាការការពារមាតុភាព បន្ទុកការងារ ប្រាក់ឈ្នួលការបំបៅកូនដោយទឹកដោះម្តាយ ការមើលថែទាំកូន និងការគាំពារផ្សេងៗទៀត[៦២]។

## លំនៅឋានសមរម្យ

យោងតាមគោលនយោបាយជាតិស្តីពីលំនៅឋានឆ្នាំ២០១៤ របស់រដ្ឋាភិបាលនៅឆ្នាំ២០៣០ ប្រជាជនកម្ពុជានឹងត្រូវការផ្ទះបន្ថែមចំនួន ១,១ លានខ្នងទៀត ដើម្បីឆ្លើយតបនឹងតម្រូវការដែលភាគច្រើននៃផ្ទះទាំងនេះនឹងត្រូវរស់នៅក្នុងសហគមន៍ដែលមានប្រាក់ចំណូលទាប និងមធ្យម។ គោលនយោបាយនេះ ចែងថា ពលរដ្ឋទាំងអស់មានសិទ្ធិទទួលបានគេហដ្ឋានគ្រប់គ្រាន់ និងផ្តល់ជម្រើសដើម្បីធានាសិទ្ធិកាន់កាប់ដីធ្លី និងសន្តិសុខ។ អង្គការលំនៅឋានដើម្បីមនុស្សជាតិកម្ពុជា ប៉ាន់ស្មានថា ២០% នៃចំនួនប្រជាជនកម្ពុជារស់នៅក្នុងតំបន់អនាធិបតេយ្យ[៦៣]។ ដើម្បីជំរុញការអភិវឌ្ឍលំនៅឋានដែលមានតំលៃសមរម្យរដ្ឋាភិបាលកម្ពុជាបានអនុម័តការលើកទឹកចិត្តនៅឆ្នាំ២០១៧ សម្រាប់អ្នកអភិវឌ្ឍន៍គម្រោងលំនៅឋានដែលមានតំលៃសមរម្យ រួមទាំងអត្រាពិសេស សម្រាប់ការបង់ពន្ធប្រាក់ចំណូល ពន្ធលើអចលនទ្រព្យ និងអាករលើតម្លៃបន្ថែម ក៏ដូចជានីតិវិធីរដ្ឋបាលសាមញ្ញ សម្រាប់ការទទួលបានលិខិតអនុញ្ញាតសាងសង់ និងអាជ្ញាបណ្ណអាជីវកម្ម។ ខណៈពេលដែលការលើកទឹកចិត្តទាំងនេះ ផ្តោតលើតំបន់នៅភ្នំពេញ វិធីសាស្ត្រស្រដៀងគ្នានេះក៏នឹងត្រូវបានស្វាគមន៍នៅក្នុងទីក្រុងធំៗដទៃទៀត។ ឧទាហរណ៍ កង្វះខាតគេហដ្ឋានដែលមានតំលៃសមរម្យនៅខេត្តសៀមរាប និងខេត្តបាត់ដំបងបានធ្វើឱ្យគ្រួសារក្រីក្ររាប់ពាន់គ្រួសារកាន់កាប់ដីសាធារណៈដោយខុសច្បាប់ (សូមមើលតារាងទី ១.៦)។ ការស្រាវជ្រាវរបស់ GGGI បានបង្ហាញពីសក្តានុពលខ្លាំងក្នុងការប្រើប្រាស់សម្ភារកាបូនទាប និងមានប្រភពក្នុងស្រុក ក្នុងការអភិវឌ្ឍលំនៅឋាន ដែលមានតម្លៃសមរម្យ[៦៤]។

## វិស័យដឹកជញ្ជូន

គិតត្រឹមឆ្នាំ ២០១៧ បណ្តាញផ្លូវថ្នល់នៅកម្ពុជាមានចម្ងាយជាង ៥៧.០០០ គីឡូម៉ែត្រ។ ផ្លូវជាតិភាគច្រើន ជាបណ្តាញផ្លូវបឋមដែលតភ្ជាប់ពីភ្នំពេញទៅរាជធានីខេត្ត និងមជ្ឈមណ្ឌលសំខាន់ៗនៃសកម្មភាពសេដ្ឋកិច្ច។ នៅចន្លោះឆ្នាំ ១៩៩៧ និងឆ្នាំ ២០១៥ ការចុះបញ្ជីយានយន្តបានកើនឡើងជាមួយនឹងកំណើនប្រចាំឆ្នាំជាមធ្យម ១១,៣% សម្រាប់រថយន្ត រថយន្តដឹកទំនិញរថយន្តលក្ខណៈគ្រួសារខ្នាតតូច ខ្នាតធំ និងរថយន្តទ្រុងដឹកទំនិញ និង ២១,៨% ក្នុងមួយឆ្នាំសម្រាប់ការចុះឈ្មោះម៉ូតូ។ ក្នុងឆ្នាំ ២០១៥ ចំនួនយានយន្តដែលបានចុះបញ្ជីសរុបសម្រាប់ម៉ូតូ មានចំនួនប្រមាណ ២.៣០០.០០០ គ្រឿង សម្រាប់រថយន្ត មានប្រមាណ ១៥៩.០០០ គ្រឿង និងសម្រាប់រថយន្តលក្ខណៈគ្រួសារធំ រថយន្តដឹកទំនិញ និងរថយន្តក្រុងដឹកអ្នកដំណើរ / រថយន្តក្រុង មានចំនួនប្រមាណ ៧២.០០០ គ្រឿង។ ក្នុងឆ្នាំដដែលវិស័យដឹកជញ្ជូនតំណាងឱ្យជាង ៤៥% នៃការប្រើប្រាស់ថាមពលចុងក្រោយនៅកម្ពុជា ដែលបានមកពីផលិតផលប្រេងដែលនាំចូល (ប្រេងសាំង ៣៥% ប្រេងម៉ាស៊ូត ៥៧% ប្រេងម៉ាស៊ូត ៦% LPG)។ ក្នុងឆ្នាំ ២០០០ វិស័យដឹកជញ្ជូនមានចំនួនតិចជាង ៣% នៃការបំភាយឧស្ម័នផ្ទះកញ្ចក់ថ្នាក់ជាតិ។ ខណៈសារពើភណ្ឌឧស្ម័នផ្ទះកញ្ចក់ជាតិ ដែលបានធ្វើបច្ចុប្បន្នភាពពេញលេញមិនទាន់មាននៅឡើយនៅពេលសរសេរបញ្ជីសារពើភណ្ឌឆ្នាំ២០១៦ សម្រាប់វិស័យដឹកជញ្ជូន បានបង្ហាញពីកំណើនប្រចាំឆ្នាំជាមធ្យមនៃការបំភាយឧស្ម័នដឹកជញ្ជូនមាន ១២,៨% ក្នុងមួយឆ្នាំ។ ក.ជ.អ.ច. ចង្អុលបង្ហាញថា និន្នាការទាំងនេះបង្ហាញពីបញ្ហាប្រឈមសម្រាប់ប្រទេសកម្ពុជាក្នុងការជំរុញកំណើនសេដ្ឋកិច្ចជាបន្ត ដោយ

[62] Ly, Sodeth; Sanchez Martin, Miguel Eduardo; Phim, Runsinarith; Ky, Linna; Tong, Kimsun; Provo, Anne Marie; Nagpal, Somil; Vashakmadze, Ekaterine T.. 2019. Cambodia Economic Update : Recent Economic Developments and Outlook (English). Cambodia Economic Update. Washington, D.C. : World Bank Group.
http://documents.worldbank.org/curated/en/843251556908260855/Cambodia-Economic-Update-Recent-Economic-Developments-and-Outlook

[63] Habitat for Humanity Cambodia, Annual Report, 2016.

[64] GGGI, “Meeting Global Housing Needs with Low Carbon Materials,” GGGI Technical Report no. 4 (2019).

ធានាលទ្ធភាពទទួលបានមធ្យោបាយធ្វើដំណើរសម្រាប់ទាំងអស់គ្នា នៅក្នុងបរិយាកាសដែលការដឹកជញ្ជូនសាធារណៈនៅតែមានកម្រិត ហើយក្នុងពេលតែមួយកាត់បន្ថយតម្រូវការថាមពលកាត់បន្ថយភាពពឹងអាស្រ័យថាមពល និងគ្រប់គ្រងផលប៉ះពាល់នៃវិស័យដឹកជញ្ជូនទៅលើការបំពុលខ្យល់ សុខភាពមនុស្ស និងការប្រែប្រួលអាកាសធាតុ។

ស្របពេលដែលបណ្តាញផ្លូវថ្នល់ និងភាពជាម្ចាស់យានយន្តមានការរីកចម្រើន ក្រុងនានារបស់ប្រទេសកម្ពុជា កាន់តែខ្វះផ្លូវដែលអាចដើរបាន និងអាចឱ្យការដឹកជញ្ជូនសាធារណៈចូលដំណើរការបាន និងលំហបៃតង។ កង្វះខាតនេះ ធ្វើឱ្យប៉ះពាល់ជាពិសេសដល់ភាពងាយស្រួលចេញចូលទីក្រុងសម្រាប់ប្រជាពលរដ្ឋនៅកម្ពុជា។ មិនបានក្លាយជាកន្លែងដែលប្រជាជនអាចទទួលបានសេវាកម្ម និងភ្ជាប់ទំនាក់ទំនងជាមួយសហគមន៍នានា បែរជាក្រុងនានារបស់ប្រទេសកម្ពុជា ក្លាយជាកន្លែងដែលពិបាកធ្វើដំណើរកាន់តែខ្លាំងឡើងថែមទៀត។

## ការចូលរួមរបស់ប្រជាពលរដ្ឋក្នុងដំណើរការអភិវឌ្ឍ

ការចូលរួមរបស់ប្រជាជន គឺជាកត្តាដ៏សំខាន់មួយនៅក្នុងការសម្រេចចិត្តធ្វើផែនការអភិវឌ្ឍន៍ទីក្រុងដើម្បីសម្រេចបាននូវក្រុងមួយដែលមានការទទួលខុសត្រូវខាងសង្គម បរិស្ថាន និងសេដ្ឋកិច្ចប្រកបដោយនិរន្តរភាពនាពេលអនាគត។ ប៉ុន្តែសម្រាប់ប្រទេសកម្ពុជា ការចូលរួមរបស់ប្រជាជននៅក្នុងការអភិវឌ្ឍទីក្រុងនៅមានកម្រិតនៅឡើយ។ ប្រទេសកម្ពុជា គឺជាប្រទេសមួយក្នុងចំណោមបណ្តាប្រទេសនៅអាស៊ីប៉ាស៊ីហ្វិកដែលមានរចនាសម្ព័ន្ធគ្រប់គ្រងអភិបាលកិច្ចប្រមូលផ្តុំអំណាចតែនៅអំណាចកណ្តាល (ថ្នាក់ជាតិ) ដែលនេះជាកត្តាមួយរារាំងការចូលរួមរបស់ប្រជាពលរដ្ឋនៅក្នុងអភិបាលកិច្ច និងធ្វើផែនការទីក្រុងនៅថ្នាក់ក្រោមជាតិ[៦៥]។ ថ្វីបើកម្ពុជាបានដាក់បញ្ចូលនូវគោលនយោបាយមួយចំនួន ដែលលើកទឹកចិត្តដល់ការធ្វើផែនការ ដោយមានការចូលរួមក៏ដោយ ប៉ុន្តែការអនុវត្តគោលនយោបាយទាំងនោះឱ្យមានប្រសិទ្ធភាព នៅតែជាបញ្ហាចោទនៅឡើយ។ ប្រទេសកម្ពុជាមិនទាន់បានអនុវត្តល្អនូវយន្តការដែលបានលើកទឹកចិត្តដល់ការចូលរួមរបស់ប្រជាពលរដ្ឋក្នុងដំណើរការរៀបចំផែនការទីក្រុង និងការអភិវឌ្ឍទីក្រុងនៅថ្នាក់ក្រោមជាតិនៅឡើយទេ។

## ឃ. អភិបាលកិច្ចក្រុង

រដ្ឋបាលក្រុង ដើរតួនាទីយ៉ាងសំខាន់ក្នុងការជំរុញការអភិវឌ្ឍតំបន់ក្រុងរបស់ខ្លួនឱ្យមាននិរន្តរភាព។ អាជ្ញាធរក្រុងជាអ្នកកំណត់ទិសដៅរួមសម្រាប់ការអនុវត្តរបស់ក្រុងនីមួយៗ តាមរយៈការធ្វើផែនការរយៈពេលវែង រួមមានការកំណត់ចក្ខុវិស័យ និងការធានាសម្រេចបាននូវចក្ខុវិស័យនោះ។ រដ្ឋបាលថ្នាក់ក្រោមជាតិ មានតួនាទី និងការទទួលខុសត្រូវក្នុងការគ្រប់គ្រង ក៏ដូចជាអនុវត្តសេវាសាធារណៈប្រកបដោយគុណភាពទៅដល់សហគមន៍ក្នុងតំបន់ ដូចជាសេវាសុខភាព សេវាអប់រំ ការថែទាំផ្លូវ និងទីធ្លាសាធារណៈ។ រដ្ឋបាលថ្នាក់ក្រោមជាតិ ក៏មានតួនាទីចេញបទប្បញ្ញត្តិ និងធ្វើការសម្រេចចិត្តក្នុងតំបន់ដែលរដ្ឋបាលថ្នាក់ក្រោមជាតិគ្រប់គ្រង។ រដ្ឋបាលថ្នាក់ក្រោមជាតិ ក៏ជាតំណាងរបស់ប្រជាពលរដ្ឋក្នុងតំបន់របស់ខ្លួនក្នុងការធ្វើការតស៊ូមតិ ឬពាំនាំតម្រូវការទៅដល់រដ្ឋបាលថ្នាក់ជាតិ។

យោងទៅតាមច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាល រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ (២០០៨) រចនាសម្ព័ន្ធគ្រប់គ្រងនៅថ្នាក់ក្រោមជាតិត្រូវបានកំណត់បែងចែកជា ៣ថ្នាក់ រួមមាន ២៥រាជធានីខេត្ត ១៩៧ ក្រុង ស្រុក ខណ្ឌ និង១.៦៤៦ ឃុំ សង្កាត់ ។

[65] J. L. Baker and G.U. Gadgil, Ed. East Asia and Pacific Cities: Expanding Opportunities for the Urban Poor ( The World Bank, 2017).

## រូបភាពទី១.៤. រចនាសម្ព័ន្ធរដ្ឋបាលថ្នាក់ក្រោមជាតិរបស់ប្រទេសកម្ពុជា




ដើម្បីឱ្យការអនុវត្តនូវតួនាទីទាំងនេះមានប្រសិទ្ធភាព រដ្ឋបាលមូលដ្ឋានត្រូវការការគាំទ្រយ៉ាងរឹងមាំពីរដ្ឋបាលថ្នាក់ជាតិ។ ដើម្បីផ្តល់អំណាចដល់រដ្ឋបាលមូលដ្ឋាន រាជរដ្ឋាភិបាលបានអនុវត្តកម្មវិធីជាតិរយៈពេល ១០ឆ្នាំ សម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ (NP-SNDD, ២០១០-២០១៩)។ កម្មវិធីនេះ ផ្តល់នូវផែនទីបង្ហាញផ្លូវសម្រាប់ការអនុវត្តកំណែទម្រង់បែបវិមជ្ឈការ និងវិសហមជ្ឈការសំដៅពង្រឹងប្រព័ន្ធគ្រប់គ្រងរដ្ឋបាលថ្នាក់ក្រោមជាតិ ដោយផ្អែកលើគោលការណ៍នៃ "ការចូលរួមតាមបែបប្រជាធិបតេយ្យ" ដើម្បីលើកកម្ពស់ការអភិវឌ្ឍមូលដ្ឋាន និងការផ្តល់សេវាសាធារណៈ ដែលបំពេញចំតម្រូវការរបស់ប្រជាពលរដ្ឋ និងរួមចំណែកដល់ការកាត់បន្ថយភាពក្រីក្រ។

ដំណាក់កាលដំបូងនៃកម្មវិធីនេះត្រូវបានបញ្ចប់ដោយជោគជ័យក្នុងឆ្នាំ ២០១៤ ជាមួយនឹងការអភិវឌ្ឍប្រព័ន្ធសំខាន់ៗ និងឯកសារច្បាប់មួយចំនួនរួមមាន៖ នីតិវិធីដើម្បីណែនាំប្រតិបត្តិការការងាររបស់ក្រុមប្រឹក្សា ការបង្កើតមូលនិធិក្រុងស្រុក និងប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុដែលគាំទ្រដល់មូលនិធិក្រុងស្រុកនេះ កម្មវិធីសម្រាប់គណនេយ្យភាពសង្គម សេចក្តីព្រាងច្បាប់ដើម្បីធ្វើវិមជ្ឈការការគ្រប់គ្រងធនធានមនុស្ស និងការអភិវឌ្ឍ និងនីតិវិធីដំបូងសម្រាប់ការអនុវត្តដំណើរការត្រួតពិនិត្យការអនុលោមតាមច្បាប់។

ទន្ទឹមនឹងការរីកចម្រើននេះ រដ្ឋបាលថ្នាក់ក្រោមជាតិនៅតែប្រឈមនឹងកង្វះខាតផ្នែកធនធានមនុស្ស និងហិរញ្ញវត្ថុ ដែលបានជះឥទ្ធិពលផ្ទាល់ដល់សមត្ថភាពរដ្ឋបាលថ្នាក់ក្រោមជាតិ

[66] Both capital/province budget and district/municipal funds are allocated at a rate of 1% of the current national revenue, 76% for the administrative component, and only 24% for the development component. Commune/sangkat funds, on the other hand, are allocated at a rate of 2.8% of the approved annual national budget of the previous year, one third of which is to be used for administration purposes.

ក្នុងការបំពេញភារកិច្ចរបស់ខ្លួន និងក្នុងកិច្ចអភិវឌ្ឍន៍ជាតិ។ ក្នុងឆ្នាំ២០១៦ រដ្ឋបាលថ្នាក់ក្រោមជាតិត្រូវបានបែងចែកថវិកាសរុប ៣៤៣ លានដុល្លារអាមេរិក ក្នុងនោះ ២២៥.៨ លានដុល្លារអាមេរិក គឺថវិកាសម្រាប់រាជធានី ខេត្ត និង ២៤.៤លានដុល្លារអាមេរិកគឺជាថវិកាសម្រាប់មូលនិធិក្រុង ស្រុក ៧៦លានដុល្លារអាមេរិកជាថវិកាមូលនិធិឃុំសង្កាត់ និង ១៦លានដុល្លារអាមេរិកជាថវិកាឧបត្ថម្ភមានលក្ខខណ្ឌពីថ្នាក់ជាតិ (តារាងទី១.៨)។[៦៦]

## តារាងទី១.៨. ថវិកាសម្រាប់រដ្ឋបាលថ្នាក់ក្រោមជាតិ[៦៧]

| ថវិការដ្ឋបាលថ្នាក់ក្រោមជាតិ(ជាលានដុល្លារអាមេរិក) | | | |
|---|---|---|---|
| | ២០១៤ | ២០១៥ | ២០១៦ |
| ថវិការាជធានី / ខេត្ត | ១៥៨,២៣ | ១៨៦,១៦ | ២២៥,៨ |
| មូលនិធិក្រុង / ស្រុក | ១៧,៥ | ១៩,១៩ | ២៤,៤ |
| មូលនិធិឃុំ / សង្កាត់ | ៥៨,៥៨ | ៦៧,១៥ | ៧៦ |
| ថវិកាឧបត្ថម្ភមានលក្ខខណ្ឌពីថ្នាក់ជាតិ | ០ | ៥ | ១៦ |
| សរុប | ២៣៣,៥៥ | ២៧៨,៣ | ៣៤២,៩ |

ជារួម ភាគច្រើននៃថវិកាជាតិ ថ្នាក់ក្រោមជាតិប្រចាំឆ្នាំ (ច្រើនជាង ៧០%) ត្រូវបានប្រើប្រាស់ដើម្បីចំណាយលើប្រាក់បៀវត្សរ៍បុគ្គលិក និងចំណាយប្រតិបត្តិការរដ្ឋបាល។ ដូច្នេះនៅសល់ថវិកាតិចតួចប៉ុណ្ណោះសម្រាប់ការអភិវឌ្ឍនៅមូលដ្ឋាន ដើម្បីផ្តល់សេវា និងហេដ្ឋារចនាសម្ព័ន្ធសាធារណៈដែលចាំបាច់ ដូចជាការប្រមូលសំរាម និងការធ្វើប្រព្រឹត្តិកម្មទឹកកខ្វក់។ ជាលទ្ធផលការវិនិយោគទៅលើគម្រោងហេដ្ឋារចនាសម្ព័ន្ធសំខាន់ៗទាំងនេះតែងតែពឹងផ្អែកលើការផ្តល់មូលនិធិរបស់ដៃគូអភិវឌ្ឍន៍ និងការចូលរួមចំណែកពីក្រសួងពាក់ព័ន្ធ។ ប្រសិនបើទីក្រុងនានារបស់ព្រះរាជាណាចក្រកម្ពុជាចង់កែប្រែមុខមាត់ឱ្យកាន់តែមានភាពបៃតង និងមានអនាគតកាន់តែប្រកបដោយនិរន្តរភាពនោះ យើងត្រូវដំឡើងប្រាក់ចំណូលនិងធនធានជាមូលដ្ឋានរបស់រដ្ឋបាលក្រុង។

ក្រៅពីឧបសគ្គកង្វះថវិកា សមត្ថភាពស្ថាប័នរបស់រដ្ឋបាលថ្នាក់ក្រោមជាតិនៅតែមានកម្រិតក្នុងការដោះស្រាយជាមួយបញ្ហាក្រុងដែលកំពុងកើតឡើង និងក្នុងការបង្កើតគំនិតថ្មីដើម្បីធ្វើកំណែទម្រង់។ ជាទូទៅ កង្វះបុគ្គលិកគឺជាបញ្ហារបស់រដ្ឋបាលក្រុង ជាពិសេសសម្រាប់បណ្តាក្រុងដែលមានការអភិវឌ្ឍតិច ដូចជាក្រុងសួង និង ក្រុងបាវិត។ រដ្ឋបាលថ្នាក់ក្រោមជាតិ ក៏មិនអាចទាក់ទាញបុគ្គលិកដែលមានជំនាញ និងមានឆន្ទៈខ្ពស់ឱ្យមកធ្វើការជាមួយពួកគេដោយសារតែប្រាក់ខែទាប និងកង្វះការលើកទឹកចិត្ត។ កត្តានេះទាមទារឱ្យមានការកែលម្អរចនាសម្ព័ន្ធគ្រប់គ្រង និងរចនាសម្ព័ន្ធស្ថាប័ន ក៏ដូចជាប្រព័ន្ធនាំការអនុវត្តការងារល្អប្រសើរជាងមុន។ ដូចគ្នានេះផងដែរ វាទាមទារឱ្យមានការរៀបចំកន្លែងប្រសើរជាងមុន ប្រព័ន្ធព័ត៌មានកុំព្យូទ័រដែលមានកម្រិតខ្ពស់ រួមជាមួយនឹងការកែលម្អការផ្តល់សេវាសាធារណៈប្រសើរជាងមុន និងការអភិវឌ្ឍឥរិយាបថប្រកបដោយភាពវិជ្ជមានដើម្បីបម្រើសាធារណជន។

[66] Both capital/province budget and district/municipal funds are allocated at a rate of 1% of the current national revenue, 76% for the administrative component, and only 24% for the development component. Commune/sangkat funds, on the other hand, are allocated at a rate of 2.8% of the approved annual national budget of the previous year, one third of which is to be used for administration purposes.

[67] Data compiled from NCDD annual reports.

ការសម្របសម្រួលស្ថាប័ននៅថ្នាក់ក្រោមជាតិ ក៏ជាកង្វះខាតមួយផងដែរ។ នៅថ្នាក់ខេត្ត / រាជធានី ឬក្រុង មន្ទីរជំនាញតាមវិស័យធ្វើការអនុវត្តគោលនយោបាយ និងផែនការទៅតាមការកំណត់របស់ក្រសួង និងស្ថាប័នពាក់ព័ន្ធពីថ្នាក់ជាតិ។ រចនាសម្ព័ន្ធនេះគឺមានលក្ខណៈឋានានុក្រម និងខ្វះការសម្របសម្រួលលើការធ្វើផែនការការងារ ផែនការថវិកា និងការគ្រប់គ្រងបុគ្គលិក។ ក្នុងនាមជាតំណាងរាជរដ្ឋាភិបាល អភិបាលរាជធានី ឬអភិបាលក្រុង ត្រូវបានប្រគល់សិទ្ធិអំណាចដោយថ្នាក់ជាតិដើម្បីសម្របសម្រួល លើកកម្ពស់ និងដឹកនាំទៅកេការកំណត់គោលដៅរបស់មន្ទីរជំនាញនៅតាមខេត្ត / ក្រុងស្របតាមគោលនយោបាយរបស់រាជរដ្ឋាភិបាល។ នៅថ្នាក់រាជធានី / ក្រុង ការសម្របសម្រួលស្ថាប័នតាមរយៈរចនាសម្ព័ន្ធផ្លូវការ គឺជាទូទៅនៅខ្សោយនៅឡើយ ហើយការទទួលខុសត្រូវគឺនៅមានលក្ខណៈឋានានុក្រមពីថ្នាក់លើ។ ការសម្របសម្រួល និងកិច្ចសហប្រតិបត្តិការល្អប្រសើររវាងទីក្រុង អាចជួយពង្រឹងសមត្ថភាពធនធានមនុស្សបន្ថែម និងមានលទ្ធភាពប្រើប្រាស់ធនធានហិរញ្ញវត្ថុដែលខ្វះខាតមានប្រសិទ្ធភាពជាងមុន។

ទីក្រុងនានានៅក្នុងប្រទេសកម្ពុជា អាចទទួលបានអត្ថប្រយោជន៍ពីប្រព័ន្ធបច្ចេកវិទ្យា និងវិធីសាស្ត្រកាន់តែមានភាពវៃឆ្លាតជាងមុន ដើម្បីឆ្លើយតបទៅនឹងតម្រូវការទីក្រុងក្នុងពេលបច្ចុប្បន្ន និងអនាគត។ ការកើនឡើងចំនួនទីក្រុងបាននឹងកំពុងត្រូវបានមើលឃើញថានឹងមាន "ភាពវៃឆ្លាត" និង "សភាពបៃតង" ជាងមុន ។ ក្នុងបរិបទប្រទេសកម្ពុជា ប្រព័ន្ធ និងវិធីសាស្ត្រកាន់តែមានភាពវៃឆ្លាតជាងមុន អាចនឹងត្រូវបានបង្កើតឡើងដើម្បីជាការគាំទ្រដល់ការផ្តល់នូវសេវាឲ្យមានភាពប្រសើរឡើង (ឧទាហរណ៍តាមរយៈកម្មវិធីទំនាក់ទំនងរវាងគ្រួសារ និងអ្នកផ្តល់សេវា) ហេដ្ឋារចនាសម្ព័ន្ធ (ដើម្បីគាំទ្រដល់ការប្រមូល និងការបែងចែកការគ្រប់គ្រងសំរាម) ព័ត៌មានសម្រាប់ប្រជាពលរដ្ឋ (រាប់បញ្ចូលទាំងការដឹកជញ្ជូនសាធារណៈ ដែលកំពុងរីកចម្រើន និងដំណោះស្រាយដឹកជញ្ជូនផ្សេងៗទៀត) ក៏ដូចជាការផ្តល់ទិន្នន័យដល់អ្នករៀបចំផែនការ ក្នុងការកំណត់ផែនការឱ្យកាន់តែមានប្រសិទ្ធភាព និងផ្តល់ជូនសម្រាប់ចំនួនប្រជាជនទីក្រុងដែលកំពុងកើនឡើងនៅក្នុងប្រទេស។ បច្ចេកវិទ្យាគ្រាន់តែសំដៅដល់ទីបញ្ចប់ ទោះបីជាយ៉ាងណា ទីក្រុងបៃតងមានភាពវៃឆ្លាតត្រូវបានគ្រប់គ្រងយ៉ាងល្អដោយរាប់បញ្ចូលការគ្រប់គ្រងធនធានធម្មជាតិប្រកបដោយនិរន្តរភាព និងដោយមានជំនួយពីបច្ចេកវិទ្យាព័ត៌មាននិងទំនាក់ទំនង (ICT) ដែលអាចផ្តល់សេវាកម្មប្រកបដោយប្រសិទ្ធភាព តម្លៃសមរម្យ និងសេវាកម្មដ៏មានភាពស័ក្តិសិទ្ធដល់ប្រជាជនទាំងអស់គ្នា។

## ១.៣.២. ការកំណត់កម្មវត្ថុជាយុទ្ធសាស្ត្រ

ដោយផ្អែកលើការប៉ាន់ប្រមាណខាងលើ ផែនការយុទ្ធសាស្ត្រនេះ កំណត់ចេញកម្មវត្ថុចំនួន ១២ ដើម្បីសម្រេចបាននូវការអភិវឌ្ឍទីក្រុងនិរន្តរភាព ពោលគឺឆ្លើយតបទៅនឹងចក្ខុវិស័យ និងគោលដៅទាំង ៤ ដែលបានរៀបរាប់ខាងលើ។ កម្មវត្ថុទាំង ១២ រួមមាន៖

### ក. ការរៀបចំផែនការអភិវឌ្ឍន៍ទីក្រុងសមាហរណ៍ និងហេដ្ឋារចនាសម្ព័ន្ធបៃតង

- ធ្វើសមាហរណ៍ផែនការ និងរចនាគម្រោងនគរូបនីយកម្មទីក្រុងប្រកបដោយចីរភាព រួមបញ្ចូលទាំងការរៀបចំប្លង់គោលសម្រាប់ការបែងចែកដីប្រើប្រាស់ និងធ្វើផែនការ និងកំណត់តំបន់ដីប្រើប្រាស់
- កសាងហេដ្ឋារចនាសម្ព័ន្ធទីក្រុងប្រកបដោយចីរភាព សម្រាប់ប្រព័ន្ធលូទឹកកខ្វក់ និងលូទឹកភ្លៀង ការគ្រប់គ្រងសំរាម ការផ្គត់ផ្គង់ទឹក ប្រព័ន្ធដឹកជញ្ជូន ប្រព័ន្ធគមនាគមន៍ និងការផ្គត់ផ្គង់ថាមពល ដោយរួមបញ្ចូលទាំងគំរូក្នុងការធ្វើមជ្ឈការពណ៌ប្រផេះមកកាន់ពណ៌បៃតង
- បង្កើតការគ្រប់គ្រងដែលមានប្រសិទ្ធភាពដើម្បីកាត់បន្ថយហានិភ័យគ្រោះថ្នាក់ បន្សាំទៅនឹងការប្រែប្រួលអាកាសធាតុ និងត្រៀមបង្ការឆ្លើយតបទៅនឹងគ្រោះមហន្តរាយ

### ខ. ការអភិវឌ្ឍសេដ្ឋកិច្ចបៃតងនៅមូលដ្ឋាន

- បង្កើនចំណែកថាមពលដែលជាថាមពលកកើតឡើងវិញ និងបង្កើនប្រសិទ្ធភាពថាមពល នៅក្នុងទីក្រុងរាប់បញ្ចូលទាំងវិស័យឧស្សាហកម្ម សំណង់អគារ និងផ្ទះប្រជាពលរដ្ឋ
- ពង្រឹងវិស័យអេកូទេសចរណ៍នៅតាមទីក្រុង តាមរយៈការការពារ និងលើកកម្ពស់ធនធានធម្មជាតិនិងបេតិកភណ្ឌវប្បធម៌
- បង្កើតបរិយាកាសអំណោយផលសម្រាប់អាជីវកម្ម និងសហគ្រាសបៃតង រួមបញ្ចូលទាំងសិប្បកម្មផលិតកម្ម និងផលិតផលសរីរាង្គ។

### គ. បរិយាបន្នសង្គម

- ផ្តល់លទ្ធភាពទទួលបានសេវាហេដ្ឋារចនាសម្ព័ន្ធសាធារណៈ និងសេវាមូលដ្ឋានចាំបាច់សម្រាប់សហគមន៍ងាយរងគ្រោះនៅក្នុងទីក្រុង ប្រកបដោយសមធម៌
- បង្កើនការផ្តល់សេវាអប់រំ ការអភិវឌ្ឍលំនៅឋានដែលមានតម្លៃសមរម្យ និងឱកាសការងារសមរម្យសម្រាប់ប្រជាជនក្រីក្រនៅទីក្រុង
- លើកកម្ពស់ការចូលរួមពីអ្នកពាក់ព័ន្ធទាំងអស់ ជាពិសេសក្រុមដែលងាយរងគ្រោះនៅក្នុងដំណើរការធ្វើសេចក្តីសម្រេចចិត្តអភិវឌ្ឍន៍ទីក្រុង។

### ឃ. អភិបាលកិច្ចក្រុង

- បង្កើនសមត្ថភាពកៀរគរធនធានហិរញ្ញវត្ថុរបស់ទីក្រុងដើម្បីអនុវត្តគម្រោងទីក្រុងនិរន្តរភាព
- ពង្រឹងសមត្ថភាពស្ថាប័ន និងធនធានមនុស្សនៅថ្នាក់ក្រុង
- លើកកម្ពស់ការចែករំលែកព័ត៌មាន ចំណេះដឹង និងបទពិសោធន៍ល្អៗរវាងទីក្រុង

## ១.៤. សកម្មភាពអាទិភាព

សកម្មភាពអាទិភាព ដែលបានកំណត់ និងស្នើឡើងខាងលើផ្អែកលើការពិគ្រោះយោបល់ជាមួយអាជ្ញាធរក្រុង ក៏ដូចជាការចែករំលែកចំណេះដឹង និងការត្រួតពិនិត្យតាមបទពិសោធន៍ពីអន្តរជាតិឧទាហរណ៍ដូចជា ការសិក្សាពីផែនការការអភិវឌ្ឍទីក្រុងនិរន្តរភាព និងគម្រោងអភិវឌ្ឍន៍ទីក្រុងសក្តានុពលបន្ទាប់ដែលមាននៅ ប្រទេសនេប៉ាល់, សេនេហ្គាល់ និងនៅប្រទេសរ៉្វាន់ដា[៦៨] ។ សកម្មភាពទាំងនេះអាចបែងចែកជារយៈពេលខ្លី (តិចជាង៥ឆ្នាំ) រយៈពេលមធ្យម (ពី៥ ទៅ១០ឆ្នាំ) ឬរយៈពេលវែង (ពី១០ ទៅ១៥ឆ្នាំ) និងរួមបញ្ចូលទាំងសកម្មភាពដែលត្រូវការការគាំទ្រនៅកម្រិតថ្នាក់ជាតិ និងថ្នាក់ខេត្ត។ សកម្មភាពសម្រាប់ថ្នាក់ជាតិ គឺដើម្បីបង្កើតបរិយាកាសសមស្របសម្រាប់ការអនុវត្តនៅរដ្ឋបាលក្រុងក្នុងការលើកកម្ពស់ការអភិវឌ្ឍបៃតង។ ដោយប្រើប្រាស់ការវិភាគពហុលក្ខណៈវិនិច្ឆ័យ (Multi Criteria Analysis) និងការពិគ្រោះយោបល់ពហុភាគីសកម្មភាពអាទិភាពទាំងនេះ ត្រូវបានបែងចែកជាក្រុមតាមកម្មវត្ថុទាំង ១២ ដូចមានរៀបរាប់ក្នុងតារាងខាងលើ។ គំនិតដែលដាក់ស្នើអាចអនុវត្តបាននៅតាមក្រុងជាច្រើននៃប្រទេសកម្ពុជា ដូច្នេះក្រុងនីមួយៗអាចជ្រើសរើសយកគំនិតដែលពាក់ព័ន្ធបំផុត ដើម្បីអនុវត្តដោយផ្អែកលើស្ថានភាពជាក់ស្តែង។[៦៩]

### កម្មវត្ថុទី១. ការតាក់តែង និងរៀបចំផែនការបែងចែកតំបន់ប្រកបដោយចីរភាព និងសមាហរណ៍ ក្នុងនោះមានការរៀបចំប្លង់គោល និងផែនការប្រើប្រាស់ដីនៅតំបន់ក្រុង (ជាប់ព្រំប្រទល់ក្រុង)

| ល.រ | សកម្មភាព | ស្ថានប័ននាំមុខ | រយៈពេល |
|---|---|---|---|
| ១ | រៀបចំប្លង់គោល (ផែនការមេ) និងផែនការប្រើប្រាស់ដី សម្រាប់ក្រុងដោយពង្រឹងទស្សនវិស័យនៃការអភិវឌ្ឍទីក្រុងនិរន្តរភាព | រដ្ឋបាលខេត្តក្រុង / ក្រសួង និងមន្ទីររៀបចំដែនដី នគរូបនីយកម្ម និងសំណង់ | រយៈពេលមធ្យម |
| ២ | កំណត់អាទិភាពតំបន់ជាប់ព្រំប្រទល់ក្រុងសម្រាប់កែលម្អហេដ្ឋារចនាសម្ព័ន្ធ | រដ្ឋបាលខេត្តក្រុង / ក្រសួងសាធារណការ និងដឹកជញ្ជូន | រយៈពេលមធ្យម |

[68] FORNEWA, "Rwanda shares green city development experience at Global Green Growth Week in South Korea," last modified July 9, 2016, http://www.fonerwa.org/blog/rwanda-shares-green-city-development-experience-global-green-growth-week-south-korea

[69] Each priority action requires a more in-depth study, as some need to have (pre)-feasibility studies on the current situation, socio-economic status, and geographical level in order to develop effective implementation plans and strategies. Priority actions that require external financing or investment from the private sector also need to be developed into bankable projects.

| | | | |
|---|---|---|---|
| ៣ | អនុវត្តការកំណត់ និងបែងចែកតំបន់ ដើម្បីថែរក្សា និងការពារច្រករបៀងបៃតង/ខៀវ[៧០] នៅក្រុង | រដ្ឋបាលខេត្តក្រុង / ក្រសួង និងមន្ទីររៀបចំដែនដី នគរូបនីយកម្ម និងសំណង់ | រយៈពេលមធ្យម |
| ៤ | រៀបចំបង្កើតផែនការមេប្រព័ន្ធដឹកជញ្ជូនក្នុងទីក្រុង រួមមាន សេវាដឹកជញ្ជូនសាធារណៈ | រដ្ឋបាលខេត្តក្រុង / ក្រសួងសាធារណការ និងដឹកជញ្ជូន | រយៈពេលវែង |
| ៥ | ពង្រីកតំបន់ និង/ឬកែលម្អចិញ្ចើមផ្លូវ ផ្លូវសម្រាប់អ្នកថ្មើរជើង និងផ្លូវសម្រាប់អ្នកជិះកង់នៅក្នុងទីក្រុង និងធ្វើការអនុវត្តច្បាប់ និងបទបញ្ញត្តិដែលពាក់ព័ន្ធ ដើម្បីមានចិញ្ចើមផ្លូវសម្រាប់អ្នកថ្មើរជើងដើរ | រដ្ឋបាលខេត្តក្រុង / ក្រសួងសាធារណការ និងដឹកជញ្ជូន | រយៈពេលមធ្យម |
| ៦ | ធ្វើការកំណត់ និងបែងចែកដីធ្លីដើម្បីការកែលម្អការមកតាំងទីលំនៅមិនស្របច្បាប់ (ដីបម្រុងក្នុងក្រុង) ដើម្បីធ្វើឱ្យប្រសើរឡើងសិទ្ធិកាន់កាប់ដីធ្លី និងការផ្តល់លំនៅឋានសមរម្យសម្រាប់ប្រជាពលរដ្ឋក្រីក្រក្នុងក្រុង | រដ្ឋបាលខេត្តក្រុង / ក្រសួង និងមន្ទីររៀបចំដែនដី នគរូបនីយកម្ម និងសំណង់ | រយៈពេលមធ្យម |
| ៧ | ធ្វើឱ្យប្រសើរឡើងនូវហេដ្ឋារចនាសម្ព័ន្ធកំពង់ផែក្នុងមូលដ្ឋាន និងប្រព័ន្ធដឹកជញ្ជូនដើម្បីផ្តល់ភាពងាយស្រួល និងសុវត្ថិភាពសម្រាប់ភ្ញៀវទេសចរណ៍និងប្រជាជនក្នុងតំបន់ | រដ្ឋបាលខេត្តក្រុង / ក្រសួងសាធារណការ និងដឹកជញ្ជូន | រយៈពេលវែង |
| ៨ | ធ្វើផែនការសម្រាប់ និងលើកកម្ពស់កិច្ចគាំពារតំបន់ប្រព័ន្ធអេកូឡូស៊ីនៅក្នុងក្រុង | រដ្ឋបាលខេត្តក្រុង / ក្រសួងបរិស្ថាន | រយៈពេលមធ្យម |
| ៩ | ដាក់ឱ្យអនុវត្តការកំណត់ (បែងចែក) តំបន់ឧស្សាហកម្មដែលមានលក្ខណៈច្បាស់លាស់ដើម្បីញែកតំបន់អភិវឌ្ឍន៍លំនៅឋានពីសកម្មភាពឧស្សាហកម្ម | រដ្ឋបាលខេត្តក្រុង / ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ | រយៈពេលមធ្យម |

## កម្មវត្ថុទី២ ៖ បង្កើតហេដ្ឋារចនាសម្ព័ន្ធទីក្រុងនិរន្តរភាពដែលរួមមានប្រព័ន្ធលូរំដោះទឹកកខ្វក់ និងទឹកភ្លៀង ប្រព័ន្ធប្រព្រឹត្តិកម្មទឹកកខ្វក់ ការគ្រប់គ្រងសំរាម ការផ្គត់ផ្គង់ទឹក និងប្រព័ន្ធដឹកជញ្ជូន

| ល.រ | សកម្មភាព | ស្ថាប័ននាំមុខ | រយៈពេល |
|---|---|---|---|
| ១ | កែលម្អការគ្រប់គ្រងសំរាមក្នុងក្រុងតាមរយៈការបង្កើនប្រតិបត្តិការប្រមូល និងពង្រីកតំបន់គ្របដណ្តប់នៃការប្រមូលសំរាម និងដោយមានការចូលរួមរបស់សហគមន៍ | រដ្ឋបាលខេត្តក្រុង / ក្រុមប្រឹក្សាជាតិអភិវឌ្ឍន៍ដោយចីរភាព / ក្រសួងបរិស្ថាន / ក្រុមហ៊ុនប្រមូលសំរាម | រយៈពេលខ្លី |
| ២ | កែលម្អទីលានចាក់សំរាមដែលមានស្រាប់ ដើម្បីគ្រប់គ្រងផលប៉ះពាល់ដល់បរិស្ថានមានដូចជាឡចំហាយ និងឧស្ម័ន និងបង្កើតបន្ថែមនូវទីលានចាក់សំរាមថ្មីដែលមានបទដ្ឋានបច្ចេកទេស | រដ្ឋបាលខេត្តក្រុង / ក្រុមប្រឹក្សាជាតិអភិវឌ្ឍន៍ដោយចីរភាព / ក្រសួងសាធារណការ និងដឹកជញ្ជូន | រយៈពេលខ្លី |

[70] “ច្រករបៀងបៃតង” គឺសំដៅទៅលើទំនាក់ទំនងនៃការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធសាធារណៈតាមវិស័យក្នុងទីក្រុង ឬតំបន់ទីប្រជុំជន ឧទាហរណ៍ផ្លូវថ្នល់ សួនច្បារតាមដងផ្លូវ ជាដើម។ល។ “ច្រករបៀងខៀវ” សំដៅទៅដល់ការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធសាធារណៈនៅក្នុងទីក្រុង ឬតំបន់ទីប្រជុំជនទាំងឡាយណាពាក់ព័ន្ធទៅនឹងចរន្តទឹក និងលំហូរនៃទឹកទាំងទឹកក្រោមដី និងលើដី។

| | | | |
|---|---|---|---|
| ៣ | បង្កើតហេដ្ឋារចនាសម្ព័ន្ធញែក និងកែច្នៃសំណល់រឹង (ប្រភេទកែវ ដប ជ័រប្លាស្ទិក) និងសំណល់សរីរាង្គ | រដ្ឋបាលខេត្តក្រុង / ក្រុមប្រឹក្សាជាតិអភិវឌ្ឍន៍ដោយចីរភាព / ក្រសួងបរិស្ថាន / ក្រសួងសាធារណការ និងដឹកជញ្ជូន / ក្រុមហ៊ុនប្រមូលសំរាម | រយៈពេលខ្លី |
| ៤ | សម្របសម្រួលឱ្យមានការចូលរួមពីសហគមន៍នៅក្នុងការកែច្នៃសម្រាប់ការប្រើប្រាស់ឡើងវិញ និងការញែកសំរាមនៅតាមគេហដ្ឋាន និងទីតាំងអាជីវកម្ម តាមរយៈការផ្តល់គ្រឿងលើកទឹកចិត្ត។ អប់រំសហគមន៍អំពីការកាត់បន្ថយកាកសំណល់ (ឧទាហរណ៍ កាត់បន្ថយការប្រើប្រាស់របស់ដែលប្រើប្រាស់ហើយដូចជា ដប និងថង់ប្លាស្ទិក) | រដ្ឋបាលខេត្តក្រុង / ក្រសួងបរិស្ថាន / ក្រសួងអប់រំ យុវជន និងកីឡា | រយៈពេលខ្លី |
| ៥ | បង្កើតរោងចក្រផលិតថាមពលពីសំរាម (ដូចជាម៉ាស៊ីនរំលាយសារធាតុអាណាឡូហ្សិក និងបដិសេធចំពោះការប្រើប្រាស់ប្រេងដែលបានមកពីការដុតឧស្ម័នជាមួយ និងការគ្រប់គ្រងបរិស្ថានដ៏សមស្រប) | រដ្ឋបាលខេត្តក្រុង / ក្រសួងរ៉ែ និងថាមពល / ក្រសួងបរិស្ថាន / ក្រុមហ៊ុនឯកជន | រយៈពេលវែង |
| ៦ | បង្កើតប្រព័ន្ធប្រព្រឹត្តិកម្មទឹកកខ្វក់បែបវិមជ្ឈការ (ខ្នាតតូចបែបវិមជ្ឈការ) នៅក្នុងតំបន់ជាយក្រុង (តាមតំបន់) | រដ្ឋបាលខេត្តក្រុង / ក្រសួងសាធារណការ និងដឹកជញ្ជូន | រយៈពេលខ្លី |
| ៧ | បង្កើត និងកែលម្អប្រព័ន្ធរំដោះទឹកភ្លៀង និងប្រព័ន្ធលូទឹកកខ្វក់ និងរៀបចំការគ្រប់គ្រងប្រព័ន្ធអាងស្តុកលាមក (feacal sludge) | រដ្ឋបាលខេត្តក្រុង / ក្រសួងសាធារណការ និងដឹកជញ្ជូន | រយៈពេលខ្លី |
| ៨ | សាងសង់ ឬពង្រីកតំបន់គ្របដណ្តប់នៃប្រព័ន្ធប្រព្រឹត្តិកម្មទឹកកខ្វក់រួម (ខ្នាតធំ) នៅតំបន់ដែលមានប្រជាជនរស់នៅច្រើន | រដ្ឋបាលខេត្តក្រុង / ក្រសួងសាធារណការ និងដឹកជញ្ជូន | រយៈពេលមធ្យម |
| ៩ | ដាក់កំហិតឱ្យតំបន់ឧស្សាហកម្ម និងពាណិជ្ជកម្ម ធ្វើការសាងសង់ប្រព័ន្ធប្រព្រឹត្តិកម្មទឹកកខ្វក់បឋមរបស់ខ្លួន (មុននឹងបញ្ចេញទៅក្នុងប្រព័ន្ធរួម) | រដ្ឋបាលខេត្តក្រុង / ក្រសួងសាធារណការ និងដឹកជញ្ជូន / ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ / ម្ចាស់ទីតាំងអាជីវកម្ម | រយៈពេលខ្លី |
| ១០ | បង្កើតហេដ្ឋារចនាសម្ព័ន្ធដឹកជញ្ជូនប្រកបដោយចីរភាព នៅក្នុងក្រុង រួមមានសេវាដឹកជញ្ជូនសាធារណៈ និងការប្រើប្រាស់រថយន្តអគ្គិសនី | រដ្ឋបាលខេត្តក្រុង / ក្រសួងសាធារណការ និងដឹកជញ្ជូន | រយៈពេលវែង |
| ១១ | សិក្សា និងរៀបចំចំណតរថយន្តក្នុងក្រុង និងការបង្កើតបទដ្ឋាននៃការចតរថយន្តតាមដងផ្លូវ | រដ្ឋបាលក្រុង / ខេត្ត / ក្រសួង និងមន្ទីរសាធារណការ និងដឹកជញ្ជូន | រយៈពេលមធ្យម |
| ១២ | កែលម្អ និងរៀបចំចិញ្ចើមផ្លូវសម្រាប់អ្នកថ្មើរជើង | រដ្ឋបាលក្រុង / ក្រសួង និងមន្ទីរសាធារណការ និងដឹកជញ្ជូន | រយៈពេលមធ្យម |
| ១៣ | ពង្រីកបណ្តាញប្រព្រឹត្តិកម្ម និងផ្គត់ផ្គង់ទឹកស្អាត | ភ្នាក់ងារ / រដ្ឋាករ | រយៈពេលខ្លី |
| ១៤ | បង្កើនការអភិវឌ្ឍផ្លូវថ្នល់ ដែលធន់នឹងការប្រែប្រួលអាកាសធាតុ | រដ្ឋបាលខេត្តក្រុង / ក្រសួងសាធារណការ និងដឹកជញ្ជូន | រយៈពេលមធ្យម |

## កម្មវត្ថុទី៣៖ បង្កើតប្រព័ន្ធគ្រប់គ្រងដែលមានប្រសិទ្ធភាពដើម្បីកាត់បន្ថយហានិភ័យគ្រោះថ្នាក់ បន្សាំទៅនឹងការប្រែប្រួលអាកាសធាតុ និងត្រៀមបង្ការឆ្លើយតបទៅនឹងគ្រោះមហន្តរាយ

| ល.រ | សកម្មភាព | ស្ថាប័ននាំមុខ | រយៈពេល |
|---|---|---|---|
| ១ | លើកកម្ពស់ និងបង្កើតឱ្យមានការប្រមូលទិន្នន័យប្រចាំថ្ងៃដើម្បីតាមដានស្ថានភាពគុណភាពខ្យល់នៅកម្រិតក្រុង | រដ្ឋបាលខេត្តក្រុង / ក្រសួង និងមន្ទីរបរិស្ថាន | រយៈពេលវែង |
| ២ | បង្កើតផែនការគ្រប់គ្រងគ្រោះមហន្តរាយជាក់លាក់ក្នុងកម្រិតក្រុង និងបង្កើតក្រុមឆ្លើយតបរហ័សពេលមានគ្រោះមហន្តរាយ | រដ្ឋបាលខេត្តក្រុង / គណៈកម្មការជាតិគ្រប់គ្រងគ្រោះមហន្តរាយ / សាខាកាកបាទក្រហមខេត្ត | រយៈពេលមធ្យម |
| ៣ | បញ្ជ្រាបការបន្សាំទៅនឹងការប្រែប្រួលអាកាសធាតុទៅក្នុងការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធរបស់ក្រុង ( ឧទាហរណ៍ សាងសង់ផ្លូវដែលធន់ទៅនឹងការប្រែប្រួលអាកាសធាតុ បង្កើតតំបន់ការពារប្រព័ន្ធអេកូឡូស៊ីនៅតាមតំបន់ឆ្នេរ ) | រដ្ឋបាលខេត្តក្រុង / ខេត្ត ក្រសួង / មន្ទីរសាធារណការ និងដឹកជញ្ជូន / ក្រសួងមន្ទីរបរិស្ថាន | រយៈពេលខ្លី |
| ៤ | ដាក់ឱ្យអនុវត្តផែនការកាត់បន្ថយហានិភ័យពីគ្រោះមហន្តរាយតាមសហគមន៍នៅកម្រិតឃុំ និងភូមិដើម្បីត្រៀមការពារគ្រោះថ្នាក់ផ្សេងៗ (អគ្គីភ័យ ទឹកជំនន់ ព្យុះ ។ល។) | រដ្ឋបាលខេត្តក្រុង / គណៈកម្មការជាតិគ្រប់គ្រងគ្រោះមហន្តរាយ | រយៈពេលវែង |
| ៥ | ការពារសហគមន៍ពីទឹកជំនន់បង្កឡើងដោយការអភិវឌ្ឍតាមរយៈការបង្កើតប្រព័ន្ធគ្រប់គ្រងទឹកជំនន់ ( តំបន់ការពារប្រព័ន្ធអេកូឡូស៊ី តំបន់ដីសើម និងច្រករបៀងខៀវ/បៃតង ) | រដ្ឋបាលខេត្តក្រុង / ក្រសួង / មន្ទីរបរិស្ថាន | រយៈពេលខ្លី |
| ៦ | បង្កើនការដាំដើមឈើតាមដងផ្លូវ និងទីធ្លាសាធារណៈនៅក្នុងទីក្រុងដើម្បីកាត់បន្ថយការឡើងកម្តៅខ្ពស់ក្នុងក្រុង និងដើម្បីសោភ័ណភាពក្រុង | រដ្ឋបាលខេត្តក្រុង / ក្រសួងបរិស្ថាន | រយៈពេលខ្លី |
| ៧ | ពង្រឹងកងអគ្គីភ័យក្នុងមូលដ្ឋាន និងសេវាសង្គ្រោះបន្ទាន់ផ្សេងៗ និងតម្រូវឱ្យគ្រប់អគារទាំងអស់មានផែនការសង្គ្រោះបន្ទាន់ពេលមានអគ្គីភ័យ | រដ្ឋបាលខេត្តក្រុង / គណៈកម្មការជាតិគ្រប់គ្រងគ្រោះមហន្តរាយ | រយៈពេលខ្លី |
| ៨ | អភិវឌ្ឍលំនៅឋានសម្រាប់ពលរដ្ឋក្រីក្រ ដើម្បីពង្រឹងភាពធន់នៃគេហដ្ឋានទាំងនោះទៅនឹងហានិភ័យទឹកជំនន់ និងគ្រោះធម្មជាតិផ្សេងៗទៀត | រដ្ឋបាលខេត្តក្រុង / ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ | រយៈពេលមធ្យម |
| ៩ | ពង្រីក/អភិវឌ្ឍច្រកផ្លូវតូចៗនៅក្នុងទីក្រុងដើម្បីឱ្យសេវាសង្គ្រោះបន្ទាន់អាចចូលទៅដល់សហគមន៍ | រដ្ឋបាលក្រុង | រយៈពេលខ្លី |

## កម្មវត្ថុទី៤៖ បង្កើតទីផ្សារថាមពលកកើតឡើងវិញ និងប្រសិទ្ធភាពថាមពលនៅក្នុងទីក្រុង ដែលអាចប្រើប្រាស់ នៅក្នុងវិស័យឧស្សាហកម្ម សំណង់អគារ និងផ្ទះសម្បែងប្រជាពលរដ្ឋ

| ល.រ | សកម្មភាព | ស្ថាប័ននាំមុខ | រយៈពេល |
|---|---|---|---|
| ១ | ដំឡើងអំពូលភ្លើងតាមដងផ្លូវដែលមានប្រសិទ្ធភាពថាមពល (ឧទាហរណ៍ អំពូលភ្លើងដើរដោយថាមពលពន្លឺព្រះអាទិត្យ អំពូលប្រភេទអិលអ៊ីឌី (LED) | រដ្ឋបាលខេត្ត និងក្រុង / ក្រសួងរ៉ែ និងថាមពល | រយៈពេលខ្លី |
| ២ | លើកកម្ពស់ការប្រើប្រាស់ថាមពលកកើតឡើងវិញនៅតាមផ្ទះ សម្រាប់ប្រើជាថាមពលកម្តៅ និងសម្រាប់ការដាំស្ល(ដូចជា ការប្រើប្រាស់ឡដែលគិតគូរពីបរិស្ថាន ម៉ាស៊ីនទឹកក្តៅ ប្រើថាមពលសូឡា បន្ទះសូឡាលើដំបូល) | រដ្ឋបាលខេត្ត ក្រុង / ក្រសួងរ៉ែ និងថាមពល / វិស័យឯកជន | រយៈពេលខ្លី |
| ៣ | បង្កើតការប្រើប្រាស់ថាមពលកកើតឡើងវិញសម្រាប់អាជីវកម្ម ជាពិសេសសម្រាប់សណ្ឋាគារ និងភោជនីយដ្ឋាន | រដ្ឋបាលក្រុង / ក្រសួងរ៉ែ និងថាមពល / ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ | រយៈពេលមធ្យម |
| ៤ | ដាក់ឱ្យអនុវត្តនូវវិធានការប្រសិទ្ធភាពថាមពល និងការប្រើប្រាស់ថាមពលកកើតឡើងវិញតាមអគារសាធារណៈ | រដ្ឋបាលខេត្តក្រុង /ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ / ក្រសួងរ៉ែ និងថាមពល / ក្រសួងបរិស្ថាន | រយៈពេលមធ្យម |
| ៥ | កំណត់ និងពង្រឹងស្តង់ដារសម្រាប់ប្រសិទ្ធភាពថាមពលសម្រាប់សម្ភារប្រើប្រាស់ និងគ្រឿងម៉ាស៊ីន | ក្រសួងរ៉ែ និងថាមពល / ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ / ក្រសួងបរិស្ថាន | រយៈពេលមធ្យម |
| ៦ | ជំរុញការប្រើប្រាស់មធ្យោបាយដឹកជញ្ជូនដែលមិនប្រើឥន្ធនៈផូស៊ីល ដូចជារថយន្តក្រុងអគ្គិសនី រថយន្តតូចអគ្គិសនី និងម៉ូតូកង់បី ដែលប្រើថាមពលសូឡា និងតាមរយៈការកែលម្អតំបន់ថ្មើរជើង និងផ្លូវសម្រាប់អ្នកជិះកង់ | រដ្ឋបាលខេត្តក្រុង / ក្រសួងសាធារណការ និងដឹកជញ្ជូន | រយៈពេលមធ្យម |
| ៧ | បង្កើតគម្រោងថាមពលកកើតឡើងវិញក្រៅបណ្តាញ និងតាមបណ្តាញតូចៗ (សូឡា ជីវម៉ាស ខ្យល់។ល។) | រដ្ឋបាលក្រុង / ក្រសួងរ៉ែ និងថាមពល / អគ្គិសនីកម្ពុជា | រយៈពេលមធ្យម |
| ៨ | លើកកម្ពស់ប្រសិទ្ធភាពថាមពលនៅក្នុងសកម្មភាពឧស្សាហកម្ម ជាពិសេសវិស័យកាត់ដេរ អាហារ និងភេសជ្ជៈ ការផលិតទឹកកក ថ្ម និងស៊ីម៉ងត៍តាមរយៈការជំរុញ និងការលើកកម្ពស់ចំណេះដឹងសម្រាប់ពោងចក្រសន្សំសំចៃប្រសិទ្ធភាពថាមពល | ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ / វិស័យឯកជន | រយៈពេលខ្លី |

| | | | |
|---|---|---|---|
| ៩ | លើកកម្ពស់ការប្រើប្រាស់បច្ចេកវិទ្យាស្អាត និងការអនុវត្តឧស្សាហកម្ម កាន់តែល្អប្រសើរដើម្បីរួមចំណែកកាត់បន្ថយការប្រើប្រាស់ថាមពល និងកាត់បន្ថយការពឹងផ្អែកទៅលើការប្រើអុសក្នុងដំណើរការឧស្សាហកម្មផលិតកម្ម | ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ | រយៈពេលខ្លី |
| ១០ | លើកទឹកចិត្តដល់អាជីវកម្មដែលប្រើប្រាស់បច្ចេកវិទ្យា និងការអនុវត្តបៃតង ដូចជាវិនិយោគទៅលើប្រសិទ្ធភាពថាមពល និងថាមពលកកើតឡើងវិញ (ដូចជា ពានរង្វាន់បៃតង ជាដើម) | រដ្ឋបាលខេត្តក្រុង / ក្រសួងរ៉ែ និងថាមពល / ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ | រយៈពេលខ្លី |

## កម្មវត្ថុទី៥៖ ពង្រឹងអេកូទេសចរណ៍នៅក្នុងទីក្រុង តាមរយៈការការពារ និងលើកកម្ពស់បេតិកភណ្ឌ វប្បធម៌ និងធនធានធម្មជាតិ

| ល.រ | សកម្មភាព | ស្ថានប័ននាំមុខ | រយៈពេល |
|---|---|---|---|
| ១ | ពង្រឹងការការពារតំបន់ទាក់ទាញទេសចរណ៍វប្បធម៌ (ដូចជាអគារបេតិកភណ្ឌ) និងទេសចរណ៍ធម្មជាតិ | រដ្ឋបាលខេត្តក្រុង / ក្រសួងទេសចរណ៍ | រយៈពេលខ្លី |
| ២ | ជំរុញការផ្សព្វផ្សាយឱ្យប្រទេសកម្ពុជាក្លាយទៅជាគោលដៅអេកូទេសចរណ៍សកល ដើម្បីទាក់ទាញភ្ញៀវទេសចរ និងការវិនិយោគអន្តរជាតិ ក្នុងវិស័យទេសចរណ៍ | រដ្ឋបាលខេត្តក្រុង / ក្រសួងទេសចរណ៍ | រយៈពេលខ្លី |
| ៣ | បង្កើត និងអនុវត្តយុទ្ធសាស្ត្រទេសចរណ៍ធម្មជាតិដែលមានភាពគ្រប់ជ្រុងជ្រោយ ក្នុងនោះរួមមានផែនការយុទ្ធសាស្ត្រផ្សព្វផ្សាយទីផ្សាររបស់ក្រុងសក្តានុពលទេសចរណ៍ (ក្រុងព្រះសីហនុ ក្រុងសៀមរាប ក្រុងបាត់ដំបង ។ល។) | រដ្ឋបាលខេត្តក្រុង / ក្រសួងទេសចរណ៍ / វិស័យឯកជន | រយៈពេលមធ្យម |
| ៤ | បង្កើតបណ្តាញក្រុងក្នុងវិស័យអេកូទេសចរណ៍ ទេសចរណ៍វប្បធម៌ និងធម្មជាតិដោយចីរភាព ដើម្បីផ្លាស់ប្តូរបទពិសោធន៍ និងអនុវត្តគំនិតផ្តួចផ្តើមលើកកម្ពស់ការផ្សព្វផ្សាយរួមគ្នា | រដ្ឋបាលខេត្តក្រុង / ក្រសួងទេសចរណ៍ | រយៈពេលខ្លី |
| ៥ | រៀបចំ និងអនុវត្តគោលនយោបាយ និងនីតិវិធីស្តីពីការវិនិយោគលើវិស័យអេកូទេសចរណ៍ | រដ្ឋបាលខេត្តក្រុង / ក្រសួងទេសចរណ៍ | រយៈពេលមធ្យម |
| ៦ | បង្កើតហេដ្ឋារចនាសម្ព័ន្ធ / សម្ភារបរិក្ខារគាំទ្រអេកូទេសចរណ៍ | រដ្ឋបាលខេត្តក្រុង / ក្រសួងទេសចរណ៍ | រយៈពេលមធ្យម |
| ៧ | កែលម្អតាមសណ្ឋាគារឱ្យមានភាពបៃតងដើម្បីលើកកម្ពស់ប្រសិទ្ធភាពធនធាន (កាត់បន្ថយការប្រើប្រាស់ទឹក ការប្រើប្រាស់អគ្គិសនី និងការប្រើប្រាស់សម្ភារសំណង់ក្នុងស្រុកកាន់តែច្រើនជាងមុន) និងការគ្រប់គ្រងសំរាមដោយនិរន្តរភាព | រដ្ឋបាលខេត្តក្រុង / ក្រសួងទេសចរណ៍ / ក្រសួងបរិស្ថាន / ក្រុមប្រឹក្សាជាតិអភិវឌ្ឍន៍ដោយចីរភាព | រយៈពេលខ្លី |
| ៨ | កែលម្អការតាមដានគុណភាពបរិស្ថាន ដូចជាគុណភាពទឹក និងជីវចម្រុះក្នុងមូលដ្ឋាន និងផ្សព្វផ្សាយលទ្ធផលដល់សហគមន៍មូលដ្ឋាន និងភ្ញៀវទេសចរ | រដ្ឋបាលខេត្តក្រុង / ក្រសួងទេសចរណ៍ / ក្រសួងបរិស្ថាន / ក្រុមប្រឹក្សាជាតិអភិវឌ្ឍន៍ដោយចីរភាព | រយៈពេលខ្លី |

## កម្មវត្ថុទី៦ ៖ បង្កើតបរិយាកាសអំណោយផលសម្រាប់អាជីវកម្ម និងសហគ្រាសបៃតង ក្នុងនោះរួមមាន វិស័យសិប្បកម្ម ផលិតកម្ម និងផលិតផលសរីរាង្គ

| ល.រ | សកម្មភាព | ស្ថាប័ននាំមុខ | រយៈពេល |
|---|---|---|---|
| ១ | ពង្រឹងចលនា "ភូមិមួយ ផលិតផលមួយ"[៧១] ដោយផ្តោតលើផលិតផលសិប្បកម្មបៃតង | រដ្ឋបាលខេត្តក្រុង / ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ | រយៈពេលខ្លី |
| ២ | បង្កើនទីផ្សារកសិផលសរីរាង្គ | រដ្ឋបាលខេត្តក្រុង / ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ | រយៈពេលខ្លី |
| ៣ | គាំទ្រសហគ្រាសបៃតងធុនតូច និងមធ្យម(SME) ដើម្បីមានលទ្ធភាពខ្ពស់ជាងមុនក្នុងការទទួលបានហិរញ្ញវត្ថុដើម្បីអភិវឌ្ឍន៍ផលិតផល និងសេវាកម្មបៃតង (ឧទាហរណ៍បង្កើតច្រកចេញចូលតែមួយដើម្បីទទួលការប្រឹក្សាអាជីវកម្ម) | រដ្ឋបាលខេត្តក្រុង / ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ | រយៈពេលខ្លី |
| ៤ | សិក្សា និងស្វែងរកឱកាសបង្កើតតំបន់សេដ្ឋកិច្ចពិសេសដែលប្រកាន់ខ្ជាប់នូវការទទួលខុសត្រូវសង្គម និងបរិស្ថាន ឧទាហរណ៍ការលើកកម្ពស់ការប្រើប្រាស់ថាមពលកកើតឡើងវិញ ពង្រឹងប្រសិទ្ធភាពថាមពលនៅក្នុងសេវាកម្មអគារ និងដំណើរការផលិតកម្ម ការត្រួតពិនិត្យការបំពុលទឹក និងការគ្រប់គ្រងសំណល់រឹង/រាវ ព្រមទាំងការគិតគូរពីសុខុមាលភាពបុគ្គលិក | រដ្ឋបាលខេត្តក្រុង ក្រសួងបរិស្ថាន / ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា / ក្រសួង និងមន្ទីរ ឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ / ក្រសួងរ៉ែ និងថាមពល | រយៈពេលខ្លី |
| ៥ | បង្កើតគោលនយោបាយដើម្បីគាំទ្រការដាំដុះដំណាំសរីរាង្គនៅក្រុង និងជំរុញផលិតកម្ម សិប្បកម្មក្នុងស្រុក (ចូលរួមបង្កើតស្លាកសញ្ញាលើផលិតផលសរីរាង្គ) | ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ / ក្រុមប្រឹក្សាជាតិអភិវឌ្ឍន៍ដោយចីរភាព | រយៈពេលមធ្យម |
| ៦ | ជំរុញ និងសម្របសម្រួលលើផលិតផលកសិកម្មកែច្នៃដែលមានគុណតម្លៃបន្ថែម | រដ្ឋបាលខេត្តក្រុង / ក្រសួងពាណិជ្ជកម្ម | រយៈពេលមធ្យម |
| ៧ | បង្កើតបទប្បញ្ញត្តិ និងគ្រឿងលើកទឹកចិត្តដើម្បីគាំទ្រជំរុញការវិនិយោគ និងការផ្ទេរបច្ចេកវិទ្យាអភិវឌ្ឍន៍បៃតង | ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ | រយៈពេលមធ្យម |
| ៨ | ធ្វើការបណ្តុះបណ្តាលវិជ្ជាជីវៈបន្ថែម លើវិស័យបច្ចេកវិទ្យា និងអាជីវកម្មបៃតងនៅតាមសាកលវិទ្យាល័យ និងមជ្ឈមណ្ឌលបណ្តុះបណ្តាលនានា (ឧទាហរណ៍ អ្នកបច្ចេកទេសថាមពលពន្លឺព្រះអាទិត្យ ប្រសិទ្ធភាពថាមពល លិខិតបញ្ជាក់ផលិតផលបៃតង) | រដ្ឋបាលខេត្តក្រុង / ក្រសួងអប់រំ យុវជន និងកីឡា / ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ | រយៈពេលខ្លី |

[71] The One Village One Product movement is an economic concept and approach in transforming local products into competitive products in local, national, and global markets. The concept started in Oita Prefecture, Japan, in 1979, and became one of the successful regional economic programs. The RGC, as one of the ASEAN members, has embraced this concept for Cambodia's local products since 2010 and developed the National Policy on Promotion of One Village, One Product Movement 2016–2026, which aims to promote the development of the production chain for village- or community-based goods or services, including the production, processing, packaging, and development of one or more products to create added value.

## កម្មវត្ថុទី៧៖ ផ្តល់លទ្ធភាពប្រកបដោយសមធម៌ក្នុងការទទួលបានហេដ្ឋារចនាសម្ព័ន្ធសាធារណៈ និងសេវាជាមូលដ្ឋានសម្រាប់សហគមន៍ក្រីក្រ និងងាយរងគ្រោះ

| ល.រ | សកម្មភាព | ស្ថាប័ននាំមុខ | រយៈពេល |
|---|---|---|---|
| ១ | កំណត់ និងដោះស្រាយចន្លោះខ្វះខាតនៅក្នុងការផ្តល់សេវាសាធារណៈ (សេវាគ្រប់គ្រងសំណល់ លំនៅឋាន ការប្រមូលសំរាម ការផ្គត់ផ្គង់អគ្គិសនី ។ល។) ដល់តំបន់សហគមន៍ក្រីក្រ និងងាយរងគ្រោះ | រដ្ឋបាលខេត្តក្រុង / ក្រសួងពាក់ព័ន្ធ | រយៈពេលខ្លី |
| ២ | បង្កើនកម្មវិធីសាងសង់លំនៅឋានដែលមានតម្លៃសមរម្យ និងផ្តល់សេវាសង្គមដល់សហគមន៍ក្រីក្ររស់នៅក្នុងក្រុង | រដ្ឋបាលខេត្តក្រុង / ក្រសួងពាក់ព័ន្ធ | រយៈពេលមធ្យម |
| ៣ | បង្កើតគម្រោងប្រមូលសំរាម និងអនាម័យតាមសហគមន៍នៅក្នុងតំបន់សំណង់មិនរៀបរយក្នុងក្រុង | រដ្ឋបាលខេត្តក្រុង / ក្រសួងពាក់ព័ន្ធ | រយៈពេលខ្លី |
| ៤ | បង្កើតផែនការធានារ៉ាប់រងសង្គមដែលនឹងធានាថា ពលរដ្ឋម្នាក់ៗមានសិទ្ធិស្មើៗគ្នាក្នុងការទទួលបានសេវាមូលដ្ឋានដូចជាសេវាថែទាំសុខភាព | រដ្ឋបាលខេត្តក្រុង / ក្រសួងសង្គមកិច្ច / ក្រសួងអប់រំ | រយៈពេលមធ្យម |
| ៥ | រៀបចំផែនការអភិវឌ្ឍន៍តំបន់សម្រាប់ប្រជាពលរដ្ឋដែលបានមកតាំងទីលំនៅថ្មី រួមមានការអភិវឌ្ឍលំនៅឋានមានតម្លៃសមរម្យ មានថាមពលអគ្គិសនីគ្រប់គ្រាន់ ទឹកស្អាតប្រើប្រាស់ មានប្រព័ន្ធប្រព្រឹត្តិកម្មទឹកកខ្វក់/អនាម័យ និងសេវាដឹកជញ្ជូន មានទីធ្លាបៃតង និងមានប្រព័ន្ធការពារជំនន់ | រដ្ឋបាលខេត្តក្រុង / ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ | រយៈពេលមធ្យម |
| ៦ | អប់រំប្រជាពលរដ្ឋនៅក្នុងសហគមន៍ក្រីក្រ និងងាយរងគ្រោះអំពីសិទ្ធិទទួលបានសេវាកម្មសាធារណៈដែលមាន និងមានលទ្ធភាពចូលទៅរកសេវាកម្មទាំងនោះ ដើម្បីលើកកម្ពស់បន្ថែមដល់សមធម៌សង្គម | រដ្ឋបាលខេត្តក្រុង / ក្រសួងអប់រំ យុវជន និងកីឡា | រយៈពេលមធ្យម |
| ៧ | ដាក់ឱ្យអនុវត្តកម្មសិទ្ធិដីធ្លី និងការជួលដីសមូហភាព ដែលជួយសម្រួលដល់ការផ្តល់កម្មសិទ្ធិដីតាមសហគមន៍ និងបង្កើនលទ្ធភាពទទួលបានលំនៅឋានសម្រាប់ពលរដ្ឋក្រីក្រក្នុងក្រុង | រដ្ឋបាលខេត្តក្រុង / ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ | រយៈពេលខ្លី |

## កម្មវត្ថុទី៨៖ ផ្តល់ឱកាសអប់រំ និងការងារសម្រាប់ពលរដ្ឋក្រីក្រ និងងាយរងគ្រោះក្នុងទីក្រុង

| ល.រ | សកម្មភាព | ស្ថាប័ននាំមុខ | រយៈពេល |
|---|---|---|---|
| ១ | បង្កើតមណ្ឌលសុខភាព និងថែទាំកុមារ ដើម្បីឱ្យឪពុកម្តាយពួកគេអាចចូលរួមការបណ្តុះបណ្តាលជំនាញ ឬទៅធ្វើការ | រដ្ឋបាលខេត្តក្រុង / ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ | រយៈពេលខ្លី |
| ២ | បង្កើនការវិនិយោគទៅលើប្រព័ន្ធអប់រំក្រៅប្រព័ន្ធដើម្បីផ្តល់អត្ថប្រយោជន៍ដល់ពលរដ្ឋក្រីក្រក្នុងទីក្រុង ដូចជាផ្តល់ការបណ្តុះបណ្តាលជំនាញ/ភាសាដល់ពលរដ្ឋក្រីក្រក្នុងទីក្រុង | រដ្ឋបាលខេត្តក្រុង / ក្រសួងមន្ទីរអប់រំ យុវជន និងកីឡា | រយៈពេលខ្លី |
| ៣ | សម្របសម្រួលសេវាដឹកជញ្ជូនសាធារណៈ និងសេវាដឹកជញ្ជូនផ្សេងៗទៀត ពីតំបន់លំនៅឋានក្រីក្រក្នុងក្រុង ទៅកាន់ទីកន្លែងធ្វើការងារ | រដ្ឋបាលខេត្តក្រុង / ក្រសួងសាធារណការ និងដឹកជញ្ជូន | រយៈពេលខ្លី |
| ៤ | ធ្វើការបណ្តុះបណ្តាលអំពីអាជីវកម្មដើម្បីអភិវឌ្ឍន៍ជំនាញផ្នែកបដិសណ្ឋារកិច្ច (រួមទាំង សេវាកម្មទេសចរណ៍) ជំនាញផ្នែកសិប្បកម្ម កសិកម្មសរីរាង្គ ព្រមទាំងការគ្រប់គ្រងសហគ្រាសធុនតូច និងមធ្យម គណនេយ្យ ។ល។ | រដ្ឋបាលខេត្តក្រុង / ក្រសួងទេសចរណ៍ / ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ / ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ | រយៈពេលខ្លី |
| ៥ | បង្កើតឱកាសការងារសម្រាប់ពលរដ្ឋក្រីក្រក្នុងទីក្រុងផ្នែកណាមួយនៃគម្រោងវិនិយោគសាធារណៈ និងឯកជន ដែលរួមមានសំណង់ ហេដ្ឋារចនាសម្ព័ន្ធ ការងារក្នុងប្រព័ន្ធគ្រប់គ្រងសំរាម ទេសចរណ៍ និងខ្សែសង្វាក់ផលិតកម្ម ។ល។ | រដ្ឋបាលខេត្តក្រុង / ក្រសួងពាក់ព័ន្ធ | រយៈពេលមធ្យម |
| ៦ | សម្របសម្រួល និងជំរុញការងារធ្វើនៅផ្ទះផ្ទាល់ ឧទាហរណ៍ផ្នែកសិប្បកម្ម និងផលិតកម្ម ដើម្បីបង្កើនលទ្ធភាពទទួលបានការងារសម្រាប់ស្ត្រី | រដ្ឋបាលខេត្តក្រុង / ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ / ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ / ក្រសួងកិច្ចការនារី | រយៈពេលខ្លី |
| ៧ | រៀបចំឱ្យមានការចូលរួមពីវិស័យឯកជន (អ្នកបើកបររ៉ឺម៉កកង់បី អ្នកនាំភ្ញៀវ) ដើម្បីលើកកម្ពស់លក្ខខណ្ឌការងារ និងទទួលបានសេវាល្អជាងមុនសម្រាប់វិស័យទេសចរណ៍ | រដ្ឋបាលខេត្ត និងក្រុង / ក្រសួងទេសចរណ៍ | រយៈពេលខ្លី |
| ៨ | ជំរុញ និងផ្តល់ការលើកទឹកចិត្តដល់អាជីវកម្មក្នុងមូលដ្ឋាន (ឧទាហរណ៍ សណ្ឋាគារ) ដែលផ្តល់ឱកាសបណ្តុះបណ្តាលកាន់តែប្រសើរ និងចូលរួមចំណែកក្នុងការអភិវឌ្ឍសហគមន៍ (ឧទាហរណ៍ តាមរយៈការអនុវត្តគោលការណ៍នៃការទទួលខុសត្រូវផ្នែកសង្គមរបស់ក្រុមហ៊ុន - CSR) តាមរយៈកម្មវិធីផ្តល់ពានរង្វាន់ ថ្នាក់មូលដ្ឋាន / ថ្នាក់ជាតិ | រដ្ឋបាលខេត្តក្រុង / ក្រសួងពាក់ព័ន្ធ / ក្រុមប្រឹក្សាជាតិអភិវឌ្ឍន៍ដោយចីរភាព | រយៈពេលខ្លី |
| ៩ | បង្កើតឱ្យមានការចូលរួមពីសិស្ស និស្សិត នៅក្នុងការអភិវឌ្ឍប្រកបដោយចីរភាព តាមរយៈកម្មវិធីសាលារៀនដែលមានមេត្រីភាពបរិស្ថាន | រដ្ឋបាលខេត្ត និងក្រុង / ក្រសួង និងមន្ទីរអប់រំ យុវជន និងកីឡា / ក្រសួង និងមន្ទីរបរិស្ថាន | រយៈពេលខ្លី |

## កម្មវត្ថុទី៩៖ រៀបចំឱ្យមានការចូលរួមពីគ្រប់ភាគីពាក់ព័ន្ធ ជាពិសេសក្រុមដែលមិនត្រូវបានយកចិត្តទុកដាក់នៅក្នុងការធ្វើសេចក្តីសម្រេចចិត្តអំពីការអភិវឌ្ឍទីក្រុង

| ល.រ | សកម្មភាព | ស្ថាប័ននាំមុខ | រយៈពេល |
|---|---|---|---|
| ១ | ពង្រឹងការអនុវត្តការពិគ្រោះយោបល់សាធារណៈរាល់គ្រប់គម្រោងអភិវឌ្ឍន៍ទីក្រុង ក្នុងនោះរួមមានគម្រោងពីវិស័យឯកជន ដែលគួរជាលក្ខខណ្ឌតម្រូវនៃការវាយតម្លៃផលប៉ះពាល់សង្គម និងបរិស្ថាន (ESIA) | រដ្ឋបាលខេត្តក្រុង / ក្រសួងពាក់ព័ន្ធ | រយៈពេលខ្លី |
| ២ | បង្កើនសមត្ថភាពរបស់មន្ត្រីក្រុងពាក់ព័ន្ធ នៅក្នុងការសម្របសម្រួលការពិគ្រោះយោបល់សាធារណៈ រួមទាំងនៅក្នុងក្រុមពលរដ្ឋក្រីក្រ និងងាយរងគ្រោះ | រដ្ឋបាលខេត្តក្រុង / ក្រសួងមហាផ្ទៃ | រយៈពេលខ្លី |
| ៣ | បង្កើនការចូលរួមរបស់ស្ត្រីនៅក្នុងតួនាទីដឹកនាំ | រដ្ឋបាលខេត្តក្រុង / ក្រសួងមហាផ្ទៃ / ក្រសួងកិច្ចការនារី | រយៈពេលខ្លី |
| ៤ | ពង្រឹងភាពជាកម្មសិទ្ធិដោយរៀបចំឱ្យមានការចូលរួមពីភាគីពាក់ព័ន្ធទាំងអស់ដើម្បីចូលរួមនៅក្នុងការពិគ្រោះយោបល់ និងការធ្វើសេចក្តីសម្រេចចិត្ត និងដោយធានាសមភាពយេនឌ័រសមស្របនៅក្នុងចំណោមភាគីពាក់ព័ន្ធ | រដ្ឋបាលខេត្តក្រុង / ក្រសួងមហាផ្ទៃ | រយៈពេលខ្លី |
| ៥ | បង្កើតគោលនយោបាយបែងចែកថវិកាដើម្បីគាំទ្រការពិគ្រោះយោបល់សាធារណៈ | រដ្ឋបាលខេត្តក្រុង / ក្រសួងមហាផ្ទៃ / ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | រយៈពេលខ្លី |
| ៦ | បង្កើនប្រសិទ្ធភាពនៃការចូលរួមសាធារណៈដោយបង្កើនចំណេះដឹងទៅដល់សាធារណជន | រដ្ឋបាលខេត្តក្រុង / ក្រសួងមហាផ្ទៃ | រយៈពេលខ្លី |

## កម្មវត្ថុទី១០៖ លើកកម្ពស់សមត្ថភាពគ្រប់គ្រង និងកៀរគរផ្នែកហិរញ្ញវត្ថុរបស់រដ្ឋបាលក្រុង ដើម្បីអនុវត្តន៍គម្រោងវិនិយោគបៃតង

| ល.រ | សកម្មភាព | ស្ថាប័ននាំមុខ | រយៈពេល |
|---|---|---|---|
| ១ | កៀរគរប្រភពហិរញ្ញវត្ថុ ឬមូលនិធិនានាក្នុងការបង្កើនថវិកាថ្នាក់ក្រោមជាតិ | រដ្ឋបាលខេត្តក្រុង / ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ / ក្រសួងមហាផ្ទៃ | រយៈពេលខ្លី |
| ២ | បង្កើនសមត្ថភាពគ្រប់គ្រងហិរញ្ញវត្ថុដើម្បីឱ្យរដ្ឋបាលក្រុងទទួលបានការទុកចិត្ត ដើម្បីឱ្យក្រុងមានលទ្ធភាពខ្ពស់ជាងមុនក្នុងការទទួលបានហិរញ្ញវត្ថុ | រដ្ឋបាលខេត្តក្រុង ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ /ក្រសួងមហាផ្ទៃ | រយៈពេលខ្លី |
| ៣ | ធ្វើឱ្យប្រសើរឡើងនូវការប្រមូលចំណូលរបស់ក្រុង ដូចជាថ្លៃសេវាសាធារណៈ | រដ្ឋបាលក្រុង / ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | រយៈពេលខ្លី |
| ៤ | បង្កើតគម្រោងវិនិយោគ ដែលជាគម្រោងអាចកៀរគរធនធានបន្ថែមបានតាមរយៈយន្តការភាពជាដៃគូរវាងរដ្ឋនិងឯកជន | រដ្ឋបាលខេត្តក្រុង / ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | រយៈពេលខ្លី |
| ៥ | ផ្តល់លទ្ធភាពការប្រមូលពន្ធដាក់លាក់នៅកម្រិតថ្នាក់ក្រោមជាតិដើម្បីពង្រឹងថវិកាថ្នាក់មូលដ្ឋាន | រដ្ឋបាលខេត្តក្រុង / ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ /ក្រសួងមហាផ្ទៃ | រយៈពេលមធ្យម |

## កម្មវត្ថុទី១១៖ ពង្រឹងសមត្ថភាពស្ថាប័ន និងធនធានមនុស្សនៅកម្រិតរដ្ឋបាលក្រុង

| ល.រ | សកម្មភាព | ស្ថាប័ននាំមុខ | រយៈពេល |
|---|---|---|---|
| ១ | កំណត់ពីចន្លោះតម្រូវការបំពេញបន្ថែមសមត្ថភាព/ចំណេះដឹង និងផ្តល់វគ្គបណ្តុះបណ្តាល ឬកម្មវិធីពង្រឹងសមត្ថភាពបន្ថែម | រដ្ឋបាលខេត្តក្រុង / មន្ទីរពាក់ព័ន្ធតាមវិស័យ | រយៈពេលខ្លី |
| ២ | លើកកម្ពស់ចំណេះដឹង និងបង្កើនការយល់ដឹងបន្ថែមអំពីចក្ខុវិស័យ គោលដៅ និងគោលបំណងទីក្រុងនិរន្តរភាព និងសកម្មភាពជាក់លាក់ ក្នុងការគ្រប់គ្រងក្រុង និងបុគ្គលិក | រដ្ឋបាលខេត្តក្រុង / ក្រសួងមហាផ្ទៃ / ក្រសួងបរិស្ថាន / ក្រុមប្រឹក្សាជាតិអភិវឌ្ឍន៍ដោយចីរភាព | រយៈពេលខ្លី |
| ៣ | ពង្រីកចំណេះដឹងបន្ថែម និងជំនាញរបស់បុគ្គលិកបច្ចេកទេសអំពីរបៀបត្រួតពិនិត្យ គ្រប់គ្រង ដំឡើង ប្រតិបត្តិការ និងថែទាំបច្ចេកវិទ្យាដែលជាផ្នែកមួយនៃហេដ្ឋារចនាសម្ព័ន្ធទីក្រុងនិរន្តរភាព | រដ្ឋបាលខេត្តក្រុង / ក្រសួងមហាផ្ទៃ / ក្រសួងបរិស្ថាន / ក្រសួងសាធារណការ និងដឹកជញ្ជូន / ក្រុមប្រឹក្សាជាតិអភិវឌ្ឍន៍ដោយចីរភាព | រយៈពេលខ្លី |
| ៤ | បង្កើតកម្មវិធីអភិវឌ្ឍន៍ក្រុង ដើម្បីជំរុញការអនុវត្តគ្រប់ជំនាញ និងចំណេះដឹងដែលបុគ្គលិកទទួលបាន | រដ្ឋបាលខេត្តក្រុង / ក្រសួងពាក់ព័ន្ធ | រយៈពេលខ្លី |
| ៥ | បង្កើនគុណភាពនៃការផ្តល់សេវាសាធារណៈតាមរយៈការផ្តល់គ្រឿងលើកទឹកចិត្តដល់មន្ត្រី ឬបុគ្គលិកដែលបានរួមចំណែកដល់ការអភិវឌ្ឍនិរន្តរភាពទីក្រុង | រដ្ឋបាលខេត្តក្រុង / ក្រសួងពាក់ព័ន្ធ | រយៈពេលខ្លី |
| ៦ | ជំរុញការធ្វើវិមជ្ឈការសិទ្ធិ និងការធ្វើសេចក្តីសម្រេចចិត្ត និងធនធានដល់រដ្ឋបាលមូលដ្ឋាន | រដ្ឋបាលខេត្តក្រុង / ក្រសួងពាក់ព័ន្ធ | រយៈពេលមធ្យម |

## កម្មវត្ថុទី១២៖ លើកកម្ពស់ឱ្យមានការចែករំលែកព័ត៌មាន ចំណេះដឹង និងការអនុវត្តល្អៗទៅវិញទៅមករវាងក្រុងនិងក្រុង

| ល.រ | សកម្មភាព | ស្ថាប័ននាំមុខ | រយៈពេល |
|---|---|---|---|
| ១ | រៀបចំកិច្ចប្រជុំទៀងទាត់ (ប្រចាំឆ្នាំ) ក្នុងចំណោមក្រុង ដើម្បីចែករំលែកព័ត៌មាន និងបទពិសោធន៍អំពីការអភិវឌ្ឍទីក្រុងនិរន្តរភាព | ក្រសួងមហាផ្ទៃ / រដ្ឋបាលក្រុង | រយៈពេលខ្លី |
| ២ | បង្កើតបណ្តាញព័ត៌មាន សារអេឡិចត្រូនិក (ឧទាហរណ៍ តេឡេក្រាម និង/ឬវ៉ៃស្ទែផ Telegram / WhatsApp...) រវាងរដ្ឋបាលក្រុងដែលអាចបង្ហោះព័ត៌មាន និងចែករំលែកព័ត៌មានជាទៀងទាត់អំពីបទពិសោធន៍នៃការអភិវឌ្ឍទីក្រុងនិរន្តរភាពរបស់ខ្លួន | រដ្ឋបាលខេត្តក្រុង / ក្រសួងមហាផ្ទៃ ក្រសួងបរិស្ថាន ក្រុមប្រឹក្សាជាតិអភិវឌ្ឍន៍ដោយចីរភាព | រយៈពេលខ្លី |
| ៣ | បង្កើតសកម្មភាពផ្សព្វផ្សាយ និងប្រព័ន្ធព័ត៌មានរួម ដើម្បីបង្កើតជាការផ្សព្វផ្សាយថ្នាក់ជាតិ និងអន្តរជាតិស្តីពីការអភិវឌ្ឍទីក្រុងនិរន្តរភាពនៅក្នុងក្រុងដែលពាក់ព័ន្ធ | រដ្ឋបាលខេត្តក្រុង / ក្រសួងមហាផ្ទៃ ក្រសួងបរិស្ថាន / ក្រុមប្រឹក្សាជាតិអភិវឌ្ឍន៍ដោយចីរភាព | រយៈពេលខ្លី |

| | | | |
|---|---|---|---|
| ៤ | បង្កើតយុទ្ធសាស្ត្រគ្រប់គ្រងប្រព័ន្ធចំណេះដឹង (ចងក្រងឯកសារ) ដែលមានភាពគ្រប់ជ្រុងជ្រោយ ស្តីពីការអភិវឌ្ឍទីក្រុងនិរន្តរភាព | រដ្ឋបាលខេត្តក្រុង / ក្រសួងអប់រំ យុវជន និងកីឡា | រយៈពេលខ្លី |
| ៥ | បង្កើតប្រព័ន្ធទំនាក់ទំនងផ្លូវការ ដើម្បីធ្វើសមាហរណកម្ម និងធ្វើបច្ចុប្បន្នភាពទិន្នន័យជាក់លាក់តាមក្រុងនីមួយៗ ដែលនឹងមានការវាស់វែងនៅថ្នាក់ជាតិ ការធ្វើរបាយការណ៍សម្រាប់អង្គការអន្តរជាតិដើម្បីកំណត់វិសាលភាពនៃការវិវឌ្ឍស្របទៅតាមកិច្ចព្រមព្រៀងអាកាសធាតុទីក្រុងប៉ារីស គោលដៅអភិវឌ្ឍន៍ប្រកបដោយនិរន្តរភាពនៃអង្គការសហប្រជាជាតិ (UN SDGs)។ល។ | រដ្ឋបាលខេត្តក្រុង / ក្រសួងបរិស្ថាន ក្រសួងផែនការ / ក្រុមប្រឹក្សាជាតិអភិវឌ្ឍន៍ដោយចីរភាព | រយៈពេលមធ្យម |
| ៦ | ពង្រឹងកម្មវិធីពានរង្វាន់ទីក្រុងស្អាត ដើម្បីពង្រីកបន្ថែមទៅកាន់ក្រុងស្អាត និងបៃតង និងដាក់បញ្ចូលសូចនាករបន្ថែមនៃវឌ្ឍនភាពលើការអភិវឌ្ឍទីក្រុងនិរន្តរភាព | រដ្ឋបាលខេត្តក្រុង / ក្រសួងបរិស្ថាន ក្រសួងទេសចរណ៍ ក្រុមប្រឹក្សាជាតិអភិវឌ្ឍន៍ដោយចីរភាព | រយៈពេលមធ្យម |
| ៧ | បង្កើត និងអនុវត្តផែនការសកម្មភាពដើម្បីភ្ជាប់ទីក្រុងដែលមានសក្តានុពលទៅនឹងទីក្រុងអន្តរជាតិដែលមានសម្ព័ន្ធមេត្រីភាព | រដ្ឋបាលខេត្តក្រុង / ក្រសួងទេសចរណ៍ / ក្រសួងបរិស្ថាន / ក្រុមប្រឹក្សាជាតិអភិវឌ្ឍន៍ដោយចីរភាព | រយៈពេលវែង |

## ១.៥ ស្ថាប័នអនុវត្ត និងយន្តការគាំទ្រ

ផែនការយុទ្ធសាស្ត្រទីក្រុងនិរន្តរភាពនេះត្រូវបានបង្កើតឡើងដើម្បីផ្តល់ការយល់ដឹងរួម និងផ្តល់ទិសដៅយុទ្ធសាស្ត្រ និងបង្ហាញនូវគោលការណ៍ណែនាំមួយចំនួនដល់រដ្ឋបាលក្រុង ដើម្បីបញ្ចូលនូវទស្សនវិស័យនៃការអភិវឌ្ឍទីក្រុងនិរន្តរភាពទៅក្នុងផែនការអភិវឌ្ឍន៍ និងកម្មវិធីវិនិយោគរបស់ក្រុងនីមួយៗ។ ផ្នែកនេះ បង្ហាញពីការស្នើរៀបចំជាយន្តការ និងរចនាសម្ព័ន្ធសម្របសម្រួល ទាំងនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ដើម្បីមានតួនាទីត្រួតពិនិត្យលើការអនុវត្តការដាក់បញ្ចូលផែនការនេះទៅក្នុងផែនការអភិវឌ្ឍន៍ និងទៅក្នុងកម្មវិធីវិនិយោគរបស់ក្រុងនីមួយៗនោះ។

រូបតាងខាងក្រោម បង្ហាញពីយន្តការសម្របសម្រួលដែលបានស្នើឡើងនៅក្នុងស្ថាប័នសំខាន់ៗ ដែលមានស្រាប់ និងកំពុងដំណើរការទាំងនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ៖

- នៅថ្នាក់ជាតិ ក្រុមការងារបច្ចេកទេសទីក្រុងនិរន្តរភាព ដើរតួនាទីដឹកនាំដើម្បីត្រួតពិនិត្យការអនុវត្តការងារនេះ
- នៅថ្នាក់រាជធានី ខេត្ត ក្រុមការងារ ឬយន្តការប្រហាក់ប្រហែលនឹងត្រូវបានរៀបចំ និងអនុវត្តផែនការយុទ្ធសាស្ត្រនេះ។ ក្រុមការងារនេះអាចនឹងត្រូវបង្កើតឡើងតាមការចាំបាច់ ឬយល់ឃើញរបស់រដ្ឋបាលរាជធានី ខេត្ត

រូបភាពទី១.៥. ការរៀបចំស្ថាប័នអនុវត្ត និងយន្តការគាំទ្រ (ទម្រង់គំរូរចនាសម្ព័ន្ធដែលបានស្នើឡើង តាមរយៈការពិគ្រោះយោបល់ជាមួយភាគីពាក់ព័ន្ធ)




**ថ្នាក់ជាតិ៖ ក្រុមការងារបច្ចេកទេសទីក្រុងនិរន្តរភាព**

ក្រុមប្រឹក្សាជាតិអភិវឌ្ឍន៍ដោយចីរភាព (ក.ជ.អ.ច.) គឺជាស្ថាប័នអន្តរក្រសួងដែលមានតំណាងជាន់ខ្ពស់ (ថ្នាក់រដ្ឋលេខាធិការ និងអនុរដ្ឋលេខាធិការ) ពីក្រសួង និងស្ថាប័នរាជរដ្ឋាភិបាលចូលរួមជាសមាជិក និងមានសម្តេចនាយករដ្ឋមន្ត្រីជាប្រធានកិត្តិយស និងមានរដ្ឋមន្ត្រីក្រសួងបរិស្ថានជាប្រធាន។ តួនាទីសំខាន់របស់ ក.ជ.អ.ច. គឺដើម្បីតាក់តែង ដឹកនាំ និងវាយតម្លៃលើការអនុវត្តគោលនយោបាយ ផែនការយុទ្ធសាស្ត្រ ផែនការសកម្មភាពលិខិតបទដ្ឋានច្បាប់ គតិយុត្តិ កម្មវិធី និងគម្រោងអភិវឌ្ឍន៍ទាំងឡាយណាដែលពាក់ព័ន្ធនឹងការអភិវឌ្ឍដោយចីរភាព។

ក្រុមការងារបច្ចេកទេសទីក្រុងនិរន្តរភាព ត្រូវបានបង្កើតឡើងដើម្បីឆ្លើយតបនឹងតម្រូវការនៃការអភិវឌ្ឍទីក្រុង និងទីប្រជុំជនប្រកបដោយនិរន្តរភាព និងគ្រប់ជ្រុងជ្រោយ ស្របតាមមាត្រា១០ នៃអនុក្រឹត្យលេខ៥៩ អនក្រ.បក ចុះថ្ងៃទី១៨ ខែឧសភា ឆ្នាំ២០១៥ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃអគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាជាតិអភិវឌ្ឍន៍ដោយចីរភាព (ក.ជ.អ.ច.)។

ក្រុមការងារនេះមានទស្សនវិស័យពន្លឿនការអភិវឌ្ឍទីក្រុងស្របតាមគោលនយោបាយជាតិអភិវឌ្ឍន៍បៃតង និងផែនការយុទ្ធ-សាស្ត្រជាតិអភិវឌ្ឍន៍បៃតងរបស់រដ្ឋាភិបាលក្នុងវិស័យសេដ្ឋកិច្ច។ ទស្សនវិស័យនេះ អាចសម្រេចទៅបានដោយគិតគូរឱ្យបានគ្រប់ជ្រុងជ្រោយលើវិស័យបរិស្ថាន ការអភិវឌ្ឍ និងសង្គម រួមបញ្ចូលទាំងការប្រែប្រួលអាកាសធាតុ និងគ្រោះមហន្តរាយធម្មជាតិ ការសន្សំសំចៃ និងប្រសិទ្ធភាពថាមពល ភាពសុខដុម និងទីក្រុងប្រកបដោយសមធម៌ ការកាត់បន្ថយភាពក្រីក្រតាមរយៈការលើកកម្ពស់ជីវភាពរស់នៅរបស់ប្រជាជនឱ្យកាន់តែប្រសើរឡើង។

- ក្រុមការងារបច្ចេកទេសទីក្រុងនិរន្តរភាព មានសមាសភាពចូលរួមជាតំណាងក្រសួង និងស្ថាប័នដូចខាងក្រោម៖

- (១) អគ្គលេខាធិការដ្ឋាន ក.ជ.អ.ច. (២) ក្រសួងមហាផ្ទៃ (៣) ក្រសួងផែនការ (៤) ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ (៥) ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ (៦) ក្រសួងសាធារណការ និងដឹកជញ្ជូន (៧) ក្រសួងរ៉ែ និងថាមពល (៨) ក្រសួងបរិស្ថាន (៩) ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ (១០) ក្រសួងធនធានទឹក និងឧតុនិយម (១១) ក្រសួងទេសចរណ៍ (១២) ក្រសួងអប់រំ យុវជន និងកីឡា (១៣) ក្រសួងអភិវឌ្ឍន៍ជនបទ (១៤) ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ (១៥) ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា (១៦) សាលារាជធានីភ្នំពេញ និងខណ្ឌទាំង១៤ និងមន្ទីរពាក់ព័ន្ធ និង (១៧) តំណាងមកពីខេត្តគោលដៅទាំង ៧។ ផែនការដាក់បញ្ចូលអ្នកតំណាងមកពីថ្នាក់ខេត្តផ្សេងទៀត គឺសម្រាប់ដំណាក់កាលបន្ទាប់។ ក្រុមការងារបច្ចេកទេសទីក្រុងនិរន្តរភាព មានលេខាធិការដ្ឋានសម្របសម្រួលដោយនាយកដ្ឋានសេដ្ឋកិច្ចបៃតង។

ក្រុមការងារបច្ចេកទេសទីក្រុងនិរន្តរភាពនេះ មានភារកិច្ចទទួលខុសត្រូវដូចខាងក្រោម៖

- ចូលរួមសម្របសម្រួល និងផ្តល់យោបល់លើការរៀបចំគោលនយោបាយ ក្របខ័ណ្ឌការងារ និងវិធីសាស្ត្ររៀបចំផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ទីក្រុងនិរន្តរភាពសម្រាប់ថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ក្នុងនោះរួមមាន៖ ផែនការយុទ្ធសាស្ត្រទីក្រុងនិរន្តរភាព ផែនការសកម្មភាពតាមវិស័យ ផែនការវិនិយោគសម្រាប់អភិវឌ្ឍន៍ទីក្រុងនិរន្តរភាព ផែនការប្រើប្រាស់ដីការវិនិយោគហេដ្ឋារចនាសម្ព័ន្ធបៃតង ការដឹកជញ្ជូនបៃតង ការគ្រប់គ្រងសំណល់រឹងរាវ ប្រសិទ្ធភាពថាមពល ការប្រើប្រាស់ថាមពលកកើតឡើងវិញទីក្រុងទីប្រជុំជន។ល។
- បញ្ច្រាបទស្សនទានស្តីពី ការអភិវឌ្ឍបៃតងទៅក្នុងដំណើរការអភិវឌ្ឍទីក្រុងទីប្រជុំជន នៅក្នុងព្រះរាជាណាចក្រកម្ពុជា រួមមានការរៀបចំផែនការទីក្រុងទីប្រជុំជន ភាពងាយរងគ្រោះរបស់ទីក្រុង ការដឹកជញ្ជូន សំណង់បរិស្ថាន វិស័យកម្មន្តសាល ការគ្រប់គ្រងសំណល់រឹងរាវ និងទីធ្លាសាធារណៈបៃតងនិងបេតិកភ័ណ្ឌវប្បធម៌
- ផ្តល់ធាតុចូលសំខាន់សម្រាប់ធ្វើសមាហរណកម្មការអភិវឌ្ឍទីក្រុងនិរន្តរភាព ទៅក្នុងច្បាប់វិនិយោគរបស់កម្ពុជា លិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធនឹងការសាងសង់ ការគ្រប់គ្រងការប្រើប្រាស់ដី និងការរៀបចំផែនការទីក្រុងទីប្រជុំជន
- ចូលរួមផ្តល់យោបល់ជូនរាជរដ្ឋាភិបាលលើការរៀបចំគោលនយោបាយ និងយន្តការផ្អែកសារពើពន្ធនិងមិនមែនសារពើពន្ធ និងហិរញ្ញវត្ថុ ដើម្បីជំរុញលើកទឹកចិត្តដល់វិស័យឯកជនក្នុងការអភិវឌ្ឍគម្រោងវិនិយោគបៃតង
- ស្នើសុំ និងផ្តល់យោបល់លើការរៀបចំលក្ខណៈវិនិច្ឆ័យ និងសេចក្តីណែនាំអគារបៃតង ការប្រើប្រាស់សម្ភារសាងសង់ និងក្នុងអគារដោយគិតគូពីប្រសិទ្ធភាពធនធាន សុខុមាលភាព ការសន្សំសំចៃ សុវត្ថិភាព និងផលចំណេញផ្នែកសេដ្ឋកិច្ចបរិស្ថាន ព្រមទាំងគាំទ្រការផ្តល់វិញ្ញាបនបត្រសម្រាប់សំណង់អគារបៃតងស្របតាមស្តង់ដារបរិបទប្រទេសកម្ពុជា រួមមានសំណង់អគារលំនៅឋាន សំណង់អគាររដ្ឋបាលសាធារណៈ សំណង់ពាណិជ្ជកម្ម ផ្សារទំនើប រួមទាំងផ្តល់ការគាំទ្រ និងសម្រួលឱ្យមានបរិយាកាសល្អសម្រាប់ការវិនិយោគក្នុងវិស័យអគារបៃតង
- សហការ និងជំរុញដល់ការរៀបចំបង្កើតគម្រូអាជីវកម្មបៃតង និងការរៀបចំសំណើគម្រោង ដើម្បីកៀរគរថវិកាពីស្ថាប័នហិរញ្ញវត្ថុអន្តរជាតិនានា សម្រាប់អនុវត្តគម្រោងអភិវឌ្ឍន៍ទីក្រុងនិរន្តរភាព
- ពិនិត្យ និងចងក្រងឯកសារមគ្គុទេសន៍ស្តីពី គោលការណ៍ណែនាំនៃការអភិវឌ្ឍទីក្រុងនិរន្តរភាពដោយផ្អែកលើគោលការណ៍ណែនាំនៃទីក្រុងនិរន្តរភាពអាស៊ានដែលមានស្រាប់
- កំណត់អាទិភាព និងរៀបចំផែនការការងារសម្រាប់ ក.ប.ទ.ន.
- ដើរតួជាជនបង្គោលបច្ចេកទេសតាមក្រសួង ស្ថាប័នរបស់ខ្លួន ដើម្បីសម្របសម្រួលដល់ការពិនិត្យ ចងក្រង និងអនុវត្តគោលនយោបាយ យុទ្ធសាស្ត្រ ផែនការសកម្មភាព និងកម្មវិធី សំដៅពង្រឹងការអនុវត្តការងារទីក្រុងនិរន្តរភាព
- ទទួលអនុវត្តការងារបន្ថែមតាមការណែនាំរបស់ប្រធានក្រុមប្រឹក្សាជាតិអភិវឌ្ឍន៍ដោយចីរភាព
- សម្របសម្រួល និងរាយការណ៍ជាទៀងទាត់ជូនសមាជិក ក.ជ.អ.ច. តាមក្រសួង ស្ថាប័នរបស់ខ្លួន។

## យន្តការទីក្រុងនិរន្តរភាពថ្នាក់ក្រោមជាតិដែលអាចនឹងត្រូវបង្កើតឡើង

ចំណុចគួរឱ្យកត់សម្គាល់មួយគឺថា បណ្តាក្រុងមួយចំនួនមានក្រុមការងារ ឬគណៈកម្មាការដែលកំពុងដំណើរការស្រាប់ ហើយដែលមានអាណត្តិស្រដៀងគ្នា ដូចជាក្រុមការងារថ្នាក់ខេត្តសម្រាប់វាយតម្លៃទីក្រុងស្អាត (PWGCCA) និងគណៈកម្មាការថ្នាក់ក្រោមជាតិសម្រាប់ការងារដែនដី និងនគរូបនីយកម្ម។ ដូច្នេះក្រុងនីមួយៗអាចពិចារណាក្នុងការពង្រីកទំហំសមាជិក និងតួនាទីរបស់ក្រុមការងារ ឬគណៈកម្មាការដែលមានរចនាសម្ព័ន្ធស្រាប់ និងកែសម្រួលក្រុមការងារ ឬគណៈកម្មាការនោះរួមបញ្ចូលការងារដែលមានបេសកម្មអភិវឌ្ឍន៍ទីក្រុងនិរន្តរភាពផងដែរសម្រាប់ការអនុវត្តផែនការយុទ្ធសាស្ត្រនេះ។

តួនាទី និងការងារទទួលខុសត្រូវគួរមានដូចខាងក្រោម៖

- ធ្វើការកំណត់ទិសដៅសូចនាករជាក់លាក់របស់ក្រុងសម្រាប់វិស័យជាអាទិភាព និងដាក់បញ្ចូលក្នុងរបាយការណ៍ប្រចាំឆ្នាំ
- ប្រមូលទិន្នន័យមូលដ្ឋានសម្រាប់វិស័យអាទិភាព
- បញ្ចូលគម្រោងវិនិយោគបៃតងនៅក្នុងកម្មវិធីវិនិយោគ ៣ ឆ្នាំរំកិលរបស់ក្រុង
- រៀបចំផែនការថវិកា និងធនធានដើម្បីអនុវត្តន៍គម្រោងវិនិយោគ
- បង្កើតវេទិកាមួយដើម្បីឱ្យអ្នកពាក់ព័ន្ធនានាចូលរួមក្នុងដំណើរការអនុវត្តសកម្មភាព ឬ គម្រោងអាទិភាព
- បំពេញការងារចាំបាច់តាមការណែនាំរបស់រដ្ឋបាលខេត្ត

ការចូលរួមពីអ្នកពាក់ព័ន្ធ មានសារៈសំខាន់ក្នុងការអភិវឌ្ឍទីក្រុងនិរន្តរភាពឱ្យមានភាពស័ក្តិសិទ្ធិ និងមានបរិយាបន្ន។ ដូច្នេះ វាជាការចាំបាច់ក្នុងការធ្វើឱ្យមានបរិយាកាសអំណោយផល ដើម្បីលើកកម្ពស់ និងជំរុញឱ្យមានការចូលរួមពីសាធារណៈនៅក្នុងដំណើរការអនុវត្តន៍ផែនការយុទ្ធសាស្ត្រ។ វេទិកាសាធារណៈ ការពិភាក្សា និងពិគ្រោះយោបល់ គួរតែត្រូវបានរៀបចំជាប្រចាំដើម្បីប្រមូលមតិយោ-បល់ជាធាតុចូលពីដៃគូអភិវឌ្ឍន៍ វិស័យឯកជន សង្គមស៊ីវិល ស្ថាប័នសិក្សាធិការ និងស្រាវជ្រាវ និងសហគមន៍។ ក្រុងនីមួយៗ អាចពិចារណាក្នុងការចាត់តាំងអង្គការសង្គមស៊ីវិលណាមួយ ឬដៃគូមកពីវិស័យឯកជនណាមួយ ជាតំណាងនៅក្នុងក្រុមការងារទីក្រុងនិរន្តរភាព។

## ១.៦. ធនធានហិរញ្ញវត្ថុ

មានវិធីសាស្ត្រជាច្រើនដែលក្រុងនីមួយៗអាចស្វែងរកហិរញ្ញ-ប្បទាន ដើម្បីអនុវត្តគម្រោងវិនិយោគបៃតងរបស់ខ្លួនបាន ដូចជាតាមរយៈថវិកាជាតិ (ថវិកាជាតិ និងថវិកាថ្នាក់ក្រោមជាតិ) ធនធានហិរញ្ញវត្ថុពីខាងក្រៅ ដូចជាតាមរយៈមូលនិធិអាកាសធាតុបៃតង (GCF) មូលនិធិបរិស្ថានសកល (GEF) កម្ចីដែលមានអត្រាការប្រាក់ទាបពីធនាគារអភិវឌ្ឍន៍ធំៗ ដូចជាធនាគារអភិវឌ្ឍន៍អាស៊ី (ADB) និងធនាគារពិភពលោក (WB) និងប្រាក់ជំនួយពីដៃគូអភិវឌ្ឍន៍នានា។ ក្រុងនីមួយៗក៏អាចទាញផលប្រយោជន៍ពីវិស័យឯកជនផងដែរ តាមរយៈការលើកកម្ពស់កិច្ចសហការដៃគូរវាងវិស័យសាធារណៈ និងវិស័យឯកជនសម្រាប់ការអភិវឌ្ឍគម្រោងវិនិយោគហេដ្ឋារចនាសម្ព័ន្ធបៃតង។ ទោះបីជាគម្រោងវិនិយោគទៅលើការប្រើប្រាស់ធនធានឱ្យមានប្រសិទ្ធភាព និងភាពធន់ទៅនឹងការប្រែប្រួលអាកាសធាតុ ត្រូវការដើមទុនដំបូងធំ ប៉ុន្តែការចំណាយក្នុងមួយវដ្តគម្រោង នៅតែទាបជាងការចំណាយដំបូង។ បន្ថែមលើនេះទៀត គម្រោងទាំងនេះផ្តល់នូវផលប្រយោជន៍ផ្នែកសង្គម និងបរិស្ថានយ៉ាងច្រើនក្នុងរយៈពេលវែង។

### ១.៦.១. ថវិកាជាតិសម្រាប់ការអនុវត្តរបស់រដ្ឋបាលក្រុង

ទោះបីមានការខិតខំប្រឹងប្រែងក្នុងការធ្វើកំណែទម្រង់វិមជ្ឈការសារពើពន្ធ ក្នុងរយៈពេលមួយទសវត្សរ៍ចុងក្រោយនេះក៏ដោយ ក៏រដ្ឋាភិបាលមិនទាន់សម្រេចបាននូវបេសកកម្មរបស់ខ្លួនសម្រាប់វិមជ្ឈការសារពើពន្ធទេ ហើយយើងសង្កេតឃើញថា រដ្ឋាភិបាលនៅតែមានទម្រង់អនុវត្តពន្ធមួយចំនួន ដែលការគ្រប់គ្រងសារពើពន្ធស្ថិតក្នុងដែនសមត្ថកិច្ចរដ្ឋបាលថ្នាក់ជាតិ។[៧២] កម្មវិធីវិនិយោគសាធារណនិងផែនការសារពើពន្ធត្រូវបានអនុវត្ត នៅថ្នាក់កណ្តាល ហើយការអនុវត្តនេះ ត្រូវបានត្រួតពិនិត្យដោយក្រសួងពាក់ព័ន្ធ។ ចាប់តាំងពីឆ្នាំ ២០០៥ មករាជរដ្ឋាភិបាលកម្ពុជា បានចាត់វិធានការដើម្បីប្រគល់ការទទួលខុសត្រូវ និងធនធានមួយចំនួនដល់រដ្ឋបាលថ្នាក់ក្រោមជាតិ តាមរយៈការអនុវត្តកម្មវិធីវិមជ្ឈការ និងវិសហមជ្ឈការ និងច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក និងខណ្ឌ (ដែលបានរំលេចនៅក្នុងជំពូកមុនស្តីពីអភិបាលកិច្ចក្រុង។)។ ទោះបីខេត្ត និងក្រុង មានទំនួលខុសត្រូវក្នុងការផ្តល់សេវាកម្មក្រុងក៏ដោយ ក៏ការសម្រេចចិត្តលើថវិកា និងការវិនិយោគរបស់រដ្ឋបាលខេត្តក្រុង ត្រូវបានធ្វើឡើងតាមវិធីសាស្ត្រពីលើចុះក្រោម។ ច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ បានចែងថា ក្រុមប្រឹក្សាថ្នាក់ក្រោមជាតិនីមួយៗ ត្រូវមានធនធានហិរញ្ញវត្ថុសម-ស្របដើម្បីបំពេញភារកិច្ច គ្រប់គ្រង ចាត់ចែង និងអនុវត្តមុខងារដែលជាកាតព្វកិច្ចរបស់ខ្លួន (មាត្រា ២៤២)។ ច្បាប់នេះក៏បានចែងដែរថា ក្រុមប្រឹក្សារាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌមានសិទ្ធិទទួល

[72] ADB, "Fiscal Decentralization Reform in Cambodia: Progress over the Past Decade and Opportunities," last modified December 2018, DOI: http://dx.doi.org/10.22617/TCS189247

បានចំណូលពីប្រភពនៅមូលដ្ឋាន ពីប្រភពនៅថ្នាក់ជាតិ និងពីប្រភពផ្សេងៗទៀតដោយអនុលោមទៅតាមច្បាប់ស្តីពីរបបហិរញ្ញវត្ថុ និងការគ្រប់គ្រងទ្រព្យសម្បត្តិរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ (មាត្រា ២៤៤)។

នៅក្រោមកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ ឃុំសង្កាត់បានបង្កើតគណៈកម្មាធិការជ្រើសរើសក្រុមប្រឹក្សាក្នុងស្រុកដែលអនុម័តលើផែនការវិនិយោគមានរយៈពេល ៣ ឆ្នាំ ដែលមានឃុំនិងសង្កាត់ចំនួន ១.៦៤៦ ទូទាំងប្រទេសកម្ពុជា។ ការចំណាយសរុបរបស់ពួកគេមានត្រឹមតែ ២,៥% នៃចំណាយថវិកាជាតិប្រចាំឆ្នាំ។ ផលទុន និងប្រាក់ចំណូលរបស់រដ្ឋបាលឃុំសង្កាត់ភាគច្រើនពឹងផ្អែកទៅលើការផ្ទេរពីថវិកាជាតិដែលក្នុងនោះ ៨០% ត្រូវបានប្រើប្រាស់សម្រាប់ចំណាយចរន្តដែលមានដូចជា ចំណាយលើដំណើរការប្រតិបត្តិការ និងការបើកប្រាក់ខែបុគ្គលិក។ គម្រោង និងសកម្មភាពដែលបានចុះបញ្ជីនៅក្នុងផែនការវិនិយោគ ៣ ឆ្នាំ ដំណើរការជាធម្មតាគឺជាគម្រោងវិនិយោគខ្នាតតូច ឬសម្រាប់ការវិនិយោគខ្នាតធំសម្រាប់ថវិកាមូលធនដែលមាន។ គម្រោងដែលបានរួមបញ្ចូលនៅក្នុងផែនការវិនិយោគជារឿយៗ តែងមានការខ្វះខាតក្នុងត្រៀមរៀបចំការងារក៏ដូចជាការសិក្សាពីលទ្ធភាពការទិញដី ឬការចំណាយលម្អិតផ្សេងៗ។ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ជាអ្នកទទួលបន្ទុកក្នុងការអនុវត្តការវិភាគលើអត្ថប្រយោជន៍ក្នុងការចំណាយ និងការវាយតម្លៃ គម្រោងសម្រាប់គម្រោងវិនិយោគមូលធនដោយមានការសម្របសម្រួលជាមួយនឹងក្រសួងពាក់ព័ន្ធ។ ទោះយ៉ាងណាក៏ដោយ មានចំនួននៃបុគ្គលិកមានកម្រិតក្នុងគម្រោងទាំងអស់មិនត្រូវបានវាយតម្លៃទេ។

រដ្ឋបាលខេត្តក្រុងស្ថិតនៅក្រោមអំណាចរបស់រដ្ឋបាលថ្នាក់ជាតិ និងក្រសួងដែលពាក់ព័ន្ធ ជាពិសេសតាមរយៈតំណាងនៃក្រសួងមហាផ្ទៃ។ ការវិនិយោគដើមទុនត្រូវបានគ្រោងទុកនៅរដ្ឋបាលថ្នាក់ជាតិនឹងត្រូវបានអនុវត្តតាមរយៈក្រសួងពាក់ព័ន្ធដោយមានការចូលរួមពីមន្ត្រីរាជរដ្ឋាភិបាលក្នុងមូលដ្ឋាន។ តារាងទី ១.៩ ពិពណ៌នាអំពីការចូលរួមរបស់រដ្ឋបាលមូលដ្ឋានក្នុងវដ្តថវិកាប្រចាំឆ្នាំ។

## តារាងទី ១.៩. តួនាទីនៃរដ្ឋបាលមូលដ្ឋានក្នុងដំណើរការរៀបចំថវិកាប្រចាំឆ្នាំ[៧៣]

| ដំណាក់កាល | សកម្មភាព | រយៈពេល | ស្ថាប័នទទួលខុសត្រូវ | ការចូលរួមពីរដ្ឋបាលមូលដ្ឋាន |
|---|---|---|---|---|
| ដំណាក់កាលទី ១ | ផែនការយុទ្ធសាស្ត្រថវិកា | មីនា-ឧសភា | | |
| ១.១ | ក្របខ័ណ្ឌម៉ាក្រូសេដ្ឋកិច្ច និងគោលនយោបាយហិរញ្ញវត្ថុសាធារណៈ | មីនា | ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ | មិនមាន |
| ១.២ | សារាចរស្តីពីការរៀបចំផែនការយុទ្ធសាស្ត្រថវិកា | មេសា-ឧសភា | ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ | អភិបាលខេត្ត/ស្រុក មានរយៈពេល ៦ សប្តាហ៍ក្នុងការរៀបចំផែនការយុទ្ធសាស្ត្រថវិកា |
| ដំណាក់កាលទី ២ | ការរៀបចំកញ្ចប់ថវិកា | មិថុនា-កញ្ញា | | |
| ២.១ | សារាចរស្តីពីការរៀបចំសេចក្តីព្រាងច្បាប់ថវិកា | មិថុនា | ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ | ចំណូលនិងចំណាយថវិកាលម្អិតដែលបានផ្ញើទៅក្រសួងពាក់ព័ន្ធ និងអភិបាលខេត្ត / ស្រុក |

[73] RGC. “Law on Public Finance System of Cambodia,” (2008).

| | | | | |
|---|---|---|---|---|
| ២.២ | ការចរចាលើកញ្ចប់ថវិកាថ្នាក់បច្ចេកទេស | កក្កដា | | |
| ២.៣ | ការចរចាលើកញ្ចប់ថវិកាថ្នាក់រដ្ឋមន្ត្រី | សីហា | ក្រសួងពាក់ព័ន្ធ | កិច្ចពិភាក្សារវាងក្រសួងពាក់ព័ន្ធនិងរដ្ឋបាលមូលដ្ឋាន |
| ២.៤ | ការរៀបចំសេចក្ដីព្រាងច្បាប់ថវិកា | កញ្ញា | ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ | មិនមាន |
| ដំណាក់កាលទី ៣ | ការអនុម័តថវិកា | តុលា-ធ្នូ | | |
| ៣.១ | ការអនុម័តដោយក្រុមប្រឹក្សាគណៈរដ្ឋមន្ត្រី | តុលា | គណៈរដ្ឋមន្ត្រី | មិនមាន |
| ៣.២ | ការអនុម័តដោយរដ្ឋសភា | វិច្ឆិកា | រដ្ឋសភា | មិនមាន |
| ៣.៣ | ការអនុម័តដោយព្រឹទ្ធសភា | ធ្នូ | ព្រឹទ្ធសភា | មិនមាន |

យោងតាមច្បាប់ស្ដីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈឆ្នាំ២០០៨ រដ្ឋបាលមូលដ្ឋានគ្រប់ថ្នាក់ឋានានុក្រមទាំងអស់ត្រូវហាមឃាត់ក្នុងការខ្ចីប្រាក់ ដើម្បីបង្កើតឱនភាពថវិកា ដើម្បីបង្កើនពន្ធ និងបង្កើតពន្ធថ្មី។ នេះគឺជាការអនុវត្តជាទូទៅសម្រាប់ប្រទេសកំពុងអភិវឌ្ឍជាច្រើន ដែលរដ្ឋាភិបាលព្យាយាមធានាឱ្យបាននូវវិន័យសារពើពន្ធទូទាំងប្រទេស និងបង្ការរដ្ឋបាលមូលដ្ឋានពីការចំណាយហួសកម្រិត ឬការចំណាយហួសហេតុដែលភាគច្រើនដោយសារតែកង្វះខាតហិរញ្ញវត្ថុ អសមត្ថភាពក្នុងការគ្រប់គ្រង និងសងបំណុល។ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងក្រសួងពាក់ព័ន្ធនានាត្រូវទទួលខុសត្រូវក្នុងការរៀបចំ និងអនុវត្តផែនការសារពើពន្ធសម្រាប់ការរៀបចំផែនការហេដ្ឋារចនាសម្ព័ន្ធមូលធនធំៗ ហើយយន្តការហិរញ្ញប្បទានដែលមានលក្ខណៈច្នៃប្រឌិតជាងមុន ដូចជាកម្រៃពីផាកពិន័យសម្រាប់ផលប្រយោជន៍សាធារណៈនៅមិនទាន់ត្រូវបានគេយកមកពិចារណា ព្រោះវាមានភាពមិនច្បាស់លាស់នៅក្នុងច្បាប់ ដែលថាតើក្រុងមានសិទ្ធិក្នុងការបង្កើត និងដកហូតសិទ្ធិទាំងនេះ។ បច្ចុប្បន្ននេះរដ្ឋបាលក្រុងធ្វើការរក្សាទុកនូវចំណូលដែលប្រមូលបានពីកាតព្វកិច្ចបង់ពន្ធប្រថាប់ត្រា។ ការប្រើប្រាស់នៃការចាប់យកតម្លៃដីធ្លីហាក់ដូចជាមានកម្រិត ទោះបីជាទីក្រុងនានាត្រូវបានគេដឹងថាការប្រើប្រាស់ដីជាការចូលរួមវិភាគទានដើមទុនដល់ភាគហ៊ុនគម្រោងក៏ដោយ។ កម្មវិធីវិមជ្ឈការ និងវិសហមជ្ឈការកំពុងផ្ទេរជាបណ្ដើរៗ នូវប្រតិបត្តិការហេដ្ឋារចនាសម្ព័ន្ធនានា ដែលសាងសង់ដោយរដ្ឋបាលថ្នាក់ជាតិទៅរដ្ឋបាលមូលដ្ឋាន។ មានន័យថា រដ្ឋបាលមូលដ្ឋានមានទំនួលខុសត្រូវកាន់តែខ្លាំងឡើង សម្រាប់ប្រតិបត្តិការ និងការថែទាំហេដ្ឋារចនាសម្ព័ន្ធ ដែលបានដាក់ឱ្យអនុវត្ត។ តាមបទពិសោធន៍បានបង្ហាញថា ក្រុងមួយចំនួនកំពុងជួបប្រទះបញ្ហាប្រឈមផ្នែកហិរញ្ញវត្ថុ និងធនធានមនុស្ស ក្នុងការធ្វើឱ្យប្រតិបត្តិការថែរក្សា និងការផ្ដល់មូលនិធិប្រតិបត្តិ និងថែរក្សាហេដ្ឋារចនាសម្ព័ន្ធ ដែលបង្កើតឡើងដោយហិរញ្ញប្បទានរបស់ម្ចាស់ជំនួយនិងរាជរដ្ឋាភិបាល។

## យន្តការថវិការដ្ឋបាលថ្នាក់ក្រោមជាតិ

យន្តការក្នុងការផ្ដល់ថវិកាសម្រាប់រដ្ឋបាលថ្នាក់ក្រោមជាតិមានភាពខុសគ្នាគួរឱ្យកត់សម្គាល់ តាមរយៈឋានានុក្រមនៃរដ្ឋបាលថ្នាក់ក្រោមជាតិ។ ចំណូលដែលបានលើស នៅក្នុងឃុំសង្កាត់ចំនួន ៩៨,៤% ក្នុងឆ្នាំ ២០១៦ បានមកពីការផ្ទេរសារពើពន្ធដែលភាគច្រើនមកពីមូលនិធិឃុំសង្កាត់។ ទោះបីជាច្បាប់ឃុំសង្កាត់ (២០០១) ផ្ដល់អំណាចដល់ឃុំនិងសង្កាត់ ដើម្បីដំឡើងថ្លៃពន្ធក៏ដោយ ក៏គ្មាន

នរណាម្នាក់ត្រូវបានគេកំណត់ ឬប្រមូលពន្ធបានដែរ។ ប្រាក់ចំណូលភាគច្រើនសម្រាប់ខណ្ឌនិងក្រុងនៅក្រៅរាជធានីភ្នំពេញ បានមកពីខណ្ឌ និង ថវិកាក្រុង ស្រុក។ ការផ្លាស់ប្តូរគួរឱ្យកត់សម្គាល់ដោយទីក្រុងភ្នំពេញបានផ្ទេរដោយផ្ទាល់ពីខណ្ឌទាំង ១២ របស់ខ្លួនហើយក៏មានការផ្ទេរពីខេត្តនានាទៅស្រុកនិងក្រុងផងដែរ។ ប្រហែល ៩៣,០% នៃប្រាក់ចំណូលសរុបក្នុងស្រុកខណ្ឌ រដ្ឋបាលក្រុង និងខណ្ឌ ក្នុងឆ្នាំ២០១៤-២០១៦ បានមកពីការផ្ទេរពីរដ្ឋបាលរាជធានីភ្នំពេញ និងការផ្ទេរមកតាមខេត្ត។ រដ្ឋបាលក្រុងនិងស្រុក មិនមានជាប់ការបង់ពន្ធលើប្រាក់ចំណូលណាមួយទេ ប៉ុន្តែចាប់ពីឆ្នាំ២០១៧ នេះរដ្ឋបាលក្រុង ខណ្ឌនិងសង្កាត់មួយចំនួន នឹងត្រូវបែងចែកសមាមាត្រនៃពន្ធលើទ្រព្យមួយចំនួន។

ប្រាក់ចំណូលមិនជាប់ពន្ធ ដែលប្រមូលបាននៅកម្រិតនេះ សង្កាត់ ខណ្ឌ ភាគច្រើនមានទំហំធំជាងនៅតាមទីប្រជុំជនធំៗ ជាពិសេសរាជធានីភ្នំពេញ។ ចំណូលដ៏ច្រើនរបស់រដ្ឋបាលខេត្តនិងរាជធានីភ្នំពេញបានមកពីចំណូលសារពើពន្ធ និងចំណូលមិនមែនសារពើពន្ធ ដែលបានផ្តល់ដល់ទៅ ៧៨,៣% នៃប្រាក់ចំណូលសរុប (ឆ្នាំ២០១៦) ។ ពន្ធដែលបណ្តាខេត្តនិងរាជធានីភ្នំពេញត្រូវជាប់ត្រូវបានប្រមូលតាមរយៈអគ្គនាយកដ្ឋានពន្ធដារនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

កម្មវិធីវិនិយោគ ៣ ឆ្នាំរបស់រាជរដ្ឋាភិបាលត្រូវបានអនុវត្តដើម្បីលើកកម្ពស់ការផ្តល់សេវាសង្គមដោយបានប្រើប្រាស់ថវិកាក្រុង ស្រុក និងមូលនិធិឃុំ សង្កាត់។ ប្រព័ន្ធផែនការគ្រប់គ្រងហិរញ្ញវត្ថុ ត្រូវបានបង្កើត និងពិនិត្យឡើងវិញ។ ទាំងនេះត្រូវបានគេរំពឹងថានឹងផ្តល់ដល់រដ្ឋបាលថ្នាក់ក្រោមជាតិ (SNAs) ជាមួយនឹងស្វ័យភាពបន្ថែមទៀតដើម្បីកាត់បន្ថយការពន្យារពេលក្នុងការផ្តល់មូលនិធិនិងដើម្បីជួយសម្រួលដល់រដ្ឋបាលថ្នាក់ក្រោមជាតិក្នុងការអភិវឌ្ឍ និងអនុវត្តផែនការដែលមានគោលដៅយុទ្ធសាស្ត្ររបស់រដ្ឋយ៉ាងទូលំទូលាយ និងច្បាស់លាស់។

មូលនិធិឃុំ សង្កាត់ ត្រូវបានបង្កើតឡើងកាលពីឆ្នាំ២០០២ ជាកញ្ចប់ថវិកាមួយមិនមានលក្ខខណ្ឌ ដែលកំណត់អត្រា ២,៨% នៃចំណូលចរន្តថវិការដ្ឋ។ ដោយសារមានការកើនឡើងនូវចំណូលជាតិ ទំហំនៃមូលនិធិឃុំ សង្កាត់ ក៏មានការកើនឡើងយ៉ាងលឿនផងដែរ។ នៅឆ្នាំ២០១៤ ទំហំមូលនិធិឃុំ សង្កាត់ មានចំនួន ៥៨,៥ លានដុល្លារសហរដ្ឋអាមេរិច ឬស្មើនឹង ៣៥.៩០០ ដុល្លារសហរដ្ឋអាមេរិចក្នុងមួយឃុំ សង្កាត់ ដែលចំនួននេះគឺច្រើនជាងបួនដងបើធៀបទៅឆ្នាំ២០០៣។ ការវិភាជន៍ថវិការដ្ឋសម្រាប់មូលនិធិឃុំ សង្កាត់ មានការកើនឡើងជាលំដាប់ពីមួយឆ្នាំទៅមួយឆ្នាំ ដែលជាបច្ច័យល្អមួយសម្រាប់ការអភិវឌ្ឍនៅថ្នាក់ក្រោមជាតិ។ ការបែងចែកទៅ ឃុំ សង្កាត់នីមួយៗគឺមានរូបមន្តក្នុងការបែងចែក ហើយដែលផ្តោតលើកត្តាចំនួនប្រជាជន និងភាពក្រីក្រ។ មូលនិធិនេះត្រូវបានបែងចែកទៅជា ២ សមាសភាគ គឺផ្នែករដ្ឋបាល និងផ្នែកអភិវឌ្ឍន៍មូលដ្ឋាន។ ដោយសារតែប្រាក់ខែមន្ត្រីរាជការមានការកើនឡើងចំនួនថវិកាទៅផ្នែករដ្ឋបាលគឺឡើងជិតដល់ ៤៥% ក្នុងឆ្នាំ២០១៤ ។ មូលនិធិរបស់ ឃុំ សង្កាត់ត្រូវបានប្រើប្រាស់ភាគច្រើនដើម្បីអភិវឌ្ឍន៍ហេដ្ឋារចនាសម្ព័ន្ធខ្នាតតូចដូចជាផ្លូវតាមជនបទ ប្រព័ន្ធធារាសាស្ត្រ និងការផ្គត់ផ្គង់ទឹក។

នៅចុងឆ្នាំ២០១៩ រាជរដ្ឋាភិបាលកម្ពុជាបានសន្យាបង្កើនថវិកាប្រចាំឆ្នាំទ្វេដងសម្រាប់មូលនិធិឃុំ សង្កាត់ នៃគ្រប់ឃុំ / សង្កាត់ទាំង ១៦៤៦ ដែលនឹងទទួលបានថវិកាប្រមាណជា ១៣០.០០០ ដុល្លារអាមេរិកចាប់ពីដើមឆ្នាំ២០២០ តែតម្រូវឱ្យមានថវិកាមូលនិធិឃុំ សង្កាត់សរុបច្រើនជាង ២០០ លានដុល្លារអាមេរិកចាប់ពីឆ្នាំ២០២០ហើយនឹងនៅដដែលរហូតដល់ឆ្នាំ២០២៣។[៧៤]

[74] Vann Vichar, “Communes Budgets to More Than Double to $130,000,” Voices of Democracy (VoD), last modified October 10, 2019, https://vodenglish.news/commune-budgets-to-more-than-double-to-130000/

រូបភាពទី១.៦. ចំនួនមូលនិធិឃុំ សង្កាត់ តាមឆ្នាំ (ជាលានដុល្លារសហរដ្ឋអាមេរិក)[៧៥]




*ប្រភព៖ របាយការណ៍ប្រចាំឆ្នាំស្តីពីការអនុវត្តគម្រោងថ្នាក់ក្រោមជាតិ ២០១៧ (NCDD)*

ថវិកាក្រុង ស្រុក ត្រូវបានបង្កើតឡើងដោយអនុក្រឹត្យលេខ ៣៦ អនក្រ.បក ចុះថ្ងៃទី០៧ ខែមីនា ឆ្នាំ២០១២ (អនុក្រឹត្យស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃមូលនិធិក្រុង ស្រុក)។ ក្នុងអំឡុងឆ្នាំ ២០១៤ មូលនិធិបានកំណត់ថវិកាចំនួន ២១លានដុល្លារអាមេរិក ឬប្រហែល ១១៤.០០០ដុល្លារអាមេរិក ក្នុងមួយក្រុង ស្រុក។ ក្នុងចំនួននេះ ថវិកា១៧លានដុល្លារអាមេរិក ត្រូវបានផ្តល់ដោយរាជរដ្ឋាភិបាល (ភាគច្រើនគឺដើម្បីចំណាយលើរដ្ឋបាល និងប្រាក់ខែ) ហើយថវិកាចំនួន ៤លានដុល្លារអាមេរិក ត្រូវបានផ្តល់ដោយភ្នាក់ងារសហប្រតិបត្តិការអភិវឌ្ឍន៍អន្តរជាតិរបស់ប្រទេសស៊ុយអែត (Swedish International Development Cooperation Agency - SIDA) និងប្រើប្រាស់សម្រាប់ការអភិវឌ្ឍ (២១.៦០០ ដុល្លារក្នុងមួយក្រុង ស្រុក)។

ក្នុងដំណាក់កាលដំបូងនៃអាយភីស្រី (IP៣) ឧបករណ៍និយ័តកម្មទាំងអស់ដែលប្រើសម្រាប់បង្កើតមូលនិធិក្រុង ស្រុកត្រូវបានបញ្ចប់។ មានបុគ្គលិកចំនួន ២៩នាក់ បានទទួលការបណ្តុះបណ្តាល និងគណៈកម្មការ និងអង្គភាពលទ្ធកម្មត្រូវបានបង្កើតឡើង។ អនុក្រឹត្យថ្មី លេខ ៥០ អនក្រ.បក ស្តីពីការផ្ទេរធនធានពីថវិការដ្ឋជូនមូលនិធិក្រុង ស្រុក (២០១៩-២០២៣) ចុះថ្ងៃទី១១ ខែមេសា ឆ្នាំ២០១៨ នឹងបង្កើនចំនួនថវិកាចាប់ពី ១,១% (២០១៩) ទៅដល់ ១,៥% (២០២៣) នៃចំណូលចរន្តថវិកាជាតិ ហើយនឹងយកទៅប្រើប្រាស់ទាំងផ្នែកប្រតិបត្តិការរដ្ឋបាលទូទៅ និងផ្នែកអភិវឌ្ឍន៍មូលដ្ឋាន។

សំរាប់រដ្ឋបាលក្រុង ស្រុក ដើម្បីក្លាយទៅជាស្ថាប័នផ្តល់សេវាសាធារណៈបានល្អប្រសើរ និងដែលអាចរួមចំណែកដល់ការអភិវឌ្ឍជាតិ ពួកគេចាំបាច់ត្រូវមានធនធានចាំបាច់ដែលប្រើប្រាស់សម្រាប់តែទៅលើផ្នែកអភិវឌ្ឍន៍។ នៅក្នុងដំណាក់កាលទី២ នៃផែនការអនុវត្តន៍កម្មវិធីជាតិស្តីពីការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ (NP-SNDD) ចំនួនថវិកាសម្រាប់សមាសភាពអភិវឌ្ឍន៍ក្រុង ស្រុក ត្រូវបានគេរំពឹងថានឹងមានយ៉ាងហោចណាស់ ០,៥% នៃថវិកាចំណូលចរន្តជាតិជារៀងរាល់ឆ្នាំចាប់ពីឆ្នាំ២០១៦ ដល់ឆ្នាំ២០១៨ ហើយរដ្ឋបាលក្រុង ស្រុក រំពឹងថានឹងអាចរកប្រាក់ចំណូលបានយ៉ាងហោចណាស់ ១០% នៃប្រាក់ចំណូលសរុបរបស់ពួកគេតាមរយៈធនធានក្នុងមូលដ្ឋាន។

[75] NCDD, NCDD's Annual Report, 2017.

## តារាងទី១.១០. មូលនិធិក្រុង ស្រុក (លានរៀល)[៧៦]

| ក្រុង | ២០១៧ | | | ២០១៨ | | |
|---|---|---|---|---|---|---|
| | រដ្ឋបាល | គម្រោងអភិវឌ្ឍន៍ | សរុប | រដ្ឋបាល | គម្រោងអភិវឌ្ឍន៍ | សរុប |
| ក្រុងសៀមរាប | ៨២២,២៥ | ៣១១,៨៦ | ១១៣៤,១១ | ៩០២,៦ | ៣៤៦,៥២ | ១២៤៩,១២ |
| ក្រុងបាត់ដំបង | ៧៥៤,៨៦ | ២៥៦,៩៦ | ១០១១,៨២ | ៨២៧,៦៧ | ២៨៩,០៨ | ១១១៦,៧៥ |
| ក្រុងព្រះសីហនុ | ៥៨៧,២៥ | ១៨៧,៨៨ | ៧៧៥,១៣ | ៧៣៨,៦៧ | ២១៤,៣ | ៩៥២,៩៧ |
| ក្រុងកែប | ៣៨៦,០១ | ១៥០,០៣ | ៥៣៦,០៤ | ៤៥៥,០៧ | ១៦៧,៦៥ | ៦២២,៧២ |
| ក្រុងកំពង់ចាម | ៤៦១,៨ | ១៦២,១៤ | ៦២៣,៩៤ | ៥៧០,៣៧ | ១៨១,៩៨ | ៧៥២,៣៥ |
| ក្រុងសួង | ៤២១,៣៣ | ១៥០,៦ | ៥៧១,៩៣ | ៤៩៣,២៨ | ១៦៨,១ | ៦៦១,៣៨ |
| ក្រុងបាវិត | ៤៨៨,៤៧ | ១៦៦ | ៦៥៤,៤៧ | ៥៤៤,៥១ | ១៨៥,៩ | ៧៣០,៤១ |

*ប្រភព៖ នាយកដ្ឋានគ្រប់គ្រងថវិកាថ្នាក់ក្រោមជាតិ នៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ*

ថវិកាខេត្ត គឺជាថវិកាដែលទទួលបានពីប្រភពចម្រុះនៃចំណូលជាតិ និងការចូលរួមពីថវិការដ្ឋ។ ក្នុងឆ្នាំ ២០១៤ វាមានចំនួន ១៥៨ លានដុល្លារអាមេរិក។ ជាផ្នែកមួយនៃដំណាក់កាលបន្ទាប់ ដំណើរការធ្វើផែនការ នឹងត្រូវកែសម្រួលឡើងវិញដើម្បីឱ្យវាមានសមភាព និងតម្លាភាពជាងមុន។ វានឹងត្រូវធ្វើឡើងដោយមានរូបមន្តសមស្រប និងមានលក្ខណៈស្មើភាព។ ថ្វីបើមិនមានចែងនៅក្នុងបទបញ្ញត្តិក៏ដោយ សម្រាប់រយៈពេលពីឆ្នាំចុងក្រោយនេះ ចំនួនមូលនិធិត្រូវបានបែងចែកទៅរាជធានី ខេត្ត ដោយផ្អែកលើរូបមន្តបណ្តោះអាសន្ន។ រូបមន្តនេះ ត្រូវបានកែលម្អជាបន្តបន្ទាប់ដោយផ្អែកលើអនុសាសន៍ជារឿយៗពីរាជធានី ខេត្ត។

មូលនិធិវិនិយោគរដ្ឋបាលថ្នាក់ក្រោមជាតិ (SNIF) ត្រូវបានបង្កើតឡើងក្នុងឆ្នាំ ២០១៦ ដោយអនុក្រឹត្យលេខ ៣២ ស្តីពីការបង្កើត និងមុខងារនៃមូលនិធិវិនិយោគរដ្ឋបាលថ្នាក់ក្រោមជាតិ ដើម្បីផ្តល់នូវថវិកាពីរដ្ឋបាលកណ្តាល និងពីប្រភពដទៃទៀតសម្រាប់គម្រោងវិនិយោគសាធារណៈដែលត្រូវបានរៀបចំ និងអនុវត្តដោយរដ្ឋបាលថ្នាក់ក្រោមជាតិ។ មូលនិធិវិនិយោគរដ្ឋបាលថ្នាក់ក្រោមជាតិ គឺជាក្របខណ្ឌផ្តល់ហិរញ្ញប្បទានផ្តោតលើគម្រោងវិនិយោគ ដែលអាចបែងចែកទៅឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិ នៅថ្នាក់ខេត្ត ស្រុក និងឃុំ ដើម្បីគាំទ្រការវិនិយោគប្រកបដោយនិរន្តរភាពលើហេដ្ឋារចនាសម្ព័ន្ធ និងការអភិវឌ្ឍសេដ្ឋកិច្ចមូលដ្ឋាន។ ហេតុផលសម្រាប់ការបង្កើតមូលនិធិវិនិយោគរដ្ឋបាលថ្នាក់ក្រោមជាតិ គឺដើម្បី (i) បន្ថយសម្ពាធនៃការប្រើប្រាស់ថវិកាជំនួយឥតសំណងសម្រាប់គម្រោងហេដ្ឋារចនាសម្ព័ន្ធធំៗ ដែលកត្តានេះនឹងធ្វើឱ្យចំនួនថវិកាជំនួយឥតសំណងកើនឡើងសម្រាប់ការងារអភិបាលកិច្ច ការអភិវឌ្ឍសេដ្ឋកិច្ចនៅមូលដ្ឋាន (ដោយសហការដៃគូជាមួយវិស័យឯកជន) សេវាកម្មសង្គម និងការផ្តល់សេវាគាំពារសង្គមដល់ជនងាយរងគ្រោះ និង (ii) ដើម្បីកែលម្អដំណើរការវាយតម្លៃនៃការវិនិយោគហេដ្ឋារចនាសម្ព័ន្ធដែលអាចអនុញ្ញាតឱ្យមានការវាយតម្លៃលើគម្រោងនានាទាក់ទងនឹងផលប៉ះពាល់នៃការអភិវឌ្ឍ។ មូលនិធិវិនិយោគរដ្ឋបាលថ្នាក់

[៧៦] Department of Sub-National Budget Management, “The District/Municipality Fund,” from 2017-2018

ក្រោមជាតិ មានការវិនិយោគលើវិស័យខុសៗគ្នា (ប្រកនៃការវិនិយោគ) លើហេដ្ឋារចនាសម្ព័ន្ធ ការគ្រប់គ្រងធនធានធម្មជាតិ ការប្រែប្រួលអាកាសធាតុនិងការអភិវឌ្ឍសេដ្ឋកិច្ចមូលដ្ឋាន។ ប្រភពថវិកាសម្រាប់មូលនិធិវិនិយោគរដ្ឋបាលថ្នាក់ក្រោមជាតិ រួមមានថវិកាជាតិ (រហូតដល់ ០,០៧% នៃប្រាក់ចំណូលចរន្តត្រឹមឆ្នាំ២០២០) និងការរួមចំណែកពីម្ចាស់ជំនួយ និងដៃគូអភិវឌ្ឍន៍។ មូលនិធិវិនិយោគរដ្ឋបាលថ្នាក់ក្រោមជាតិ ត្រូវបានដឹកនាំដោយក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

ក្រសួងបរិស្ថាន - ការរៀបចំមុខងារថវិកាឡើងវិញដល់រដ្ឋបាលថ្នាក់ក្រោមជាតិ៖ អនុក្រឹត្យលេខ ១១៣ (ឆ្នាំ២០១៥) និងប្រកាសរួម (២០១៦) បានផ្ទេរការទទួលខុសត្រូវជាកាតព្វកិច្ចចំពោះការគ្រប់គ្រងសំរាម និងសំណល់រឹង ឱ្យទៅរដ្ឋបាលស្រុកនិងក្រុង ដោយបន្សល់ទុកនូវគោលនយោបាយអភិវឌ្ឍន៍បច្ចេកទេស គាំទ្រ និងត្រួតពិនិត្យជាមួយក្រសួង។ ឥឡូវនេះ រដ្ឋបាលក្រុងចំនួន ២៦ ទទួលបានថវិកាបន្ថែមតិចតួច ដើម្បីគាំទ្រមុខងារនេះ (ប្រហែល ២លានដុល្លារអាមេរិកក្នុងមួយឆ្នាំ) ប៉ុន្តែរដ្ឋបាលស្រុកជាច្រើនត្រូវការស្វែងរកប្រភពពីមូលនិធិដែលគ្មានលក្ខខណ្ឌ។ គំនិតផ្តួចផ្តើមផ្សេងទៀត ដែលត្រូវបានអនុម័ត និងកំពុងដំណើរការ គឺ (i) ការផ្ទេរការទទួលខុសត្រូវជាក់លាក់សម្រាប់ការគ្រប់គ្រងតំបន់ការពារដល់ ៦៤ ស្រុក (ii) ការផ្តល់ការទទួលខុសត្រូវនឹងការប្រែប្រួលអាកាសធាតុតាមរយៈជំនួយតិចតួចក្នុងស្រុក និង (iii) ការផ្ទេរការទទួលខុសត្រូវសម្រាប់ការអប់រំលើបរិស្ថាន។ ក្រសួង ក៏កំពុងបន្តការងាររៀបចំសម្រាប់ការផ្ទេរមុខងារផ្សេងទៀតរួមមាន (i) ការគ្រប់គ្រងកាកសំណល់រាវ និងការគ្រប់គ្រងលូទឹកកខ្វក់ (ii) ការគ្រប់គ្រងសំរាមប្លាស្ទិក និង (iii) ការងាររបស់អ្នកអភិរក្សសម្រាប់តំបន់ការពារ។

ក្រសួងតាមវិស័យផ្សេងទៀត ក៏ត្រូវបានអនុវត្តវិធីសាស្ត្រនេះផងដែរ ដូចជាការអប់រំ ការធ្វើកិច្ចការសង្គមសុខភាព។ ឧទាហរណ៍ក្រសួងសង្គមកិច្ច អតីតយុទ្ធជននិងយុវនីតិសម្បទា បានផ្ទេរមុខងារត្រួតពិនិត្យអង្គការសង្គមស៊ីវិលដែលធ្វើការជាមួយក្មេងកំព្រា ពីរដ្ឋបាលខេត្ត ក្រុង និងស្រុក ទោះបីជានេះជាការទទួលខុសត្រូវរបស់រដ្ឋបាលក្រុង និងស្រុកក៏ដោយ។[៧៧]

ចំណូលពីប្រភពផ្ទាល់ខ្លួន៖មិនមានប្រាក់ចំណូលពីប្រភពផ្ទាល់ខ្លួននៅរដ្ឋបាលថ្នាក់ក្រោមជាតិទេ។ គ្មានរដ្ឋបាលថ្នាក់ក្រោមជាតិណាមួយដែលមានអំណាច ក្នុងការដំឡើងពន្ធថ្មី ឬផ្លាស់ប្តូរលក្ខណៈឬកែប្រែអត្រាពន្ធដែលមានស្រាប់នោះទេ។ លើសពីនេះទៀត រដ្ឋបាលថ្នាក់ក្រោមជាតិគ្រប់កម្រិត មានតែអំណាចក្នុងការកំណត់ការដាក់ចេញឬកែទម្រង់គោលនយោបាយ និងអត្រាចំណូលមិនមែនសារ-ពើពន្ធតែប៉ុណ្ណោះ។ រាល់ចំណូលពន្ធ និងចំណូលមិនមែនសារពើពន្ធភាគច្រើនត្រូវបានប្រមូលដោយរដ្ឋបាលរបស់អគ្គនាយកដ្ឋានពន្ធដារ និងអគ្គនាយកដ្ឋានចំណូលមិនមែនសារពើពន្ធរបស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ដោយគ្មានវត្តមាននៃអង្គភាពប្រមូលចំណូលក្នុងរដ្ឋបាលថ្នាក់ក្រោមជាតិ។ ដោយសារការរៀបចំចំណូលត្រូវបានអនុវត្តតាមបែបរិមជ្ឈការ មានវិសាលភាពកំណត់ សម្រាប់បង្កើតគណនេយ្យភាពក្នុងស្រុក ដូចនេះអំណាចរវាងកម្រិតរដ្ឋបាលថ្នាក់ក្រោមជាតិមានភាពខុសគ្នាយ៉ាងខ្លាំង។ ច្បាប់ស្តីពីឃុំសង្កាត់ (២០០១) បានផ្តល់សិទ្ធិអំណាចក្នុងការប្រមូលពន្ធនិងចំណូលដែលមិនរាប់បញ្ចូលទាំងពន្ធលើដីធ្លី ពន្ធលើអចលនវត្ថុនិងពន្ធបានមកពីការជួល។ ទោះយ៉ាងណាក៏ដោយ ច្បាប់ស្តីពីប្រាក់ចំណូល ដែលកំពុងមានតម្រូវការ មិនដែលត្រូវបានអនុម័ត និងគ្មានការប្រមូលប្រាក់ណាមួយ បានកើតឡើងនៅក្នុងការអនុវត្តជាក់ស្តែងទេ។ រដ្ឋបាលស្រុក មិនមានអំណាចអនុវត្តទាក់ទងនឹងបញ្ហាពន្ធនោះទេ ទោះបីជាអំណាចពន្ធទូទៅត្រូវបានផ្តល់ជូននៅក្នុងច្បាប់រៀបចំអង្គការ (ឆ្នាំ២០០៨) និងនៅក្នុងច្បាប់ស្តីពីហិរញ្ញវត្ថុថ្នាក់ក្រោមជាតិ (ឆ្នាំ២០១១) ដែលរដ្ឋទាំងពីរនេះបានផ្តល់អំណាចក្នុងការប្រមូលប្រាក់ចំណូលដែលមិនមាន។ ទោះយ៉ាងណាក៏ដោយមិនមានច្បាប់ដូចដែលបានស្នើសុំទេ។[៧៨]

ជារួមគឺរដ្ឋបាលថ្នាក់ក្រោមជាតិ ត្រូវការកញ្ចប់ធនធានថវិកាបន្ថែមទៀត ដើម្បីបំពេញភារកិច្ចតាមអាណត្តិរបស់ពួកគេដោយជោគជ័យ។ ប្រភពធនធានថវិកា ក៏គួរត្រូវបានផ្លាស់ប្តូរពីរដ្ឋាភិបាលថ្នាក់ជាតិទៅឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិ ពោលគឺអនុញ្ញាតឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិបង្កើតប្រភពប្រាក់ចំណូលដោយផ្ទាល់ខ្លួនដើម្បីបន្ថយការពឹងផ្អែកតែទៅលើការផ្ទេរពីថ្នាក់ជាតិ ហើយវាក៏នឹងជួយពង្រឹងគណនេយ្យភាព និងការទទួលខុសត្រូវចំពោះប្រជាពលរដ្ឋក្នុងមូលដ្ឋាន។ ការគ្រប់គ្រងហិរញ្ញវត្ថុ គួរតែត្រូវបានពង្រឹងដើម្បី

[77] ADB, "Fiscal Decentralization Reform in Cambodia: Progress over the Past Decade and Opportunities," last modified December 2018, DOI: http://dx.doi.org/10.22617/TCS189247

[78] ADB, last modified December 2018.

កាត់បន្ថយការពន្យារពេលក្នុងការរៀបចំផែនការថវិកា ការធ្វើរបាយការណ៍ថវិកា និងការផ្ទេរថវិកា។ ការធ្វើបែបនេះ នឹងកាន់តែមានសារសំខាន់ឡើងនៅពេលដែលធនធានហិរញ្ញវត្ថុបន្ថែមត្រូវបានដាក់ក្រោមការគ្រប់គ្រងរបស់រដ្ឋបាលក្រុង ស្រុក។ រដ្ឋបាលថ្នាក់ក្រោមជាតិ គួរតែខិតខំប្រឹងប្រែងធ្វើយ៉ាងណាកាត់បន្ថយការចំណាយលើថ្លៃរដ្ឋបាលដើម្បីឱ្យចំនួនថវិកាមានការកើនឡើងសម្រាប់គម្រោងអភិវឌ្ឍន៍នានានៅមូលដ្ឋាន។

## ១.៦.២. ជំនួយសម្រាប់ការអភិវឌ្ឍផ្លូវការ

ហិរញ្ញប្បទានអភិវឌ្ឍន៍ជាធម្មតាបានតាមរយៈធនាគារអភិវឌ្ឍន៍ទ្វេភាគី ឬពហុភាគី ឬទីភ្នាក់ងារអភិវឌ្ឍន៍ និងអង្គការក្រៅរដ្ឋាភិបាល។ ក្នុងករណីសិក្សាភាគច្រើនគម្រោងម្ចាស់ជំនួយដែលផ្តល់ហិរញ្ញប្បទានតាមរយៈជំនួយឥតសំណង ឬប្រាក់កម្ចីសម្បទាន ត្រូវបានអនុវត្តតាមរយៈក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងក្រសួងដែលពាក់ព័ន្ធ។ សម្រាប់គម្រោងមូលនិធិជំនួយបរទេស រដ្ឋបាលថ្នាក់ក្រោមជាតិចាំបាច់ត្រូវទទួលបានការអនុញ្ញាតពីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងក្រសួងពាក់ព័ន្ធ។ ការទទួលបានមូលនិធិទាំងនេះ ត្រូវការកិច្ចខិតខំប្រឹងប្រែងជាច្រើនក្នុងការរៀបចំការសិក្សាជាបឋម និងការសរសេរផែនការគម្រោងការអភិវឌ្ឍន៍ ដើម្បីអនុវត្តស្របតាមលក្ខខន្តិកៈរបស់ម្ចាស់ជំនួយ។ ការបង្ហាញពីបញ្ហាប្រឈមសម្រាប់មន្ត្រីរដ្ឋបាលក្រុង ហើយក្នុងករណីភាគច្រើន គឺត្រូវការការគាំទ្រពីរដ្ឋបាលថ្នាក់ជាតិ និងដៃគូអភិវឌ្ឍន៍។ លើសពីនេះទៅទៀត ដោយសារទំហំនៃក្រុងដែលមានសក្តានុពលបន្តបន្ទាប់នៅក្នុងប្រទេសកម្ពុជាដែលគម្រោងជាច្រើនពុំទាន់មានការទាក់ទាញចំណាប់អារម្មណ៍របស់ម្ចាស់ជំនួយ។ គម្រោងដែលទាក់ទងទៅនឹងដំណោះស្រាយអនាម័យតាមបែបវិមជ្ឈការ ការស្តារនីតិសម្បទាសាធារណៈ ឬដំណោះស្រាយប្រមូលសំរាម ជាញឹកញាប់មិនឆ្លើយតបនឹងការរំពឹងទុកថវិកាអប្បបរមាសម្រាប់ម្ចាស់ជំនួយ។ មានកន្លែងពិសេសមួយ នោះគឺចន្លោះសម្រាប់ម្ចាស់ជំនួយតូចៗដែលមានឆន្ទៈធ្វើការជាមួយរដ្ឋាភិបាល ហើយយន្តការដើម្បីរៀបចំគម្រោងតូចៗ អាចត្រូវបានចាប់ផ្តើម។ សម្រាប់គម្រោងទីក្រុងប្រកបដោយនិរន្តរភាព មូលនិធិអាកាសធាតុមួយចំនួនគួរមានការយកចិត្តទុកដាក់ជាពិសេស។

មូលនិធិបរិស្ថានសកល (GEF) ត្រូវបានបង្កើតឡើងនៅអំឡុងពេលសន្និបាតពិភពលោកនៅឯទីក្រុងរីយ៉ូ (Rio Earth Summit) កាលពីឆ្នាំ១៩៩២ ដើម្បីជួយដោះស្រាយបញ្ហាបរិស្ថានដែលកំពុងមានផលប៉ះពាល់ខ្លាំងបំផុតនៅលើផែនដី។ ចាប់តាំងពីពេលនោះមក មូលនិធិបរិស្ថានសកល បានផ្តល់ជំនួយជាង ១៧ ពាន់លានដុល្លារ និងបានផ្តល់ហិរញ្ញប្បទាន ៨៨ ពាន់លានដុល្លារបន្ថែមទៀតដល់ទៅជាង ៤.០០០ គម្រោងនៅ ១៧០ ប្រទេស។ មូលនិធិបរិស្ថានសកល បានគ្រប់គ្រងមូលនិធិទំនុកចិត្តជាច្រើន។ មូលនិធិបម្រែបម្រួលអាកាសធាតុពិសេស (SCCF) បានផ្តល់ហិរញ្ញប្បទានដល់ការប្រែប្រួល និងការផ្ទេរបច្ចេកវិទ្យានៅតាមប្រទេសដែលកំពុងអភិវឌ្ឍន៍ និងជាហត្ថលេខីនៅក្នុងក្របខ័ណ្ឌអនុសញ្ញាក្របខ័ណ្ឌសហប្រជាជាតិស្តីពីការប្រែប្រួលអាកាសធាតុ (UNFCCC)។ មូលនិធិនេះផ្តល់ការគាំទ្រសម្រាប់ការចំណាយបន្ថែមទៀតនៃកម្មវិធីបន្សាំនឹងការប្រែប្រួលអាកាសធាតុ ដើម្បីជាផលប្រយោជន៍ដែលអាចវាស់វែងបាន[៧៩]។

មូលនិធិសម្រាប់ប្រទេសមានការអភិវឌ្ឍតិចតួចបំផុត (LDCF) គឺផ្តល់ឱ្យសម្រាប់តាមតម្រូវការចាំបាច់ និងបន្ទាន់លើកម្មវិធីបន្សាំរបស់ប្រទេសដែលមានការអភិវឌ្ឍតិចតួចបំផុតចំនួន ៥១ ប្រទេសដែលជាប្រទេសងាយទទួលរងផលប៉ះពាល់ពីការប្រែប្រួលអាកាសធាតុ។ មូលនិធិបន្សាំ មានផ្តល់ជូនសម្រាប់ការគាំទ្រគម្រោង និងកម្មវិធីបន្សាំនៅក្នុងបណ្តាប្រទេសកំពុងអភិវឌ្ឍន៍ដែលជាភាគីនៃពិធីសារក្យូតូ ហើយដែលជាប្រទេសងាយទទួលរងផលប៉ះពាល់អវិជ្ជមាននៃការប្រែប្រួលអាកាសធាតុ[៨០]។

អ្វីដែលទាក់ទងនឹងការអភិវឌ្ឍទីក្រុង គឺកម្មវិធីជំនួយខ្នាតតូច (SGP) របស់មូលនិធិបរិស្ថានសកល ដែលផ្តល់ការគាំទ្រផ្នែកហិរញ្ញវត្ថុ និងបច្ចេកទេសដល់គម្រោងដែលអភិរក្ស និងស្តារធនធានបរិស្ថានឡើងវិញ ព្រមទាំងលើកកម្ពស់សុខមាលភាព និងជីវភាពរបស់ប្រជាជន។ កម្មវិធីជំនួយខ្នាតតូចរបស់មូលនិធិបរិស្ថានសកលបង្ហាញថា សកម្មភាពរបស់សហគមន៍អាចរក្សាតុល្យភាពល្អរវាងតម្រូវការរបស់មនុស្ស និងការចាំបាច់នៃបរិស្ថាន។ កម្មវិធីនេះផ្តល់ជំនួយថវិកាហូតដល់ ៥០.០០០ ដុល្លារ ទៅដល់សហគមន៍មូលដ្ឋានដោយផ្ទាល់ រួមទាំងជនជាតិដើមភាគតិច អង្គការនៅតាមសហគមន៍

[79] For more information about the fund, visit https://www.thegef.org/about/funding

[80] For more information about the fund, visit https://www.thegef.org/about/funding

និងអង្គការមិនមែនរដ្ឋាភិបាលដទៃទៀត សម្រាប់គម្រោងនានាទាក់ទងនឹងជីវៈចម្រុះ ការកាត់បន្ថយ និងបន្សាំពីការបម្រែបម្រួលអាកាសធាតុ ការធ្លាក់ចុះនៃគុណភាពដី ការគ្រប់គ្រងព្រៃឈើប្រកបដោយចីរភាព ទឹកស្អាត និងសារធាតុគីមី។ នៅប្រទេសកម្ពុជាចាប់តាំងពីឆ្នាំ២០១៤ មក កម្មវិធីជំនួយខ្នាតតូច របស់មូលនិធិបរិស្ថានសកល (GEF-SGP) បានផ្តល់មូលនិធិដល់គម្រោងចំនួន ២០៤គម្រោង នៅក្នុងកម្មវិធីបន្សាំនឹងការប្រែប្រួលអាកាសធាតុនៅតាមសហគមន៍ គម្រោងជីវៈចម្រុះ ការកាត់បន្ថយការប្រែប្រួលអាកាសធាតុ និងការបំផ្លិចបំផ្លាញដីធ្លី សរុបជាថវិកាមានចំនួន ៧,៧ លានដុល្លារអាមេរិក និងជាសាច់ប្រាក់ ១,៧ លានដុល្លារអាមេរិក សម្រាប់ជាសហហិរញ្ញប្បទាន និង ៤,២ លានដុល្លារអាមេរិកជាការចូលរួមសហហិរញ្ញប្បទានដោយស្ម័គ្រចិត្ត។

មូលនិធិអាកាសធាតុបៃតង (GCF)[៨១] គឺជាមូលនិធិសកលថ្មី និងធំជាងគេមួយដែលជួយប្រទេសកំពុងអភិវឌ្ឍន៍ក្នុងការអនុវត្តការបន្សាំ និងកាត់បន្ថយដើម្បីទប់ទល់នឹងការប្រែប្រួលអាកាសធាតុ។ មូលនិធិអាកាសធាតុបៃតង គាំទ្រដល់គម្រោងកម្មវិធី គោលនយោបាយ និងសកម្មភាពដទៃទៀតនៅក្នុងប្រទេសកំពុងអភិវឌ្ឍន៍ដែលជាភាគី ដោយប្រើប្រាស់កម្មវិធីមូលនិធិតាមវិស័យ។ មូលនិធិអាកាសធាតុបៃតង មានគោលបំណងជាមូលនិធិស្នូលនៃកិច្ចខិតខំប្រឹងប្រែងក្នុងការបង្កើនថវិកាសម្រាប់ហិរញ្ញប្បទានអាកាសធាតុឱ្យបាន ១០០ ពាន់លានដុល្លារក្នុងមួយឆ្នាំនៅត្រឹមឆ្នាំ២០២០។ មូលនិធិអាកាសធាតុបៃតង ផ្តល់ឱ្យប្រទេសទទួលជំនួយនូវលទ្ធភាពទទួលបានមូលនិធិតាមរយៈស្ថាប័នអនុវត្តន៍ថ្នាក់ជាតិ ថ្នាក់ក្រោមជាតិ ស្ថាប័នថ្នាក់តំបន់ និងអន្តរការី ដែលបានទទួលស្គាល់ដោយមូលនិធិអាកាសធាតុបៃតង។ រដ្ឋាភិបាលនៃប្រទេសនីមួយៗក៏អាចទទួលបានមូលនិធិនេះតាមរយៈអង្គការអន្តរជាតិ និងអង្គការថ្នាក់តំបន់ (ដូចជាធនាគារអភិវឌ្ឍន៍ពហុភាគី និងធនាគារអភិវឌ្ឍន៍ថ្នាក់តំបន់ និងទីភ្នាក់ងារអង្គការសហប្រជាជាតិ) ក្រោមការប្រើប្រាស់ច្រកអង្គការអន្តរជាតិ។ មូលនិធិមួយចំនួននឹងត្រូវផ្តល់ឱ្យតាមរយៈការបង្កើនការស្នើសុំដោយផ្ទាល់ (Enhance Direct Access) ដែលក្នុងនោះស្ថាប័នដែលមានការទទួលស្គាល់នៅតាមប្រទេសកំពុងអភិវឌ្ឍន៍ទទួលបានហិរញ្ញវត្ថុពីមូលនិធិអាកាសធាតុបៃតង ហើយបន្ទាប់មកធ្វើការសម្រេចចិត្តដោយខ្លួនឯងលើរបៀបវារៈនៃការប្រើប្រាស់។

នៅខែតុលាឆ្នាំ២០១៦ មូលនិធិអាកាសធាតុបៃតង បានអនុម័តសំណើថវិកាចំនួន ៧៤៥ លានដុល្លារអាមេរិក។ មានគម្រោង និងកម្មវិធីចំនួន ១០ ដែលមានតម្លៃសរុបចំនួន ២,៦ ពាន់លានដុល្លារ ដែលនឹងជួយដល់ប្រទេសចំនួន ២៧ប្រទេស នៅទូទាំងពិភពលោកដើម្បីកាត់បន្ថយការបំភាយឧស្ម័ន និងបន្សាំទៅនឹងផលប៉ះពាល់នៃការប្រែប្រួលអាកាសធាតុ។ គម្រោង និងកម្មវិធីគឺភាគច្រើនផ្តោតទៅលើការបន្សាំ (៥២%) អន្តរវិស័យ (២២%) និងការកាត់បន្ថយ (២៦%) ។

រហូតមកដល់ពេលនេះ ប្រទេសកម្ពុជាកំពុងធ្វើពិពិធកម្មយុទ្ធសាស្ត្ររបស់ខ្លួនដើម្បីទទួលបានមូលនិធិសកល មូលនិធិអាកាសធាតុបៃតង ដោយដាក់ពាក្យស្នើសុំ តាមរយៈច្រកអង្គការអន្តរជាតិ និងស្នើសុំដោយផ្ទាល់។ គ.ជ.អ.ប. ថ្មីៗនេះបានបង្កើតសំណើគម្រោងមួយស្តីពីការបន្សាំនឹងការប្រែប្រួលអាកាសធាតុនៅតាមកម្រិតមូលដ្ឋាន តាមរយៈអង្គការ UNDP។

គណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ (NCDDs) ត្រូវបានជ្រើសរើសដោយក្រសួងបរិស្ថាន (អាជ្ញាធរជាតិដែលបានចាត់តាំងជាតំណាងទៅ GCF) ឱ្យធ្វើជាស្ថាប័នអនុវត្តន៍ជាតិ (NIE) ដែលមានសក្តានុពលនៅក្នុងប្រទេសកម្ពុជា ហើយឥឡូវនេះកំពុងចាប់ផ្តើមដាក់ពាក្យស្នើសុំការទទួលស្គាល់ (Accredited) ពីមូលនិធិអាកាសធាតុបៃតង។ គ.ជ.អ.ប គឺជាអង្គភាពជាតិដំបូងគេដែល មូលនិធិអាកាសធាតុបៃតង បានជ្រើសរើសមុនគេដើម្បីផ្តល់ថវិកាសម្រាប់ថ្នាក់ក្រោមជាតិ។ កម្មវិធីសាកល្បងដែលសំណើគម្រោងមូលនិធិអាកាសធាតុបៃតងនឹងត្រូវបានបង្កើតឡើងមានស្រុកគោលដៅចំនួន ៨ នៅប្រទេសកម្ពុជា។

កម្មវិធីសាកល្បងសម្រាប់ភាពធន់ទៅនឹងការប្រែប្រួលអាកាសធាតុ (ភីភីស៊ីអ៊ែរ PPCR) គឺជាច្រកហិរញ្ញប្បទានមួយនៃមូលនិធិវិនិយោគអាកាសធាតុសម្រាប់ពង្រឹងការបន្សាំ និងការកសាងភាពធន់ទៅនឹងការប្រែប្រួលអាកាសធាតុ។ តាមរយៈការបង្កើតកម្មវិធីភីភីស៊ីអ៊ែរ (PPCR) ជួយរាជរដ្ឋាភិបាលកម្ពុជាក្នុងការរួមបញ្ចូលភាពធន់នឹងអាកាសធាតុទៅក្នុងផែនការអភិវឌ្ឍន៍តាមគ្រប់

[81] For more information about the fund, visit https://www.greenclimate.fund/who-we-are/about-the-fund

វិស័យ និងផ្តល់ហិរញ្ញប្បទានដើម្បីសាកល្បងកម្មវិធី/គម្រោងដើម្បីដោះស្រាយហានិភ័យនៃបញ្ហាអាកាសធាតុតាមរយៈការចូលរួមពីវិស័យសធារណៈ និងឯកជន។ គិតមកដល់ពេលនេះ ថវិកាប្រមាណ ៩៣៩ លានដុល្លារអាមេរិក (ឬ ៨០% នៃមូលនិធិ PPCR) ត្រូវបានបែងចែកសម្រាប់គម្រោងចំនួន ៥៨គម្រោង។ គេរំពឹងថានឹងមានការកៀរគរកធនធានដើម្បីសហហិរញ្ញប្បទានប្រមាណ ២ ពាន់លានដុល្លារអាមេរិក។ រាជរដ្ឋាភិបាលកម្ពុជា កំពុងទទួលបានប្រាក់ជំនួយចំនួន ៨៦ លានដុល្លារអាមេរិក និងកម្ចីដែលមានការប្រាក់ទាបជិតដល់សូន្យពីកម្មវិធីភីភីស៊ីអ៊ែរ (PPCR) (ជាដំណាក់កាលទី ២ នៃ SPCR) ដើម្បីគាំទ្រដល់ការវិនិយោគហេដ្ឋារចនាសម្ព័ន្ធរូបវន្តទ្រទ្រង់ភាពធន់ទៅនឹងការប្រែប្រួលអាកាសធាតុ នៅក្នុងវិស័យសំខាន់ៗមួយចំនួនដូចជា៖ ទឹក កសិកម្ម និងហេដ្ឋារចនាសម្ព័ន្ធជនបទ[៨២]។

កម្មវិធីភីភីស៊ីអ៊ែរ (PPCR) ក៏កំពុងគិតពិចារណាលើច្រកវិនិយោគផ្នែកទន់ ពោលគឺការបណ្តុះបណ្តាលសមត្ថភាពស្ថាប័នដើម្បីជំរុញការធ្វើផែនការអភិវឌ្ឍន៍ភាពធន់ទៅនឹងការប្រែប្រួលអាកាសធាតុប្រកបដោយប្រសិទ្ធភាព។ ផែនការវិនិយោគនៅក្នុងកម្មវិធីភីភីស៊ីអ៊ែរ (PPCR) របស់កម្ពុជា កំពុងត្រូវបានអនុវត្តន៍ដោយធនាគារអភិវឌ្ឍន៍អាស៊ី (ADB) និងត្រូវបានប្រតិបត្តិដោយស្ថាប័នជាតិដែលពាក់ព័ន្ធ។ ដំណាក់កាលបង្កើត និងរៀបចំ គឺបានការគាំទ្រពីក្រុមធនាគារពិភពលោក (the World Bank Goup) ក្នុងនោះរួមមាន ធនាគារអន្តរជាតិសម្រាប់ការស្តារឡើងវិញ និងអភិវឌ្ឍន៍ (International Bank for Reconstruction and Development - IBRD) និងសហប្រតិបត្តិការហិរញ្ញវត្ថុអន្តរជាតិ (International Finance Cooperation - IFC) ក៏ដូចជាភាគីពាក់ព័ន្ធសំខាន់ៗថ្នាក់ជាតិ និងដៃគូអភិវឌ្ឍន៍។

យន្តការផ្តល់ហិរញ្ញប្បទានសម្រាប់ប្រទេសកំពុងអភិវឌ្ឍន៍អនុវត្តន៍គម្រោងដែលជួយដល់ការអភិវឌ្ឍ និងកាត់បន្ថយការបំភាយឧស្ម័នទៅក្នុងបរិយាកាស (NAMA Facility)[៨៣] គឺជាយន្តការហិរញ្ញប្បទានជំនួយអន្តរជាតិមួយដែលត្រូវបានបង្កើតឡើងនៅឆ្នាំ ២០១២ នៅអំឡុងពេលកិច្ចចរចាអន្តរជាតិស្តីពីអាកាសធាតុសកលនៅទីក្រុងដូហា ប្រទេសកាតា។ ក្នុងពេលបច្ចុប្បន្ន ប្រភពថវិកានៃយន្តការនេះ គឺទទួលបានពីក្រសួងបរិស្ថាន អភិរក្សធម្មជាតិ និងសុវត្ថិភាពនុយក្លេអ៊ែរ នៃប្រទេសអាឡឺម៉ង់ ក្រសួងរៀបចំយុទ្ធសាស្ត្រពាណិជ្ជកម្ម ថាមពល និងឧស្សាហកម្ម នៃចក្រភពអង់គ្លេស ក្រសួងថាមពល និងអាកាសធាតុ នៃប្រទេសដែណឺម៉ាក និងគណៈកម្មការនៃសហភាពអឺរ៉ុប។ មូលនិធិនេះ មានគោលដៅផ្តល់ទៅឱ្យប្រទេសកំពុងអភិវឌ្ឍន៍ក្នុងការយកទៅអនុវត្តន៍គម្រោងនានាដែលជួយដល់ការប្រយុទ្ធប្រឆាំងនឹងបម្រែបម្រួលអាកាសធាតុ កាត់បន្ថយការបំភាយឧស្ម័នក្នុងបរិយាកាស ពោលគឺគម្រោងអភិវឌ្ឍន៍នានាដែលបញ្ចេញជាតិកាបូនតិច។ ទោះបីជាយ៉ាងណាក៏ដោយ យន្តការនេះគឺមានលក្ខណៈប្រកួតប្រជែងខ្លាំង ហើយតម្រូវឱ្យមានការសិក្សា និងសរសេរសំណើគម្រោងលម្អិត ដើម្បីធ្វើការវាយតម្លៃពីគណៈកម្មការរបស់យន្តការនេះ។ កាលពីឆ្នាំ២០១៨ គណៈកម្មការនៃយន្តការនេះ បានទទួលសំណើគម្រោងចំនួន ៧៦ គម្រោង ដែលមានថវិកាសរុបជិត ១,១ ពាន់លានយូរ៉ូ ហើយមានតែ ៧ គម្រោងប៉ុណ្ណោះដែលអាចទទួលបានថវិកាសម្រាប់អនុវត្តនៅដំណាក់កាលរៀបចំគម្រោងលម្អិត (Detailed Preparation Phase - DPP)។

## ១.៦.៣. ការវិនិយោគពីវិស័យឯកជន

នៅឆ្នាំ២០១៦ វិស័យឯកជន មានចំនួន ៦២% នៃហិរញ្ញវត្ថុអាកាសធាតុពិភពលោក។ តាមរយៈការបង្កើតបរិយាកាសបទប្បញ្ញត្តិត្រឹមត្រូវ វិស័យសាធារណៈអាចឈានទៅជំរុញការវិនិយោគឯកជនបែបនេះបានវែងឆ្ងាយតាមរយៈ ឧទាហរណ៍ ភាពជាដៃគូរវាងរដ្ឋនិងឯកជន (PPP) យន្តការហិរញ្ញប្បទានបញ្ចូលគ្នាប្រកបដោយភាពច្នៃប្រឌិត និងឧបករណ៍កាត់បន្ថយហានិភ័យ។ ទោះយ៉ាងណាក៏ដោយ មានឧបសគ្គដែលមានស្រាប់ ដែលរារាំងការចូលរួមរបស់តួអង្គឯកជនក្នុងការវិនិយោគលើការត្រៀមបម្រុងទល់នឹងការប្រែប្រួលអាកាសធាតុនៅកម្ពុជា។ ឧបសគ្គទាំងនេះរួមមាន (១) ខ្វះព័ត៌មាន និងការណែនាំស្តីពី បច្ចេកវិទ្យាថ្មីៗដែលមានលក្ខណៈច្នៃប្រឌិត និងបញ្ចេញកាបូនទាប និង/ឬ គាំទ្រដល់ការបន្សាំទៅនឹងការប្រែប្រួលអាកាសធាតុ (២) មិនមានលទ្ធភាពទទួលបានហិរញ្ញប្បទាន និង (៣) ខ្វះធនធានមនុស្ស និងជំនាញ។ ឧទាហរណ៍ វិស្វករ និងអ្នកជំនាញបច្ចេកទេសដែលមានសមត្ថភាពក្នុងវិស័យប្រសិទ្ធភាព

[82] For more information about the fund, visit https://www.climateinvestmentfunds.org/country/cambodia

[83] For more information about the fund, visit https://www.nama-facility.org/

ថាមពល ឬថាមពលកកើតឡើងវិញ អ្នកជំនាញផ្នែកអាកាសធាតុក្នុងវិស័យកសិកម្ម ឬអ្នកវិភាគហិរញ្ញវត្ថុក្នុងវិស័យអភិវឌ្ឍន៍បៃតង ដែលវាជាកត្តារារាំងការអភិវឌ្ឍ និងការអនុវត្តសកម្មភាពគម្រោងដែលមានមេត្រីភាពបរិស្ថាន និងទី(៤) ខ្វះនូវគោលនយោបាយ និងក្របខ័ណ្ឌច្បាប់។ មានសក្តានុពលច្រើននៅក្នុងការបង្កើនការចូលរួមរបស់វិស័យឯកជននៅក្នុងគម្រោងវិនិយោគទីក្រុងនិរន្តរភាព ប្រសិនបើរបាំងឧបសគ្គទាំងនេះត្រូវបានដោះស្រាយ និងបរិយាកាសវិនិយោគល្អប្រសើរជាងមុនត្រូវបានបង្កើតឡើង។[៨៤]

### តារាងទី ១.១១. ប្រភេទហានិភ័យក្នុងការវិនិយោគរបស់វិស័យឯកជន[៨៥]

| ប្រភេទនៃហានិភ័យ | ឧទាហរណ៍ទូទៅ |
|---|---|
| ហានិភ័យនយោបាយ | - បរិយាកាសនយោបាយមិនស្ថិតស្ថេរ ការព្រួយបារម្ភពីសន្តិសុខ<br>- ការផ្លាស់ប្តូរការគាំទ្រពីរដ្ឋបាលថ្នាក់ជាតិ និងថ្នាក់មូលដ្ឋានសម្រាប់គម្រោងបៃតង |
| ហានិភ័យបទប្បញ្ញត្តិ | - គោលនយោបាយដែលលើកកម្ពស់កំណើន<br>- មិនមានគោលនយោបាយគ្រប់គ្រាន់, ផ្លាស់ប្តូរបទប្បញ្ញត្តិ<br>- ក្របខ័ណ្ឌច្បាប់មានសភាពខ្សោយ និងការអនុវត្តបទប្បញ្ញត្តិដែលមានកំណត់ |
| ហានិភ័យបច្ចេកវិទ្យា | - បច្ចេកវិទ្យាដែលមានការបំពេញគុណផលអន់ អ្នកជំនាញក្នុងប្រទេសនៅមានកម្រិត<br>- ហេដ្ឋារចនាសម្ព័ន្ធគាំទ្រមិនគ្រប់គ្រាន់ |
| ហានិភ័យបំណុល | - ភាពគួរឱ្យទុកចិត្តរបស់សមភាគី,ហានិភ័យនៃការខកខាន ឬមិនបានទូទាត់<br>- ការទូទាត់សម្រាប់អ្នកប្រើប្រាស់សេវាសាធារណៈចុងក្រោយ |
| ហានិភ័យទីផ្សារមូលធន | - ភាពមិនទាន់ចាស់ទុំនៃទីផ្សារហិរញ្ញវត្ថុទាំងក្នុងកម្រិតជាតិ និងកម្រិតមូលដ្ឋាន។ ភាពមិនទាន់ពេញលក្ខណៈនៃលទ្ធភាពចូលកាន់ទីផ្សារ<br>- ចលនាចុះឡើងនៃចរន្តរូបិយវត្ថុ |

រដ្ឋាភិបាលថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ អាចប្រើយុទ្ធសាស្ត្រមួយចំនួន ដើម្បីផ្តល់ហិរញ្ញប្បទានដល់វិស័យឯកជន។ ឧទាហរណ៍គម្រោងសាកល្បងអាចជួយបង្ហាញពីករណីជំនួញសម្រាប់ការវិនិយោគក្នុងវិស័យឯកជន។ វិធានការចែករំលែកហានិភ័យ ដូចជាការធានារ៉ាប់រង និងការធានាអាចកាត់បន្ថយហានិភ័យហិរញ្ញវត្ថុនិងជួយសម្រួលដល់ការចូលរួមរបស់វិស័យឯកជន។ ឧបករណ៍ហិរញ្ញវត្ថុដែលមានលក្ខណៈច្នៃប្រឌិតអាចជួយសម្រួលដល់ការវិនិយោគរបស់វិស័យឯកជនក្នុងគម្រោងអភិវឌ្ឍន៍ដែលត្រូវនឹងអាកាសធាតុ។ ការប្រើប្រាស់សហគ្រាសខ្នាតតូច និងមធ្យមដែលមានស្រាប់ក្នុងស្រុក និងស្ថាប័នហិរញ្ញវត្ថុបង្ហាញនូវឱកាសបន្ថែមទៀតដើម្បីជំរុញហិរញ្ញវត្ថុក្នុងវិស័យឯកជន។

[84] General Secretariate of National Council for Sustainable Development, "Study Report on Promoting Private Sector Contribution to the Climate Change Response in Cambodia," accessed July 18, 2018, http://www.camclimate.org.kh/en/activities/347-new-release-%E2%80%93-study-report-on-promoting-private-sector-contribution-to-the-climate-change-response-in-cambodia.html

[85] GGGI (2019). Green Cities Development: A Training Manual. https://gggi.org/report/green-cities-development-a-training-manual/

[86] GGGI (2019). Green Cities Development: A Training Manual. https://gggi.org/report/green-cities-development-a-training-manual/

រូបភាពទី ១.៧. យន្តការហិរញ្ញប្បទានដែលមានសក្តានុពលខ្ពស់[៨៦]




## ១.៧. ការរាយការណ៍ ការតាមដាន និងវាយតម្លៃ

ក្រុមការងារបច្ចេកទេសរបស់ក្រុមប្រឹក្សាជាតិអភិវឌ្ឍន៍ដោយចីរភាព បានធ្វើការលើទីក្រុងនិរន្តរភាព (ប្រសិនបើត្រូវបានចាត់តាំងឱ្យសម្របសម្រួលការអនុវត្តផែនការយុទ្ធសាស្ត្រទីក្រុងនិរន្តរភាព) នេះនឹងដើរតួនាទីយ៉ាងសំខាន់ក្នុងការគាំទ្រការធ្វើសមាហរណកម្មសកម្មភាពអាទិភាព ដែលបានកំណត់នៅក្នុងផែនការទៅក្នុងដំណើរការរៀបចំផែនការតាមដាន និងវាយតម្លៃ ដែលមានស្រាប់។

ដោយសារគម្រោងទីក្រុងប្រកបដោយនិរន្តរភាពដែលទាញចេញ ពីផែនការយុទ្ធសាស្ត្រទីក្រុងនិរន្តរភាព ត្រូវបានដាក់បញ្ចូលទៅក្នុងផែនការអភិវឌ្ឍ ៥ ឆ្នាំរបស់ទីក្រុង និងក្នុងផែនការវិនិយោគ ៣ ឆ្នាំរំកិល វាជាការសំខាន់ដែលសូចនាករទីក្រុងនិរន្តរភាពប្រកបដោយភាពឆ្លាតវៃ (SMART) សម្រាប់គម្រោងទាំងនេះ ត្រូវបានដាក់បញ្ចូលទៅក្នុងឯកសារផែនការ។ ការធ្វើដូចនេះ នឹងអនុញ្ញាតឱ្យមានការត្រួតពិនិត្យវឌ្ឍនភាពក្នុងការអភិវឌ្ឍទីក្រុងចីរភាពតាមរយៈវដ្តនៃការតាមដាន និងវាយតម្លៃប្រចាំឆ្នាំរបស់រដ្ឋាភិបាល។ ខាងក្រោមនេះគឺជាសូចនាករដែលបានស្នើ ប៉ុន្តែសូចនាករទាំងនេះអាចមានការកែប្រែអាស្រ័យលើបរិបទនិងទិន្នន័យរបស់ក្រុងនីមួយៗ ដើម្បីវាស់វឌ្ឍនភាពនៃគោលដៅទាំងបួន។

## តារាងទី ១.១២. សូចនាករដែលស្នើឡើងសម្រាប់ការតាមដាន និងវាយតម្លៃ

| ទិសដៅ | សូចនាករ |
|---|---|
| ការរៀបចំផែនការនគរូបនីយកម្ម ដែលមានលក្ខណៈសមាហរណកម្ម និងការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធបៃតង | - ផែនការមេទីក្រុង (% ដែលបានបញ្ចប់)<br>- ផ្ទៃលំហបៃតងសម្រាប់មនុស្សម្នាក់ (ម២/ម្នាក់)<br>- ចំនួនតំបន់មានស្រាប់ត្រូវបានកំណត់សម្រាប់ការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធបន្ថែម<br>- ចំណែកនៃសំណល់ទឹកកខ្វក់ដែលបានធ្វើប្រព្រឹត្តិកម្មដោយសុវត្ថិភាព (%)<br>- ចំណែកផ្លូវកៅស៊ូ (% នៃប្រវែងផ្លូវសរុប)<br>- ភាគរយនៃសំណល់ទីក្រុងដែលបានកែច្នៃឡើងវិញ<br>- ការសន្សំសំចៃថាមពលនៅក្នុងអគារសាធារណៈ |
| ការអភិវឌ្ឍសេដ្ឋកិច្ចបៃតងក្នុងមូលដ្ឋាន | - យុទ្ធសាស្ត្រអេកូទេសចរណ៍ (% ដែលបានបញ្ចប់)<br>- ចំណូលពីវិស័យអេកូទេសចរណ៍ (ដុល្លារ)<br>- ចំនួនការងារនៅក្នុងវិស័យអេកូទេសចរណ៍ (% អ្នកមានការងារធ្វើ)<br>- ការងារនៅក្នុងវិស័យថាមពលកកើតឡើងវិញ និងប្រសិទ្ធភាពថាមពល (% អ្នកមានការងារធ្វើ)<br>- បរិមាណថាមពលកកើតឡើងវិញដែលផលិតនៅក្នុងទីក្រុង<br>- ចំនួនគម្រោងវិនិយោគទៅលើវិស័យហេដ្ឋារចនាសម្ព័ន្ធ/សំណង់ដែលគាំទ្រដល់វិស័យ អេកូទេសចរណ៍<br>- ចំនួនខ្នងផ្ទះ អាជីវកម្ម ដែលប្រើប្រាស់ថាមពលកកើតឡើងវិញសម្រាប់ បំភ្លឺ និងការចម្អិនម្ហូបអាហារ |
| ការធានាឱ្យមានបរិយាបន្ន សង្គមក្នុងទីក្រុង | - ចំនួនគ្រួសារដែលទទួលផលប្រយោជន៍ពីគម្រោងលំនៅឋានតម្លៃសមរម្យ<br>- ចំនួនគ្រួសារដែលមានលទ្ធភាពទទួលបានសេវាទឹកស្អាត<br>- ចំនួនគ្រួសារដែលទទួលបានសេវាប្រមូលសំរាម<br>- ចំនួនប្រជាជនដែលទទួលបានសេវាអនាម័យល្អ (% នៃចំនួនខ្នងផ្ទះ)<br>- ស្ត្រីចូលរួមនៅក្នុងការធ្វើសេចក្តីសម្រេចចិត្ត (%)<br>- ចំនួនការងារដែលបានបង្កើតសម្រាប់សហគមន៍ដែលខ្វះខាត ឬខ្សត់ខ្សោយ |
| អភិបាលកិច្ចក្រុង | - % នៃកំណើនថវិកាថ្នាក់ក្រោមជាតិ<br>- កម្រិតប្រាក់ចំណូលដែលក្រុងប្រមូលបាន<br>- ចំនួនបុគ្គលិកក្រុងដែលទទួលបានអត្ថប្រយោជន៍ពីកម្មវិធីកសាងសមត្ថភាព<br>- ទិន្នន័យក្រុងដែលអាចរកបានសម្រាប់សាធារណជន |



ក្រុងព្រះសីហនុ


ក្រុងសៀមរាប

# ២. ការវិភាគនិន្នាការទូទៅរបស់ក្រុងគោលដៅ៧ សម្រាប់ការអភិវឌ្ឍទីក្រុងនិរន្តរភាព

## ក្រុងសៀមរាប

### ២.១. សេចក្ដីផ្ដើម

ក្រុងសៀមរាប ស្ថិតនៅក្នុងទឹកដីខេត្តសៀមរាបភាគពាយព្យនៃប្រទេសកម្ពុជា។ ក្រុងសៀមរាប ជាទីកន្លែងមួយក្នុងចំណោមទីកន្លែងដែលមានភាពទាក់ទាញផ្នែកបុរាណវិទ្យាដ៏ល្បីល្បាញបំផុតលើឆាកអន្តរជាតិ ពោលគឺមានប្រាង្គប្រាសាទនានាពីសម័យបុរាណក្នុងឧទ្យានអង្គរវត្ត ដែលជា "តំបន់បេតិកភណ្ឌលំដាប់ពិភពលោកមួយ ទទួលស្គាល់ដោយអង្គការយូណេស្កូ (UNESCO)"។ ក្រុងសៀមរាប មានប្រជាជនរស់នៅកើនឡើងជាលំដាប់ ពីជាង២៤០.០០០នាក់ក្នុងឆ្នាំ២០១៦ មកដល់ប្រមាណ ២៨៧.៧៥៣នាក់ នៅឆ្នាំ២០១៨ និងតាមរយៈការព្យាករ អត្រាកំណើនប្រចាំឆ្នាំ ចំនួនប្រជាជននឹងឡើងដល់ ៤៤០.០៩៩នាក់ ក្នុងឆ្នាំ២០៣៥។[៨៧] កំណើននេះបណ្ដាលមកពីការហូរចូលមករស់នៅរបស់ប្រជាជនពីបណ្ដាខេត្តក្រុងនានានៃប្រទេសកម្ពុជា ដើម្បីស្វែងរកប្រាក់ចំណូលពីវិស័យទេសចរណ៍ និងការហូរចូលនូវចំនួនភ្ញៀវទេសចររាប់លាននាក់ក្នុងមួយឆ្នាំៗ (ស្ថិតិសេដ្ឋកិច្ចសង្គមក្រុងសៀមរាប ២០១៦)។[៨៨]

វិស័យទេសចរណ៍បានបង្កើតឱកាសការងារថ្មីៗជាច្រើន និងបង្កើនប្រាក់ចំណូលប្រជាជនក្នុងក្រុងដែលធ្វើឱ្យក្រុងសៀមរាប ក្លាយទៅជាក្រុងមួយមានការរីកចម្រើនយ៉ាងឆាប់រហ័សរបស់ប្រទេសកម្ពុជា។ ក្រុងសៀមរាប ជាក្រុងទីពីរដែលមានចំនួនប្រជាជនរស់នៅច្រើនជាងគេក្នុងប្រទេសកម្ពុជាបន្ទាប់ពីរាជធានីភ្នំពេញដែលមានប្រជាជនរស់នៅជាង ១,៥លាននាក់។ បើមើលតាមតារាងខាងក្រោម អត្រាកំណើនប្រជាជនក្រុងសៀមរាបមានការកើនឡើងជាមធ្យមប្រចាំឆ្នាំជាង ៣%។ អត្រាកំណើនជាក់ស្ដែងទំនងជាត្រូវបានប៉ាន់ស្មានដោយសារតែអត្រាការធ្វើចំណូលស្រុក ដែលមិនត្រូវបានបង្ហាញឱ្យបានត្រឹមត្រូវនៅក្នុងទិន្នន័យដែលអាចរកបាន។

តារាង៖ ស្ថិតិប្រជាសាស្ត្រសំខាន់ៗ ក្រុងសៀមរាប (ស្ថិតិសេដ្ឋកិច្ចសង្គមក្រុងសៀមរាប ឆ្នាំ២០១៦)

| ស្ថិតិប្រជាសាស្ត្រ | ២០១៣ | ២០១៤ | ២០១៥ | ២០១៦ |
|---|---|---|---|---|
| ចំនួនប្រជាជន (នាក់) | ២១៧.៦០៩ | ២២៣.០៧១ | ២២២.៩៧៩ | ២៤០.៦៤៨ |
| អត្រាកំណើនប្រចាំឆ្នាំ (ភាគរយ) | ២,៥ | ៥,៧ | -៣,១ | ៧,៩ |
| ចំនួនស្ត្រី (នាក់) | ១១១.៤១៨ | ១១៨.៥៦៥ | ១១២.៥១៧ | ១២២.៥៤៤ |
| សមាមាត្រស្ត្រីធៀបនឹងបុរស (ក្នុងចំណោមបុរស ១០០នាក់) | ១០៤,៩ | ១០៦,៣ | ១០១,៩ | ១០៣,៨ |
| ចំនួនគ្រួសារ (គ្រួសារ) | ៤១.៤៥១ | ៤២.៩៩៧ | ៤៣.៣៣៥ | ៤៧.២២៥ |
| សមាជិកគ្រួសារគិតជាមធ្យម (នាក់) | ៥,២ | ៥,៤ | ៥,១ | ៥,១ |

[87] MLMUPC, Siem Reap's Municipal Land Use Master Plan 2035, 2018.

[88] Siem Reap Socio-economic Statistics," 2016.

## ២.២. ការវិភាគតាមវិស័យ សម្រាប់ការអភិវឌ្ឍទីក្រុងនិរន្តរភាព

### ទេសចរណ៍

ទេសចរណ៍គឺជាវិស័យសេដ្ឋកិច្ចមួយយ៉ាងសំខាន់សម្រាប់ក្រុងសៀមរាប ហើយវិស័យនេះត្រូវបានគេរំពឹងថានឹងកើនឡើងនៅឆ្នាំខាងមុខ។ ព្រលានយន្តហោះអន្តរជាតិក្រុងសៀមរាប បានទទួលភ្ញៀវទេសចរប្រមាណ ១,៩លាននាក់កាលពីឆ្នាំ ២០១៨ ស្មើនឹងព្រលានយន្តហោះភ្នំពេញ។[៩៩] តំបន់ប្រវត្តិសាស្ត្រអង្គរពីសម័យបុរាណ គឺជាគោលដៅផ្នែកទេសចរណ៍ដ៏សំខាន់សម្រាប់ភ្ញៀវទេសចរអន្តរជាតិមកកម្ពុជា ហើយក្រុងសៀមរាប គឺជាក្រុងដែលត្រូវទទួលភ្ញៀវទេសចរអន្តរជាតិរបស់ប្រទេសកម្ពុជា។ យ៉ាងណាមិញ ការរីកចម្រើនរបស់ក្រុងសៀមរាបយ៉ាងឆាប់រហ័សដោយសារមានភ្ញៀវទេសចរចូលមកទស្សនា គឺត្រូវការចាំបាច់នូវក្របខ័ណ្ឌ និងហេដ្ឋារចនាសម្ព័ន្ធដើម្បីធានាបាននូវការរីកចម្រើនប្រកបដោយចីរភាព។ កត្តាទាំងនេះ រួមមាន ការគ្រប់គ្រងសំណល់ ការផ្គត់ផ្គង់ថាមពល ទឹក ការរក្សាអនាម័យ ការរចនាអគារដែលមានប្រសិទ្ធភាពធនធាន និងការគ្រប់គ្រងវិស័យដឹកជញ្ជូន។ ក្របខ័ណ្ឌ និងហេដ្ឋារចនាសម្ព័ន្ធទេសចរណ៍បៃតងនេះ ពុំទាន់ត្រូវបានធ្វើការអភិវឌ្ឍ និងដំណើរការឱ្យបានពេញលេញនៅឡើយទេ។

ក៏ដូចជាក្រុងដែលមានសក្តានុពលដទៃទៀតក្នុងប្រទេសកម្ពុជា ក្រុងសៀមរាបទទួលបានថវិកាតិចតួចពីរដ្ឋបាលថ្នាក់ជាតិ ដែលនឹងអាចយកមកប្រើប្រាស់ដើម្បីជំរុញដល់ទេសចរណ៍បៃតង។ កង្វះធនធានមនុស្ស និងថវិកាមានកំណត់ គឺជាឧបសគ្គធំមួយក្នុងការអនុវត្តសកម្មភាពនានា ឧទាហរណ៍សកម្មភាពជំរុញស្តង់ដារនិងបទប្បញ្ញត្តិបៃតង និងការវិនិយោគហេដ្ឋារចនាសម្ព័ន្ធបៃតង។ កង្វះថវិកា អាចនឹងដោះស្រាយបាន បើមានការបែងចែកថវិកាពីថ្នាក់ជាតិបានល្អប្រសើរជាងមុន ដូចជាថវិកាដែលបានមកពីអាជីវកម្មនានាក្នុងវិស័យទេសចរណ៍ (ឧទាហរណ៍ តាមរយៈកម្រៃនៃការចេញអាជ្ញាប័ណ្ណអាជីវកម្មជាដើម) និងថវិកាបានមកពីវិស័យរដ្ឋ និងឯកជនផ្សេងទៀតផងដែរ។ ការបង្កើតបានប្រវត្តិសាវតារល្អអំពីទេសចរណ៍បៃតងរបស់ក្រុង នឹងធ្វើឱ្យក្រុងសៀមរាបមានឱកាសល្អប្រសើរជាងមុនក្នុងការទាក់ទាញការវិនិយោគអន្តរជាតិ ឧទាហរណ៍ ការវិនិយោគលើសណ្ឋាគារ និងផ្ទះសំណាក់ប្រកបដោយចីរភាព និងមានប្រសិទ្ធភាពធនធាន និងការផ្តល់ហិរញ្ញប្បទានសម្បទានពីស្ថាប័នអន្តរជាតិ។ វិស័យទេសចរណ៍ក្នុងខេត្តសៀមរាប ក៏អាចដើរតួយ៉ាងសំខាន់ក្នុងការលើកកម្ពស់និរន្តរភាពបរិស្ថាន តាមរយៈការគាំទ្រដល់វិស័យទេសចរណ៍ដែលគាំទ្រការមិនប្រើប្លាស្ទិក សេវាកម្មប្រសិទ្ធភាពថាមពល និងថាមពលកកើតឡើងវិញ សម្រាប់ប្រតិបត្តិករ (ដូចជា យានអេឡិចត្រូនិកជុំវិញក្រុង និងជុំវិញតំបន់អង្គរ) និងការបង្កើតការងារជុំវិញគំនិតផ្តួចផ្តើមទាំងនេះ។

### ឧស្សាហកម្ម និងសិប្បកម្មបៃតង

បច្ចុប្បន្ន ក្រុងសៀមរាប មានអាជីវកម្មខ្នាតតូច និងមធ្យមលើសពី ៥០០កន្លែង ដែលកំពុងធ្វើអាជីវកម្មលើផលិតផលសិប្បកម្មជាច្រើនប្រភេទផ្សេងៗគ្នាដូចជា៖ ផលិតផលកន្សែងសូត្រ និងស្បែកក្រពើ ដែលវាជាផលិតផលត្រូវការក្នុងឧស្សាហកម្មទេសចរណ៍។ ជាមួយនឹងការកើនឡើងនូវចំនួនភ្ញៀវទេសចរ និងតម្រូវការកើនឡើងលើផលិតផលវត្ថុអនុស្សាវរីយ៍ដែលមានសក្តានុពលផលិតក្នុងស្រុក និងប្រើប្រាស់នូវវត្ថុធាតុដើមដែលមានក្នុងស្រុកដែលមិនប៉ះពាល់ដល់បរិស្ថាន រួមជាមួយនឹងបច្ចេកទេសសិប្បកម្ម នឹងធ្វើឱ្យទីផ្សារផលិតផលសិប្បកម្មនឹងកើនឡើងយ៉ាងខ្លាំងនៅពេលអនាគត។ ដូចនេះ ក្រុងសៀមរាប គឺមានសក្តានុពលច្រើនសម្រាប់ការពង្រីកឧស្សាហកម្មវិស័យសិប្បកម្ម ដែលនឹងចូលរួមចំណែកដល់ការអភិវឌ្ឍសេដ្ឋកិច្ចបៃតង តាមរយៈការបង្កើតការងារក្នុងស្រុក និងប្រាក់ចំណូលទៅដល់ផលិតករ (ហត្ថករ) សិប្បករ អាជីវករ និងកសិករ ដែលនឹងរួមចំណែកដោះស្រាយបញ្ហាភាពក្រីក្រ និងបញ្ហាបរិយាប័ន្នសង្គមផងដែរ។

ក្នុងចំណោមឧបសគ្គសំខាន់ៗសម្រាប់អភិវឌ្ឍន៍ឧស្សាហកម្មសិប្បកម្មក្នុងស្រុក (ដែលបានលើកឡើងដោយអាជ្ញាធរក្រុង) រួមមាន៖ កង្វះក្នុងការចេញអាជ្ញាបណ្ណទទួលស្គាល់ផលិតផលក្នុងស្រុក។ ការផ្តល់អាជ្ញាបណ្ណអាចរួមចំណែកដល់ការធានាគុណភាពល្អជាងមុន សូម្បីតែនៅតាមទីកន្លែងកម្សាន្ត និងផ្តល់ឱកាសបង្កើតជាវិញ្ញាបនបត្របញ្ជាក់ប្រភពដើម និងគាំទ្រដល់និរន្តរភាពនៃវត្ថុធាតុដើម និងផលិតកម្ម។ ការខិតខំប្រឹងប្រែងបង្កើតឱ្យមានអាជ្ញាបណ្ណសម្រាប់ផលិតករក្នុងស្រុក យ៉ាងហោចណាស់ នឹងផ្តល់អត្ថប្រយោជន៍ដល់ទីផ្សារលក់ផលិតផលរបស់ពួកគាត់។ ការចំណាយខ្ពស់លើអគ្គិសនីនៅក្នុងប្រទេសកម្ពុជា បើធៀបទៅនឹងប្រទេសជិតខាង ត្រូវបានគេមើលឃើញថា ជាឧបសគ្គមួយដល់ផលិតកម្មក្នុងស្រុក ដូច្នេះ កិច្ចខិតខំប្រឹងប្រែងដើម្បីកាត់បន្ថយការចំណាយទាំងនេះ នឹងជួយបង្កើនប្រាក់ចំណូលរបស់ពួកគេ។

## សំណល់រឹង

ការគ្រប់គ្រងសំណល់រឹងនិងរាវឱ្យបានកាន់តែប្រសើរគឺជាកត្តាសំខាន់មួយសម្រាប់ការអភិវឌ្ឍទីក្រុងនិរន្តរភាពក្នុងក្រុងសៀមរាប និងជាកម្មវិធីគម្រោងដ៏សំខាន់មួយផងដែររបស់សាលាក្រុង។ យើងបានដឹងច្បាស់ហើយថាប្រព័ន្ធនៃការគ្រប់គ្រងសំណល់ដែលមានដំណើរការល្អ រួមបញ្ចូលទាំងកិច្ចខិតខំប្រឹងប្រែងក្នុងការកាត់បន្ថយ និងលើកកម្ពស់ការកែច្នៃប្រើប្រាស់ឡើងវិញនូវសំណល់ និងចូលរួមចំណែកធ្វើឱ្យសុខុមាលភាពកាន់តែប្រសើរឡើង និងធ្វើឱ្យបរិស្ថានទីក្រុងកាន់តែមានសោភ័ណភាព និងភាពរីករាយ ដែលវាផ្តល់នូវអត្ថប្រយោជន៍ដល់ប្រជាពលរដ្ឋ និងធ្វើឱ្យទីក្រុងកាន់តែមានភាពទាក់ទាញដល់ភ្ញៀវទេសចរ។

បញ្ហាប្រឈមមួយដែលកំពុងកើតមាន គឺបញ្ហាប្រសិទ្ធភាពនៃការប្រមូល និងការទុកដាក់សំរាម។ ការបោលសំរាមទៅក្នុងធុងឱ្យបានសមរម្យនៅមានកម្រិត ហើយការប្រមូលសំរាមនាពេលបច្ចុប្បន្នមិនបានគ្របដណ្តប់គ្រប់លំនៅឋាននិងអាជីវកម្មនៅឡើយទេ។ ជាផលវិបាក សំរាមត្រូវបានគេបោលនៅតាមដងផ្លូវ នៅខាងក្រៅផ្ទះ និងតាមតំបន់អាជីវកម្មនានា។ ស្របគ្នានេះដែរ សេវាកម្មប្រមូល និងដឹកជញ្ជូនសំរាម មិនទាន់គ្រប់គ្រាន់ និងទាន់ពេលវេលានៅឡើយទេ ហើយតែងតែអាស្រ័យលើការបង់ថ្លៃសេវា ថាតើប្រជាពលរដ្ឋបានបង់ថ្លៃឱ្យទៅក្រុមហ៊ុនប្រមូលសំរាមហើយឬនៅ។ ប្រជាជនមានការយល់ដឹងតិចតួចអំពីការញែកសំរាម ឧទាហរណ៍ បំណែកសំរាមទៅកែច្នៃប្រើប្រាស់ឡើងវិញបានជាបន្តទៀត (ការបែងចែកប្រភេទសំរាមសរីរាង្គ និងមិនមែនសរីរាង្គដូចជាប្រភេទកញ្ចក់ ក្រដាស លោហៈធាតុជាដើម។ល។) និងឱកាសជំរុញការញែកសំរាម គឺនៅមានកម្រិតនៅឡើយ។ ជាងនេះទៅទៀត កន្លែងចាក់សំរាមដែលមានស្រាប់ នៅមិនទាន់ត្រឹមត្រូវទៅតាមកម្រិត ស្តង់ដារបច្ចេកទេសនោះទេ។

ឆ្លើយតបក្នុងការដោះស្រាយបញ្ហាប្រឈមចាំបាច់ទាំងអស់នេះ គឺត្រូវពង្រីកសេវាប្រមូលសំរាមឱ្យបានគ្រប់ទីកន្លែងទាំងអស់ក្នុងទីក្រុង និងត្រូវកែលម្អទីលានចាក់សំរាមឱ្យស្របទៅតាមស្តង់ដារជាតិ និងអន្តរជាតិ។ ដោយចាប់នូវឱកាសក្នុងការអភិវឌ្ឍបៃតង ដំណោះស្រាយនេះអាចធ្វើរួមគ្នាជាមួយគម្រោងកម្មវិធីកែច្នៃសំរាមសម្រាប់ប្រើប្រាស់ឡើងវិញ (ឧទាហរណ៍ការបង្កើតរោងចក្រធ្វើជីកំប៉ុសពីសំរាម) និងគម្រោងកម្មវិធីកែច្នៃសំរាម សម្រាប់ជាប្រភពថាមពល (ឧទាហរណ៍តាមរយៈការប្រើប្រាស់ឧស្ម័នដែលចេញពីសំរាមធ្វើជាថាមពលប្រេងឥន្ធនៈ)។

ជាមួយគ្នានេះដែរ ហេដ្ឋារចនាសម្ព័ន្ធ/យន្តការគាំទ្រ គួរតែត្រូវបានដាក់ចេញ និងដាក់ឱ្យអនុវត្តន៍សម្រាប់ការញែកសំរាមនៅតាមលំនៅឋាននិងតាមទីតាំងអាជីវកម្ម ការកែច្នៃសំរាមសម្រាប់យកទៅប្រើប្រាស់ឡើងវិញជាដើម។ ការកែច្នៃសំរាមប្រើប្រាស់ឡើងវិញ គួរតែត្រូវបានអនុវត្តន៍ជាបន្តបន្ទាប់ ឧទាហរណ៍តាមរយៈយន្តការគាំទ្រការអភិវឌ្ឍទីផ្សារសម្រាប់ផលិតផលដែលបានផលិតចេញពីសំរាមកែច្នៃ និងតាមរយៈការជំរុញដល់ប្រតិបត្តិការក្នុងវិស័យឧស្សាហកម្មខ្នាតតូច និងមធ្យមដើម្បីអភិវឌ្ឍន៍អាជីវកម្មកែច្នៃសំរាម។

លើកកម្ពស់ការយល់ដឹង និងការអប់រំប្រជាជន គឺជាកត្តាចាំបាច់សម្រាប់ការគ្រប់គ្រងសំរាមឱ្យបានល្អប្រសើរ រួមមានការសិក្សាអំពីរបៀបកាត់បន្ថយសំរាម របៀបញែក និងចាត់ថ្នាក់សំរាមទៅតាមប្រភេទសំរាម និងអំពីរបៀបទុកដាក់សំរាមឱ្យបានត្រឹមត្រូវ និងបោលសំរាមទៅតាមពេលកំណត់ប្រមូលសំរាមរបស់ក្រុមហ៊ុន។

## សំណល់រាវ និងការថែរក្សាអនាម័យ

ការខ្វះខាតនូវហេដ្ឋារចនាសម្ព័ន្ធនៃប្រព័ន្ធប្រព្រឹត្តិកម្មទឹកកខ្វក់ គឺជាបញ្ហាប្រឈមដ៏ធំមួយផ្សេងទៀតរបស់ក្រុងសៀមរាប។ ប្រហែល ៧៥% នៃប្រជាជននៅក្រុងសៀមរាប មានបង្គន់អនាម័យដែលមានបរិក្ខារអនាម័យត្រឹមត្រូវនៅនឹងកន្លែង។ ៤៥% នៃដីល្បាប់ដែលលេចចេញពីកន្លែងទាំងនេះ ហើយភាគច្រើនមិនត្រូវបានគ្រប់គ្រងដោយសុវត្ថិភាពនោះទេដោយសារតែការលេចធ្លាយចេញពីរណ្តៅដែលគ្មានការត្រួតពិនិត្យ និងការបោះចោលដោយខុសច្បាប់។[90] ការស្រាវជ្រាវដែលធ្វើឡើងដោយសាកលវិទ្យាល័យអេម៉រី (Emory University) នៅឆ្នាំ២០១៧ នៅសង្កាត់គម្រូចំនួន ៥ បានបង្ហាញថា ១០០% នៃចំនួនប្រជាជននៅទីនោះ ប្រឈមនឹងបញ្ហាកង្វះកន្លែងបន្ទោរបង់ដែលមានអនាម័យ ដែលទាំងនេះ បង្ហាញពីហានិភ័យចំពោះសុខភាព

ចំណុចតភ្ជាប់ទៅបណ្តាញលូទឹកកខ្វក់របស់ក្រុងសៀមរាប មានចំនួនត្រឹមតែ ២.០០០ កន្លែងតែប៉ុណ្ណោះ (ចំណែកឯចំនួនផ្ទះ

[89] Ministry of Tourism. “Tourism Statistics of Cambodia,” 2018.

[90] WaterAid, 2016. “Assessment feacal waste flows and associated practices in Siem Reap, Cambodia,” Accessed September 20, 2019. http://cityforall.net/wp-content/uploads/sites/3/2018/10/How-much-of-Siem-Reap%E2%80%99s-Faeces-is-Safely-Managed-James-Wicken-WaterAid.pdf

ក្នុងក្រុងសៀមរាបមានច្រើនជាង ៤៤.០០០ ខ្នង) ហើយសណ្ឋាគារ និងផ្ទះសំណាក់នៅក្នុងក្រុងសៀមរាបមានប្រមាណ ៣៥០ ដែលបានបំពាក់អាងប្រព្រឹត្តិកម្មនៅនឹងកន្លែងដោយផ្ទាល់។ ក្រុងសៀមរាប មិនទាន់មានប្រព័ន្ធដាច់ដោយឡែករវាងទឹកកខ្វក់ និងទឹកភ្លៀង ដែលនេះធ្វើឱ្យបរិមាណទឹកកខ្វក់ដែលមានសារធាតុពុលមានច្រើនជាងធម្មតាដែលហូរចូលទៅក្នុងខ្សែទឹកទន្លេ និងបឹងទន្លេសាប។ នៅមានបញ្ហាជាច្រើនទៀតដែលត្រូវដោះស្រាយបន្ត និងអភិវឌ្ឍបន្ថែមពាក់ព័ន្ធប្រព័ន្ធលូបង្ហូរទឹក ដូច្នេះប្រព័ន្ធបង្ហូរទឹកភ្លៀងខ្លះបានរាំងស្ទះនៅពេលមានភ្លៀងខ្លាំង។ ប្រសិនបើនៅតែបន្តអនុវត្តន៍តាមទម្លាប់ធម្មតា រួមផ្សំជាមួយនឹងការកើនឡើងនៃចំនួនប្រជាជន និងភ្ញៀវទេសចរនៅក្នុងក្រុងសៀមរាប បញ្ហាទឹកកខ្វក់នឹងកាន់តែធ្ងន់ធ្ងរនៅពេលអនាគត ។

ក្រៅពីកិច្ចខិតខំប្រឹងប្រែងក្នុងការតភ្ជាប់លូបង្ហូរទឹកពីលំនៅឋានប្រជាពលរដ្ឋ និងតាមអាជីវកម្មទៅនឹងប្រព័ន្ធលូបង្ហូរទឹកមេក្នុងក្រុង បញ្ហាដែលចាំបាច់មួយទៀត គឺការធ្វើប្រព័ន្ធលូដាច់ដោយឡែករវាងទឹកកខ្វក់ និងទឹកភ្លៀង ព្រោះប្រព័ន្ធដាច់ដោយឡែកវានឹងជួយកាត់បន្ថយបរិមាណទឹកក្នុងអាងប្រព្រឹត្តិកម្មទឹកកខ្វក់ដែលមានស្រាប់ និងទៅថ្ងៃអនាគត និងធ្វើឱ្យអាងប្រព្រឹត្តិកម្មកាន់តែមានប្រសិទ្ធភាពក្នុងការចម្រោះទឹកកខ្វក់បានច្រើនជាងមុន។ ផ្តើមចេញពីទស្សនទានអភិវឌ្ឍន៍បៃតង ការអនុវត្តឱ្យបាន១០០ភាគរយ នូវប្រព័ន្ធលូទឹក និងការចម្រោះទឹកកខ្វក់ប្រកបដោយប្រសិទ្ធភាពនឹងផ្តល់អត្ថប្រយោជន៍ច្រើនដល់បរិស្ថាន និងសុខភាពសាធារណៈ។ ក្រៅពីនេះ នៅមានលទ្ធភាពក្នុងការកាត់បន្ថយបរិមាណទឹកស្អួត និងសារធាតុប៊ីអូឌី (BOD[៩១]) នៅក្នុងទឹកកខ្វក់ដោយការចម្រោះភក់តាមរយៈរោងចក្រជីវៈឧស្ម័ន និងការប្រើប្រាស់ជីវៈឧស្ម័នដើម្បីជាប្រភពថាមពលកកើតឡើងវិញ។

## គេហដ្ឋាន

សហគមន៍ក្រីក្របំផុតនៅខេត្តសៀមរាប ភាគច្រើនអាស្រ័យនៅលើដីសាធារណៈរបស់រដ្ឋ និងច្រករបៀងផ្លូវដែលមិនរាប់បញ្ចូលពួកគេពីការទទួលសេវាផ្លូវការពីរដ្ឋ ដូចជាហេដ្ឋារចនាសម្ព័ន្ធផ្លូវ ប្រព័ន្ធលូបង្ហូរទឹកស្អាត និងភ្លើង និងសេវាកម្មគ្រប់គ្រងសំរាម។ ស្ថានភាពរស់នៅរបស់អ្នកក្រីក្រ អាចត្រូវបានធ្វើឱ្យប្រសើរឡើងដោយការផ្លាស់ប្តូរទីលំនៅបច្ចុប្បន្នពីការរស់នៅតាមចិញ្ចើមផ្លូវទៅតំបន់ដែលបានកំណត់ច្បាស់លាស់ និងធានាដីសម្រាប់ការតាំងទីលំនៅថ្មី និងសម្រាប់ការលើកកម្ពស់ជីវភាពរស់នៅរបស់ប្រជាជន ដែលរស់នៅតំបន់អនាធិបតេយ្យ។ គួរមានការរៀបចំទុកមុននូវការតាំងទីលំនៅថ្មីដែលបានគ្រោងទុកត្រឹមត្រូវ ដើម្បីកាត់បន្ថយការប្រើប្រាស់ថាមពល និងការប្រើប្រាស់ទឹកនិងការបង្កើតសំណល់ និងដើម្បីឱ្យប្រជាជនមានមធ្យោបាយងាយស្រួលក្នុងការដឹកជញ្ជូនសាធារណៈ និងជាមួយតំបន់លំហបៃតង។

## ការដឹកជញ្ជូន

អាជ្ញាធរក្រុង ទទួលស្គាល់ពីភាពចាំបាច់ដើម្បីកែលម្អការដឹកជញ្ជូន ដើម្បីកាត់បន្ថយការបំពុលបរិយាកាស និងធ្វើឱ្យប្រសើរឡើងនូវការធ្វើដំណើរទៅមកសម្រាប់អ្នកថ្មើរជើង ដោយបង្កើនការអនុវត្តច្បាប់ចរាចរណ៍រួមទាំងការចតរថយន្ត។ ក្រៅពីការត្រួសត្រាយផ្លូវ (បច្ចុប្បន្នមានតែ ១៥ ភាគរយប៉ុណ្ណោះ ដែលត្រូវបានក្រាលរួចក្រៅពីនេះ ហេដ្ឋារចនាសម្ព័ន្ធផ្លូវថ្នល់នៅតាមរមណីយដ្ឋាននានាកំពុងមានភាពយឺតយ៉ាវ)។ នៅមានឱកាសធ្វើឱ្យប្រសើរឡើងនូវការដឹកជញ្ជូនសាធារណៈរួមទាំងការលើកកម្ពស់ការប្រើប្រាស់យានយន្តអគ្គិសនី ជាពិសេសពីកណ្តាលទីក្រុងទៅកាន់តំបន់ទេសចរណ៍សំខាន់ៗ ព្រមទាំងបង្កើតឱ្យមានផ្លូវសម្រាប់ជិះកង់ និងថ្មើរជើង។ ហេដ្ឋារចនាសម្ព័ន្ធបែបនេះ នឹងបម្រើដល់ទីផ្សារទេសចរណ៍ទំនើប ក៏ដូចជាគាំទ្រដល់ការអភិវឌ្ឍសេដ្ឋកិច្ចក្នុងតំបន់។

## ផែនការទីក្រុង

ស្របនឹងអន្តរាគមន៍ជាក់លាក់ដែលបានពិភាក្សាខាងលើ រដ្ឋបាលក្រុងសៀមរាបចាំបាច់ត្រូវដាក់វិធីសាស្ត្រទីក្រុងប្រកបដោយនិរន្តរភាពនៅក្នុងក្របខ័ណ្ឌផែនការទីក្រុងរបស់ខ្លួន ដើម្បីធានាថាវិធីសាស្ត្រនេះ នឹងរួមចំណែកដល់ចក្ខុវិស័យ និងគោលដៅរួមរបស់ប្រទេសកម្ពុជា។ ធ្វើដូចនេះ គឺដើម្បីបញ្ចៀសការចំណាយថ្លៃច្រើន ការចំណាយធនធានច្រើន ប្រព័ន្ធសម្រាប់ការបំពុលបរិស្ថាននិង ដើម្បីដោះស្រាយបញ្ហាប្រឈមនិងឱកាសបន្ថែមទៀត ដូចជា

[៩១] BOD - គឺជាសារធាតុមួយសម្រាប់វាយតម្លៃគុណភាពទឹកដែលត្រូវបានធ្វើប្រព្រឹត្តកម្ម

ការគ្រប់គ្រងការរីករាលដាលនៃទីក្រុងដែលមិនមានការគ្រប់គ្រង និងជំរុញការអភិរក្សតំបន់ការពារ។ ការរួមបញ្ចូលគោលការណ៍ គោលដៅ និងហេដ្ឋារចនាសម្ព័ន្ធទីក្រុងនិរន្តរភាពដែលបានចែងនៅក្នុងផែនការយុទ្ធសាស្ត្រទីក្រុងនិរន្តរភាព ទៅក្នុងការប្រើប្រាស់ដីធ្លី និងផែនការមេនៃវិស័យទីក្រុងក៏មានសារៈសំខាន់ផងដែរ ពីព្រោះវានឹងជួយឱ្យក្រុងនេះ ទាក់ទាញការយកចិត្តទុកដាក់ ប្រមូលធនធាន និងហិរញ្ញវត្ថុពីដៃគូអភិវឌ្ឍន៍អន្តរជាតិ និងវិនិយោគិនឯកជន និងសាធារណៈ។

## ២.៣. សកម្មភាពអាទិភាព

ក្រោមកម្មវត្ថុរួមទាំង ១២ និងសកម្មភាពទូទៅ ៩៨ ដែលបានចែងនៅក្នុងផែនការយុទ្ធសាស្ត្រទីក្រុងសូមលុបចោលនិរន្តរភាព ក្រុងសៀមរាបបានជ្រើសរើសសកម្មភាពអាទិភាព ដូចខាងក្រោម៖

| ល.រ | ឈ្មោះគម្រោង | បរិយាយសង្ខេបអំពីអត្ថប្រយោជន៍ផ្នែកសង្គម សេដ្ឋកិច្ច និងបរិស្ថាននៃគម្រោងអាទិភាពរបស់ក្រុង |
|---|---|---|
| ១ | ស្តារ និងពង្រីកប្រព័ន្ធលូមេរំដោះទឹកភ្លៀង និងទឹកកខ្វក់ក្នុងតំបន់កណ្តាលក្រុង | កែលម្អបណ្តាញលូរំដោះទឹកភ្លៀង និងទឹកកខ្វក់ ដែលអាចបញ្ចៀសបញ្ហាជំនន់ទឹកភ្លៀងក្នុងក្រុង និងការស្ទះលូរំដោះទឹក។ កាត់បន្ថយផលប៉ះពាល់ បរិស្ថាន និងជីវៈចម្រុះ។ លើកកម្ពស់សោភ័ណភាពក្រុងនិងសុខភាពសាធារណៈ។ |
| ២ | កែលម្អប្រព័ន្ធគ្រប់គ្រងសំណល់កក់ចេញពីបង្គន់អនាម័យ និងការតភ្ជាប់ទៅ បណ្តាញលូមេ។ | កាត់បន្ថយការបញ្ចេញចោលនូវសំណល់កក់ និងទឹកកខ្វក់ចេញពីបង្គន់ ទៅក្នុងប្រភពទឹកធម្មជាតិ (ប្រឡាយ ស្ទឹង ដៃទន្លេធម្មជាតិ) ដើម្បី ជួយដល់និរន្តរភាពបរិស្ថាន និងលើកកម្ពស់សោភ័ណភាពក្រុង សុខមាលភាព ប្រជាពលរដ្ឋ។ គោលបំណងនេះអាចសម្រេចបានតាមរយៈការកែលម្អនូវគុណភាពបច្ចេកទេសលូដែលផ្ទុកសំណល់ ការស្តារលូ ការដឹកជញ្ជូន និងការធ្វើប្រព្រឹត្តកម្ម។ |
| ៣ | បង្កើតប្រព័ន្ធ (វដ្ត) នៃការគ្រប់គ្រងខ្សែសង្វាក់សំរាមដែលអាចកែច្នៃឡើងវិញបាននៅក្រុងសៀមរាប និងអភិវឌ្ឍន៍ទីលានចាក់សំរាមដែលមានស្តង់ដារបច្ចេកទេសបរិស្ថាន | កាត់បន្ថយបរិមាណសំរាមតាមទីសាធារណៈក្នុងក្រុង និងការចោលសំរាម តាមប្រឡាយ បឹង ស្រះទឹក និងតាមដៃទន្លេធម្មជាតិ ដើម្បី ជួយដល់និរន្តរភាព បរិស្ថាន និងលើកកម្ពស់សោភ័ណភាពក្រុង សុខមាលភាពប្រជាពលរដ្ឋ។<br><br>ជំរុញ និងលើកទឹកចិត្តឱ្យមានខ្សែសង្វាក់តម្លៃនៃការធ្វើអាជីវកម្មកែច្នៃសំរាម (រាប់ចាប់ពីការញែកសំរាមនៅប្រភពផ្ទាល់ ការប្រមូល ការដឹកជញ្ជូន និងការកែច្នៃ) ដែលវាជាកត្តារួមចំណែកដល់ការរក្សានិរន្តរភាពបរិស្ថាន និងកំណើនសេដ្ឋកិច្ចសង្គម។ |
| ៤ | សិក្សាពីលទ្ធភាពបង្កើតប្រភពថាមពលកកើតឡើងវិញ និងប្រសិទ្ធភាពថាមពល នៅក្រុងសៀមរាប | ដើម្បីឆ្លើយតបទៅនឹងតម្រូវការថាមពលសម្រាប់អគ្គិសនី តាមរយៈការប្រើប្រាស់នូវប្រភពថាមពលកកើតឡើងវិញ និងអនុវត្តនូវប្រសិទ្ធភាពថាមពល ដែលនឹងរួមចំណែកដល់ការរក្សាបាននូវនិរន្តរភាពធនធានធម្មជាតិ និងផលប៉ះពាល់លើបរិស្ថាន។ |
| ៥ | បំពាក់អំពូលភ្លើងប្រភេទ LED តាមដងផ្លូវសាធារណៈដែលដើរដោយថាមពលពន្លឺព្រះអាទិត្យ | លើកកម្ពស់សោភ័ណភាពក្រុង និងឆ្លើយតបទៅនឹងតម្រូវការថាមពលសម្រាប់អគ្គិសនី តាមរយៈការប្រើប្រាស់នូវប្រភពថាមពលពន្លឺព្រះអាទិត្យ និងការអនុវត្តនូវប្រសិទ្ធភាពថាមពល ដែលនឹងរួមចំណែកដល់ការរក្សាបាននូវនិរន្តរភាពធនធានធម្មជាតិ និងផលប៉ះពាល់លើបរិស្ថាន។ |

| | | |
|---|---|---|
| ៦ | ធ្វើការអភិវឌ្ឍលំនៅឋានដែលមានតម្លៃសមរម្យ និងកែលម្អតំបន់វប្បធម៌ តំបន់ អេកូទេសចរណ៍ តំបន់ពាណិជ្ជកម្ម និងទីធ្លា សាធារណៈ ក្នុងក្រុង | កាត់បន្ថយការមកតាំងទីលំនៅខុសច្បាប់ និងដើម្បីកាត់បន្ថយផលប៉ះពាល់ ផ្នែកសុខភាពរបស់ប្រជាពលរដ្ឋដែលបណ្តាលមកពីការរស់នៅខុសច្បាប់(តាមដងផ្លូវ ដែលហុយ និងគ្មានអនាម័យ...) តាមរយៈសមាហរណកម្មពួកគេ ទៅក្នុងកម្មវិធីលំនៅឋានសមរម្យស្របតាមច្បាប់របស់ រដ្ឋ។ រក្សានូវសណ្តាប់ធ្នាប់ សាធារណៈ និងការលើកកម្ពស់សោភ័ណភាពក្រុងដើម្បីទាក់ទាញភ្ញៀវទេសចរ។ |
| ៧ | រៀបចំប្រព័ន្ធមធ្យោបាយដឹកជញ្ជូនសាធារណៈ ដែលមិនបំពុលបរិស្ថានក្នុង រមណីយដ្ឋានអង្គរ | កាត់បន្ថយការប្រើប្រាស់រថយន្តឯកជន កាត់បន្ថយការកកស្ទះ កាត់បន្ថយផ្សែងពុលក្នុងបរិយាកាសនៅក្នុងតំបន់រមណីយដ្ឋានអង្គរ លើកកម្ពស់សុខុមាលភាពប្រជាពលរដ្ឋ និងរក្សាបាននូវនិរន្តរភាពបរិស្ថាន។ |
| ៨ | ផ្សព្វផ្សាយដល់ប្រជាពលរដ្ឋឱ្យយល់ដឹងពីការ គ្រប់គ្រងសំរាម ដូចជាការចោល/ទុកដាក់សំរាម និងការប្រើប្រាស់ថង់សំរាម បរិស្ថាន (eco-bag) | ជំរុញ និងលើកទឹកចិត្តឱ្យប្រជាពលរដ្ឋទុកដាក់សំរាមឱ្យបានសមរម្យដែលជួយដល់ការប្រមូល/ដឹកជញ្ជូន។ លើកកម្ពស់ការយល់ដឹងរបស់ប្រជាពលរដ្ឋពីផលប៉ះពាល់លើបរិស្ថានពីការចោលសំរាមពាសវាលពាសកាលគ្មានអនាម័យ តាមរយៈការដាក់នូវផ្លាកសញ្ញាបរិស្ថានពីការទុកដាក់សំរាម នៅក្នុងក្រុង ទីធ្លាសាធារណៈ និងតាមផ្សារ។ |
| ៩ | អភិវឌ្ឍន៍តំបន់ទេសចរណ៍បែបធម្មជាតិនៅក្នុងតំបន់អង្គរ | លើកកម្ពស់វិស័យទេសចរណ៍បែបធម្មជាតិ ដែលជួយដល់ការរក្សាបាននូវធនធានធម្មជាតិ និរន្តរភាពបរិស្ថាន។ ការបង្កើតនូវទេសចរណ៍បែបធម្មជាតិ ក៏នឹងជួយដល់ការបង្កើតការងារបៃតងសម្រាប់ប្រជាពលរដ្ឋនៅខេត្តសៀមរាបផងដែរ។ |
| ១០ | បង្កើតភូមិមួយ ផលិតផលមួយ | លើកកម្ពស់ការប្រើប្រាស់វត្ថុធាតុដើម ផលិតផលក្នុងស្រុក ការបង្កើតការងារបៃតង និងជំនាញក្នុងការផលិតផលិតផលក្នុងស្រុក ដែលនេះនឹងជួយដល់ការរក្សាបាននូវធនធានធម្មជាតិ និងរក្សាបាននូវនិរន្តរភាពបរិស្ថាន។ |

*ប្រភព៖ ការប្រឹក្សាយោបល់ជាមួយរដ្ឋបាលក្រុងសៀមរាប*

## ២.៤. ព័ត៌មានអំពីស្ថិតិសេដ្ឋកិច្ច-សង្គម

| សន្ទស្សន៍ | ឆ្នាំ២០១៦ |
|---|---|
| ចំនួនប្រជាជន (នាក់) | ២៤០.៦៤៨ |
| ដង់ស៊ីតេប្រជាជន(នាក់/គ.ម²) | ៥៤៩,៤៨ |
| អត្រាក្រីក្រ (ភាគរយ) | ១៤,៨១% |
| ផ្ទៃក្រឡា (គ.ម²) | ៤២៤,៧៣ |
| អត្រាអក្ខរកម្ម (ការបង្ហាញសិក្ខាសាលា) (ភាគរយ) | ៨៧% |
| វិស័យសេដ្ឋកិច្ចសំខាន់ | ទេសចរណ៍ |
| អត្រាការងារក្នុងវិស័យផ្សេងៗ (ភាគរយ) | |

| | |
|---|---|
| - កសិកម្ម | ២៨,៦% |
| - ផលិតកម្ម | ២,៧% |
| - សេវាកម្ម | ៦៨,៧% |
| ចំណាកស្រុក (ទៅក្រៅប្រទេស) (នាក់) | ១.៨២៦ |
| មធ្យមភាគទោចក្រយានយន្តក្នុងផ្ទះ (គ្រឿង) | ១ |
| ចំនួនប្រជាជនដែលជាប់បំណុល (ធនាគារ ឬមីក្រូហិរញ្ញវត្ថុ) (នាក់) | ១៥.៥៧៩ |
| ចំនួនផ្ទះនៅសំណង់អនាធិបតេយ្យ/លំនៅឋានខុសច្បាប់ (ខ្នងផ្ទះ) | ២.៩៧២ |
| ចំនួនផ្ទះដែលទទួលឥទ្ធិពលពីខ្យល់ព្យុះ (ខ្នងផ្ទះ) | ១២ |
| ចំនួនផ្ទះដែលទទួលឥទ្ធិពលពីទឹកជំនន់ (ខ្នងផ្ទះ) | ៥១ |
| ចំនួនផ្ទះដែលទទួលឥទ្ធិពលពីភាពរាំងស្ងួត (ខ្នងផ្ទះ) | ១.៩២១ |
| ភាគរយផ្ទះដែលសេវាកម្មប្រមូលសំរាមអាចចូលទៅដល់ (ភាគរយ) | ៧៣,៦៨% |
| ភាគរយផ្ទះដែលមានប្រព័ន្ធទឹកតាមបំពង់ទុយោ (ភាគរយ) | ៨២,៦% |
| ភាគរយផ្ទះដែលមានភ្លើងប្រើប្រាស់ (ភាគរយ) | ១៩,១៨%(៨.៦០២HHs) |
| ភាគរយផ្ទះដែលមានភ្លើងប្រើប្រាស់ (ភាគរយ) | ៩៥,៦% |
| ចំនួនសំរាមក្នុងមួយថ្ងៃ (តោន) | ៣៨០តោន |


ក្រុងសៀមរាប




ក្រុងបាត់ដំបង

# ក្រុងបាត់ដំបង

## ២.១. សេចក្តីផ្តើម

ក្រុងបាត់ដំបង មានទីតាំងស្ថិតនៅតាមដងស្ទឹងសង្កែតាមផ្លូវជាតិលេខ៥ ជាទីក្រុងដែលមានប្រជាជនរស់នៅជាង ១៥០.០០០ នាក់ ជាមួយនឹងកំណើនប្រជាជនកើនឡើងជាបន្តបន្ទាប់។ ដោយក្រុងបាត់ដំបងមានព្រំប្រទល់ជាប់គ្នាជាមួយក្រុងសៀមរាប ក្រុងបាត់ដំបងក្លាយជាគោលដៅទេសចរណ៍ពេញនិយមមួយដែលមានទាំងផ្នែកទេសចរណ៍ធម្មជាតិ និងទេសចរណ៍បែបបេតិកភណ្ឌវប្បធម៌។ ស្ថិតនៅភាគខាងលើនៃប្រទេស បាត់ដំបងជាទីតាំងភូមិសាស្ត្រអំណោយផលល្អមួយដោយសារមានព្រំប្រទល់អន្តរជាតិជាប់ជាមួយប្រទេសថៃ ដែលជាគោលដៅទេសចរណ៍ដ៏ល្បីល្បាញបំផុតមួយនៅក្នុងតំបន់អាស៊ីអាគ្នេយ៍។

ក្រុងបាត់ដំបង នឹងទទួលបានផលប្រយោជន៍ផ្នែកសេដ្ឋកិច្ចនៅពេលដែលខ្សែរថភ្លើងតភ្ជាប់ពីរាជធានីភ្នំពេញទៅក្រុងប៉ោយប៉ែតដែលមានព្រំប្រទល់ជាប់ប្រទេសថៃ ត្រូវបានរៀបចំឱ្យដំណើរការបានចប់សព្វគ្រប់។ ទោះបីជាក្រុងបាត់ដំបងបានទទួលផលប្រយោជន៍បែបនេះក្តី ក្រុងបាត់ដំបង និងតំបន់ជាយក្រុង នឹងរងឥទ្ធិពលយ៉ាងធំដោយសារកម្រិតកម្ពស់ទឹកភ្លៀងប្រចាំឆ្នាំ ធ្វើឱ្យក្រុងបាត់ដំបងជួបប្រទះនូវភាពរាំងស្ងួត ឬករណីទឹកជំនន់ដែលធ្វើឱ្យតំបន់ខ្លះមិនអាចធ្វើដំណើរទៅបានបើមិនមានទូក។ ក្នុងឆ្នាំ២០១៤ ក្រុងបាត់ដំបងបានទទួលពានរង្វាន់ក្របខ័ណ្ឌអាស៊ានស្តីពី គុណភាពបរិស្ថានក្នុងក្រុង ប៉ុន្តែក្នុងពេលបច្ចុប្បន្នក្រុងក៏កំពុងរងសម្ពាធក្នុងការរក្សាបរិស្ថានឱ្យស្អាត ដូចជាសម្ពាធនៃការកើនឡើងកម្រិតជាតិពុលក្នុងទឹកស្ទឹងសង្កែដែលហូរកាត់ចំកណ្តាលក្រុងបាត់ដំបង បញ្ហាអនាម័យ និងទឹកកខ្វក់ បញ្ហាសំរាម និងការដឹកជញ្ជូនក្នុងក្រុង។ បញ្ហាទាំងនេះ នាំឱ្យមានផលប៉ះពាល់លើវិស័យទេសចរណ៍ក្រុង និងផលប៉ះពាល់អវិជ្ជមានដល់បរិស្ថាន និងគុណភាពនៃការរស់នៅប្រចាំថ្ងៃរបស់ប្រជាជនក្រុង។

តារាង៖ ស្ថិតិប្រជាសាស្ត្រក្រុងបាត់ដំបង(ស្ថិតិសេដ្ឋកិច្ចសង្គមរបស់ក្រុងបាត់ដំបង ឆ្នាំ២០១៦)

| ស្ថិតិប្រជាសាស្ត្រ | ២០១២ | ២០១៣ | ២០១៤ | ២០១៥ |
|---|---|---|---|---|
| ចំនួនប្រជាជន (នាក់) | ១៤៧.៦៦២ | ១៥០.៧១១ | ១៥៣.៧២៧ | ១៥៥.៥៨៤ |
| អត្រាកំណើនប្រចាំឆ្នាំ (ភាគរយ) | ០,១ | ២,១ | ២,០ | ១,២ |
| ចំនួនស្ត្រី (នាក់) | ៧៥.៤២៤ | ៧៦.៨៤៥ | ៧៨.៣៨៣ | ៧៨.៧៤៤ |
| សមាមាត្រស្ត្រីធៀបនឹងបុរស (ក្នុងចំណោមបុរស ១០០នាក់) | ១០៤,៤ | ១០៤,០ | ១០៤,០ | ១០២,៥ |
| ចំនួនគ្រួសារ (គ្រួសារ) | ២៦.៧៧៧ | ២៧.០៧១ | ២៧.៧៦៧ | ២៨.៦៩៥ |
| សមាជិកគ្រួសារគិតជាមធ្យម (នាក់) | ៥,៥ | ៥,៦ | ៥,៥ | ៥,៤ |

# ២.២.ការវិភាគតាមវិស័យ សម្រាប់ការអភិវឌ្ឍទីក្រុងនិរន្តរភាព

## ទេសចរណ៍

យោងតាមមន្ទីរទេសចរណ៍ខេត្តក្រុងបាត់ដំបងមានភ្ញៀវទេសចរណ៍ប្រមាណ ៩៦.៤៦០នាក់ ក្នុងឆ្នាំ២០១៦។ កន្លែងទាក់ទាញរបស់ក្រុងបាត់ដំបង គឺតំបន់ប្រវត្តិសាស្ត្រ និង "រទេះភ្លើងឬស្សី" នៅផ្លូវរថភ្លើងដែលកំពុងចាស់ទ្រុឌទ្រោម។ ក្រុងមានសណ្ឋាគារចំនួន ៤៨ (១.៩៥៨បន្ទប់) មានផ្ទះសំណាក់ចំនួន ៧១ (១.១៩៩ បន្ទប់) ភោជនីយដ្ឋានចំនួន៦៥ កន្លែងខារ៉ាអូខេចំនួន ២១ និងកន្លែងម៉ាស្សាចំនួន ៦ (៣៥គ្រែ) និងទីកន្លែងរាំកម្សាន្ត ៤។ ឯកសារស្តីពីស្ថាបត្យកម្ម និងតំបន់បេតិកភណ្ឌក្រុង កំពុងត្រូវបានរៀបចំដោយមន្ទីរទេសចរណ៍។ មន្ទីរក៏កំពុងរៀបចំឱ្យមានការបើកឱ្យសាធារណជនចូលទស្សនាអគាររដ្ឋបាលខេត្ត និងការពង្រីកនូវផ្សាររាត្រីនៅក្នុងតំបន់ប្រវត្តិសាស្ត្រ (ផ្លូវសម្រាប់តែអ្នកថ្មើរជើងកំពុងត្រូវបានរចនារៀបចំ) ក៏ដូចជាការបង្កើតទីធ្លាសាធារណៈ[៩២]។

អាជ្ញាធរក្រុង បានកំណត់យកវិស័យទេសចរណ៍ជាកត្តាសេដ្ឋកិច្ចមួយយ៉ាងសំខាន់ក្នុងការអភិវឌ្ឍក្រុងនៅថ្ងៃអនាគត។ ដោយសារមានទីតាំងនៅជិតនឹងអាកាសយានដ្ឋានអន្តរជាតិសៀមរាប និងជិតព្រំប្រទល់អន្តរជាតិជាមួយប្រទេសថៃ ព្រមទាំងពេលអនាគតមានខ្សែរថភ្លើងឆ្លងកាត់ពីព្រំប្រទល់ប្រទេសថៃមកភ្នំពេញ ដោយកាត់តាមក្រុងបាត់ដំបង ធ្វើឱ្យក្រុងបាត់ដំបងក្លាយជាច្រកចេញចូលទាំងអ្នកដំណើរជាតិ និងអន្តរជាតិកាន់តែច្រើនឡើង។

នៅកណ្តាលក្រុងបាត់ដំបង មានអគារជាង ៧០០ខ្នង សល់ពីជំនាន់អាណានិគម ដែលភាគច្រើននៃអគារទាំងនោះមានសក្តានុពលត្រូវបានចាត់ថ្នាក់ជាបេតិកភណ្ឌពិភពលោក និងជាកន្លែងទាក់ទាញភ្ញៀវទេសចរយ៉ាងសំខាន់។ ហេតុដូចនេះអគារទាំងនោះត្រូវបានចាត់ជាអាទិភាពក្នុងការថែរក្សា និងអភិរក្ស ដើម្បីធ្វើឱ្យក្លាយទៅជាកន្លែងសំខាន់នៃការផ្សព្វផ្សាយព័ត៌មានទេសចរណ៍ ឧទាហរណ៍តាមរយៈទេសចរណ៍បែប "វប្បធម៌"។ ការទាក់ទាញបន្ថែមទៀតរួមមានការបង្កើនចំនួនសណ្ឋាគារ និងភោជនីយដ្ឋានដែលមានគុណភាពខ្ពស់ និងការអភិវឌ្ឍទីធ្លាសាធារណៈឱ្យបានល្អ ដូចជាសួនច្បារជាដើម។

ក្រុងបាត់ដំបង ជួបប្រទះបញ្ហាប្រឈមជាច្រើនក្នុងការអភិវឌ្ឍវិស័យទេសចរណ៍ដែលត្រូវការដោះស្រាយដើម្បីឱ្យក្រុងកាន់តែមានភាពទាក់ទាញ។ បញ្ហាប្រឈមទាំងនេះរួមមាន សំណង់អគារមរតក-បេតិកភណ្ឌដែលចាស់ទ្រុឌទ្រោម និងកង្វះទស្សនីយភាព (ការបាំងដោយសារផ្ទាំងប៉ាន់ណូផ្សាយពាណិជ្ជកម្មធំៗ) ប្រព័ន្ធលូរំដោះទឹកភ្លៀង និងទឹកកខ្វក់ មានសភាពចាស់ និងខូចគុណភាព គំនរសំរាមនៅតាមដងផ្លូវ និងថវិកាក្រុងមានកំណត់ដើម្បីអភិវឌ្ឍន៍សក្តានុពលទេសចរណ៍ ក្នុងបរិបទសេដ្ឋកិច្ចបៃតង។

ការកើនឡើងនូវសណ្ឋាគារ និងភោជនីយដ្ឋាន កម្មវិធីដាក់ស្លាកសញ្ញាបៃតង ឬបណ្ណបញ្ជាក់បៃតងគឺផ្តោតលើស្តង់ដារអនាម័យខ្ពស់និងប្រកបដោយនិរន្តភាពដែលផ្តល់ឱ្យម្ចាស់អាជីវកម្មនូវប្រយោជន៍ក្នុងការប្រកួតប្រជែង និងលើកកម្ពស់ការផ្សព្វផ្សាយភាពបៃតងរបស់ក្រុងបាត់ដំបង។ ការអភិវឌ្ឍនិរន្តរភាពក្នុងវិស័យទេសចរណ៍ មិនត្រឹមតែផ្តោតនៅតំបន់ក្រុងនោះទេ គឺការធ្វើអេកូទេសចរណ៍គួរតែត្រូវបានពង្រីកដើម្បីប្រើប្រាស់នូវធនធានធម្មជាតិប្រកបដោយប្រសិទ្ធភាព។

## ការគ្រប់គ្រងសំណល់

ក៏ដូចជាក្រុងធំៗដទៃទៀតរបស់ប្រទេសកម្ពុជា ការកែលម្អការគ្រប់គ្រងសំណល់គឺនៅតែជាបញ្ហាចម្បងមួយសម្រាប់ក្រុងបាត់ដំបង និងជាកត្តាប្រឈមដ៏ធំមួយទៅថ្ងៃអនាគតក្នុងការអភិវឌ្ឍទីក្រុងនិរន្តរភាព។

បច្ចុប្បន្នការប្រមូលសំរាមមានសភាពយឺតយ៉ាវនិងមិនត្រូវបានប្រមូលគ្រប់ទីកន្លែងក្នុងក្រុងនោះទេ។ លំនៅឋានខ្លះរថយន្តប្រមូលសំរាមមិនអាចចូលទៅដល់បានដោយសារផ្លូវតូចចង្អៀត ហើយប្រជាជនមិនមានលទ្ធភាពបង់ថ្លៃសេវាប្រមូលសំរាមបាន។ គ្មានការទប់ស្កាត់ការចោលសំរាមនៅតាមដងផ្លូវតូចៗ និងលើប្រឡាយ/ផ្លូវរទេះតាមលំនៅឋានប្រជាជនរស់នៅ។ សំរាមត្រូវបានប្រមូលដោយក្រុមហ៊ុនឯកជនដោយភាគច្រើនយកទៅដុតចោលនៅកន្លែងទីលានចាក់សំរាម ដែលធ្វើឱ្យមានផ្សែងពុលអាក្រក់ជះទៅបរិយាកាស និងដីជាពិសេសសារជាតិពុលតាមរយៈការដុតជ័រប្លាស្ទិកទាំងនោះ។ សព្វថ្ងៃនេះ ក្រុងបាត់ដំបងមានកន្លែងកែច្នៃសំរាមចំនួន ២កន្លែង សម្រាប់

[92] AFD, "Terms of Reference for the Feasibility Study on Sustainable Development of Cambodian Cities," 2017.

ធ្វើកំប៉ុសពីសំរាមដែលប្រមូលពីតាមផ្សារ និងកន្លែងកែច្នៃប្លាស្ទិក ទៅជាគ្រាប់ ដើម្បីលក់ទៅប្រទេសថៃធ្វើជាវត្ថុធាតុដើម។ ទីតាំងកែច្នៃសំរាមទាំងពីរកន្លែង មានបញ្ហាក្នុងការទទួលបាននូវសំរាមដែលល្អ និងទុកចិត្តបាន។ ស្ថានីយកែច្នៃមួយ (Material Recovery Facility) ទើបតែត្រូវបានសាងសង់រួច និងបានដាក់ស្ថិត នៅក្រោមការទទួលខុសត្រូវរបស់ក្រុង។ ប៉ុន្តែស្ថានីយនេះមិនទាន់បានចាប់ផ្តើមដំណើរការល្អនៅឡើយទេ ហើយក៏មិនទាន់បំពាក់សម្ភារបានពេញលេញដែរ។

ដើម្បីឱ្យក្រុងស្អាត និងកាន់តែសប្បាយរីករាយសម្រាប់ប្រជាជន ព្រមទាំងភ្ញៀវទេសចរ ចាំបាច់ត្រូវដោះស្រាយបញ្ហាប្រឈមទាំងនោះ។ វិធានការរយៈពេលខ្លីជាក់លាក់ រួមមានការពង្រីកសេវាកម្មប្រមូលសំរាមហូតទៅដល់ជាយក្រុង ការបង្កើតហេដ្ឋារចនាសម្ព័ន្ធសម្រាប់ការបែកចែកប្រភេទសំរាមតាមផ្ទះ និងអាជីវកម្ម និងការកែច្នៃប្រើប្រាស់ឡើងវិញ ព្រមទាំងការអភិវឌ្ឍកន្លែងចាក់សំរាមឱ្យមានអនាម័យ។ ផ្តើមចេញពីទស្សនអភិវឌ្ឍន៍បៃតង សំរាមកែច្នៃ ក៏ជាមូលដ្ឋានសម្រាប់បង្កើតក្រុមហ៊ុនខ្នាតតូច និងមធ្យម ដែលធ្វើការប្រមូល កែច្នៃ និងលក់ផលិតផលដែលកែច្នៃចេញពីសំរាមឱ្យទៅជាអាជីវកម្មផ្សេងទៀត។ ការផលិតថាមពលដោយការដុតសំរាម ឬការស្រូបយកឧស្ម័ន (មេតាន) គឺជាឱកាសអភិវឌ្ឍន៍គម្រោងបៃតងមួយទៀតសម្រាប់ប្រតិបត្តិការឯកជន ហើយជាមួយគ្នានេះដែរ វាក៏ជាការចូលរួមមួយសម្រាប់គោលដៅជាតិរបស់ប្រទេសកម្ពុជាក្នុងការកាត់បន្ថយការបំភាយឧស្ម័នផ្ទះកញ្ចក់ផងដែរ។ សហគ្រាសធុនតូច និងមធ្យម នឹងត្រូវការការគាំទ្រពីរាជរដ្ឋាភិបាលដើម្បីធានាដល់ផ្នែកហិរញ្ញវត្ថុ ឧទាហរណ៍តាមរយៈការសម្របសម្រួលលទ្ធភាពក្នុងការទទួលបានសំរាម ឬផ្តល់ការលើកទឹកចិត្តផ្នែកសារពើពន្ធ។

## ទឹកកខ្វក់ និងអនាម័យ

ក្នុងប៉ុន្មានឆ្នាំថ្មីៗនេះ ក្រុងបាត់ដំបងមានការរីកលូតលាស់តំបន់ក្រុងទៅភាគខាងលិចនៃទន្លេ ដោយមិនមានការរៀបចំផែនការក្រុងច្បាស់លាស់។ កត្តានេះធ្វើឱ្យមានការថយចុះនូវផ្នែកខ្លះបែបធម្មជាតិនៃទន្លេដែលអាចស្រូបយកសំណល់រាវ ពីតំបន់ក្រុង (sponge) ក្នុងក្រុង ហើយទឹកភ្លៀងនៅតំបន់ធំៗមួយចំនួនមិនបានហូរចូលស្ទឹងសង្កែនោះទេ។ ក្រុងបាត់ដំបង ក៏ធ្លាប់ជួបប្រទះបញ្ហាទឹកជំនន់ (ជាពិសេសពីខែតុលា ដល់ធ្នូ) ដែលបានប៉ះពាល់ដល់ប្រជាពលរដ្ឋក្នុងតំបន់ និងបានបំផ្លាញដំណាំរាប់ពាន់ហិកតាផងដែរ ដែលភាគច្រើននៅតំបន់ដីសើម។ គម្រោងហេដ្ឋារចនាសម្ព័ន្ធមួយដែលផ្តល់ហិរញ្ញប្បទានដោយធនាគារអភិវឌ្ឍន៍អាស៊ី (ADB) និងទីភ្នាក់ងារអភិវឌ្ឍន៍បារាំង (AFD) នឹងកែលម្អស្ថានីយផ្គត់ផ្គង់ទឹកស្អាត និងស្ថានីយប្រព្រឹត្តិកម្មទឹកកខ្វក់ និងដើម្បីដោះស្រាយបញ្ហាទឹកកខ្វក់ហូរចូលទន្លេ[៩៣]។ នៅក្នុងអំឡុងពេលសរសេរផែនការនេះ ផែនការគ្រប់គ្រងទឹកកខ្វក់របស់ក្រុងកំពុងត្រូវបានរៀបចំបន្ថែមទៀត ដោយក្រុមហ៊ុនចិនឈ្មោះប៉េដឹងអឺប៊ីនខនស្រ្តាក់ស្ទឹនហ្គ្រុប (Beijing Urban Construction Group)។ មួយផ្នែកនៃប្រព័ន្ធលូទឹកភ្លៀង មិនទាន់ស្របតាមស្តង់ដារបច្ចេកទេសដែលតម្រូវដោយមន្ទីរសាធារណការ និងដឹកជញ្ជូន ហើយលូជាច្រើនមានលក្ខណៈស្ទះដោយសារសំរាម។ ដូច្នេះ វាត្រូវការជាចាំបាច់ដើម្បីថែទាំ និងកែលម្អប្រព័ន្ធទាំងនោះឱ្យត្រូវតាមស្តង់ដារ។

ក្រុងបាត់ដំបងមានប្រព័ន្ធប្រព្រឹត្តិកម្មទឹកកខ្វក់ចំនួន ៣ កន្លែង (អាងប្រព្រឹត្តិកម្មសារ៉ា អាងប្រព្រឹត្តិកម្មក្នុងសង្កាត់ព្រែកព្រះស្តេច អាងរំដោះទឹកខាងកើតស្ទឹង)។ កន្លែងទី១ បច្ចុប្បន្នមិនទាន់ដំណើរការនៅឡើយទេ ដូចនេះជាបន្ទាន់ត្រូវធ្វើការស្តារប្រព័ន្ធប្រព្រឹត្តិកម្មទឹកកខ្វក់ដែលមានស្រាប់។ ជាទូទៅ ប្រព័ន្ធលូទឹកភ្លៀង និងទឹកកខ្វក់ គឺងាយប៉ះពាល់ដល់បម្រែបម្រួលបរិយាកាស (ភាពរាំងស្ងួត និងទឹកជំនន់)។

ឱកាសពីការអភិវឌ្ឍបៃតងមួយទៀតចេញពីបញ្ហាទឹកកខ្វក់ គឺការបង្កើតថាមពលអគ្គិសនីពីជីវៈឧស្ម័ន យកចេញពីកាក់ដែលបានមកពីដំណើរការប្រព្រឹត្តិកម្មទឹកកខ្វក់។ ការអភិវឌ្ឍបែបនេះ នឹងចូលរួមចំណែកទាំងសេដ្ឋកិច្ចក្នុងស្រុក ក៏ដូចជាគោលដៅកាត់បន្ថយការបំភាយឧស្ម័នផ្ទះកញ្ចក់ផងដែរ។

## ផលិតផលកសិកម្មបៃតង

ដីកសិកម្មជុំវិញក្រុងបាត់ដំបងគឺជាដីមានជីវជាតិហើយវិស័យកសិកម្មមានសក្តានុពលល្អសម្រាប់ការអភិវឌ្ឍបៃតង ឧទាហរណ៍តាមរយៈការធ្វើស្រែសរីរាង្គប្រកបដោយនិរន្តរភាព និងការបង្កើតក្រុមហ៊ុនកែច្នៃ កសិផលខ្នាតតូច និងមធ្យម។ វិស័យទេសចរណ៍

[93] Cambodia Development Initiative for Asia (CDIA). "Climate Vulnerability Study to Help Shape Investments in Four Cambodian Cities," 2019. Accessed December 2, 2019. https://cdia.asia/2019/12/02/climate-vulnerability-study-to-help-shape-investments-in-four-cambodian-cities/

ក្នុងស្រុក ក៏ជាទីផ្សារដ៏ល្អមួយសម្រាប់ផលិតផលផលិតក្នុងស្រុក (ឧទាហរណ៍ សូត្រ ផ្លែឈើស្រស់ ដំណាប់ ទឹកឃ្មុំ ឬអង្ករសរីរាង្គ) ដែលគេលក់ទៅឱ្យសណ្ឋាគារ និងភោជនីយដ្ឋាន និងលក់ផ្ទាល់ទៅឱ្យភ្ញៀវទេសចរតាមហាងលក់វត្ថុអនុស្សាវរីយ៍។ លើសពីនេះទៅទៀត ផ្លែក្រូចដែលមានគុណភាពល្អដាំក្នុងក្រុងបាត់ដំបងត្រូវបានគេយកទៅលក់នៅតាមទីក្រុងផ្សេងៗទៀតនៃប្រទេសកម្ពុជា និងអាចធ្វើការនាំចេញផលិតផលទាំងនោះដូចជាទឹកក្រូច និងអង្ករ ទៅកាន់ប្រទេសជិតខាងដូចជាប្រទេសថៃជាដើម។

បញ្ហាប្រឈមមួយក្នុងការអភិវឌ្ឍសក្តានុពលទីផ្សារខាងលើគឺការខ្វះខាតចំណេះដឹងទូទៅ និងជំនាញបច្ចេកទេសក្នុងចំណោមកសិករ និងអាជីវករក្នុងស្រុក។ លើសពីនេះទៀត តួអង្គសំខាន់នៅក្នុងវិស័យទេសចរណ៍ ដូចជាសណ្ឋាគារ ភោជនីយដ្ឋាន មជ្ឈមណ្ឌលព័ត៌មានទេសចរណ៍ និងភ្នាក់ងារទេសចរណ៍ចាំបាច់ត្រូវយល់ដឹង និងត្រៀមខ្លួនក្នុងការប្រើប្រាស់សក្តានុពលនេះផងដែរ ឧទាហរណ៍ ផ្នែកទីផ្សាររបស់ខ្លួន ពោលគឺចំណេះដឹងបច្ចេកទេសនៅមានកម្រិតនៅឡើយ ព្រមទាំងកង្វះធនធានជំនាញនៅគ្រប់ផ្នែកទាំងនោះ។

ការអភិវឌ្ឍទីផ្សារទៅលើផលិតផលជំនាញ និងផលិតផលកសិកម្មមានគុណភាពខ្ពស់ នឹងផ្តល់ឱ្យនូវការចូលរួមចំណែកយ៉ាងសំខាន់ក្នុងការអភិវឌ្ឍបៃតងក្នុងក្រុងបាត់ដំបង ក៏ដូចជាតំបន់ផ្សេងទៀត តាមរយៈការធ្វើពិពិធកម្មផលិតផល និងការជំរុញសេដ្ឋកិច្ច ការបង្កើតប្រាក់ចំណូល និងការងារដល់កសិករ ជំរុញដល់ការរីកលូតលាស់វិស័យឧស្សាហកម្មកែច្នៃ ការធ្វើពាណិជ្ជកម្ម និងអាជីវកម្មលក្ខណៈគ្រួសារ។ ការអភិវឌ្ឍនេះ ក៏បង្ហាញនូវឱកាសសម្រាប់ការបង្កើតនូវបរិយាប័ន្នសង្គម ដែលរួមចំណែកដល់ការកាត់បន្ថយភាពក្រីក្រ និងកាត់បន្ថយការធ្វើចំណាកស្រុកទៅក្រៅប្រទេសផងដែរ។

**នគរូបនីយកម្ម (ការរៀបចំផែនការក្រុង)**

ប្លង់គោលប្រើប្រាស់ដីក្រុងបាត់ដំបង បានអនុម័តក្នុងឆ្នាំ ២០១៥។ បន្ថែមទៅលើដំណោះស្រាយតាមវិស័យដែលបានរៀបរាប់ខាងលើ កត្តាចាំបាច់មួយទៀតគឺការដាក់បញ្ចូលការអភិវឌ្ឍទីក្រុងនិរន្តរភាពនៅក្នុងក្របខ័ណ្ឌផែនការអភិវឌ្ឍន៍ទីក្រុង ដើម្បីធានាដល់ការរួមចំណែកក្នុងគោលដៅ និងចក្ខុវិស័យរួមរបស់ក្រុង និងដើម្បីដោះស្រាយបញ្ហាប្រឈមផ្សេងៗទៀត។ ប្លង់គោលប្រើប្រាស់ដីក្រុងបាត់ដំបង គឺមានសារៈសំខាន់ក្នុងការការពារក្រុងពីការប្រើប្រាស់នូវធនធានដោយមិនមានប្រសិទ្ធភាព ការចំណាយខ្ពស់ និងការបំពុលនៅក្នុងប្រព័ន្ធក្រុង។

ការរៀបចំផែនការអភិវឌ្ឍក្រុងបៃតងរួមបញ្ចូលទាំងការអភិវឌ្ឍ និងការពង្រីកទីធ្លាសាធារណៈបៃតង (សព្វថ្ងៃក្រុងបាត់ដំបងមានទីធ្លាសាធារណៈចំនួន ១៤ កន្លែង) និងការកែលម្អវិស័យដឹកជញ្ជូនក្នុងក្រុង មានដូចជាការបង្កើតចិញ្ចើមផ្លូវសម្រាប់អ្នកថ្មើរជើង ការបង្កើតខ្សែផ្លូវសម្រាប់អ្នកជិះកង់។ ការបង្កើតផ្លូវក្រវ៉ាត់ក្រុង និងស្ពានចំនួន ២ បន្ថែមទៀត ដែលស្ថិតនៅភាគខាងជើង និងខាងត្បូងក្រុងនឹងជួយសម្រួលការកកស្ទះនៅក្នុងតំបន់កណ្តាលក្រុង។

## ២.៣. សកម្មភាពអាទិភាព

នៅក្នុងកម្មវត្ថុរួមទាំង ១២ និងសកម្មភាពគម្រោងទាំង ៩៨ ដែលបានរៀបរាប់នៅផ្នែកទី ១ ខាងលើ មានគម្រោងចំនួន ១០ខាងក្រោមនេះគឺជាអាទិភាពសម្រាប់ក្រុង៖

| ល.រ | ឈ្មោះគម្រោង | បរិយាយសង្ខេបពីអត្ថប្រយោជន៍ផ្នែកសង្គម សេដ្ឋកិច្ច និងបរិស្ថាននៃគម្រោងវិនិយោគអាទិភាពរបស់ក្រុង |
|---|---|---|
| ១ | បង្កើតស្ថានីយសម្រាប់កែច្នៃសំរាម និងពង្រឹងយន្តការគាំទ្រដល់ស្ថានីយដែលកំពុងដំណើរការស្រាប់ | ផលប្រយោជន៍ផ្នែកសេដ្ឋកិច្ច សង្គម និងជួយកាត់បន្ថយបរិមាណសំរាមនៅទីលានចាក់សំរាម ដែលអាចធ្វើឱ្យទីលានចាក់សំរាមប្រើប្រាស់បានរយៈពេលយូរអង្វែង ព្រមទាំងកាត់បន្ថយផលប៉ះពាល់អវិជ្ជមានដល់បរិស្ថាន។ ជួយជំរុញឱ្យមានការបង្កើតនូវអាជីវកម្មថ្មីៗនៅក្នុងខ្សែសង្វាក់ផលិតកម្មសំរាមដែលអាចជួយដល់ ការបង្កើតការងារបៃតងបាន។ |

| | | |
|---|---|---|
| ២ | បង្កើតទីតាំងប្រមូល/ស្តុកសំរាម ប្រកបដោយ អនាម័យ សម្រាប់សំរាមសរីរាង្គ និងប្លាស្ទិក នៅតាមតំបន់ផ្សារក្នុងតំបន់ អភិរក្សក្រុង។ ការលើកកម្ពស់ការយល់ដឹងអំពីការគ្រប់គ្រង សំរាមដល់មជ្ឈដ្ឋានសាធារណៈ - តាមផ្ទះ សហគ្រាស ក្រុមហ៊ុនឯកជន ស្ថាប័ន សាធារណៈ និងឯកជន។ | លើកកម្ពស់សោភ័ណភាព និងអនាម័យបរិស្ថាននៅជុំវិញផ្សារឱ្យកាន់ តែមានភាពប្រសើរឡើងក្នុងតំបន់កណ្តាលក្រុង។<br><br>ធ្វើឱ្យប្រសើរឡើងនូវការបែងចែក និងញែកសំរាមសរីរាង្គ ពីសំរាមប្លាស្ទិក សម្រាប់ការកែច្នៃឡើងវិញ។ |
| ៣ | រៀបចំ និងពង្រីកច្រករបៀងបៃតងដែលមាន ស្រាប់ (ពង្រីកទីធ្លាសាធារណៈ ការដាំដើម ឈើ និងសួនច្បារសាធារណៈ និងបង្កើត កន្លែងលំហែកម្សាន្តឱ្យបានច្រើន) | រក្សានិរន្តរភាពនៃតំបន់បៃតង (ច្រករបៀងបៃតង) ដែលមានស្រាប់ ការពង្រឹង ច្រករបៀងបៃតងរបស់ក្រុងឆ្លើយតបទៅនឹងការប្រែប្រួលអាកាសធាតុ។ លើកកម្ពស់អនាម័យក្រុង និងបរិស្ថានរីករាយ និងលើកកម្ពស់សម្រស់ក្រុង ក៏ដូចជាលើកកម្ពស់សុខភាពសាធារណៈ។ |
| ៤ | បង្កើតគម្រូអាជីវកម្មសម្រាប់ការគ្រប់គ្រង ខ្សែសង្វាក់ផ្គត់ផ្គង់សំរាមប្រកបដោយចីរភាព សំរាប់សង្កាត់មួយនៅក្រុងបាត់ដំបង | ការគ្រប់គ្រងសំរាមនៅក្រុងបាត់ដំបង នឹងមានភាពប្រសើរជាងមុន និងប្រកប ដោយនិរន្តរភាពតាមរយៈការបង្កើតនូវអាជីវកម្មតាមខ្សែសង្វាក់នៃប្រព័ន្ធ គ្រប់គ្រងសំរាមទាំងមូល។ គម្រោងនេះនឹងចាប់ផ្តើមអនុវត្តក្នុងសង្កាត់មួយ ដើម្បីធ្វើជា គម្រូដល់សង្កាត់ផ្សេងៗទៀតនៅទូទាំងក្រុងបាត់ដំបង។ |
| ៥ | រៀបចំស្តារ និងពង្រីក ប្រព័ន្ធលូរំដោះទឹកស្អុយ និងទឹកភ្លៀង | កាត់បន្ថយការជន់លិចនៅក្នុងតំបន់ក្រុង និងកាត់បន្ថយផលប៉ះពាល់អវិជ្ជមាន ដល់បរិយាកាសក្នុងក្រុង លើកកម្ពស់សោភ័ណភាព អនាម័យបរិស្ថានក្នុង តំបន់ទីប្រជុំជនក្រុង។ កាត់បន្ថយបរិមាណទឹកកខ្វក់ ដែលបញ្ចេញចោលទៅ ក្នុងប្រភពទឹកធម្មជាតិ ដូចជាប្រឡាយ បឹង ស្រះ ជាដើម។ |
| ៦ | បង្កើតស្ថានីយប្រព្រឹត្តកម្មទឹកកខ្វក់ បែបវិមជ្ឈការ (ដាច់ដោយឡែក) | កាត់បន្ថយបរិមាណទឹកកខ្វក់ ដែលបញ្ចេញចោលទៅក្នុងប្រភពទឹកធម្មជាតិ ដូចជាប្រឡាយ បឹង ស្រះ ជាដើម នៅតំបន់មួយចំនួនក្រៅក្រុងបាត់ដំបង ដែល មិនអាចភ្ជាប់ទៅប្រព័ន្ធមជ្ឈការ (ប្រព័ន្ធមេរួម) |
| ៧ | បង្កើតនូវប្រព័ន្ធដឹកជញ្ជូនសាធារណៈ ស្ថានីយឡានក្រុង និងកន្លែងចតយានជំនិះ ដែលមានបទដ្ឋាន និងបទបញ្ញត្តិត្រឹមត្រូវ | កាត់បន្ថយការកកស្ទះចរាចរណ៍ និងពង្រឹងសណ្តាប់ធ្នាប់នៃការចតយានយន្ត តាមផ្លូវក្នុងក្រុង។ ពង្រឹងគុណភាពខ្យល់ និងសុខភាពសាធារណៈ ក៏ដូចជា ការលើកកម្ពស់សោភ័ណភាពក្រុង។ |
| ៨ | កែលម្អនូវចិញ្ចើមថ្នល់ និងតំបន់សម្រាប់អ្នកថ្មើរជើងដែលមានស្រាប់ | ជំរុញ និងលើកទឹកចិត្តប្រជាពលរដ្ឋឱ្យមានការដើរតាមចិញ្ចើមផ្លូវ កាត់បន្ថយ ការធ្វើដំណើរដោយយានយន្តឯកជន។ កាត់បន្ថយការកកស្ទះចរាចរណ៍ ពង្រឹងគុណភាពខ្យល់ និងសុខភាពសាធារណៈ។ |
| ៩ | ស្តារ និងផ្សព្វផ្សាយពីអគារបេតិកភណ្ឌវប្បធម៌ | ដើម្បីភាពទាក់ទាញរបស់ក្រុងសម្រាប់ទាំងវិស័យទេសចរណ៍ និងអាជីវកម្ម |
| ១០ | អភិវឌ្ឍន៍ទីផ្សារសម្រាប់ផលិតផលកសិកម្ម ប្រកបដោយចីរភាព | បង្កើតការងារបៃតង និងបង្កើនចំណូលតាមរយៈការផ្សព្វផ្សាយពី ផលិតផល កសិកម្មរបស់ក្រុងបាត់ដំបង និងលើកទឹកចិត្តអ្នកវិនិយោគ ទៅលើរោងចក្រ កែច្នៃម្ហូបអាហារជាដើម។ |
| ១១ | បង្កើត និងផ្សព្វផ្សាយពីសណ្ឋាគារបៃតង | ជំរុញ លើកទឹកចិត្តឱ្យមានការប្រើប្រាស់នូវសម្ភារក្នុងសណ្ឋាគារប្រកបដោយ ចីរភាព ដែលអាចជួយដល់ផលប៉ះពាល់អវិជ្ជមានដល់បរិស្ថាន។ |

*ប្រភព៖ ការប្រឹក្សាយោបល់ជាមួយរដ្ឋបាលក្រុងបាត់ដំបង*

## ២.៤. ព័ត៌មានអំពីស្ថិតិសេដ្ឋកិច្ច-សង្គម

| សន្ទស្សន៍ | ឆ្នាំ២០១៥ |
|---|---|
| ចំនួនប្រជាជន (នាក់) | ១៥៥.៥៨៤ |
| ដង់ស៊ីតេប្រជាជន(នាក់/គ.ម២) | ១.៣៤៧ |
| ផ្ទៃក្រឡា (គ.ម២) | ១១៥.៤៤ |
| អត្រាអក្ខរកម្ម (ភាគរយ) | ០,៨៦% |
| វិស័យសេដ្ឋកិច្ចសំខាន់ | ពាណិជ្ជកម្ម |
| បំណែងចែកការងារក្នុងវិស័យផ្សេងៗ (ភាគរយ) | |
| - កសិកម្ម | ៧២,៦% |
| - ផលិតកម្ម | ១,៩% |
| - សេវាកម្ម | ៧០,៧% |
| ចំណាកស្រុក(ទៅក្រៅប្រទេស) (នាក់) | ៧.០៤៦ |
| មធ្យមភាគទោចក្រយានយន្តក្នុងផ្ទះ (គ្រឿង) | ០,៨ |
| ចំនួនប្រជាជនដែលជាប់បំណុល(ធនាគារ ឬមីក្រូហិរញ្ញវត្ថុ) (នាក់) | ៥.៣១៧ |
| ចំនួនផ្ទះនៅសំណង់អនាធិបតេយ្យ/លំនៅឋានខុសច្បាប់ (ខ្នងផ្ទះ) | ២.៦៣១ |
| ចំនួនផ្ទះដែលទទួលឥទ្ធិពលពីខ្យល់ព្យុះ (ខ្នងផ្ទះ) | ២៦ |
| ចំនួនផ្ទះដែលទទួលឥទ្ធិពលពីទឹកជំនន់ (ខ្នងផ្ទះ) | ០ |
| ចំនួនផ្ទះដែលទទួលឥទ្ធិពលពីភាពរាំងស្ងួត (ខ្នងផ្ទះ) | ០ |
| ភាគរយផ្ទះដែលសេវាកម្មប្រមូលសំរាមអាចចូលទៅដល់ (ភាគរយ) | ១៩,១៨%(៥.៨៩២គ្រួសារ) |
| ភាគរយផ្ទះដែលមានប្រព័ន្ធទឹកតាមបំពង់ទុយោ (ភាគរយ) | ៨១,១% |
| ភាគរយផ្ទះដែលមានភ្លើងប្រើប្រាស់ (ភាគរយ) | ៥៥,៧០%(១៥.៩៨៣គ្រួសារ) |
| ភាគរយផ្ទះដែលមានភ្លើងប្រើប្រាស់ (ភាគរយ) | ៩៧,៧% |
| ចំនួនសំរាមក្នុងមួយថ្ងៃ (តោន) | ១៤០តោន |



ក្រុងបាត់ដំបង




ក្រុងព្រះសីហនុ

# ក្រុងព្រះសីហនុ

## ២.១. សេចក្តីផ្តើម

ការរីកចម្រើនយ៉ាងឆាប់រហ័សនៃក្រុងព្រះសីហនុ បានរួមចំណែកយ៉ាងសំខាន់សម្រាប់សេដ្ឋកិច្ចរបស់ប្រទេសកម្ពុជាបន្ទាប់ពីរាជធានីភ្នំពេញ ដោយសារក្រុងនេះជាក្រុងកំពង់ផែដ៏ធំជាងគេក្នុងប្រទេសកម្ពុជា។ សារៈសំខាន់នៃទីក្រុងនេះ ត្រូវបានគេមើលឃើញដោយសារការដាក់ឱ្យដំណើរការឡើងវិញដោយក្រុមហ៊ុនរ៉ូយ៉ាល់អេយស្វ័យយាននូវផ្លូវរថភ្លើងដែលតភ្ជាប់ទៅកាន់រាជធានីភ្នំពេញសម្រាប់បម្រើទាំងការធ្វើដំណើររបស់ប្រជាពលរដ្ឋ និងការដឹកទំនិញ។ ក្រុងព្រះសីហនុជាអាកាសយានដ្ឋានអន្តរជាតិសំខាន់ទី៣របស់ប្រទេសកម្ពុជាជាមួយនឹងការហោះហើរប្រចាំថ្ងៃទៅកាន់ក្រុងសៀមរាប រាជធានីភ្នំពេញ និងការហោះហើរផ្ទាល់ពីតំបន់ជាច្រើននៃប្រទេសចិន។ ក្រុងព្រះសីហនុជាកន្លែងដែលមានតំបន់សេដ្ឋកិច្ចពិសេសជាច្រើនកន្លែង និងមានការវិនិយោគកើនឡើងពីអ្នកវិនិយោគប្រទេសចិនដោយសារមានកិច្ចព្រមព្រៀងវិនិយោគរួមគ្នាចុះហត្ថលេខារវាងរដ្ឋាភិបាលប្រទេសទាំងពីរ។

ជាមួយនឹងការរីកចម្រើនគួរឱ្យកត់សម្គាល់ក្នុងការវិនិយោគបរទេសដែលផ្តោតសំខាន់លើវិស័យកាស៊ីណូ អចលនទ្រព្យ និងរមណីយដ្ឋាន ទីក្រុងនេះនឹងមានការរីកចម្រើនយ៉ាងឆាប់រហ័សដោយមានប្រជាជនមករស់នៅច្រើន ហើយរដ្ឋាភិបាលចាំបាច់ត្រូវគិតគូរបន្ថែមពីលើការតាមដាន "សៀវភៅគ្រួសារ សៀវភៅស្នាក់នៅ" គឺត្រូវធ្វើបច្ចុប្បន្នភាពដើម្បីតាមដានកំណើនប្រជាជនផងដែរ។ ស្ថិតិប្រជាសាស្ត្រនៅក្នុងតារាងខាងក្រោមនៅមានកម្រិតដោយសារខ្វះការធ្វើបច្ចុប្បន្នភាពទិន្នន័យប្រជាជន ហើយជាក់ស្តែងចំនួនប្រជាជនអាចច្រើនជាងនេះដោយសារ ការចូលមករស់នៅរបស់បរទេស កម្មករសំណង់ និងបុគ្គលិកបដិសណ្ឋារកិច្ច។ វិធីសាស្ត្រគណនាចំនួនប្រជាជន ចូលមករស់នៅក្នុងក្រុង គួរត្រូវបានកែលម្អ៖

តារាង៖ កត្តាស្ថិតិប្រជាសាស្ត្រ ក្រុងព្រះសីហនុ(ស្ថិតិសេដ្ឋកិច្ច-សង្គមរបស់ក្រុងព្រះសីហនុ ឆ្នាំ២០១៦)

| ស្ថិតិប្រជាសាស្ត្រ | ២០១២ | ២០១៣ | ២០១៤ | ២០១៥ |
|---|---|---|---|---|
| ចំនួនប្រជាជន (នាក់) | ៧៥.២១៦ | ៧៧.៦៥៧ | ៨២.០៤៨ | ៧៨.៣៨០ |
| អត្រាកំណើនប្រចាំឆ្នាំ(គិតជាភាគរយ) | ១,២ | ៣,២ | ៥,៧ | -៤,៥ |
| ចំនួនស្ត្រី (នាក់) | ៣៨.៥០២ | ៣៩.៥៥៤ | ៤១.៩៤២ | ៣៩.៦៥៦ |
| សមាមាត្រស្ត្រីធៀបនឹងបុរស (ក្នុងចំណោមបុរស១០០នាក់) | ១០៤,៨ | ១០៣,៨ | ១០៤,៦ | ១០២,៤ |
| ចំនួនគ្រួសារ (គ្រួសារ) | ១៦.២២៤ | ១៧.០០៣ | ១៨.០៣៤ | ១៧.២៥០ |
| ទំហំគ្រួសារជាមធ្យម (នាក់) | ៤,៦ | ៤,៦ | ៤,៥ | ៤,៥ |

## ២.២.ការវិភាគតាមវិស័យ សម្រាប់ការអភិវឌ្ឍទីក្រុងនិរន្តរភាព

### ទេសចរណ៍

ក្រុងព្រះសីហនុ មានស្ថានភាពសមស្របដើម្បីអភិវឌ្ឍន៍វិស័យទេសចរណ៍ ដែលវានៅតែជាវិស័យសេដ្ឋកិច្ចសំខាន់មួយសម្រាប់ក្រុងនេះ ជាមួយនឹងការអភិវឌ្ឍបៃតង និងប្រកបដោយចីរភាព។ ក្រុងព្រះសីហនុជាក្រុងដែលមានមធ្យោបាយធ្វើដំណើរគ្រប់ប្រភេទតាមរយៈផ្លូវថ្នល់ ផ្លូវដែក ផ្លូវទឹក (កំពង់ផែសមុទ្រ) និងផ្លូវអាកាស (អាកាសយានដ្ឋានអន្តរជាតិ) និងជាក្រុងដែលមានឆ្នេរខ្សាច់ដ៏ធំស្អាត និងមានសក្តានុពលសម្រាប់វិស័យទេសចរណ៍ធម្មជាតិតាមសមុទ្រ ដូចជាឆ្នេរខ្សាច់ទៅកាន់កោះតូចៗ ស្អាតៗដែលនៅឆ្ងាយពីប្រាំងសមុទ្រជាដើម។ ជាក្រុងដែលយើងអាចរកបាននូវម្ហូបសមុទ្រស្រស់ៗ ដែលជាកត្តាមួយបន្ថែមទៀតលើសក្តានុពលក្នុងការទាក់ទាញភ្ញៀវទេសចរ។

នៅក្នុងប៉ុន្មានឆ្នាំចុងក្រោយនេះ ក្រុងព្រះសីហនុមានការអភិវឌ្ឍខ្លាំងជាពិសេសក្នុងវិស័យសំណង់ ដូចជាការសាងសង់កាស៊ីណូ សណ្ឋាគារ និងភោជនីយដ្ឋាន ដែលធ្វើឱ្យមានការកើនឡើងនូវតម្លៃសេវា និងតម្លៃផលិតផល។ តួលេខនៃចំនួនភ្ញៀវបរទេសចូលមកក្នុងក្រុងព្រះសីហនុក៏មានការប្រែប្រួលខ្លាំងដែរ ដែល១ភាគ៣ នៃភ្ញៀវដែលមកដល់គឺជាជនជាតិចិន ដោយប្រើប្រាស់ទិដ្ឋាការប្រភេទទេសចរណ៍ និងប្រភេទអាជីវកម្ម។[៩៤] មន្ទីរទេសចរណ៍ខេត្តបានបង្ហាញថាត្រឹមពាក់កណ្តាលឆ្នាំ២០១៨ ចំនួនភ្ញៀវទេសចរជនជាតិចិនបានកើនឡើង ៤៤% ចាប់តាំងពីឆ្នាំ២០១៧។ ភ្ញៀវទេសចរពី វៀតណាមបានកើនឡើង ៣,៣% ខណៈពេលដែលភ្ញៀវទេសចរពីអឺរ៉ុប និងអាមេរិក មានការធ្លាក់ចុះយ៉ាងគំហុក។ ភ្ញៀវទេសចរជាតិមានប្រមាណ ១លាននាក់សម្រាប់ពាក់កណ្តាលឆ្នាំ២០១៨នេះ មានការកើនឡើង ៨,១០% ពីមួយឆ្នាំទៅមួយឆ្នាំ។

បច្ចុប្បន្ននេះ បញ្ហាប្រឈមសំខាន់ៗក្នុងការបន្តអភិវឌ្ឍន៍វិស័យទេសចរណ៍រួមមាន ចំនួនសណ្ឋាគារ និងផ្ទះសំណាក់ នៅមានកម្រិត (ជាពិសេសក្នុងរដូវវិស្សមកាល) និងបញ្ហាតម្លៃថ្លៃលើការស្នាក់នៅ និងម្ហូបអាហារ។ ជំនាញបដិសណ្ឋារកិច្ចរបស់បុគ្គលិកក្នុងផ្នែកមគ្គុទេសទេសចរណ៍ (សណ្ឋាគារ ភោជនីយដ្ឋានជាដើម) មានកម្រិតទាប ហើយត្រូវការអភិវឌ្ឍបន្ថែម។ បញ្ហាផ្សេងទៀតមានដូចជាការបញ្ចេញចោលទឹកកខ្វក់ទៅក្នុងស្ទឹង បឹងបួរ និងសមុទ្រ គំនរសំរាមតាមដងផ្លូវ និងឆ្នេរខ្សាច់ ព្រមទាំងការកកស្ទះចរាចរណ៍ គឺជាកត្តាដែលកាត់បន្ថយភាពទាក់ទាញភ្ញៀវទេសចរដែលស្រលាញ់ធម្មជាតិ និងបរិស្ថានស្អាត។ លើសពីនេះទៅទៀត វិស័យទេសចរណ៍ងាយប៉ះពាល់ដល់បម្រែបម្រួលអាកាសធាតុ ដូចជាខ្យល់ព្យុះ ភ្លៀងធ្លាក់ជោគជាំ និងជួបប្រទះភាពរាំងស្ងួតជាដើម។ ក្រុងព្រះសីហនុក៏ជួបប្រទះបញ្ហាផងដែរក្នុងការអនុវត្តបទបញ្ញានិងច្បាប់ចរាចរណ៍ ទប់ស្កាត់ការកាន់កាប់ឆ្នេរ និងដែនកោះខុសច្បាប់ និងការការពារបរិស្ថាននិងអភិវឌ្ឍន៍ក្រុងឱ្យកាន់តែស្អាត។

មានឱកាសជាច្រើនក្នុងការអភិវឌ្ឍវិស័យទេសចរណ៍ប្រកបដោយចីរភាព ដែលរួមចំណែកក្នុងគោលបំណងអភិវឌ្ឍន៍ទីក្រុងនិរន្តរភាពរបស់ក្រុងព្រះសីហនុ ហើយដែលអាចទាក់ទាញភ្ញៀវទេសចរបន្ថែមទៀត។ កត្តាសំខាន់គឺការកសាង និងជួសជុលសណ្ឋាគារ និងភេណីយដ្ឋានឡើងវិញ ទៅតាមគោលនយោបាយនិរន្តរភាព ដែលរួមមានប្លង់ និងទេសភាព ការរក្សាទឹកទុក ការសន្សំសំចៃថាមពលថាមពលកកើតឡើងវិញ (ឧទាហរណ៍ ម៉ាស៊ីនទឹកក្តៅដែលប្រើដោយថាមពលកំដៅព្រះអាទិត្យ) សំរាមកែច្នៃ ការការពារប្រឆាំងនឹងការហូរច្រោះដី (ឧទាហរណ៍ កើតចេញពីភ្លៀងធ្លាក់ខ្លាំង)។ គេត្រូវការប្រសិទ្ធភាពផែនការបន្ថែមទៀត ក្នុងការត្រួតពិនិត្យ និងអនុញ្ញាតឱ្យមានតូប និងភោជនីយដ្ឋាននៅតាមបណ្តោយឆ្នេរ។ ក្រៅពីនេះនៅមានការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធប្រកបដោយចីរភាពនៅជុំវិញសណ្ឋាគារ ភេណីយដ្ឋាន និងឆ្នេរខ្សាច់ ឧទាហរណ៍ការផ្គត់ផ្គង់ថាមពល និងទឹកស្អាត ការប្រមូលសំរាម/ការប្រើប្រាស់ធ្វើប្រព្រឹត្តិកម្មទឹកកខ្វក់មកប្រើប្រាស់ម្តងទៀត។

ការផ្លាស់ប្តូរដ៏ឆាប់រហ័សនេះ ក៏បានបង្កើតនូវការងារមួយចំនួនផងដែរនៅក្នុងក្រុងព្រះសីហនុ។ នៅខណៈពេលដែលកម្មករជាជនជាតិចិនកំពុងចូលមកក្រុងនេះដើម្បីធ្វើការក្នុងវិស័យកាស៊ីណូ និងសណ្ឋាគារ ក៏មានការងារមួយចំនួនក្នុងវិស័យទាំងនេះសម្រាប់ប្រទេសកម្ពុជាផងដែរ។

[94] Ministry of Tourism. “Tourism Statistics of Cambodia,” 2018.

## ឧស្សាហកម្ម

ការអភិវឌ្ឍវិស័យឧស្សាហកម្មនៅក្រុងព្រះសីហនុ ប្រមូលផ្តុំខ្លាំងនៅតំបន់សេដ្ឋកិច្ចពិសេស (SEZ) ៤កន្លែង។ តំបន់សេដ្ឋកិច្ចពិសេសដែលបានបង្កើតក្រោយគេ គឺតំបន់សេដ្ឋកិច្ចពិសេសក្រុងព្រះសីហនុ (SSEZ) ដែលដំបានដំបូងផ្តោតលើឧស្សាហកម្មវាយនភណ្ឌ សំលៀកបំពាក់ គ្រឿងម៉ាស៊ីន គ្រឿងអេឡិចត្រូនិច និងឧស្សាហកម្មធុនស្រាលដទៃទៀត។ ក្រៅពីជាកន្លែងផលិត ទីនោះក៏ជាទីកន្លែងសម្រាប់ធ្វើពាណិជ្ជកម្ម និងរស់នៅផងដែរ។ តាមរយៈការពិភាក្សាជាមួយអ្នកគ្រប់គ្រងតំបន់សេដ្ឋកិច្ចពិសេសក្រុងព្រះសីហនុ បានឱ្យដឹងថា នៅពេលតំបន់សេដ្ឋកិច្ចនេះបានបញ្ចប់សព្វគ្រប់នឹងមានរោងចក្រជាង ៣០០កន្លែង ដែលមានបុគ្គលិកចាប់ពី ៨០.០០០ ដល់ ១០០.០០០ នាក់។

តំបន់សេដ្ឋកិច្ចពិសេសនៅក្រុងព្រះសីហនុ មានសារៈសំខាន់សម្រាប់ការអភិវឌ្ឍក្រុងទៅថ្ងៃអនាគត។ តំបន់សេដ្ឋកិច្ចពិសេសទាំងនេះបង្កើតឱ្យមានកំណើនសេដ្ឋកិច្ច ការងារ និងប្រាក់ចំណូល ប៉ុន្តែក៏បង្កើតឱ្យមាននូវបញ្ហាសង្គម និងបរិស្ថានផងដែរ ដែលវាអាចនឹងជះឥទ្ធិពលអាក្រក់ដល់ទីក្រុង និងប្រជាជន ហើយក៏នឹងប៉ះពាល់ដល់សក្តានុពលវិស័យទេសចរណ៍ផងដែរ។

តំបន់សេដ្ឋកិច្ចពិសេសស្ថិតនៅក្រោមការគ្រប់គ្រងរបស់រាជរដ្ឋាភិបាល ដែលវាអាចជាបញ្ហាក្នុងការធ្វើសមាហរណកម្មតំបន់ទាំងនេះក្នុងការអភិវឌ្ឍទីក្រុងនិរន្តរភាពរបស់ក្រុងព្រះសីហនុ។ តាមរយៈការពិគ្រោះយោបល់ជាមួយអាជ្ញាធរមូលដ្ឋាន ឧទាហរណ៍មួយនៃបញ្ហាប្រឈមនេះ គឺរោងចក្រថាមពលធ្យូងថ្ម ១៣៥មេហ្គាវ៉ាត់ដែលត្រូវបានគេបង្កើតឡើងជាដំបូងដើម្បីផ្គត់ផ្គង់អគ្គិសនីប្រើប្រាស់ដល់តំបន់សេដ្ឋកិច្ចក្រុងព្រះសីហនុ។ប្រសិនបើផ្សែងចេញពីរោងចក្រមិនត្រូវបានគេសម្អាតឱ្យបានត្រឹមត្រូវទេ នោះរោងចក្រនឹងបញ្ចេញផ្សែងពុលកាន់តែច្រើនទៅបរិយាកាស និងចូលទៅទីក្រុងផងដែរ ហើយជាឧទាហរណ៍វាអាចប៉ះពាល់អវិជ្ជមានដល់ការវិនិយោគក្នុងវិស័យទេសចរណ៍។ ក្នុងករណីណាក៏ដោយវានឹងបន្ថែមទៅដល់ការបំភាយឧស្ម័នផ្ទះកញ្ចក់ជាតិ។

នៅក្នុងបរិបទក្រុងបៃតង វាចាំបាច់សម្រាប់តំបន់សេដ្ឋកិច្ចពិសេសក្នុងក្រុងព្រះសីហនុតម្រូវឱ្យបរិស្ថានការងារមានសុវត្ថិភាព ស្អាត និងមានផាសុខភាពក្នុងដំណើរការផលិតកម្មរបស់ខ្លួន(ដោយធ្វើតាមគោលការណ៍ ការងាររឹមជ្ឈការ)។ ដូចជាការកំណត់ជាតិពុលក្នុងបរិយាកាស ក្នុងទឹក និងក្នុងដី ព្រមទាំងហេដ្ឋារចនាសម្ព័ន្ធប្រកបដោយនិរន្តរភាព និងសេវាកម្មដែលគាំទ្រសកម្មភាពនៃការផលិតកន្លែងពាណិជ្ជកម្ម ព្រមទាំងកន្លែងរស់នៅ។ កត្តាដែលត្រូវយកចិត្តទុកដាក់រួមមានការផ្គត់ផ្គង់ថាមពល (ប្រភពថាមពលកកើតឡើងវិញ) និងការផ្គត់ផ្គង់ ទឹកស្អាត ការគ្រប់គ្រងសំណល់រឹង និងរាវ ការដឹកជញ្ជូន និងទូរគមនាគមន៍។ លើសពីនេះទៅទៀត វាចាំបាច់ត្រូវមានសក្តានុពលល្អសម្រាប់បង្កើតការងារបន្ថែមតាមរយៈទិសដៅបណ្តុះបណ្តាល និងសកម្មភាពពង្រីកជំនាញបន្ថែម សម្រាប់ក្រុមស្ត្រីនិងក្រុមងាយរងគ្រោះ។

ការអភិវឌ្ឍបៃតងនៅក្នុងតំបន់សេដ្ឋកិច្ចពិសេសបច្ចុប្បន្ន និងតំបន់សេដ្ឋកិច្ចពិសេសដែលនឹងត្រូវបង្កើតឡើងនៅថ្ងៃអនាគត តម្រូវឱ្យអាជ្ញាធរជាតិ ខេត្ត និងក្រុងឯកភាព បង្កើត និងពង្រឹងស្តង់ដារបរិស្ថាននិងសង្គម ដើម្បីអភិវឌ្ឍន៍តំបន់សេដ្ឋកិច្ចពិសេសទាំងនោះដែលជាផ្នែកមួយនៃទីក្រុងនិរន្តរភាព។ ជាការចាំបាច់ផងដែរសម្រាប់កិច្ចសហការយ៉ាងជិតស្និទ្ធជាមួយក្រុមហ៊ុនទាំងឡាយ ដែលដំណើរការនៅក្នុងតំបន់សេដ្ឋកិច្ចពិសេសទាំងនោះអំពីសក្តានុពលនៃការអភិវឌ្ឍទីក្រុងនិរន្តរភាព ឧទាហរណ៍តាមរយៈសមាគមន៍ពាណិជ្ជកម្មរបស់ក្រុមហ៊ុនទាំងនោះ។ ក្រុមហ៊ុនទាំងឡាយដំណើរការនៅក្នុងតំបន់សេដ្ឋកិច្ចពិសេសបៃតងត្រូវយល់ដឹងអំពីអត្ថប្រយោជន៍សេដ្ឋកិច្ច ជាឧទាហរណ៍ការវាស់វែងប្រសិទ្ធភាពថាមពល និងយល់ឃើញអំពីសក្តានុពលសម្រាប់ការធ្វើទីផ្សារលក្ខណៈជាតិនិងអន្តរជាតិនៃផលិតផលរបស់ខ្លួន ដែលផលិតនិងដាក់ឈ្មោះផលិតផលរបស់ខ្លួនឈរលើមូលដ្ឋានទទួលខុសត្រូវសង្គមនិងបរិស្ថាន។

## ទឹកកខ្វក់

ប្រព័ន្ធលូបង្ហូរទឹករបស់ក្រុងព្រះសីហនុគ្របដណ្តប់តែផ្នែកខ្លះនៃទីក្រុងតែប៉ុណ្ណោះ និងមានអាងប្រព្រឹត្តិកម្មទឹកកខ្វក់តែមួយកន្លែងទេ។ នេះមានន័យថា ទឹកកខ្វក់ទាំងនោះត្រូវបានបង្ហូរចូលទៅក្នុងស្ទឹង បឹងបួរ និងសមុទ្រ នាំឱ្យមានការគម្រាមកំហែងដល់ប្រព័ន្ធសេដ្ឋកិច្ចនិងសុខភាពប្រជាជន ព្រមទាំងធ្វើឱ្យអន់ថយដល់សក្តានុពលទេសចរណ៍ផងដែរ។ ម្យ៉ាងទៀត ការយល់ដឹងរបស់ប្រជាជននៅមានកម្រិត និងការខ្វះខាតកិច្ចសហការក៏ដូចជាការត្រួតពិនិត្យប្រព័ន្ធបង្ហូរទឹកពុំទាន់បានអនុវត្តល្អនៅឡើយ។ ការរីកលូតលាស់ខ្លាំងនៃវិស័យសំណង់ បាននឹងកំពុងធ្វើឱ្យស្ថានការណ៍កាន់តែអាក្រក់ទៅ

ដោយមានការបំពុលដល់បរិស្ថានសមុទ្រ ដែលនេះបានជំរុញឱ្យរាជរដ្ឋាភិបាលដាក់ចេញនូវផែនការកែលម្អសមត្ថភាពប្រព្រឹត្តិកម្មទឹកដល់ទៅ ៣០.០០០ ម៉ែត្រគីបក្នុងមួយថ្ងៃ[៩៥]។ រាជរដ្ឋាភិបាល ដោយមានការគាំទ្រពីដៃគូអភិវឌ្ឍន៍ ក៏មានការគិតគូរដល់ការថែទាំ និងពង្រីកប្រព័ន្ធលូក្នុងក្រុង លើកកម្ពស់ការយល់ដឹង និងការតភ្ជាប់បណ្ដាញលូរដ្ឋដោយមិនមានគិតកម្រៃ។ ក្នុងខណៈពេលនៃការការរៀបចំឯកសារនេះ ក្រសួងសាធារណការ និងដឹកជញ្ជូនបានរៀបចំសេចក្ដីព្រាងផែនការគ្រប់គ្រងទឹកកខ្វក់សម្រាប់ក្រុងព្រះសីហនុដោយមានការគាំទ្រពីក្រុមហ៊ុនចិន ( Beijing Urban Construction Group ) ។

ដើម្បីដោះស្រាយបញ្ហាទាំងនេះក្រុងព្រះសីហនុត្រូវខិតខំស្ដារនិងពង្រីកប្រព័ន្ធលូបង្ហូរទឹក និងធានាថាទឹកកខ្វក់ទាំងនោះត្រូវបានប្រោះមុនពេលបង្ហូរចូលទៅក្នុងទន្លេ និងសមុទ្រ។ ហើយត្រូវខិតខំបង្កើនការយល់ដឹងជាសាធារណៈ ក្រោមការគាំទ្ររបស់ធនាគារអភិវឌ្ឍន៍អាស៊ី ដើម្បីណែនាំការតភ្ជាប់លូដោយមិនគិតថ្លៃទៅកាន់ប្រព័ន្ធបង្ហូរទឹក។

ប្រព័ន្ធលូបង្ហូរទឹកដំណើរការល្អមួយ អាចគ្របដណ្ដប់បាន ១០០% ទៅដល់លំនៅឋានអគារពាណិជ្ជកម្ម និងស្ថាប័ន ជាមួយអាងប្រព្រឹត្តិកម្មយ៉ាងមានប្រសិទ្ធភាព គឺជាផ្នែកមួយយ៉ាងសំខាន់ក្នុងការអភិវឌ្ឍគម្រោងទីក្រុងនិរន្តរភាពរបស់ក្រុងព្រះសីហនុ។ គម្រោងនេះនឹងជួយកែប្រែទីក្រុងឱ្យមានសោភ័ណភាពល្អ ប្រជាជនមានសុខភាពល្អនិងមានកំណើនភ្ញៀវទេសចរ គុណភាពទឹកនិងបរិស្ថានល្អជារួម។ ទស្សនៈក្នុងការអភិវឌ្ឍទីក្រុងនិរន្តរភាពមួយទៀតគឺការសម្អាតសំណល់ចេញពីអាងប្រព្រឹត្តិកម្មនៅក្នុងរោងចក្រជីវឧស្ម័នដែលអាចកាត់បន្ថយបរិមាណសារធាតុស្ងួត និងបង្កើតទៅជាជីនិងជីវឧស្ម័នដែលអាចយកទៅប្រើការបាន។

## សំរាម

បច្ចុប្បន្ន ប្រព័ន្ធប្រមូលសំរាមនៅក្រុងព្រះសីហនុមិនត្រូវបានប្រមូលគ្រប់ទីកន្លែងទាំងអស់នៃក្រុងនោះទេ គឺអនុវត្តន៍បានប្រមាណ ៤០% ប៉ុណ្ណោះតាមលំនៅឋានដែលសេវាកម្មប្រមូលសំរាមអាចចូលទៅបាន។ កន្លែងខ្លះឡានសំរាមពុំអាចទៅដល់បានដោយសារផ្លូវតូចចង្អៀត។ ជាពិសេសទៅទៀតនោះ ក្រុមហ៊ុនប្រមូលសំរាម ពុំមានកម្មករនិងឧបករណ៍ប្រមូលសំរាមគ្រប់គ្រាន់ ក្នុងការពង្រីកសេវាកម្មប្រមូលសំរាមនោះទេ។ ម្យ៉ាងវិញទៀត កន្លែងចាក់សំរាមស្ថិតនៅឆ្ងាយក្រៅក្រុង។ ក្នុងចំណោមបញ្ហាផ្សេងៗទៀត រួមមានការខ្វះខាតការយល់ដឹងជាទូទៅអំពីការទុកដាក់សំរាម និងវេចខ្ចប់ឱ្យបានត្រឹមត្រូវ និងការចូលរួមពីសំណាក់សាធារណជននៅមានកម្រិតក្នុងការដោះស្រាយបញ្ហាសំរាមរបស់ខ្លួន។ ក្រុមហ៊ុនដឹកសំរាមថ្មីមួយត្រូវបានជ្រើសរើសកាលពីឆ្នាំ២០១៧ ប៉ុន្តែមិនអាចដោះស្រាយនូវបញ្ហាសំរាមក្នុងទីក្រុងបាន ដោយសារបរិមាណសំរាមមានការកើនឡើងពីមួយថ្ងៃទៅមួយថ្ងៃមានច្រើន។ ការរីកលូតលាស់យ៉ាងឆាប់រហ័សរបស់ក្រុងព្រះសីហនុបាននាំឱ្យមានបរិមាណសំរាមកើនឡើងយ៉ាងខ្លាំងដល់ទៅ១.០០០តោន ក្នុងមួយថ្ងៃក្នុងឆ្នាំ២០១៩នេះ ដែលខុសពីឆ្នាំ២០១៥ បរិមាណសំរាមមាន ប្រមាណតែ ១០០ ទៅ ២០០ តោន ក្នុងមួយថ្ងៃ។

ដើម្បីចូលរួមចំណែកដោះស្រាយបញ្ហាប្រឈមខាងលើ ក្រុងព្រះសីហនុត្រូវខិតខំពង្រីកការរៀបចំប្រមូលសំរាមឱ្យបាន ១០០% គ្រប់ទីកន្លែងក្នុងក្រុងដើម្បីរៀបចំការប្រមូលសំរាមតាមមូលដ្ឋានសហគមន៍ដែលមិនអាចធ្វើដំណើរចូលទៅដល់បាន ដើម្បីណែនាំការបែងចែកសំរាមដែលធ្វើឱ្យសំរាមទាំងនោះអាចកែច្នៃយកទៅប្រើប្រាស់បានបន្តទៀត កន្លែងចាក់សំរាមមានអនាម័យដែលវាឆ្លើយតបទៅនឹងស្តង់ដារបរិស្ថានអន្តរជាតិ ការយល់ដឹង និងចលនាចូលរួមជាសាធារណៈ។ សកម្មភាពចូលរួមចំណែកទាំងនេះ នឹងក្លាយជាកត្តាសំខាន់ ក្នុងការអភិវឌ្ឍទីក្រុងនិរន្តរភាពនៅពេលយើងបានចូលរួមអនុវត្តន៍។ ក្នុងចំណោមឱកាសផ្សេងៗ ដែលអាចផ្ដល់នូវការរួមចំណែកបន្ថែមដល់ការអភិវឌ្ឍទីក្រុងនិរន្តរភាពរួមមានការអភិវឌ្ឍដំណើរសម្របសម្រួលទីផ្សារ និងពាណិជ្ជកម្មអំពីការបែងចែកនិងការកែច្នៃសំរាម និងអំពីគម្រោងថាមពលកកើតចេញពីសំរាមដែលផ្អែកលើការដុតសំរាម ឬការបំភាយឧស្ម័នចេញពីកន្លែងចាក់សំរាម។

[95] Pech Sotheary, "Sihanoukville wastewater plant upgrades receive greenlight," Khmer Times, last modified May 24, 2019, https://www.khmertimeskh.com/50607407/sihanoukville-wastewater-plant-upgrades-receive-greenlight/

## បញ្ហាផ្សេងពុលក្នុងបរិយាកាស

រោងចក្រថាមពលដើរដោយធ្យូងថ្ម នឹងបញ្ចេញកម្រិតជាតិពុលក្នុងបរិយាកាសយ៉ាងអាក្រក់ក្នុងទីក្រុង និងការកើនឡើងនូវការវិនិយោគក្នុងវិស័យឧស្សាហកម្មនិងទេសចរណ៍ នឹងធ្វើឱ្យលេចចេញជាបញ្ហាជាច្រើននៅពេលអនាគត។ ការដុតធ្យូងថ្មក៏បញ្ចេញជាតិពុលអាក្រក់គ្រប់បែបយ៉ាងបន្ថែមទៀតផងដែរ ដូចជាឧស្ម័នសុលភួរិចឌីអុកស៊ីត ($SO_2$) ឧស្ម័ននីត្រូហ្សែនឌីអុកស៊ីត ($NO_2$) និងឧស្ម័នតូចៗផ្សេងៗទៀត។ ជាតិពុលទាំងនេះនឹងធ្វើឱ្យប៉ះពាល់ដល់ជម្ងឺផ្លូវដង្ហើមធ្ងន់ធ្ងរ ធ្វើឱ្យខូចជាលិកាសួត និងបណ្តាលឱ្យស្លាប់មុនអាយុកាលជាដើម។ ជាតិពុលទាំងនោះក៏ធ្វើឱ្យប៉ះពាល់ផងដែរទៅដល់គុណភាពដំណាំបន្លែ កសិផល និងទឹក[៩៦]។ ការដុតសំរាមនៅតាមទីវាល គឺកំពុងមានការអនុវត្តនៅទូទាំងក្រុងព្រះសីហនុ ដែលជាធាតុមួយបង្កឱ្យមានការបំពុលបរិយាកាស។

## ការកើនឡើងកម្ពស់ទឹកសមុទ្រ និងទឹកជំនន់

ក្រុងព្រះសីហនុ ងាយទទួលរងគ្រោះចំពោះកំណើនកម្ពស់ទឹកសមុទ្រ និងការហូរច្រោះតំបន់ឆ្នេរសមុទ្រ។ ជាពិសេស ចំពោះផ្ទះសម្បែងដែលស្ថិតនៅតាមតំបន់ទំនាបនៃឆ្នេរសមុទ្រ ដែលផ្ទះទាំងនោះនឹងកាន់តែរងគ្រោះធ្ងន់ធ្ងរខ្លាំងដោយការសាងសង់ផ្ទះគ្មានគុណភាព និងកង្វះសេវាកម្មនិងហេដ្ឋារចនាសម្ព័ន្ធក្រុងជាមូលដ្ឋាន។ ការហូរច្រោះតំបន់ឆ្នេរសមុទ្រនឹងប៉ះពាល់ដល់ឆ្នេរខ្សាច់ ដែលជះឥទ្ធិពលអាក្រក់ទៅដល់វិស័យទេសចរណ៍។ ការបាត់បង់ជីវិតក្នុងចំណោមកម្មករទៅនេសាទ និងការបែកបាក់ផ្ទះសម្បែងគឺជារឿងធម្មតាដែលត្រូវតែកើតមានដោយសារខ្យល់ព្យុះកំណាចកើតមានឡើងយ៉ាងញឹកញាប់ ព្រមទាំងកង្វះខាតព័ត៌មានផ្លូវការអំពីការព្យាករអាកាសធាតុ។ កំណើនភ្លៀងធ្លាក់ច្រើនញឹកញាប់នៅរដូវវស្សា នឹងបន្ថែមបញ្ហាទឹកទំនន់ ហើយកាន់តែធ្ងន់ធ្ងរខ្លាំងទៀតដោយសារវិបត្តិដែលបណ្តាលមកពីការគ្រប់គ្រងសំរាម និងប្រព័ន្ធលូមិនបានល្អ។

## នគរូបនីយកម្ម (ការរៀបចំផែនការក្រុង)

បន្ថែមទៅលើការពិភាក្សាតាមវិស័យ និងដំណោះស្រាយដែលបានរៀបរាប់ខាងលើ វាជាការចាំបាច់ក្នុងការបញ្ជ្រាបការអភិវឌ្ឍទីក្រុងនិរន្តរភាពចូលទៅក្នុងគម្រោងផែនការអភិវឌ្ឍន៍ក្រុងព្រះសីហនុ ដើម្បីធានាដល់ការចូលរួមចំណែកក្នុងចក្ខុវិស័យ និងទិសដៅរបស់ក្រុងក៏ដូចជារបស់ប្រទេសកម្ពុជាទាំងមូល និងដើម្បីដោះស្រាយបញ្ហាប្រឈមដទៃទៀត។ ដើម្បីចៀសវាងការធ្វើផែនការអភិវឌ្ឍន៍ក្រុងឡើងវិញ វិធីសាស្ត្រដែលមានប្រសិទ្ធភាព គឺការបញ្ចូលទស្សនៈ និងគោលការណ៍អភិវឌ្ឍន៍ទីក្រុងនិរន្តរភាពទៅក្នុងការរៀបចំផែនការមេរបស់ក្រុង ផែនការប្រើប្រាស់ដី និងផែនការវិនិយោគក្រុង រួមទាំងការរៀបចំផែនការអភិវឌ្ឍន៍នានារបស់ក្រុងនាពេលអនាគត។ ក្រុងព្រះសីហនុកំពុងស្ថិតក្នុងដំណាក់កាលដំបូងនៃការរៀបចំបង្កើតផែនការមេ (ប្លង់គោល) របស់ក្រុង ហើយបើមានជំនួយបច្ចេកទេសពីថ្នាក់ខេត្ត និងពីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ គឺការរៀបចំផែនការមេរបស់ក្រុងអាចបញ្ជ្រាប ឬបញ្ចូលទស្សនៈនៃការអភិវឌ្ឍទីក្រុងនិរន្តរភាព ជាពិសេសទៅក្នុងវិស័យដែលបានបង្ហាញខាងលើ។

ក្នុងចំណោមបញ្ហាប្រឈមទាំងឡាយរបស់ក្រុងព្រះសីហនុ គឺបញ្ហាថា តើត្រូវធ្វើសមាហរណកម្មនៅតំបន់សេដ្ឋកិច្ចពិសេសនេះយ៉ាងដូចម្តេចបញ្ចូលទៅក្នុងផែនការអភិវឌ្ឍន៍ក្រុង ដើម្បីធានាដល់ការរួមចំណែកក្នុងការអភិវឌ្ឍទីក្រុងនិរន្តរភាព។ បញ្ហាប្រឈមផ្សេងៗទៀត ដូចជាការកំណត់តំបន់អភិរក្ស តំបន់ឧស្សាហកម្ម ឧទ្យានជាតិ ការផ្គត់ផ្គង់ទឹកស្អាតប្រើប្រាស់ឱ្យមានសុវត្ថិភាព និងការអភិវឌ្ឍប្រព័ន្ធដឹកជញ្ជូន (ដូចជាការផ្សព្វផ្សាយពីសេវាដឹកជញ្ជូនសាធារណនិងការសម្រួលចរាចរណ៍ ទាំងផ្លូវជិះកង់ និងផ្លូវថ្មើរជើង)។ ក្រុងព្រះសីហនុខ្វះខាតប្រព័ន្ធដឹកជញ្ជូនសាធារណៈ ដែលវានឹងមានសារៈសំខាន់បន្ថែមទៀតនៅពេលចំនួនប្រជាជនមាន ការកើនឡើងរួមគ្នាជាមួយនិងឱកាសការងារកើនឡើងដោយសារតំបន់សេដ្ឋកិច្ចពិសេសទាំងនេះ។ បណ្តាញរថយន្តក្រុងសាធារណៈខ្នាតតូច នឹងជួយសម្រួលបានច្រើននៅពេលមានកំណើនប្រជាជន។

[96] T.M. Chen, W.G. Kuschner, J. Gokhale, and S. Shofer, “Outdoor air pollution: nitrogen dioxide, sulfur dioxide, and carbon monoxide health effects,” The American Journal of the Medical Sciences 333, no. 4 (2007): 249-256.

## ២.៣. សកម្មភាពអាទិភាព

នៅក្នុងកម្មវត្ថុទាំង ១២ និងសកម្មភាពគម្រោងទាំង ៩៨ ដែលបានរៀបរាប់នៅផ្នែកទី ១ ខាងលើ មានគម្រោងចំនួន ១០ខាងក្រោមនេះគឺជាអាទិភាពសម្រាប់ក្រុង៖

| ល.រ | ឈ្មោះគម្រោង | បរិយាយពីមូលហេតុដែលជាគម្រោងអាទិភាព និង អត្ថប្រយោជន៍ផ្នែកសង្គម សេដ្ឋកិច្ច និងបរិស្ថានរបស់ក្រុង |
|---|---|---|
| ១ | អភិវឌ្ឍន៍បណ្តាញលូទឹកកខ្វក់ និងប្រព័ន្ធប្រព្រឹត្តកម្មទឹកកខ្វក់បែបវិមជ្ឈការ (លក្ខណៈដាច់ដោយឡែកតាមតំបន់) នៅសង្កាត់កោះរ៉ុង និងសង្កាត់កោះរ៉ុង សន្លឹម) | បញ្ចៀសការបង្ហូរទឹកកខ្វក់ចូលទៅក្នុងសមុទ្រ។ លើកកម្ពស់គុណភាព និងអនាម័យឆ្នេរសមុទ្រ ដើម្បីទាក់ទាញទេសចរណ៍ និងកាត់បន្ថយផលប៉ះពាល់អវិជ្ជមានដល់បរិស្ថាន។ |
| ២ | បង្កើតវិធានការ និងអភិវឌ្ឍន៍ប្រព័ន្ធគ្រប់គ្រងប្រើប្រាស់បច្ចេកវិទ្យាបៃតងដើម្បីកាត់បន្ថយការកើនឡើងយ៉ាងឆាប់រហ័សនៃបរិមាណសំរាមក្នុងក្រុង ដូចជាការប្រើប្រាស់ នូវឡដុតសំរាម បច្ចេកវិទ្យា RDF ស្ថានីយកែច្នៃសំរាមទៅថាមពល។ល។ | កាត់បន្ថយបរិមាណសំរាម។ លើកកម្ពស់គុណភាព និងសោភ័ណ្ឌភាពក្រុង និងកាត់បន្ថយបាននូវផលប៉ះពាល់អវិជ្ជមានពីសំរាមទៅលើបរិស្ថាន និងសុខមាលភាពប្រជាពលរដ្ឋ។ |
| ៣ | អភិវឌ្ឍន៍ប្រព័ន្ធគ្រប់គ្រងខ្សែសង្វាក់ផ្គត់ផ្គង់សំរាមក្នុងក្រុងដែលអាចកែច្នៃឡើងវិញបាន។ បង្កើតប្រព័ន្ធប្រមូល និងទុកដាក់សំរាមដែលមានលក្ខណៈគ្រប់ជ្រុងជ្រោយ ក្នុងនោះរួមមានទីលានចាក់សំរាមដែលមានស្តង់ដាអនាម័យ | កែលម្អ និងពង្រឹងការគ្រប់គ្រងសំរាមប្រកបដោយចីរភាពនៅក្រុងព្រះសីហនុ។ ជំរុញ និងលើកទឹកចិត្តឱ្យមានការបង្កើតអាជីវកម្មផ្លូវការនៅខ្សែសង្វាក់សំរាមដែលនឹងអាចជួយបង្កើតការងារបៃតងបានផងដែរ។ ទាំងអស់នេះ នឹងជួយដល់ការកាត់បន្ថយបរិមាណសំរាមក្នុងក្រុង និងលើកកម្ពស់បរិស្ថាន និងសោភ័ណ្ឌភាពក្រុង។ |
| ៤ | រៀបចំ និងស្តារ នូវប្រព័ន្ធអាងស្តុកទឹកធម្មជាតិ មានដូចជាអូរ ប្រឡាយ បឹងក្នុងក្រុង ប្រព័ន្ធរក្សា និងចរន្តទឹក នៅក្នុងក្រុង | កាត់បន្ថយការជន់លិចក្នុងក្រុង និងស្ទះលូ ដែលបង្កឱ្យខូចខាតផ្លូវ និងផ្ទះសម្បែង។ |
| ៥ | បង្កើត និងពង្រឹងការអនុវត្តស្តង់ដារអគារបៃតង និងការបង្កើតប្រព័ន្ធត្រួតពិនិត្យស្តង់ដារគ្រប់ជ្រុងជ្រោយមួយ ទាក់ទងទៅនឹងសុវត្ថិភាព បរិស្ថាន និងប្រសិទ្ធភាពថាមពល | ធានាបានថាអគារនីមួយៗនឹងត្រូវអនុវត្តស្របតាមស្តង់ដារអគារបៃតងដែលពង្រឹងសុវត្ថិភាព និងបរិស្ថាន។ |
| ៦ | បង្កើតនូវស្ថានីយឡានក្រុងប្រកបដោយស្តង់ដា ដែលស្ថិតនៅក្រៅក្រុង និងការពង្រឹង ប្រព័ន្ធផ្លូវសាធារណៈ រួមមានកន្លែងចតយាន្តយន្ត និងចិញ្ចើមផ្លូវសម្រាប់អ្នកថ្មើរជើង | កាត់បន្ថយការកកស្ទះចរាចរណ៍នៅក្នុងក្រុង។ ពង្រឹងគុណភាពខ្យល់ និងសោភ័ណភាពក្រុង ដើម្បីបង្កើនភាពទាក់ទាញភ្ញៀវទេសចរ និងផលប្រយោជន៍ដល់ប្រជាពលរដ្ឋក្នុងក្រុង។<br><br>កន្លែងចំណតរថយន្តក្រុងបណ្តោះអាសន្នរបស់ក្រុង មានទីតាំងបច្ចុប្បន្ននៅលើដីសួនច្បារមហោស្រព។ |

| | | |
|---|---|---|
| ៧ | បង្កើតសួនច្បារ សួនលំហែ ពហុគោលបំណង តាមស្តង់ដារ (មានកន្លែងសម្រាប់កុមារ ឧបករណ៍ហាត់ប្រាណ) | លើកកម្ពស់សោភ័ណភាពក្រុង បង្កភាពសប្បាយរីករាយដល់គ្រួសារនីមួយៗ និងសុខភាពសាធារណៈ។ |
| ៨ | សិក្សា និងរៀបចំប្លង់គោលប្រើប្រាស់ដីក្នុងក្រុង (ផ្អែកលើផែនការមេប្រើប្រាស់ដីរបស់ខេត្តដែលមានស្រាប់) | លើកកម្ពស់ការប្រើប្រាស់ដីប្រកបដោយចីរភាព ការរៀបចំតំបន់ក្រុង និង ការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធក្រុង។ |
| ៩ | រៀបចំដាក់ភ្លើងបំភ្លឺសាធារណៈប្រើប្រាស់ថាមពលពន្លឺព្រះអាទិត្យ | លើកកម្ពស់សោភ័ណភាព និងសុវត្ថិភាពធ្វើដំណើរក្នុងក្រុង និង លើកកម្ពស់ការប្រើប្រាស់ថាមពលប្រកបដោយប្រសិទ្ធភាព។ |
| ១០ | ផ្សព្វផ្សាយពីផលិតកម្មស្អាត | អនុម័ត និងពង្រឹងការអនុវត្តបទដ្ឋានពីប្រសិទ្ធភាពប្រើប្រាស់ធនធានក្នុងផលិតកម្ម និងការត្រួតពិនិត្យការបញ្ចេញសារធាតុពុល និងជំរុញការប្រើប្រាស់បច្ចេកវិទ្យាថាមពលកកើតឡើងវិញ និងបច្ចេកវិទ្យាប្រសិទ្ធភាពធនធាន នៅក្នុងចង្វាក់ផលិតកម្ម។ |

*ប្រភព៖ ការប្រឹក្សាយោបល់ជាមួយរដ្ឋបាលក្រុងព្រះសីហនុ*

## ២.៤. ព័ត៌មានអំពីស្ថិតិសេដ្ឋកិច្ច-សង្គម

| សូចនាករ | ទិន្នន័យ ឆ្នាំ២០១៥ |
|---|---|
| ចំនួនប្រជាជន (នាក់) | ៧៨.៣៨០ |
| ដង់ស៊ីតេប្រជាជន (នាក់/គ.ម២) | ៤០០,១ |
| អត្រាភាពក្រីក្រ (បទបង្ហាញពីសិក្ខាសាលា) (ភាគរយ) | ៦,៨១% |
| ផ្ទៃក្រឡា (គ.ម២) | ១៩៥,៩០ |
| អត្រាអ្នកចេះអក្សរ (បទបង្ហាញពីសិក្ខាសាលា) (ភាគរយ) | ៩៩,៥% |
| វិស័យសេដ្ឋកិច្ចសំខាន់ៗ | សេវាកម្ម និង កំពង់ផែ |
| បំណែងចែកការងារតាមវិស័យផ្សេងៗ (ភាគរយ) | |
| - កសិកម្ម | ៦% |
| - ផលិតកម្ម | ៣,៩% |
| - សេវាកម្ម | ៩០,១% |

| | |
|---|---|
| ចំណាកស្រុក (ទៅក្រៅបរទេស) (នាក់) | ៥៧០ |
| មធ្យមភាគទោចក្រយានយន្តក្នុងផ្ទះ (គ្រឿង) | ០,៩ |
| ចំនួនប្រជាជនដែលជាប់បំណុល(ធនាគារ ឬមីក្រូហិរញ្ញវត្ថុ) (នាក់) | ៤.៧៥៩ |
| ចំនួនផ្ទះនៅសំណង់អនាធិបតេយ្យ/លំនៅឋានខុសច្បាប់ (ខ្នងផ្ទះ) | ៩៧២ |
| ចំនួនផ្ទះដែលទទួលឥទ្ធិពលពីខ្យល់ព្យុះ (ខ្នងផ្ទះ) | ៥ |
| ចំនួនផ្ទះដែលទទួលឥទ្ធិពលពីទឹកជំនន់ (ខ្នងផ្ទះ) | ០ |
| ចំនួនផ្ទះដែលទទួលឥទ្ធិពលពីភាពរាំងស្ងួត (ខ្នងផ្ទះ) | ០ |
| ភាគរយផ្ទះដែលសេវាកម្មប្រមូលសំរាមអាចចូលទៅដល់ (ភាគរយ) | ៤០% |
| ភាគរយផ្ទះដែលមានលទ្ធភាពទទួលបានសេវាអនាម័យ (ភាគរយ) | ៨៣,៨៩% |
| ភាគរយផ្ទះដែលមានប្រព័ន្ធទឹកតាមបំពង់ទុយោ (ភាគរយ) | ៦៣,០៨% |
| ភាគរយផ្ទះដែលមានភ្លើងប្រើប្រាស់ (ភាគរយ) | ៩៨% |
| ចំនួនសំរាមក្នុងមួយថ្ងៃ (តោន) | ១៥០តោន |



ក្រុងព្រះសីហនុ



ក្រុងកែប

# ក្រុងកែប

## ២.១. សេចក្តីផ្តើម

ក្រុងកែបជាក្រុងទេសចរណ៍ធម្មជាតិប្រវត្តិសាស្ត្រមួយនៃតំបន់ឆ្នេរសមុទ្រកម្ពុជា។ ក្រុងកែបមាន ចំនួនប្រជាជនរស់នៅប្រហែល ២១.២១០នាក់ (២០១៨) និងមានសក្តានុពលអេកូទេសចរណ៍ដែលមានតំបន់ល្បីៗជាច្រើនដូចជាផ្សារក្តាម ឧទ្យានជាតិកែប និងកោះទន្សាយ។ ក្រុងកែបជាក្រុងមួយដែលមានអនាម័យស្អាត និងធ្លាប់បានទទួលពានរង្វាន់ទីក្រុងស្អាតផ្ការំដួលបីទង ពានរង្វាន់ទីក្រុងនិរន្តរភាពបរិស្ថានអាស៊ាន ពានរង្វាន់ទីក្រុងទេសចរណ៍ស្អាតអាស៊ាន និងពានរង្វាន់កិត្តិយសជាច្រើនទៀត។

ក្រុងកែបមានភូមិសាស្ត្រជាតំបន់ឆ្នេរសមុទ្រនាទិសនិរតីនៃព្រះរាជាណាចក្រកម្ពុជា និងព័ទ្ធជុំវិញដោយកោះតូចៗជាច្រើន។ ក្រុងកែបមានតំបន់ ៣ ដែលមានសកម្មភាពខ្លាំងជាងគេ គឺឆ្នេរកែបស្ថិតនៅតំបន់ឆ្នេរទិសខាងត្បូង ផ្សារកែបដែលស្ថិតតាមបណ្តោយឆ្នេរប្រហែល ១គម និងផ្សារក្នុងក្រុងធំមួយទៀតដែលនៅទិសខាងកើតនៃតំបន់ក្រុង។ ក្រុងកែប មានសមុទ្រ កោះ ឆ្នេរសមុទ្រ ព្រៃកោងកាង ស្រែអំបិល វាលទំនាប ខ្ពង់រាប ជម្រាលភ្នំ គម្របព្រៃ និងឧទ្យានជាតិនៅកណ្តាលទីក្រុង។ ក្រុងកែបស្ថិតនៅតាមបណ្តោយអ័ក្សនៃការអភិវឌ្ឍតំបន់ឆ្នេរសមុទ្រអាស៊ាន ហាយវេលេខ ១២៣ និងលេខ៣៣អា។

ក្រុងកែបមានគោលដៅអភិវឌ្ឍន៍វិស័យសេដ្ឋកិច្ចសង្គមរបស់ខ្លួនដោយផ្តោតសំខាន់តែទៅលើវិស័យ ទេសចរណ៍ កសិកម្ម និងសិប្បកម្ម។ ជាមួយនឹងការលើកទឹកចិត្តតិចតួចសម្រាប់កំណើនឧស្សាហកម្ម ដែលធ្វើឱ្យវាក្លាយជាករណីដ៏ល្អមួយសម្រាប់ការអភិវឌ្ឍក្រុងនិរន្តរភាព។ កែប គឺជាក្រុងតូចបើធៀបនឹងក្រុងដែលមានតំបន់ឆ្នេរជាប់ជិតខាងនៃខេត្តកំពតនិងក្រុងព្រះសីហនុ ប៉ុន្តែក្រុងមួយនេះបានត្រៀមខ្លួនសម្រាប់កំណើនយ៉ាងឆាប់នៅក្នុងឆ្នាំខាងមុខនេះ។ មានការកើនឡើងជាលំដាប់នូវការទាក់ទាញភ្ញៀវទេសចរជាតិ និងអន្តរជាតិដោយសារឆ្នេរខ្សាច់គ្មានការបំពុលបរិស្ថាន។ ដោយឡែកម្ហូបដ៏ល្បីល្បាញ នៃក្រុងកែប មានដូចជាក្តាម មឹក បង្គារ និងត្រីសមុទ្រស្រស់ៗ ។

តារាង៖ ស្ថិតិប្រជាសាស្ត្រ ក្រុងកែប(ស្ថិតិសេដ្ឋកិច្ច-សង្គមរបស់ក្រុងកែប ឆ្នាំ២០១៧)

| ស្ថិតិប្រជាសាស្ត្រ | ២០១៥ | ២០១៦ | ២០១៧ | ២០១៨ |
|---|---|---|---|---|
| ចំនួនប្រជាជន (នាក់) | ២០.៦០៨ | ២១.០១៨ | ២០.៦៩៤ | ២១.២១០ |
| អត្រាកំណើនប្រចាំឆ្នាំ(គិតជាភាគរយ) | ០,២ | ២,០ | -១,៥ | ២,៥ |
| ចំនួនស្ត្រី (នាក់) | ១០.៥៤៥ | ១០.៨២២ | ១០.៦៥៥ | ១០.៨២៤ |
| សមាមាត្រស្ត្រីធៀបនឹងបុរស (ក្នុងចំណោមបុរស១០០នាក់) | ១០៥ | ១០៦ | ១០៦ | ១០៤ |
| ចំនួនគ្រួសារ (គ្រួសារ) | ៤.៥២៨ | ៤,៥៤៥ | ៤.៥៦២ | ៤.៦០១ |
| ទំហំគ្រួសារជាមធ្យម (នាក់) | ៤,៥ | ៤,៥ | ៤,៥ | ៤,៥ |

## ២.២. ការវិភាគតាមវិស័យ សម្រាប់ការអភិវឌ្ឍទីក្រុងនិរន្តរភាព

### ទេសចរណ៍

ក្រុងកែប មានសក្តានុពលធម្មជាតិសម្រាប់ការកសាងសេដ្ឋកិច្ចរបស់ខ្លួនលើវិស័យទេសចរណ៍ប្រកបដោយនិរន្តរភាព មានឆ្នេរសមុទ្រ កោះ ភ្នំ ឧទ្យានជាតិ ដើមកោងកាង ផ្កាថ្ម និងស្មៅសមុទ្រ ។ល។ អាហារសមុទ្រ ស្រស់ៗដែលអាចរកបាន និងផលិតផលកសិកម្មចេញពីចំការអ្នកស្រុក ព្រមទាំងឧទ្យានជាតិប្រកបដោយភាពទាក់ទាញនៅកណ្តាលក្រុងដែលសម្បូរទៅដោយជីវៈចម្រុះគ្រប់ប្រភេទ ។ ក្រុងកែបស្ថានីយអយស្ម័យយាន ០១កន្លែងមិនទាន់ដំណើរការ ដោយមានផ្លូវដែកឆ្លងកាត់ចំនួន១ខ្សែ និង មានខ្សែរត់ពីភ្នំពេញទៅក្រុងព្រះសីហនុកំពុងដំណើរការ ។ ឆ្នេរសមុទ្រក្រុងកែបមានឱកាសក្នុងការទាក់ទាញភ្ញៀវទេសចរចាប់ពីថ្នាក់កណ្តាល រហូតដល់ថ្នាក់ខ្ពស់ដែលពេញចិត្តចំពោះភាពស្និទ្ធស្នាលជាមួយធម្មជាតិ និងការសម្រាកលំហែកាយដែលវាខុសគ្នាពីទេសចរណ៍កងរំពង។ សក្តានុពលទាំងនេះបាននឹងកំពុងរៀបបន្ថែមទៀត ដើម្បីឆ្លើយតបទៅនឹងទីផ្សារទេសចរណ៍បច្ចុប្បន្នដែលបានមើលឃើញទេសចរណ៍សេដ្ឋកិច្ចនិងនិរន្តរភាពដែលជាវិស័យសេដ្ឋកិច្ចដ៏សំខាន់សម្រាប់ក្រុងកែប និងជាកត្តាចំបងមួយក្នុងការអភិវឌ្ឍទីក្រុងនិរន្តរភាព។

ក្រុងកែបជួបប្រទះបញ្ហាប្រឈមជាច្រើនក្នុងការបន្តអភិវឌ្ឍន៍វិស័យទេសចរណ៍ បញ្ហាទាំងនោះពាក់ពាន់នឹងធនធានមនុស្ស និងហិរញ្ញវត្ថុ ឧទាហរណ៍ជំនាញបដិសណ្ឋារកិច្ចនៅមានកម្រិតរបស់បុគ្គលិកសណ្ឋាគារ ភោជនីយដ្ឋាន និងហាងលក់ទំនិញ កង្វះខាតសមត្ថភាពក្នុងការអភិវឌ្ឍផលិតផលអេកូទេសចរណ៍ថ្មី ទាំងនៅលើកោះ។ តំបន់ដីដែលមានសក្តានុពលខ្ពស់ត្រូវបានទិញដោយអ្នកវិនិ-យោគមានសក្តានុពល ដែលភាគច្រើនទុកចោលដោយគ្មានការអភិ-វឌ្ឍបន្ថែម បើទោះបីជាទទួលបានលិខិតអនុញ្ញាតឱ្យវិនិយោគក៏ដោយ។ ការផ្គត់ផ្គង់ម្ហូបគ្រឿងសមុទ្រស្រស់ៗ មិនគ្រប់តម្រូវការ និងមានការបំផ្លិចបំផ្លាញធនធានធម្មជាតិដោយបទល្មើសនេសាទ។ ថែមទាំងមានកង្វះខាតផ្នែកហេដ្ឋារចនាសម្ព័ន្ធរូបវន្តដើម្បីគាំទ្រការអភិវឌ្ឍវិស័យទេសចរណ៍ ឧទាហរណ៍ ការផ្គត់ផ្គង់ទឹកស្អាត ការធ្វើអាងប្រព្រឹត្តិកម្មទឹកកខ្វក់ ការរៀបចំសំរាម និងការផ្គត់ផ្គង់ថាមពលប្រកបដោយនិរន្តរភាព។ ក្រុងកែបក៏ងាយរងគ្រោះជួបផលប៉ះពាល់ដោយសារបម្រែបម្រួលអាកាសធាតុ និងគ្រោះមហន្តរាយធម្មជាតិដូចជាការកើនកំដៅទឹកសមុទ្រ ភ្លៀងធ្លាក់ខ្លាំង និងខ្យល់កន្ត្រាក់ដែលអាចប៉ះពាល់ទៅដល់ការអភិវឌ្ឍវិស័យទេសចរណ៍។ ដើម្បីប្រែក្លាយសក្តានុពលនេះឱ្យក្លាយទៅជាការពិត ក្រុងកែបត្រូវការបន្តការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធរូបវន្តដើម្បីឱ្យទីក្រុងកាន់តែមានភាពទាក់ទាញដល់ភ្ញៀវទេសចរជាតិ និងអន្តរជាតិ។ រួមមានការរៀបចំសំរាមនិងការបង្ហូរទឹកឱ្យបានកាន់តែប្រសើរឡើង ការពង្រីកបំពង់ផ្គត់ផ្គង់ទឹកស្អាតប្រើប្រាស់ឱ្យបានគ្រប់ទីកន្លែង និងសាងសង់បង្គន់សាធារណៈ និងធុងសំរាមសាធារណៈ/ធុងសំរាមតាមបណ្តោយឆ្នេរខ្សាច់ ឧទាហរណ៍ ភ្លើងបំភ្លឺតាមសាធារណៈដែលប្រើប្រាស់ថាមពលពន្លឺព្រះអាទិត្យ។

តាមរយៈការពង្រឹងច្បាប់ដែលមានស្រាប់ និងការចូលរួមពីគ្រប់ភាគីពាក់ព័ន្ធ ក្រុងកែបអាចជំរុញប្រតិបត្តិការទេសចរណ៍ឯកជនឱ្យអនុវត្តន៍នូវស្តង់ដារបៃតង ដោយការបង្កើនប្រសិទ្ធភាពក្នុងការប្រើប្រាស់ទឹកស្អាត និងអគ្គិសនី ឱ្យប្រើប្រាស់ប្រព័ន្ធថាមពលអគ្គិសនីកកើតថ្មី(ឧទាហរណ៍ម៉ាស៊ីនទឹកក្តៅ និងបន្ទះអគ្គិសនី PV ដោយប្រើថាមពលសូឡា) ប្រើប្រាស់សំរាមកែច្នៃ និងអាងប្រព្រឹត្តិកម្មការរៀបចំតំបន់ដីជុំវិញសណ្ឋាគារ និងរមនីយដ្ឋាន និងប្រើប្រាស់ផលិតផលគ្រឿងម្ហូបដែលយកចេញពីចំការ និងសមុទ្រក្នុងស្រុកតាមភោជនីយដ្ឋាន។

ក្រុងកែបអាចបន្តអភិវឌ្ឍន៍សកម្មភាព និងវិធីសាស្ត្រអេកូទេសចរណ៍បន្ថែមទៀត ពង្រីកផែទេសចរណ៍ឱ្យកាន់តែទាក់ទាញដូចជាកប៉ាល់ និងទូកកម្សាន្តតូចៗ ដឹកអ្នកទេសចរ ដោយផ្អែកលើគោលការណ៍បៃតង ឧទាហរណ៍ការផ្គត់ផ្គង់អគ្គិសនីបានមកពីថាមពលអគ្គិសនីកកើតថ្មី(បន្ទះPV)ការប្រមូលនិងកែច្នៃសំរាម និងការណែនាំមធ្យោបាយធ្វើដំណើរ (បៃតង) គ្រប់ប្រភេទនៅក្នុងក្រុងកែបនិងតាមផ្ទៃសមុទ្រ និងដោយផ្អែកលើ យានយន្តប្រើអគ្គិសនី/អាគុយ(ដូចជាម៉ូតូកង់បី រថយន្ត រថយន្តក្រុងសាធារណៈ) និងទូកប្រើអគ្គិសនីព្រមទាំងការបន្ថែមនូវគំនូសផ្លូវសម្រាប់កង់ និងអ្នកថ្មើរជើង។

ដើម្បីពង្រឹងគោលការណ៍ទេសចរណ៍ប្រកបដោយនិរន្តរភាពនៅក្នុងក្រុងកែប សាលាក្រុងកែបត្រូវបង្កើតវេទិកាសហការដោយមានការចូលរួមពីសំណាក់ប្រតិបត្តិការទេសចរណ៍ឯកជន និងសង្គមស៊ីវិល។ វេទិកានេះនឹងជួយបន្តឱ្យមានកិច្ចសន្ទនាគ្នាមួយស្តីពីគោលបំណង និងគោលការណ៍ទេសចរណ៍បៃតង ស្តីពីការពិភាក្សាអំពីការដាក់ចេញនូវសកម្មភាពអាទិភាពខុសៗគ្នា ស្តីពីការគាំទ្រយីហោ

របស់ក្រុងកែបដែលវាជាគោលដៅទាក់ទាញអេកូទេសចរណ៍មួយ ព្រមទាំងការផ្ដួចផ្ដើមផ្សព្វផ្សាយផែនការសកម្មភាពជាតិនិងអន្តរជាតិ ជាពិសេសតាមរយៈគេហទំព័រ កៀរគរការចូលរួមជាសាធារណៈនៅក្នុងការគ្រប់គ្រងក្រុងនិរន្តរភាពនិងការគ្រប់គ្រងសំណល់ ព្រមទាំងរៀបចំសកម្មភាពអភិវឌ្ឍន៍ធនធានមនុស្ស ដើម្បីកសាងសមត្ថភាពរបស់បុគ្គលិកលើផ្នែកបដិសណ្ឋារកិច្ចជារួមនាពេលបច្ចុប្បន្ននឹងទៅថ្ងៃអនាគត និងផ្នែកអនុវត្តន៍ការអភិវឌ្ឍបៃតង។ វេទិកាអភិវឌ្ឍន៍ វិស័យរដ្ឋ និងឯកជនដែលមានស្រាប់ គឺជាកត្តាសំខាន់ក្នុងការទាក់ទាញថវិកាជាតិនិងអន្តរជាតិសម្រាប់គម្រោងនិងការវិនិយោគក្នុងផែនការបៃតង និងគម្រោងដែលគិតគូរពីការប្រែប្រួលអាកាសធាតុ។

## ការគ្រប់គ្រងសំណល់រឹង (សំរាម)

ព័ត៌មានទូទៅអំពីក្រុងបៃតងត្រូវការការរៀបចំសំណល់រឹងប្រកបដោយប្រសិទ្ធភាព និងចីរភាព។ យ៉ាងណាមិញប្រព័ន្ធប្រមូលសំរាមនាពេលបច្ចុប្បន្ន នៅក្រុងកែបទើបតែប្រមូលបាន៣១%នៃសំរាមតាមលំនៅឋាន។ កម្រិតនៃការកែច្នៃសំរាមនៅមានកំណត់នៅឡើយ និងកន្លែងចាក់សំរាមដែលមានស្រាប់ មិនមានលក្ខណៈត្រឹមត្រូវទៅតាមបទដ្ឋានបច្ចេកទេស សម្រាប់ជាកន្លែងចាក់សំរាមប្រកបដោយអនាម័យនោះទេ។ បញ្ហាប្រឈមផ្សេងៗទៀត គឺកង្វះខាតក្នុងការចូលរួមជាសាធារណៈ និងការយល់ដឹងអំពីរបៀបកាត់បន្ថយបរិមាណសំរាម ការញែកសំរាម និងការទុកដាក់សំរាមឱ្យបានត្រឹមត្រូវ។ បញ្ហាទាំងនេះគឺដោយសារការខំប្រឹងប្រែងអប់រំសម្រាប់សហគមន៍នៅមានកម្រិតនៅឡើយ។

ដើម្បីដោះស្រាយបញ្ហាប្រឈមទាំងនោះ ក្រុងកែបត្រូវខិតខំអនុវត្តន៍តាមគោលការណ៍បីយ៉ាងគឺ "ការកាត់បន្ថយ ការប្រើប្រាស់ឡើងវិញ និងការកែច្នៃ" ក្នុងការរៀបចំសំរាម និងខិតខំធ្វើឱ្យសេវាកម្មប្រមូលសំរាមមានភាពល្អប្រសើរឡើង តាមរយៈការអនុវត្តហេដ្ឋា-រចនាសម្ព័ន្ធសម្រាប់ការញែកសំរាមតាមផ្ទះ និងការប្រើប្រាស់សំរាមនិងប្រើសំរាមកែច្នៃ តាមរយៈការពង្រីកសេវាប្រមូលសំរាមឱ្យបាន ១០០% គ្រប់ទីកន្លែង តាមរយៈការបន្ថែមឡានដឹកសំរាម និងការអភិវឌ្ឍកន្លែងចាក់សំរាម។ បច្ចុប្បន្នធនាគារអភិវឌ្ឍន៍អាស៊ី គ្រោងនឹងធ្វើទីលានចាក់សំរាមដែលមានបទដ្ឋានច្បាស់លាស់មួយ។ គម្រោងនេះ បង្កើតឱកាសដើម្បីអភិវឌ្ឍអាជីវកម្មខ្នាតតូចជុំវិញការប្រមូលការតម្រៀបប្រភេទ ការដាក់ឱ្យដំណើរការ និងការធ្វើទីផ្សារកាកសំណល់កែច្នៃ។ ក្រុងកែបអាចស្វែងយល់ពីភាពជាដៃគូជាមួយក្រុងកំពតដែលនៅជិតខាង ដើម្បីបង្កើនលទ្ធភាពប្រើប្រាស់សម្ភារកែច្នៃ។ ធ្វើដូចនេះ អាចរួមចំណែកដល់ការបង្កើតការងារ បង្កើតប្រាក់ចំណូល ខណៈពេលដែលកាត់បន្ថយការបំពុលបរិយាកាសពីការដុតសំរាមពាសវាលពាសកាល។ ថែមលើនេះ ក្រុងកែបត្រូវចាប់ផ្ដើមយុទ្ធនាការសម្រាប់ថែរក្សាបរិស្ថានទីក្រុងឱ្យល្អស្អាត ព្រមទាំងត្រូវថែរក្សាឆ្នេរខ្សាច់ឱ្យស្អាតផងដែរ។

## ការគ្រប់គ្រងសំណល់រាវ (ទឹកកខ្វក់)

ក្រុងកែបខ្វះខាតប្រព័ន្ធបណ្ដាញលូបង្ហូរទឹក និងអាងប្រព្រឹត្តិកម្មទឹកកខ្វក់ ដែលអាចការពារការបង្ហូរទឹកកខ្វក់ចូលទៅកាន់សមុទ្រ។ ផ្ទះប្រជាពលរដ្ឋនីមួយៗនៅក្នុងក្រុង មិនទាន់បានតភ្ជាប់បណ្ដាញលូទឹកកខ្វក់និងទឹកភ្លៀងនោះទេ។ ស្ថានភាពបែបនេះ គឺជាបញ្ហាប្រឈមយ៉ាងពិតប្រាកដក្នុងការអភិវឌ្ឍក្រុងនិរន្តរភាពរបស់ក្រុងកែប និងគម្រាមកំហែងដល់ស្ថានភាពទីក្រុងដែលវាជាគោលដៅអេកូទេសចរណ៍។ តាមរយៈការជួបពិភាក្សាជាមួយអាជ្ញាធរក្រុង ជាដំណោះស្រាយ គឺក្រុងកែបបានខិតខំអភិវឌ្ឍន៍ប្រព័ន្ធលូទឹកកខ្វក់ដែលរួមមានការសាងសង់បណ្ដាញបំពង់លូបង្ហូរទឹក និងអាងប្រព្រឹត្តិ-កម្មទឹកកខ្វក់ដែលមានទំហំអាចចម្រោះទឹកកខ្វក់បានចំនួន ៥តោនក្នុងមួយថ្ងៃ សម្រាប់ពេលបច្ចុប្បន្ន និងអាចកើនឡើងដល់ ២៤តោនក្នុងមួយថ្ងៃ នៅឆ្នាំ២០៣០។ បន្ថែមលើនេះ ក្រុងកែប កំពុងផ្សព្វផ្សាយលើកទឹកចិត្តលើការបំពាក់លូស្តុកទឹកកខ្វក់ (លូសិបទិច) នៅតាមផ្ទះប្រជាពលរដ្ឋ និងតាមទីកន្លែងអាជីវកម្ម។ ស្ថានភាពភូមិសាស្ត្រនៃក្រុងកែប ធ្វើឱ្យមានការលំបាកក្នុងការបង្កើតប្រព័ន្ធប្រព្រឹត្តិ-កម្មរួម ដូច្នេះក្រុងមានស្ថានភាពសាកសមក្នុងការបង្កើតប្រព័ន្ធខ្នាតតូចដាច់ដោយឡែក។ នៅក្នុងខណៈពេលនៃការសរសេរនេះ ក្រសួងសាធារណការ និងដឹកជញ្ជូន មានផែនការក្នុងការអភិវឌ្ឍផែនការគ្រប់គ្រងទឹកកខ្វក់ដោយមានការជួយគាំទ្រពីក្រុមហ៊ុនចិន (Beijing Urban Construction Group)។

## អាជីវកម្មខ្នាតតូច

ក្រុងកែបសំបូរទៅដោយអាជីវកម្មខ្នាតតូច ជំនាញខាងធ្វើចំណីអាហារក្នុងស្រុក ដូចជាសាច់ក្ដាម ទឹកត្រី អំបិល និងម្រេច។ ដោយមានការកើនឡើងចំនួនភ្ញៀវទេសចរ ដែលតែងតែចាប់អារម្មណ៍ក្នុងការទិញផលិតផលក្នុងស្រុកធ្វើជាវត្ថុអនុស្សាវរីយ៍ ក្រុងកែបមានសក្ដានុពលផ្នែកវិនិយោគក្នុងការពង្រីកវិស័យនេះឱ្យកាន់តែធំ។ ផលិតផលក្នុងស្រុកដែលមានការបញ្ជាក់ទទួលស្គាល់ ហើយដែល

អាចដឹកជញ្ជូន និងនាំចេញបានងាយស្រួល គឺអាចមានតម្រូវការទីផ្សារខ្ពស់ ដែលជាសក្តានុពលមួយក្នុងការអភិវឌ្ឍអាជីវកម្មក្នុងស្រុកលើវិស័យចំណីអាហារសរីរាង្គ និងអាហារសុខភាព។ ផលិតផលធម្មជាតិដែលបានមកពីសមុទ្រ(ត្រី ក្តាម បង្គារ មឹក សារាយសមុទ្រជាដើម) ត្រូវបានគេចាត់ទុកថាជាអាហារសុខភាព ដែលមានទីផ្សារពេញនិយម។

បន្ថែមលើនេះដីកសិកម្មជុំវិញក្រុងកែបគឺជាដីមានជីវជាតិនិងអាចដាំដុះដំណាំបានគ្រប់ប្រភេទ ដូចជាដំណាំម្រេចមានតម្លៃទីផ្សារខ្ពស់ ដែលក្រុងកែបកំពុងល្បីល្បាញស្រាប់ខាងដំណាំម្រេច និងផ្លែឈើដូចជាផ្លែស្វាយ និងធូរ៉េន។ ចំការដំណាំ និងអាជីវកម្មផលិតកម្មនៃផលិតផលទាំងនោះ ក៏អាចជាកត្តាទាក់ទាញភ្ញៀវទេសចរបន្ថែមទៀតផងដែរ។ ការអភិវឌ្ឍ និងផ្សព្វផ្សាយទីផ្សារផលិតផលទាំងនេះអាចជួយបង្កើតការងារក្នុងស្រុក ជាពិសេសសម្រាប់ស្ត្រី កាត់បន្ថយចំណាកស្រុក និងចូលរួមចំណែកក្នុងការកាត់បន្ថយភាពក្រីក្រ និងបរិយាបន្នសង្គម។

មានបញ្ហាប្រឈមជាច្រើនក្នុងការអភិវឌ្ឍផលិតផលគុណភាពខ្ពស់បានមកពីសមុទ្រ និងដំណាំចំការ ក្នុងនោះមានដូចជា ជំនាញ និងចំណេះដឹងនៅមានកម្រិតអំពីការនេសាទ និងការដាំដុះ ការប្រមូលផល ផលិត និងទីផ្សារ។ គុណភាពផលិតផលក្នុងពេលបច្ចុប្បន្នមិនទាន់ត្រូវតាមស្តង់ដាររបស់ទីផ្សារអ្នកទេសចរនៅឡើយទេ ហើយការលក់ដូរបានតម្លៃទាប។ ចំពោះអ្នកដាំដុះ កង្វះទឹកប្រើប្រាស់ក៏ជាបញ្ហាមួយ នេះគឺដោយសារប្រព័ន្ធស្រោចស្រពមិនគ្រប់គ្រាន់ ។ ទាំងការនេសាទ និងការដាំដុះងាយរងនូវការទទួលឥទ្ធិពលពីបម្រែបម្រួលអាកាសធាតុដូចជាការកើតមានញឹកញាប់នូវគ្រោះរាំងស្ងួត ទឹកជំនន់ និងខ្យល់កន្ត្រាក់ ។ ចំពោះអ្នកនេសាទ ការនេសាទហួសកម្រិតដោយមិនកំណត់នូវប្រភេទឧបករណ៍នេសាទ បានបង្កជាបញ្ហាប្រឈមនាពេលអនាគត។ បញ្ហាចុងក្រោយគឺការខ្វះខាតថវិកាវិនិយោគក្នុងការធ្វើអាជីវកម្មទាំងនេះ។

ការផ្តល់សម្បទានទៅតំបន់នេះ បានជួយដល់ការអភិវឌ្ឍក្រុងនិរន្តរភាព ដូចជាការបង្កើនប្រាក់ចំណូល បង្កើនការងារ ដោះស្រាយបញ្ហាសង្គម និងការប្រើប្រាស់ធនធានធម្មជាតិប្រកបដោយនិរន្តរភាពរបស់ក្រុងកែប ជាមួយគ្នានេះការខិតខំជំរុញម្ចាស់អាជីវកម្ម និងបង្កើតឱ្យមានបរិស្ថានសម្រាប់អ្នកវិនិយោគ។ ផ្តើមចេញពីទស្សនទានអភិវឌ្ឍន៍ទីក្រុងនិរន្តរភាព ការផ្តោតការយកចិត្តទុកដាក់ទៅលើការអភិវឌ្ឍទីផ្សារសម្រាប់ផលិតផលដែលផលិតដោយផលិតកម្មក្នុងស្រុក ដែលមាននិរន្តរភាពដោយជំរុញយ៉ាងសកម្មនូវចំណាប់អារម្មណ៍ ពីវិស័យទេសចរណ៍ដែលមានអតិថិជនសំខាន់គឺភ្ញៀវទេសចរ និងម្ចាស់សណ្ឋាគារផ្ទះសំណាក់និងភោជនីយដ្ឋាន។

## ២.៣. សកម្មភាពអាទិភាព

នៅក្នុងកម្មវត្ថុទាំង ១២ និងសកម្មភាពគម្រោងទាំង ៩៨ ដែលបានរៀបរាប់នៅផ្នែកទី ១ ខាងលើ មានគម្រោងចំនួន ១០ខាងក្រោមនេះគឺជាអាទិភាពសម្រាប់ក្រុង៖

| ល.រ | ឈ្មោះគម្រោង | បរិយាយពីមូលហេតុដែលជាគម្រោងអាទិភាព និង អត្ថប្រយោជន៍ផ្នែកសង្គម សេដ្ឋកិច្ច និងបរិស្ថានរបស់ក្រុង |
|---|---|---|
| ១ | អភិវឌ្ឍន៍ប្រព័ន្ធប្រព្រឹត្តិកម្មទឹកកខ្វក់សម្រាប់ក្រុងកែប ក្នុងនោះរួមមានការបង្កើតប្រព័ន្ធប្រព្រឹត្តិកម្មបែបវិមជ្ឈការ (ដាច់ដោយឡែក) សម្រាប់កោះនានា នៅក្នុងក្រុងកែប | ប្រព័ន្ធនេះរួមមានទាំងប្រព័ន្ធនៅទីតាំងផ្ទាល់ និងនៅក្រៅទីតាំងផ្ទាល់ អាស្រ័យទៅលើស្ថានភាពតំបន់។ គម្រោងនេះ នឹងជួយដល់ការកាត់បន្ថយនូវ បរិមាណទឹកកខ្វក់ចូលទៅក្នុងសមុទ្រ ឆ្នេរ ឬប្រភពទឹកធម្មជាតិ។ |
| ២ | កសាងហេដ្ឋារចនាសម្ព័ន្ធ និងអភិវឌ្ឍន៍ទីលានចាក់សំរាមស្របតាមស្តង់ដារបច្ចេកទេសអនាម័យ លើផ្ទៃដីទំហំសរុបប្រមាណ ១៤ ហិកតា ស្ថិតនៅ ភូមិដំណាក់ចង្អើរ សង្កាត់ព្រៃធំ។ ការលើកកម្ពស់គោលការណ៍ ៣R និងពង្រឹងការប្រមូល និងដឹកជញ្ជូន | កាត់បន្ថយបរិមាណក្នុងក្រុង និងនៅតាមទីសាធារណៈ និងកាត់បន្ថយផលប៉ះពាល់អវិជ្ជមានលើបរិស្ថាន ឆ្នេរនិងទឹកសមុទ្រ ខ្យល់ ទឹក ដី និងធនធានធម្មជាតិ។ លើកកម្ពស់សោភ័ណភាពក្រុងកែប ទាក់ទាញទេសចរណ៍បន្ថែម លើកកម្ពស់ សុខុមាលភាពប្រជាជន និងភ្ញៀវទេសចរ។ |

| | | |
|---|---|---|
| ៣ | លើកកម្ពស់ការយល់ដឹងសាធារណៈ ស្តីពីការគ្រប់គ្រងសំរាម (ជាពិសេសការកាត់បន្ថយសំរាម) ទឹកកខ្វក់ និងអនាម័យ និងការគាំពារបរិស្ថាន នៅតតាមផ្ទះ ប្រជាពលរដ្ឋ ផ្ទះសំណាក់ សណ្ឋាគារ ហាងអាជីវកម្ម ។ល។ | កាត់បន្ថយបរិមាណសំរាម និងនៅតាមទីសាធារណៈ និងកាត់បន្ថយផលប៉ះពាល់អវិជ្ជមានលើបរិស្ថាន។ លើកកម្ពស់សោភ័ណភាពក្រុងកែប ទាក់ទាញទេសចរណ៍បន្ថែម លើកកម្ពស់សុខុមាលភាពប្រជាជន និងភ្ញៀវទេសចរ។ |
| ៤ | រៀបចំបង្កើតសហគមន៍នេសាទ (ព្រៃកោងកាង) ជាតំបន់ទេសចរណ៍ បែបធម្មជាតិ | បង្កើនភ្ញៀវទេសចរតាមបែបធម្មជាតិ បង្កើនមុខរបរ ការងារ និងចំណូលដល់សហគមន៍ព្រៃកោងកាង ដែលវានឹងជួយដល់ការរក្សានូវធនធានព្រៃកោងកាងរបស់ក្រុងកែប។ |
| ៥ | ស្តាទំនប់ និងរៀបចំនូវស្ថានីយ៍ស្តុកទឹក ២ កន្លែងនៅអូក្រសោម និងកំពង់ត្រាច | បង្កើតការងារក្នុងតំបន់ និងបង្កើនទិន្នផលកសិកម្ម។ |
| ៦ | សិក្សាពីលទ្ធភាព និងបង្កើតប្រភពថាមពលកកើតឡើងវិញ ដូចជាការបង្កើតសួនបន្ទះស្រូបថាមពលពន្លឺព្រះអាទិត្យ ថាមពលដើរដោយកម្លាំងខ្យល់ ជាដើម។ល។ | កំណត់ពីសក្តានុពលរបស់ក្រុងក្នុងការលើកកម្ពស់ការផលិត និងប្រើប្រាស់ថាមពលកកើតឡើងវិញ ដូចជាការស្វែងរកឱកាសវិនិយោគនៅក្នុងការបង្កើតសួនបន្ទះស្រូបថាមពលពន្លឺព្រះអាទិត្យ។ វានឹងជួយដល់ការផ្គត់ផ្គង់ថាមពលដល់ក្រុងបានគ្រប់គ្រាន់ បង្កើតការងារក្នុងវិស័យនេះ។ |
| ៧ | បង្ហាញពីការប្រើប្រាស់នូវមធ្យោបាយដឹកជញ្ជូនបៃតងតាមផ្លូវគោក ផ្លូវសមុទ្រ ដូចជាការប្រើប្រាស់នូវរ៉ឺម៉កកង់បីដើរដោយ អគ្គិសនី រថយន្ត ឬទូកដឹកជញ្ជូនសាធារណៈ និងការកែលម្អខ្សែអក្សផ្លូវសម្រាប់អ្នកជិះកង់ និងសម្រាប់អ្នកថ្មើរជើង | បង្កើនសេដ្ឋកិច្ចក្នុងតំបន់ និងការងារបៃតង។ គម្រោងនេះនឹងជួយធានានិរន្តរភាពបរិស្ថានក្រុងកែប។ |
| ៨ | ផ្សព្វផ្សាយ និងលើកកម្ពស់វិស័យទេសចរណ៍ប្រកបដោយចីរភាព តាមរយៈយន្តការពិភាក្សាជាមួយវិស័យឯកជន និងសង្គមស៊ីវិល | ពង្រឹងវិស័យឧស្សាហកម្មទេសចរណ៍ ក្នុងការផ្តោតទៅលើទេសចរណ៍ប្រកបដោយចីរភាពបរិស្ថាន។ |
| ៩ | លើកកម្ពស់ និងផ្សព្វផ្សាយទីផ្សារពីផលិតផលក្នុងស្រុក ដូចជាម្ហូបអាហារសមុទ្រ ផ្លែឈើ ម្រេច និងអំបិល | បង្កើនអាជីវកម្មក្នុងស្រុក និងពង្រឹងទីផ្សារសម្រាប់ផលិតផលក្នុងស្រុក ដែលក្រុងកែបមានសក្តានុពលប្រកួតប្រជែងទៅលើផលិតផលគ្រឿងសមុទ្រ ផ្លែឈើ ម្រេច អំបិល។ |
| ១០ | ពង្រឹងការផ្គត់ផ្គង់ទឹកស្អាតក្នុងក្រុង | ដោះស្រាយបញ្ហាខ្វះទឹកស្អាតប្រើប្រាស់ ជាពិសេសនៅរដូវប្រាំង។ |

*ប្រភព៖ ការប្រឹក្សាយោបល់ជាមួយរដ្ឋបាលក្រុងកែប*

## ២.៤. ព័ត៌មានអំពីស្ថិតិសេដ្ឋកិច្ច-សង្គម

| សន្ទស្សន៍ | ឆ្នាំ២០១៦ |
|---|---|
| ចំនួនប្រជាជន (នាក់) | ១៩.៥៥៣ |
| ដង់ស៊ីតេប្រជាជន (នាក់/គ.ម២) | ២៥៥,៨៩ |
| អត្រាភាពក្រីក្រ (បទបង្ហាញពីសិក្ខាសាលា) (ភាគរយ) | ១១,១% |
| ផ្ទៃក្រឡា (គ.ម២) | ៧៦,៤១ |
| អត្រាអ្នកចេះអក្សរ (បទបង្ហាញពីសិក្ខាសាលា) (ភាគរយ) | ៩៧,៦% |
| វិស័យសេដ្ឋកិច្ចសំខាន់ៗ | ទេសចរណ៍ |
| បំណែងចែកការងារតាមវិស័យផ្សេងៗ (ភាគរយ) | |
| - កសិកម្ម | ៩៤,៩% |
| - ផលិតកម្ម | ០% |
| - សេវាកម្ម | ៥,១% |
| ចំណាកស្រុក (ទៅក្រៅបរទេស) (នាក់) | ៣៣៣ |
| មធ្យមភាគទោចក្រយានយន្តក្នុងផ្ទះ (គ្រឿង) | ០,៧ |
| ចំនួនប្រជាជនដែលជាប់បំណុល(ធនាគារ ឬមីក្រូហិរញ្ញវត្ថុ) (នាក់) | ២.៣៩០ |
| ចំនួនផ្ទះនៅសំណង់អនាធិបតេយ្យ/លំនៅឋានខុសច្បាប់ (ខ្នងផ្ទះ) | ១៤ |
| ចំនួនផ្ទះដែលទទួលឥទ្ធិពលពីខ្យល់ព្យុះ (ខ្នងផ្ទះ) | ៣៨ |
| ចំនួនផ្ទះដែលទទួលឥទ្ធិពលពីទឹកជំនន់ (ខ្នងផ្ទះ) | ៩ |
| ចំនួនផ្ទះដែលទទួលឥទ្ធិពលពីភាពរាំងស្ងួត (ខ្នងផ្ទះ) | ៣៧ |
| ភាគរយផ្ទះដែលសេវាកម្មប្រមូលសំរាមអាចចូលទៅដល់ (ភាគរយ) | ៣១% |
| ភាគរយផ្ទះដែលមានលទ្ធភាពទទួលបានសេវាអនាម័យ (ភាគរយ) | ៣៩,៣៩% |
| ភាគរយផ្ទះដែលមានប្រព័ន្ធទឹកតាមបំពង់ទុយោ (ភាគរយ) | ០% |
| ភាគរយផ្ទះដែលមានភ្លើងប្រើប្រាស់ (ភាគរយ) | ៤១,១% |
| ចំនួនសំរាមក្នុងមួយថ្ងៃ (តោន) | ៣៤តោន |



ក្រុងកែប



ក្រុងកំពង់ចាម

# ក្រុងកំពង់ចាម

## ២.១. សេចក្តីផ្តើម

ក្រុងកំពង់ចាមជាក្រុងដែលមានប្រជាជនចំនួនប្រមាណ ៥០.០០០ នាក់រស់នៅលើផ្ទៃដី ២២ គ.ម² ដែលធ្វើឱ្យក្រុងនេះ ក្លាយជាក្រុងមួយដែលមានដង់ស៊ីតេចំនួនប្រជាជនខ្ពស់ជាងគេបំផុតមួយក្នុងប្រទេសកម្ពុជា (ស្ថិតិសេដ្ឋកិច្ចសង្គមរបស់ក្រុងកំពង់ចាម)។[៩៧] ក្រុងកំពង់ចាមជាក្រុងដែលមានគុណសម្បត្តិពិសេសមួយ ដោយមានទីតាំងនៅជិតរាជធានីភ្នំពេញចំងាយប្រហែល ១២៥ គ.ម ហើយមានស្ពានគីហ្សូណាដែលសាងសង់ឡើងឆ្លងកាត់ទន្លេមេគង្គបានបើកឱ្យប្រើប្រាស់ក្នុងឆ្នាំ ២០០១ និងជាលើកដំបូងដែលបានតភ្ជាប់ពីទិសបូព៌ាទៅទិសបស្ចិមប្រទេសកម្ពុជា។ ស្ពាននេះសាងសង់អស់រយៈពេល ៣ ឆ្នាំក្រោមជំនួយរបស់រាជរដ្ឋាភិបាលជប៉ុន។

ស្ពានគីហ្សូណាបង្កើតជាចំណាប់អារម្មណ៍នៃការអភិវឌ្ឍត្រើយទន្លេ ដែលមានទិសដៅដើម្បីបង្កើនចំនូលឱ្យក្រុងកំពង់ចាមយ៉ាងច្រើន។ ក្រុងដ៏បវរមួយនេះ ផ្តល់ឱ្យមាននូវសមាសភាគទេសចរណ៍បែបធម្មជាតិ និងវប្បធម៌ដែលចង្អុលបង្ហាញពីលក្ខណៈភាគច្រើននៃប្រទេសកម្ពុជា ប៉ុន្តែក៏មានកន្លែងពិសេសទាក់ទាញផងដែរ ដូចជានៅតំបន់កោះប៉ែនដែលជាកោះដាច់ស្រយាលដ៏ស្រស់ស្អាតមួយ នៅចំពាក់កណ្តាលទន្លេមេគង្គដែលត្រូវតភ្ជាប់ពីដីគោកដោយស្ពានថ្មីមួយដែលកំពុងសាងសង់។

តារាង៖ ស្ថិតិប្រជាសាស្ត្រសំខាន់ៗ ក្រុងកំពង់ចាម (ស្ថិតិសេដ្ឋកិច្ចសង្គមនៃក្រុងកំពង់ចាមឆ្នាំ២០១៧)

| ស្ថិតិប្រជាសាស្ត្រ | ២០១៥ | ២០១៦ | ២០១៧ |
|---|---|---|---|
| ចំនួនប្រជាជន (នាក់) | ៤០.៤១៩ | ៤០.៩២៥ | ៤៨.៧៨១ |
| អត្រាកំណើនប្រចាំឆ្នាំ (គិតជាភាគរយ) | N/A | ១,៣ | ៨,០ |
| ចំនួនស្ត្រី (នាក់) | N/A | N/A | ២៤.៧២៥ |
| សមាមាត្រស្ត្រីធៀបនឹងបុរស (ក្នុងចំណោមបុរស១០០នាក់) | ១០០,៦ | ៩៩,០ | -- |
| ចំនួនគ្រួសារ (គ្រួសារ) | ៨.៨៤៨ | ៩.០៥០ | ៩.២៣៤ |
| ទំហំគ្រួសារជាមធ្យម (នាក់) | ៤,៥ | ៤,៥ | -- |

## ២.២. ការវិភាគតាមវិស័យ សម្រាប់ការអភិវឌ្ឍទីក្រុងនិរន្តរភាព

### ទេសចរណ៍

ក្រុងកំពង់ចាម មានសក្តានុពលសម្រាប់វិស័យទេសចរណ៍ ប្រកបដោយចីរភាពដែលអាចអភិវឌ្ឍបន្ថែមទៀត នៅក្នុងទស្សនៈនៃការអភិវឌ្ឍទីក្រុងនិរន្តរភាព និងអាចក្លាយទៅជាសសរស្តម្ភមួយទៀតនៅក្នុងការអភិវឌ្ឍសេដ្ឋកិច្ចបៃតង។ មានរមណីយដ្ឋានធម្មជាតិ និងប្រវត្តិសាស្ត្រជាច្រើននៅក្នុង និងនៅជុំវិញទីក្រុងនេះ ដោយរួមបញ្ចូលទាំងសំណង់អគារកេរដំណែលជាច្រើន វត្តនគរបាជ័យ និងស្ពានឫស្សី ។ ទន្លេមេគង្គផ្តល់នូវឱកាសជាច្រើនខាងវិស័យទេសចរណ៍ដែលពឹងផ្អែកលើទឹកទន្លេ ដូចជា នាវាកម្សាន្ត ឬកីឡាលើផ្ទៃទឹក

[៩៧] Socio-economic statistics 2017 for Kampong Cham

ជាច្រើន។ កោះប៉ែនដែលស្ថិតនៅកណ្តាលទន្លេមេគង្គ មានឆ្នេរកម្សាន្តមួយហើយមានសក្តានុពលល្អខាងវិស័យទេសចរណ៍ធម្មជាតិ ហើយកោះប៉ែននឹងត្រូវតភ្ជាប់ទៅដីគោកដោយស្ពានបេតុងថ្មីមួយក្នុងពេលឆាប់ៗនេះ។ ក្រុងកំពង់ចាម មានសណ្ឋាគារ ផ្ទះសំណាក់ និងភោជនីយដ្ឋានជាច្រើន ឧទ្យានប្រហែល៦០កន្លែង និងផ្លូវថ្នល់ល្អ និងមានសុវត្ថិភាពជាច្រើន។

ក្រុងមួយនេះ នឹងមានការប្រឈមមួយចំនួនក្នុងការអភិវឌ្ឍសក្តានុពលវិស័យទេសចរណ៍របស់ខ្លួន។ ហេដ្ឋារចនាសម្ព័ន្ធទូទៅ និងកម្រិតសេវាកម្មសម្រាប់ភ្ញៀវទេសចរណ៍នៅមានកម្រិតទាប (ឧទាហរណ៍ ភាពកង្វះនូវភ្នាក់ងារទេសចរណ និងមានតែមណ្ឌលព័ត៌មានមួយគត់) ដែលធ្វើឱ្យភ្ញៀវទេសចរណគ្រាន់តែស្នាក់នៅតែរយៈពេលខ្លីប៉ុណ្ណោះ។ សំណង់អគារកេរដំណែល និងកន្លែងទេសចរណ៍ជាច្រើនមិនត្រូវបានថែទាំល្អ ហើយការគ្រប់គ្រងសំណល់រឹង និងរាវ (ទឹកកខ្វក់) មិនមានភាពល្អប្រសើរឡើយ (ធ្វើឱ្យទីក្រុងនេះមានភាពទាក់ទាញតិចតួច)។ កំពង់ផែទន្លេចំនួនពីរនៅក្រុងកំពង់ចាមនៅមានភាពអន់ថយ ហើយមិនគោរពតាមស្តង់ដារបច្ចេកទេសទេ។ មានរមណីយដ្ឋានមួយចំនួនដែលមានភាពទាក់ទាញ តែទីតាំងនៅឆ្ងាយ និងមានស្ថានភាពពិបាកមិនងាយមានភ្ញៀវទេសចរទៅដល់។ ក្រុងកំពង់ចាម ក៏មានហានិភ័យពីទឹកជំនន់ទន្លេមេគង្គ និងមានភ្លៀងធ្លាក់ខ្លាំង ដែលជាការគំរាមមួយចំពោះហេដ្ឋារចនាសម្ព័ន្ធវិស័យទេសចរណ៍។

ឆ្លើយតបនឹងបញ្ហាប្រឈមទាំងនេះ ក្រុងកំពង់ចាមមានបំណងដាក់ចេញនូវគំនិតផ្តួចផ្តើមដើម្បីថែរក្សា និងធ្វើនីតិសម្បទានឧទ្យានសាធារណៈ និងរមណីយដ្ឋានប្រវត្តិសាស្ត្រជាច្រើនឡើងវិញ ហើយនឹងថែរក្សាស្ពានឫស្សីដែលមានភាពទាក់ទាញពីសំណាក់ភ្ញៀវទេសចរជាតិ និងអន្តរជាតិជាច្រើន។ ក្រុងក៏នឹងធ្វើឱ្យប្រសើរឡើងនូវកំពង់ផែទាំងពីរ អភិវឌ្ឍន៍តំបន់មាត់ទន្លេ ហើយជំរុញលើកទឹកចិត្តឱ្យម្ចាស់អាជីវកម្មសណ្ឋាគារឱ្យគោរពតាមស្តង់ដារជាតិ និងអន្តរជាតិទាំងឡាយ។ ក្រុងនេះក៏មើលឃើញនូវតម្រូវការដើម្បីផ្សព្វផ្សាយព័ត៌មានអំពីក្រុងទៅកាន់ភ្នាក់ងារទេសចរណ៍ និងដើម្បីអភិវឌ្ឍសមត្ថភាពបុគ្គលិកបដិសណ្ឋារកិច្ច និងអ្នកផ្តល់សេវាកម្មទាំងឡាយ និងបន្តកសាងកេរ្តិ៍ឈ្មោះក្រុងនេះ ជាក្រុងនិរន្តរភាព និងជាទិសដៅទេសចរណ៍មួយ។

មានជម្រើសជាច្រើន ក្នុងការអនុវត្តទស្សនទាននៃការអភិវឌ្ឍបៃតង ដើម្បីពង្រឹងបន្ថែមនូវការអភិវឌ្ឍ វិស័យទេសចរណ៍ដែលជាវិស័យអាទិភាពចម្បងមួយរបស់ក្រុងកំពង់ចាម។ ក្រៅពីការធ្វើឱ្យប្រសើរឡើងក្នុងការគ្រប់គ្រងសំណល់រឹង និងរាវដែលអាចធ្វើឱ្យទីក្រុងនេះកាន់តែមានភាពទាក់ទាញ មធ្យោបាយធ្វើដំណើរបៃតងក៏គួរធ្វើឱ្យប្រសើរឡើងផងដែរ (ឧទាហរណ៍ ផ្លូវសម្រាប់អ្នកជិះកង់ និងតំបន់ថ្មើរជើងទាំងឡាយ) ជំរុញការប្រើប្រាស់យានយន្តអគ្គិសនី (សម្រាប់រ៉ឺម៉កកង់បី ឡាន និងឡានក្រុង) នៅក្នុងទីក្រុងនិងរមណីយដ្ឋានឆ្ងាយៗមួយចំនួន។ ការថែទាំសំណង់អគារកេរដំណែលបេតិកភណ្ឌទាំងឡាយ ដោយផ្អែកលើគោលការណ៍បៃតងដូចជាប្រសិទ្ធភាពធនធាន និងការបង្កើតកន្លែងរមណីយដ្ឋានថ្មីៗលើភ្នំ នៅតាមដងទន្លេ និងតាមកោះទាំងឡាយ ដែលគួរតែត្រូវបានរៀបចំដោយគិតទុកជាមុនពីវិធានការនៃការទប់ទល់ជាមួយបញ្ហាទឹកជន់ដែលអាចកើតមាន ហើយជាមួយនឹងការប្រើប្រាស់ប្រសិទ្ធភាពនៃថាមពល និងធនធានទឹក ការកែច្នៃសំរាម ការប្រើប្រាស់ថាមពលកកើតឡើងវិញ និង អគារបៃតងជាដើម។

ដោយមើលឃើញថាវិស័យទេសចរណ៍ក្នុងក្រុងកំពង់ចាម គឺស្ថិតនៅដំណាក់កាលដំបូងនៃការអភិវឌ្ឍ នៅឡើយ អ្វីដែលត្រូវធ្វើ ដោយមានកិច្ចសហការជាមួយនឹងភាគីពាក់ព័ន្ធក្នុងវិស័យទេសចរណ៍ គឺការបង្កើតក្របខ័ណ្ឌមួយសម្រាប់ការអភិវឌ្ឍបៃតងនៅក្នុងវិស័យទេសចរណ៍ ដែលអាចជាផ្នែកមួយនៃផែនការអភិវឌ្ឍរួមរបស់ក្រុង (ផែនការមេ) ដើម្បីធានាថាការវិនិយោគក្នុងក្រុងនាពេលអនាគត នឹងរួមចំណែកដល់ទិសដៅអភិវឌ្ឍន៍។ បន្ថែមទៅលើការធ្វើឱ្យបន្សុីគ្នានៃផែនការអភិវឌ្ឍក្រុង ក្របខ័ណ្ឌនេះនឹងអាចធ្វើឱ្យវិស័យទេសចរណ៍កាន់តែមានភាពទាក់ទាញចំពោះដៃគូអភិវឌ្ឍន៍ និងអ្នកវិនិយោគទុនជាតិ និងអន្តរជាតិផងដែរ។

## ឧស្សាហកម្ម និងពាណិជ្ជកម្មបៃតង

ក្រុងកំពង់ចាម ក៏ជាក្រុងពាណិជ្ជកម្មមួយសម្រាប់ខេត្តទាំងមូលផងដែរ ដោយស្ថិតនៅមិនឆ្ងាយពីរាជធានីភ្នំពេញ (ចំណាយពេលប្រមាណ ២,៥ ម៉ោងធ្វើដំណើរដោយរថយន្ត) និងមានព្រំប្រទល់ជាប់ជាមួយប្រទេស វៀតណាម (ចំណាយពេលប្រមាណ ១,៥ ម៉ោងធ្វើដំណើរដោយរថយន្ត) ហើយក៏ជាក្រុងដែលមានឱកាសនៃការធ្វើឱ្យមានប្រព័ន្ធដឹកជញ្ជូន ភ្ជាប់ទំនាក់ទំនងតាមផ្លូវទឹក និងផ្លូវគោក

ឧទាហរណ៍សម្រាប់ការដឹកជញ្ជូនទំនិញ ដែលជាឱកាសសម្រាប់អាជីវកម្មទាំងខ្នាតតូច និងធំ នៅក្នុងក្រុងកំពង់ចាម។ សក្តានុពលផ្សេងៗទៀតរបស់ក្រុងកំពង់ចាម គឺការមានទីផ្សារស្រាប់សម្រាប់ពាណិជ្ជកម្ម មានសល់ដីទំនេរសម្រាប់ការអភិវឌ្ឍបន្ថែមទៀត មានបរិយាកាសច្បាប់ និងបទប្បញ្ញត្តិអំណោយផល មានសណ្ឋាគារ និងភោជនីយដ្ឋាន ហើយក្រុងកំពង់ចាម ក៏ជាក្រុងមួយដែលមានសុវត្ថិភាពល្អផងដែរ។

ដោយខេត្តកំពង់ចាម ក៏ជាខេត្តកសិកម្មមួយយ៉ាងធំ ដូច្នេះវាផ្តល់នូវសក្តានុពលល្អដល់ក្រុងកំពង់ចាម ដើម្បីពង្រីកតួនាទីជាទីផ្សារបោះដុំលើផលិតផលស្រស់ៗដូចជា ពោត ដំឡូងមី គ្រាប់ស្វាយចន្ទី ផ្លែស្វាយ និងចេក ហើយក៏មានសក្តានុពលក្លាយជាមណ្ឌលឧស្សាហកម្ម (កសិឧស្សាហកម្ម) ទាំងតូច ទាំងធំ មួយផងដែរសម្រាប់ការផលិត និងលក់នូវផលិតផលកសិកម្មជាច្រើនសម្រាប់ទីផ្សារជាតិ និងអន្តរជាតិ ដូចជាទីផ្សារប្រទេសវៀតណាម។

មានកត្តាប្រឈមជាច្រើនដែលត្រូវការដោះស្រាយ ដើម្បីអភិវឌ្ឍន៍បន្ថែមនូវសក្តានុពលវិស័យផលិតកម្ម និងពាណិជ្ជកម្ម។ កម្រិតនៃផលិតភាពពីការវិនិយោគ គឺនៅមានកម្រិតទាប ហើយផលិតផលជាច្រើន មិនទាន់មានស្តង់ដារទាំងថ្នាក់ជាតិ និងអន្តរជាតិនៅឡើយ។ បន្ថែមពីលើនេះ គឺប្រព័ន្ធលូទឹក (ទឹកកខ្វក់ និងទឹកភ្លៀង)នៅមានកម្រិតគុណភាពទាប ហើយងាយទទួលរងគ្រោះខ្ពស់ពីផលប៉ះពាល់នៃការប្រែប្រួលអាកាសធាតុ ដូចជា ទឹកជន់ពីការធ្លាក់ភ្លៀងខ្លាំង និងពីទន្លេមេគង្គ ហើយនិងការសឹករិចរិលនៃច្រាំងទន្លេជាដើម។

ដើម្បីឆ្លើយតបទៅនឹងកង្វះខាតការវិនិយោគ ក្រុងមានគម្រោងក្នុងការទាក់ទាញការវិនិយោគបន្ថែម និងចូលរួមក្នុងការអភិវឌ្ឍក្រុងបៃតង។ ក្នុងចំណោមគម្រោងការថ្មីៗទាំងនោះរួមមានការបង្កើតតំបន់សេដ្ឋកិច្ចពិសេស (SEZs) សម្រាប់ការវិនិយោគក្នុងវិស័យឧស្សាហកម្មទាំងខ្នាតតូច និងខ្នាតធំ ប្រសិនបើអនុវត្តន៍ទៅតាមកម្រិតស្តង់ដារបរិស្ថាន និងសង្គម។

## សំណល់រឹង (សំរាម)

ដូចគ្នាទៅនឹងបណ្តាក្រុងដទៃទៀតដែរ មានកិច្ចការជាច្រើនដែលត្រូវធ្វើដើម្បីធ្វើការកែលម្អការគ្រប់គ្រងសំណល់រឹងប្រកបដោយចីរភាព។ នៅក្រុងកំពង់ចាម មានតែ ៥៦% នៃផ្ទះប្រជាពលរដ្ឋក្នុងក្រុង មានលទ្ធភាពទទួលបានសេវាប្រមូលសំរាម ប៉ុន្តែការកែច្នៃសំរាមនៅមានកម្រិតនៅឡើយ។ កម្រៃសេវាកម្មប្រមូលសំរាមថ្លៃ ហើយយឺតយ៉ាវ កង្វះឡានដឹកសំរាម និងកន្លែងចាក់សំរាមដែលមាននៅក្រៅទីក្រុងចំងាយ ២៥ គ.ម។ ការវិនិយោគទៅលើវិស័យនេះ គឺមិនមានភាពទាក់ទាញ និងគ្មានការប្រកួតប្រជែងណាមួយក្នុងចំណោមក្រុមហ៊ុនផ្តល់សេវាកម្មដទៃទៀត។ លើសពីនេះទៅទៀត ការយល់ដឹងរបស់ប្រជាជននៅមានកម្រិតទាប កង្វះការចូលរួមពីសាធារណៈជន ហើយជាទូទៅ ប្រជាជនមិនដឹងអំពីរបៀបទុកដាក់សំណល់។

ជាការឆ្លើយតបទៅនឹងបញ្ហានេះ សាលាក្រុងមានគម្រោងការផ្តួចផ្តើមមួយចំនួនដើម្បីលើកកម្ពស់ការរៀបចំគ្រប់គ្រងសំណល់រឹង និងការកែច្នៃឡើងវិញ។ ទាំងនេះរួមបញ្ចូល ការបង្កើនការយល់ដឹងជាសាធារណៈអំពី អនាម័យ ការបែងចែកសំរាម ឬការកែច្នៃសំរាមឡើងវិញ ការទុកដាក់សំរាមត្រឹមត្រូវ និងសេវាកម្មចាក់សំរាម ហើយនឹងការបំពាក់នូវធុងសំរាមតាមសាលារៀន និងទីសាធារណៈទាំងឡាយ។ សាលាក្រុងក៏ចង់ពង្រីកការប្រមូលសំរាមហើយធ្វើឱ្យវាកាន់តែមានប្រសិទ្ធភាព និងអនុវត្តការបែងចែកប្រភេទសំរាម និងការកែច្នៃ សំរាមឡើងវិញ ហើយក៏ចង់កំណត់ទីតាំងចាក់សំរាមដែលស្ថិតក្នុងរយៈចំងាយសមស្របមួយពីតំបន់ធ្វើជំនួញនិងផ្ទះសំបែងប្រជាជន។ ជាចុងក្រោយ សាលាក្រុងចង់បង្កើតបរិយាកាសវិនិយោគល្អប្រសើរមួយដែលអនុញ្ញាតឱ្យក្រុមហ៊ុនប្រមូលសំរាមអាចធ្វើការប្រកួតប្រជែងត្រឹមត្រូវក្នុងចំណោមក្រុមហ៊ុនប្រមូលសំរាមដទៃទៀត។

ការអនុវត្តការផ្តួចផ្តើមបែបនេះ ផ្តល់ការចូលរួមយ៉ាងមានសារៈសំខាន់ដែលសមស្របទៅនឹងផែនការ ការអភិវឌ្ឍទីក្រុងនិរន្តរភាព ហើយនឹងធ្វើឱ្យជីវភាពប្រជាជនប្រសើរឡើងនិងធ្វើឱ្យទីក្រុងកាន់តែមានភាពទាក់ទាញអ្នកវិនិយោគ និងភ្ញៀវទេសចរណ៍។ ដោយចេញពីទស្សនៈអភិវឌ្ឍន៍បៃតង ការបំណែងចែកនិងការកែច្នៃសំរាមឡើងវិញអាចទាក់ទាញឱកាសជំនួញជាច្រើនសម្រាប់សហគ្រាសធុនតូច និងមធ្យមក្នុងស្រុក ឬសម្រាប់ក្រុមហ៊ុនប្រមូលសំរាមជាដើម។ ការបង្កើតនូវដីទំនេរថ្មីមួយ សម្រាប់ចាក់សំរាមអនាម័យ ហើយការប្រើប្រាស់សំរាមនៅកន្លែងចាក់សំរាមដើម្បីផលិតថាមពល (ឧទាហរណ៍ ឧស្ម័នកន្លែងចាក់សំរាម រឺការដុតសំរាម) អាចធ្វើឱ្យបរិស្ថានប្រសើរឡើង និងជំរុញល្បឿនសេដ្ឋកិច្ចដល់ក្រុមហ៊ុនប្រមូលសំរាមជាច្រើនដោយការបង្កើតលំហូរចំណូលបន្ថែមទៀត ដូច្នេះហើយធ្វើឱ្យមុខជំនួញក្នុងវិស័យនេះកាន់តែមានភាពទាក់ទាញបន្ថែមទៀត។

## សំណល់រាវ (ទឹកកខ្វក់)

បច្ចុប្បន្ននេះប្រព័ន្ធលូទឹកកខ្វក់ក្នុងក្រុងកំពង់ចាម អាចគ្របដណ្តប់បានប្រមាណត្រឹមតែ ៥៣% នៃគ្រួសារសរុបក្នុងក្រុងប៉ុណ្ណោះ។ ក្រុងនៅមិនទាន់មានអាងប្រព្រឹត្តិកម្មទឹកកខ្វក់នៅឡើយទេ ហើយទឹកកខ្វក់គឺត្រូវបង្ហូរចូលក្នុងទន្លេមេគង្គដែលនឹងធ្វើឱ្យខូចគុណភាពទឹក នឹងធ្វើឱ្យសក្តានុពលទេសចរណ៍ធ្លាក់ចុះ។ ប្រព័ន្ធលូទឹកកខ្វក់ដែលបានសាងសង់នាសម័យកាលអាណានិគមនិយម មិនបានបែងចែកប្រព័ន្ធលូសម្រាប់ ទឹកភ្លៀង និងទឹកកខ្វក់នោះទេ ហើយត្រូវស្រុតបាក់បន្តិចម្តងៗ ហើយបង្កជាការកកស្ទះលូ។ ម្ចាស់សណ្ឋាគារ និងម្ចាស់អាជីវកម្មមិនមានអាងស្តុកទឹកកខ្វក់ទេ (Septic Tank)។ បញ្ហានេះ តម្រូវឱ្យមានការវិនិយោគលើហេដ្ឋារចនាសម្ព័ន្ធក្នុងវិស័យទឹកកខ្វក់នេះ ប៉ុន្តែពេលបច្ចុប្បន្នក្រុងកំពង់ចាមប្រឈមនឹងកង្វះថវិកាសាធារណៈ និងដៃគូ វិនិយោគទុន។

គោលដៅរួមរបស់ក្រុងកំពង់ចាម គឺកៀរគរការវិនិយោគទុនពីវិស័យសាធារណៈ និងឯកជន និងដៃគូអភិវឌ្ឍន៍ជាដើម។ល។ សម្រាប់ប្រព័ន្ធលូថ្មីមួយ ដែលជាប្រព័ន្ធលូដាច់ដោយឡែកសម្រាប់ទឹកកខ្វក់ និងទឹកភ្លៀងហើយនិងអាងប្រព្រឹត្តិកម្មទឹកកខ្វក់។ បន្ថែមលើនេះ រដ្ឋបាលក្រុងក៏មានបំណងបង្កើនការយល់ដឹងសាធារណៈតាមគ្រួសារ ម្ចាស់ជំនួញ និងស្ថាប័នសាធារណៈ ឬឯកជន លើការគ្រប់គ្រងទឹកកខ្វក់ឱ្យបានប្រសើរឡើង ហើយជំរុញលើកទឹកចិត្តម្ចាស់អាជីវកម្មសហគ្រាស និងផ្ទះប្រជាពលរដ្ឋ ក្នុងការសាងសង់លូស្តុក និងចម្រោះទឹកកខ្វក់បឋមនៅតាមទីតាំងរបស់ខ្លួន (ឧទាហរណ៍ លូស្តុក និងចម្រោះទឹកកខ្វក់ លូសិបទិច) មុននឹងចាក់បង្ហូរទៅក្នុងប្រព័ន្ធលូរួម។

ការមានប្រព័ន្ធអាងប្រព្រឹត្តិកម្មទឹកកខ្វក់ស្តង់ដារ និងមានមុខងារពេញលេញមួយ គឺជាធាតុសំខាន់ក្នុងការអភិវឌ្ឍទីក្រុងនិរន្តរភាព ហើយនឹងអាចចូលរួមចំណែកដល់ការលើកកម្ពស់សុខុមាលភាពល្អប្រសើរ បរិស្ថានស្អាតជាងមុន ព្រមទាំងធ្វើឱ្យទីក្រុងកាន់តែមានភាពទាក់ទាញ។ ផ្អែកលើទស្សនទានអភិវឌ្ឍន៍បៃតង ការច្រោះយកចេញនូវកាកដីពីប្រព័ន្ធប្រព្រឹត្តិកម្មទឹកកខ្វក់ អាចជាប្រភពធនធានប្រើប្រាស់មួយផងដែរ ឧទាហរណ៍ប្រើប្រាស់សម្រាប់បង្កើនគុណភាពដី ឬផលិតជាជីវឧស្ម័នត្រជាក់ បានបន្ថែមនូវគុណតម្លៃគួរឱ្យកត់សម្គាល់។ ការដាក់បញ្ចូលការស្តារប្រព័ន្ធលូទឹកកខ្វក់ទៅក្នុងបរិបទនៃការអភិវឌ្ឍទីក្រុងនិរន្តរភាព នឹងអាចធ្វើឱ្យក្រុងកាន់តែទាក់ទាញជាងមុន។

## ការហូរច្រោះដីពីទន្លេមេគង្គ

ក្រុងកំពង់ចាម ទទួលរងឥទ្ធិពលយ៉ាងខ្លាំងពីទឹកជន់ទន្លេមេគង្គរាល់ឆ្នាំដែលធ្វើឱ្យទឹកជន់លិច និងសំណឹកដីច្រាំងទន្លេធ្ងន់ធ្ងរ ហើយធ្វើឱ្យខូចខាតផ្លូវថ្នល់ជាចម្បង និងហេដ្ឋារចនាសម្ព័ន្ធតាមដងទន្លេ។ ក្រុងកំពង់ចាមប្រឈមនឹងភាពងាយទទួលរងគ្រោះថ្នាក់នៅត្រង់កន្លែងដែលទឹកទន្លេហូរត្រឡប់ និងប្រឈមនឹងការទទួលនូវចរន្តទឹកខ្លាំងក្លាជាងគេ។ កន្លែងដែលគួរយកចិត្តទុកដាក់ គឺការពង្រឹង និងគ្រប់គ្រងច្រាំងទន្លេដើម្បីបន្ថយការខូចខាត។ ក្រុងកំពង់ចាមក៏ប្រឈមនឹងទឹកជំនន់ម្តងម្កាលដោយសារភ្លៀងធ្លាក់ខ្លាំង និងការកើនឡើងនូវកម្រិតនីវ៉ូទឹកទន្លេមេគង្គ ថ្មីៗបំផុតក្នុងឆ្នាំ២០១៣ នេះ។

## ២.៣. សកម្មភាពអាទិភាព

| ល.រ | ឈ្មោះគម្រោង | បរិយាយពីមូលហេតុដែលជាគម្រោងអាទិភាព និងអត្ថប្រយោជន៍ផ្នែកសង្គម សេដ្ឋកិច្ច និងបរិស្ថានរបស់ក្រុង |
|---|---|---|
| ១ | ពង្រឹងប្រព័ន្ធគ្រប់គ្រងសំរាមពេល បច្ចុប្បន្ន រួមទាំងការគ្រប់គ្រងទីលានចាក់សំរាម តាមស្តង់ដារអនាម័យបរិស្ថាន និងការប្រើប្រាស់បច្ចេកវិទ្យា កែច្នៃសំរាម ( Material Recovery Facilities - MRF ) | បង្កើតទីលានចាក់សំរាមដែលសមស្របមួយ ជាមួយនិងស្ថានីយ៍កែច្នៃសំរាម។ លើកកម្ពស់ការយល់ដឹងសាធារណៈអំពីការញែក និងទុកដាក់សំរាម និងពង្រឹងសេវាប្រមូល និងការដឹកជញ្ជូនសំរាមរបស់ក្រុមហ៊ុន ផ្អែកលើការប្រកួតប្រជែងទីផ្សារ។ |
| ២ | ស្តារ និងពង្រីកបណ្តាញលូក្នុងក្រុង ទាំងលូរំដោះទឹកភ្លៀង និងលូទឹកកខ្វក់ | បញ្ចៀសជំនន់ទឹកភ្លៀងក្នុងក្រុងពេលមានភ្លៀងខ្លាំង និងការពារហេដ្ឋារចនាសម្ព័ន្ធក្នុងក្រុង ដូចជាផ្លូវថ្នល់ជាដើម។ កាត់បន្ថយទឹកកខ្វក់ចូលទៅក្នុងប្រភពទឹកធម្មជាតិ។ លើកកម្ពស់សោភ័ណភាពក្រុង។ |
| ៣ | រៀបចំប្រព័ន្ធប្រព្រឹត្តិកម្មទឹកកខ្វក់ បែបវិមជ្ឈការ( ដាច់ដោយឡែក ) | បញ្ចៀសទឹកកខ្វក់ចូលទៅក្នុងប្រភពទឹកធម្មជាតិ ដូចជាប្រឡាយ បឹង ស្រះ ឬដៃទន្លេ។ លើកកម្ពស់បរិស្ថាន និងអនាម័យ ក៏ដូចជាសុខភាព និងសុខមាលភាពរបស់ប្រជាពលរដ្ឋ។ |
| ៤ | សាងសង់ប្រព័ន្ធការពារច្រាំងទន្លេ | ការពារការបាក់ច្រាំងពេលមានទឹកជំនន់ -ការពារគ្រប់ហេដ្ឋារចនាសម្ព័ន្ធនៅតាមច្រាំងទន្លេ -ការពារទ្រព្យសម្បត្តិប្រជាពលរដ្ឋក្នុងក្រុង។ |
| ៥ | ពង្រីកបណ្តាញផ្លូវក្នុងក្រុង ក្នុងនោះរួមមានខ្សែផ្លូវសម្រាប់អ្នកជិះកង់ និងសម្រាប់អ្នកថ្មើរជើង | ពង្រឹងប្រព័ន្ធដឹកជញ្ជូនសាធារណៈ កាត់បន្ថយការស្ទះចរាចរណ៍ និងជួយនូវការដឹកជញ្ជូនផលិតផលកសិកម្មពីទីជនបទមកទីប្រជុំជនក្រុង។ |
| ៦ | កែលម្អតំបន់ទាកទាញទេសចរណ៍ក្នុងក្រុង | ការថែរក្សាស្ពានឫស្សី និងកែលម្អតំបន់ទេសចរណ៍កោះប៉ែន ដើម្បីទាក់ទាញភ្ញៀវទេសចរក្នុងស្រុក និងអន្តរជាតិ។ |
| ៧ | រៀបចំប្លង់គោល និងផែនការប្រើប្រាស់ដីក្នុងក្រុង រួមមានការរៀបចំតំបន់សម្រាប់វិស័យឧស្សាហកម្ម ដូចជា តំបន់សេដ្ឋកិច្ចពិសេសបៃតង | កំណត់តំបន់ក្រុងរណប ការធ្វើផែនការ និងតំបន់ប្រើប្រាស់ដីធ្លី និងការកែលម្អបណ្តាញផ្លូវក្នុងក្រុង។ ផែនការដែលបញ្ចូលក្របខ័ណ្ឌអភិវឌ្ឍន៍ទេសចរណ៍។ |
| ៨ | ការកែលម្អការផ្គត់ផ្គង់ទឹកស្អាតក្នុងក្រុង | ពង្រឹងការប្រើប្រាស់ទឹកស្អាតប្រកបដោយប្រសិទ្ធភាព តាមរយៈការកំណត់តម្លៃប្រើប្រាស់ទឹកសមរម្យ។ គ្រប់ផ្ទះនៅក្នុងក្រុងនឹងមានទឹកស្អាតប្រើប្រាស់។ |
| ៩ | ការកែលម្អស្ថានីយ៍រថយន្តក្រុង និងចំណតរថយន្តសាធារណៈ | កាត់បន្ថយគ្រោះថ្នាក់ ក៏ដូចជាការកកស្ទះចរាចរណ៍។ ពង្រឹងគុណភាពខ្យល់ក្នុងក្រុង។ បង្កើន និងពង្រឹងទីធ្លាចតយានយន្តតាមទីសាធារណៈក្នុងតំបន់កណ្តាលក្រុង។ |
| ១០ | កែលម្អសួនច្បារទីសាធារណៈ ដែលមានលក្ខណៈពហុគោលបំណង និងស្របតាមស្តង់ដារបច្ចេកទេស | ធ្វើឱ្យក្រុងមានសោភណ្ឌភាពស្រស់បំព្រង និងមានភាពធន់ទៅនឹងការប្រែប្រួលអាកាសធាតុ លើកកម្ពស់សុខាមាលភាពប្រជាពលរដ្ឋ។ |

*ប្រភព៖ ការប្រឹក្សាយោបល់ជាមួយរដ្ឋបាលក្រុងកំពង់ចាម*

## ២.៤. ព័ត៌មានស្ថិតិសេដ្ឋកិច្ចសង្គម

| សន្ទស្សន៍ | ទិន្នន័យ (២០១៦) |
|---|---|
| ចំនួនប្រជាជន (នាក់) | ៤០.៩២៥ |
| ដង់ស៊ីតេប្រជាជន (នាក់/គ.ម២) | ១.៨៤៧,៦៣ |
| អត្រាភាពក្រីក្រ (បទបង្ហាញពីសិក្ខាសាលា) (ភាគរយ) | ១,៨% |
| ផ្ទៃក្រឡា (គ.ម២) | ២២,១៥ |
| អត្រាអ្នកចេះអក្សរ (បទបង្ហាញពីសិក្ខាសាលា) (ភាគរយ) | ៩៩,៥% |
| វិស័យសេដ្ឋកិច្ចសំខាន់ៗ | សេវាកម្ម ពាណិជ្ជកម្មនិងទេសចរណ៍ |
| បំណែងចែកការងារតាមវិស័យផ្សេងៗ (ភាគរយ) | |
| - កសិកម្ម | ១៦,១% |
| - ផលិតកម្ម | ២,៥% |
| - សេវាកម្ម | ៨១,៤% |
| ចំណាកស្រុក (ទៅក្រៅប្រទេស) (នាក់) | ៧២០ |
| មធ្យមភាគទោចក្រយានយន្តក្នុងផ្ទះ (គ្រឿង) | ១ |
| ចំនួនប្រជាជនដែលជាប់បំណុល(ធនាគារ ឬមីក្រូហិរញ្ញវត្ថុ) (នាក់) | ១.៧៣៣ |
| ចំនួនផ្ទះនៅសំណង់អនាធិបតេយ្យ/លំនៅឋានខុសច្បាប់ (ខ្នងផ្ទះ) | ៩២ |
| ចំនួនផ្ទះដែលទទួលឥទ្ធិពលពីខ្យល់ព្យុះ (ខ្នងផ្ទះ) | ១ |
| ចំនួនផ្ទះដែលទទួលឥទ្ធិពលពីទឹកជំនន់ (ខ្នងផ្ទះ) | ០ |
| ចំនួនផ្ទះដែលទទួលឥទ្ធិពលពីភាពរាំងស្ងួត (ខ្នងផ្ទះ) | ០ |
| ភាគរយផ្ទះដែលសេវាកម្មប្រមូលសំរាមអាចចូលទៅដល់ (ភាគរយ) | ៥៦% |
| ភាគរយផ្ទះដែលមានលទ្ធភាពទទួលបានសេវាអនាម័យ (ភាគរយ) | ៧៥,០៨% |
| ភាគរយផ្ទះដែលមានប្រព័ន្ធទឹកតាមបំពង់ទុយោ (ភាគរយ) | ៩៧,១៦ |
| ភាគរយផ្ទះដែលមានភ្លើងប្រើប្រាស់ (ភាគរយ) | ៩៩,៥% |
| ចំនួនសំរាមក្នុងមួយថ្ងៃ (តោន) | ៧០ តោន |





ក្រុងកំពង់ចាម



ក្រុងបាវិត

# ក្រុងបាវិត

## ២.១. សេចក្តីផ្តើម

ស្ថិតនៅតាមបណ្តោយផ្លូវជាតិលេខ១ ជាប់ព្រំប្រទល់ប្រទេសវៀតណាម និងខេត្តស្វាយរៀង ក្រុងបាវិតជាក្រុងដែលប្រមូលផ្តុំដោយតំបន់សេដ្ឋកិច្ចពិសេស និងកាស៊ីណូ ដែលអាចទទួលបានផលប្រយោជន៍ពីប្រទេសជិតខាង និងទេសចរណ៍ដែលឆ្លងកាត់ព្រំដែនមកលេងកាស៊ីណូ។ ក្រុងនេះ ជាក្រុងកសិកម្មដ៏ធំមួយដែលអាចមានការអភិវឌ្ឍខ្លាំង ប៉ុន្តែយើងសង្កេតឃើញថាមានការហូរចូលជាប្រចាំថ្ងៃនៃចំនួនកម្មកររាប់រយនាក់មកពីប្រទេសជិតខាងមកធ្វើការនៅតំបន់សេដ្ឋកិច្ចពិសេស និងកាស៊ីណូ។ តំបន់ផ្សេងទៀតនៃក្រុងបាវិតដែលឆ្ងាយពីផ្លូវជាតិលេខ ១ និងឆ្ងាយពីតំបន់សេដ្ឋកិច្ចពិសេស និងច្រកព្រំដែន គឺភាគច្រើនជាតំបន់មានការអភិវឌ្ឍតិចតួចដោយសារតំបន់ទាំងនោះមានទីតាំងភូមិសាស្ត្ររបស់ខ្លួនមិនទាន់ត្រូវបានប្រែក្លាយទៅជាតំបន់សម្រាប់ការអភិវឌ្ឍសេដ្ឋកិច្ចសង្គម និងការរស់នៅរបស់ប្រជាជន។

ក្រុងបាវិត គឺមានចំណុចពិសេសខុសប្លែកពីក្រុងផ្សេងៗទៀត ដោយសារតែកំណើនប្រជាជននៅក្នុងក្រុងគឺភាគច្រើនដោយសារការមកស្វែងរកការងារធ្វើនៅតាមកាស៊ីណូ និងនៅតាមរោងចក្រឧស្សាហកម្មដែលស្ថិតនៅក្នុងតំបន់សេដ្ឋកិច្ចពិសេស ហើយកំណើននេះក៏ដោយសារតែក្រុងបាវិតស្ថិតនៅជាប់ព្រំប្រទល់ប្រទេសវៀតណាម ដែលជាអំណោយផលមួយល្អដល់ក្រុងបាវិត។ ទោះបីជាយ៉ាងណាក៏ដោយ អត្ថប្រយោជន៍នៃទីតាំងភូមិសាស្ត្រក្រុងបាវិតក៏អាចបាត់បង់ទៅវិញយ៉ាងរហ័ស ប្រសិនបើថ្ងៃអនាគតមានច្បាប់ណាមួយតាក់តែងឡើងដើម្បីបិទកាស៊ីណូ (នៅក្នុងប្រទេសកម្ពុជា) ឬច្បាប់ប្រទេសវៀតណាម បើកឱ្យមានកាស៊ីណូស្របច្បាប់នៅ ព្រំដែនប្រទេសខ្លួន ឬថាស្តង់ដារនៃការរស់នៅនិងប្រាក់ខែនៃកម្មករនៅតំបន់សេដ្ឋកិច្ចពិសេសមានការដំឡើងដល់ ចំនុចមួយដែលមិនមានការទាក់ទាញ វានឹងធ្វើឱ្យកំណើនប្រជាជនក្រុងបាវិតងាយរងឥទ្ធិពលពីកត្តាខាងក្រៅលើសពីការគ្រប់គ្រងបានដោយផ្ទាល់របស់រដ្ឋបាលក្រុង។

តារាង៖ ស្ថិតិប្រជាសាស្ត្រសំខាន់ៗ ក្រុងបាវិត (ស្ថិតិសេដ្ឋកិច្ចសង្គមនៃក្រុងបាវិត ឆ្នាំ២០១៦)

| ស្ថិតិប្រជាសាស្ត្រ | ២០១២ | ២០១៣ | ២០១៤ | ២០១៥ |
|---|---|---|---|---|
| ចំនួនប្រជាជន (នាក់) | ៣៨.៧៣៣ | ៣៨.៧៩៥ | ៣៩.៧៤៤ | ៣៩.៧៤៧ |
| អត្រាកំណើនប្រចាំឆ្នាំ (គិតជាភាគរយ) | ២,៥ | ០,២ | ២,៤ | ០ |
| ចំនួនស្ត្រី (នាក់) | ២០.០២១ | ១៩.៧៩១ | ២០.៤៥៨ | ២០.៥១៦ |
| សមាមាត្រស្ត្រីធៀបនឹងបុរស (ក្នុងចំណោមបុរស១០០នាក់) | ១០៧,០ | ១០៤,១ | ១០៦,១ | ១០៦,១ |
| ចំនួនគ្រួសារ (គ្រួសារ) | ៨.៥៦៩ | ៨.៧៧៨ | ៨.៩២៧ | ៩.៩៧១ |
| ទំហំគ្រួសារជាមធ្យម (នាក់) | ៤,៥ | ៤,៤ | ៤,៥ | ៤,០ |

## ២.២. ការវិភាគតាមវិស័យ សម្រាប់ការអភិវឌ្ឍទីក្រុងនិរន្តរភាព

### ទេសចរណ៍

បច្ចុប្បន្ននេះក្រុងបាវិតមានកាស៊ីណូចំនួន១១ដែលជាមូលដ្ឋានគ្រឹះសម្រាប់វិស័យទេសចរណ៍ដែលពឹងផ្អែកលើភ្ញៀវមកលេងល្បែងពីប្រទេសជិតខាងវៀតណាម ដែលនៅប្រទេសនោះការលេងល្បែងត្រូវបានហាមឃាត់។ ដោយសារតែចំណូលពន្ធបានមកពីកាស៊ីណូភាគច្រើន គឺចូលទៅរដ្ឋបាលថ្នាក់ជាតិផ្ទាល់ កត្តានេះធ្វើឱ្យផលប្រយោជន៍សេដ្ឋកិច្ចសម្រាប់ក្រុងបាវិតគឺនៅមានកម្រិត ហើយដោយសារថាចំនួនភ្ញៀវមកកម្សាន្តពីប្រទេសវៀតណាមប្រហែលនឹងថយចុះយ៉ាងខ្លាំងនាពេលអនាគត ខណៈដែលច្បាប់លើការលេងល្បែងស៊ីសងនឹងកាន់តែបន្ធូរបន្ថយនៅប្រទេសវៀតណាម ដូច្នេះហើយក្រុងបាវិតបានដាក់អាទិភាពលើការអភិវឌ្ឍវិស័យទេសចរណ៍តាមបែបផ្សេងៗទៀតដើម្បីថែរក្សាវិស័យនេះឱ្យនៅតែស្ថិតស្ថេរសម្រាប់ក្រុង។

ក្នុងចំណោមកត្តាប្រឈមនានាសម្រាប់ការអភិវឌ្ឍវិស័យទេសចរណ៍របស់ក្រុងរួមមាន កង្វះនូវកន្លែងទេសចរណ៍បែបធម្មជាតិ ដោយសារក្រុងមានសួនច្បារ និងកន្លែងទំនេរសាធារណៈតិចតួចនៅឡើយសម្រាប់សកម្មភាពច្នៃប្រឌិត ហើយសណ្ឋាគារ ផ្ទះសំណាក់ និងភោជនីយដ្ឋានមានចំនួនតិចតួច ហើយមិនមានដល់កម្រិតស្តង់ដារសមរម្យឡើយ។ បន្ថែមលើនេះទៀត គឺកង្វះខាតពលករជំនាញ និងការផ្គត់ផ្គង់អាហារក្នុងតំបន់មិនគ្រប់គ្រាន់។

ដើម្បីធ្វើឱ្យក្រុងបាវិតកាន់តែទាក់ទាញរដ្ឋបាលក្រុងមានផែនការកសាងសួនច្បារសរុបលើផ្ទៃដីទំហំ ៣០.០០០ម² ហើយជំរុញឱ្យមានសំណង់សណ្ឋាគារ ផ្ទះសំណាក់ និងភោជនីយដ្ឋានដែលមានស្តង់ដារនិងផាសុកភាពថ្មីៗល្អៗ ហើយបង្កើនឱ្យមានសេវាកម្មព័ត៌មានទេសចរណ៍។ គោលបំណងមួយផងដែរនោះគឺដើម្បីអភិវឌ្ឍន៍រមណីយដ្ឋានធម្មជាតិក្រៅក្រុង នៅតាមទួលឃាយដូន និងព្រៃសហគមន៍ចំការកូនគគីរ ដោយរួមបញ្ចូលផ្លូវដែលប្រើប្រាស់បាន។

ការគិតគូរថ្មីនេះជុំវិញវិស័យទេសចរណ៍ក្នុងក្រុងបាវិត គឺជាការបើកដំណើរការសកម្មភាពបៃតងនៃវិស័យនេះតាមគោលការណ៍នៃការអភិវឌ្ឍទីក្រុងនិរន្តរភាព។ ទាំងនេះអាចរួមមានការបង្កើតឧទ្យានប្រកបដោយជីវៈចម្រុះ មានផុងសំរាម បង្គន់សាធារណៈ និងមធ្យោបាយងាយស្រួលក្នុងដំណើរកម្សាន្ត ជំរុញឱ្យមានការប្រើប្រាស់សម្ភារសំណង់ ប្រសិទ្ធភាពថាមពល និងថាមពលកើតឡើងវិញប្រកបដោយចីរភាព (ឧទាហរណ៍ PV និងឧបករណ៍កម្តៅទឹកដោយប្រព័ន្ធពន្លឺព្រះអាទិត្យ) នៅតាមសណ្ឋាគារ និងផ្ទះសំណាក់ដោយរក្សាទឹកទុក និងការកែច្នៃសំណល់សំរាមឡើងវិញ។ ភាពទាក់ទាញរបស់រមណីយដ្ឋានទួលឃាយដូន និងតំបន់ព្រៃសហគមន៍កូនគគីរ អាចបង្កើតជាតំបន់អេកូទេសចរណ៍ ដែលមានគោលបំណងថែរក្សាធម្មជាតិនិងមរតវប្បធម៌។ ក្រុងនេះមាននូវសក្តានុពលដ៏ល្អមួយចំពោះការបង្កើតចំណូលពីការផលិតនូវផលិតផលអាហារឯកទេសទាំងឡាយ ចេញពីកសិដ្ឋានក្នុងស្រុកនិង ការដាំដុះក្នុងទឹក (ឧទាហរណ៍ ដំណាំសរ៉ាវង្គ) ដែលអាចបម្រើក្នុងភោជនីយដ្ឋាន និងអាចយកមកធ្វើនិងលក់ជាវត្ថុអនុស្សាវរីយ៍ផ្សេងៗបាន។ ការរៀបចំព័ត៌មានទូទៅអំពីទេសចរណ៍បៃតងមួយនេះមានសក្តានុពលទាក់ទាញភ្ញៀវទេសចរណាកាន់តែច្រើនឡើង កែលម្អបរិស្ថាន ពង្រឹងសេដ្ឋកិច្ច បង្កើតការងារ ជួយអ្នកក្រីក្រ និងក្រុមដែលងាយរងគ្រោះផងដែរ។

### ឧស្សាហកម្ម

ក្រុងបាវិតដែលមានទីតាំងលើផ្លូវជាតិលេខ១ជាប់នឹងព្រំប្រទល់អន្តរជាតិជាមួយប្រទេសវៀតណាម និងជិតនឹងកំពង់ផែទឹកជ្រៅក្នុងទីក្រុងហូជីមិញ គឺជាកន្លែងធ្វើមុខជំនួញដែលមានទិសដៅពាណិជ្ជកម្ម និងនាំចេញនាំចូល។ សក្តានុពលនេះបានធ្វើឱ្យមានការបង្កើតនូវតំបន់សេដ្ឋកិច្ចពិសេសចំនួន៥ ដែលមានរោងចក្រចំនួន ៥៨ មានបុគ្គលិកចំនួនប្រហែល ៦១.០៩៣នាក់ ស្រី ២៩.៨៥១ ហើយបុគ្គលិកបរទេស ២.៤៦៣នាក់ ស្រី៦១៥នាក់។ ក្នុងចំនោមផលិតផលទាំងនោះមាន វិស័យកាត់ដេរ ស្បែកជើង កង់ ខ្សែខ្វង និងសម្ភារវេចខ្ចប់ផ្សេងៗទៀតជាច្រើន។

តំបន់សេដ្ឋកិច្ចពិសេសក្នុងក្រុងបាវិត គឺជាតំបន់ដែលប្រើប្រាស់នូវធនធានបរិស្ថានក្នុងក្រុងដ៏ច្រើន។ គ្មានប្រព័ន្ធមធ្យោបាយធ្វើដំណើរសម្រាប់ដឹកជញ្ជូនអ្នកធ្វើការចេញចូលក្នុងតំបន់សេដ្ឋកិច្ចពិសេសនោះទេ។ ហើយ ផ្លូវជាតិលេខ១ដែលនៅជុំវិញតំបន់សេដ្ឋកិច្ចពិសេសមានការកកស្ទះពេលព្រឹក និងពេលល្ងាចរៀងរាល់ថ្ងៃ។ ធនធានទឹកគឺមានប្រភពពីក្រោមដីហើយកំពុងមានស្ថានភាពបំពុល ឧទាហរណ៍នៅតាមតំបន់សេដ្ឋកិច្ចពិសេស ម៉ាហាតាន់ (Manhattan)។ ក្រុងនេះ ក៏នៅមិនទាន់មានប្រព័ន្ធលូទឹកត្រឹមត្រូវនៅឡើយ។

ដោយតំបន់សេដ្ឋកិច្ចពិសេសស្ថិតក្រោមការគ្រប់គ្រងនៃក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា (CDC) ដូច្នេះហើយ វាស្ថិតនៅក្រៅប្រព័ន្ធដែនអំណាចគ្រប់គ្រងនៃរដ្ឋបាលក្រុង។ រដ្ឋបាលក្រុងមានឥទ្ធិពលតិចតួចក្នុងការធ្វើផែនការ និងប្រតិបត្តិការនៅក្នុងតំបន់សេដ្ឋកិច្ចពិសេស។ មានតែក្នុងករណីបញ្ហាជាក់លាក់មួយចំនួនទាក់ទងនឹងផលប៉ះពាល់បរិស្ថាននិងសង្គម ដូចជាការបញ្ចេញសំណល់ទឹកកខ្វក់ សំរាម រឺជម្លោះជាមួយបុគ្គលិកដែល អាជ្ញាធរក្រុង រដ្ឋបាលខេត្ត ហើយក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា សហការគ្នាដើម្បីដោះស្រាយបញ្ហា។

តំបន់សេដ្ឋកិច្ចពិសេស ក៏បង្កជាកត្តាប្រឈមមួយចំនួនដល់ការអភិវឌ្ឍទីក្រុងនិរន្តរភាពក្រុងបាវិតផងដែរ។ ក្រុងអាចទទួលផលប្រយោជន៍បានមួយផ្នែកពីសកម្មភាពសេដ្ឋកិច្ចមួយចំនួនពីតំបន់សេដ្ឋកិច្ចពិសេស (ឧទាហរណ៍ ការបង្កើតការងារ ទីកន្លែងស្នាក់នៅសម្រាប់បុគ្គលិក) ប៉ុន្តែមួយផ្នែកទៀត ទីក្រុងនេះស្ថាយនូវបន្ទុកមួយពេលគិតទៅលើបញ្ហាបរិស្ថាន (ឧទាហរណ៍ សំណល់សំរាម ការកកស្ទះចរាចរណ៍ ការបំពុលខ្យល់ និងទឹក) ហើយនៅខណៈពេលមានភាពចលាចលសង្គម ឧទាហរណ៍កម្មករធ្វើបាតុកម្មម្តងៗ។

ចេញពីទស្សនៈទីក្រុងនិរន្តរភាពជារួមមកបញ្ហាប្រឈមគឺដើម្បីធានានូវចីរភាពក្នុងប្រតិបត្តិការបច្ចុប្បន្ន និងការអភិវឌ្ឍបន្ថែមនៃតំបន់សេដ្ឋកិច្ចពិសេស។ នេះអាចរួមបញ្ចូលថាតើវត្ថុធាតុដើមជាច្រើនត្រូវផលិត រឺទាញយកជាមួយការគិតពិចារណាខាងបរិស្ថាន និងសង្គមត្រឹមត្រូវ ដំណើរផលិតកម្មគឺកើតមានក្នុងមជ្ឈដ្ឋានការងារសុវត្ថិភាពស្អាតនិងមានសុខភាពល្អ (ដោយគោរពតាមគោលកាលណ៍នៃការងារគ្រប់គ្រាន់) ជាមួយការបំពុលមានកម្រិតនៃខ្យល់ ទឹក និងដី ហើយផលិតផលចុងក្រោយជាធនធានគ្រប់គ្រាន់និងអាចកែច្នៃឡើងវិញបាន។ ការបន្ថែមលើនេះ គឺជាចីរភាពនៃហេដ្ឋារចនាសម្ព័ន្ធនិងសេវាកម្មទាំងឡាយដែលបង្កើតជាមូលដ្ឋានសម្រាប់ទ្រទ្រង់ផលិតកម្ម ដោយរួមបញ្ចូលថាមពលនិងការផ្គត់ផ្គង់ទឹក ការគ្រប់គ្រងសំណល់រឹងនិងរាវ មធ្យោបាយធ្វើដំណើរ និងទំនាក់ទំនង។

ដោយសារការអភិវឌ្ឍប្រកបដោយចីរភាពនៃតំបន់សេដ្ឋកិច្ចពិសេស គឺជាកត្តាសំខាន់សម្រាប់ក្រុងបាវិត និងការរស់នៅរបស់ប្រជាជន អាជ្ញាធរខេត្តចាំបាច់ត្រូវមានការពិភាក្សាឱ្យល្អិតល្អន់ជាមួយក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា (CDC) ដើម្បីឱ្យប្រាកដថាតំបន់សេដ្ឋកិច្ចពិសេសគឺមិនមែនត្រឹមតែជា “តំបន់” ដែលដាច់ស្រយាលពីការអភិវឌ្ឍទីក្រុងនិរន្តរភាពទេ ប៉ុន្តែចូលរួមចំណែកយ៉ាងសកម្មទៅលើការអភិវឌ្ឍបៃតងព្រមទាំងចូលរួមក្នុងគោលដៅជាតិជាច្រើនសម្រាប់ការអភិវឌ្ឍប្រកបដោយចីរភាព។

ចំពោះក្រុងបាវិត ការអភិវឌ្ឍទីក្រុងនិរន្តរភាពគឺមានសក្តានុពលចំពោះការជំរុញនូវមុខជំនួញផ្សេងៗទៀតក្រៅពីតំបន់សេដ្ឋកិច្ចពិសេសផងដែរ ហើយវានឹងចូលរួមចំណែកបន្ថែមទៀតដល់ការរីកលូតលាស់ប្រកបដោយចីរភាពនៃសេដ្ឋកិច្ចក្រុង និងបង្កើតការងារក្នុងមូលដ្ឋាន។ វិធីសាស្ត្រនៃការអភិវឌ្ឍបៃតងអាចមានដូចជានៅក្នុងដំណើរការផលិតកម្មបៃតង រួមមានដំណើរការនៅក្នុងកសិឧស្សាហកម្មដែលផ្អែកលើដំណាំជាំដុះដែលមាននិរន្តរភាព រឺរោងចក្រអំបោះ រឺឧស្សាហកម្មដែលផ្អែកលើចំណេះដឹងប្រសិទ្ធភាពធនធាន ឧទាហរណ៍ ផ្អែកលើបច្ចេកវិទ្យាព័ត៌មាន។ សិប្បកម្ម និងចំណីអាហារ ដែលជាជំនួញផលិតក្នុងស្រុក អាចស្វែងរកទីផ្សារក្នុង វិស័យទេសចរណ៍បាន។ ការអភិវឌ្ឍសេដ្ឋកិច្ចក្រុងក្រៅតំបន់សេដ្ឋកិច្ចពិសេស អាចជួយកាត់បន្ថយការធ្វើចំណាកស្រុករបស់ប្រជាពលរដ្ឋ ហើយវានឹងតម្រូវឱ្យមានការកៀរគរការវិនិយោគជាច្រើនសម្រាប់ទីក្រុង និងទីប្រជុំជន ដោយផ្តោតគោលដៅទៅលើការបណ្តុះបណ្តាលវិជ្ជាជីវៈ និងសកម្មភាពពង្រឹងជំនាញនានា ដោយរួមមានទាំងស្ត្រី និងក្រុមងាយរងគ្រោះ។

## ការគ្រប់គ្រងសំណល់

ក៏ដូចជាក្រុងដទៃទៀតនៃប្រទេសកម្ពុជាភាគច្រើន ក្រុងបាវិត (មិនរួមបញ្ចូលនូវតំបន់សេដ្ឋកិច្ចពិសេស) មានភាពប្រឈមនឹងបញ្ហាសំណល់សំរាមដែលត្រូវដោះស្រាយដើម្បីជាផលប្រយោជន៍ដល់ប្រជាជនជាច្រើនព្រមទាំងបរិស្ថាន ហើយក៏ជាធាតុដ៏ចាំបាច់មួយនៅក្នុងការអភិវឌ្ឍក្រុងបៃតង។ សម្រាប់ពេលបច្ចុប្បន្ន អត្រាប្រជាជនក្នុងក្រុងបាវិតមានតែ១០% ប៉ុណ្ណោះដែលមានលទ្ធភាពទទួលបានសេវាប្រព័ន្ធលូ ហើយមិនមានអាងប្រព្រឹត្តិកម្មទឹកកខ្វក់។ អត្រាប្រជាជនតែ ៨% ប៉ុណ្ណោះដែលទទួលបាននូវសេវាប្រមូលសំណល់រឹង (សំរាម) ប៉ុន្តែមិនមានការកែច្នៃដែលរៀបចំត្រឹមត្រូវទេ ហើយកន្លែងចាក់សំរាមក៏មិនត្រឹមត្រូវតាមស្តង់ដារ។

ចំពោះសំណល់រាវ (ទឹកកខ្វក់) គឺចាំបាច់តម្រូវឱ្យមានការបង្កើតនូវប្រព័ន្ធលូមួយដែលអាចតភ្ជាប់ដល់ផ្ទះប្រជាពលរដ្ឋទាំងអស់ កន្លែង

អាជីវកម្ម និងស្ថាប័នជាច្រើនទៀត និងប្រព័ន្ធលូទឹកភ្លៀងដាច់ដោយឡែកមួយ (លូក្រោមដី) សម្រាប់បង្ហូរទឹកភ្លៀង ហើយដើម្បីសាងសងនូវអាងចម្រោះ និងអាងប្រព្រឹត្តិកម្មទឹកកខ្វក់។

បញ្ហាសំណល់រឹង (សំរាម) ចាំបាច់ត្រូវដោះស្រាយដោយការធ្វើឱ្យសេវាកម្មប្រមូលសំរាមកាន់តែមានប្រសិទ្ធភាពហើយបានដល់ផ្ទះប្រជាពលរដ្ឋទាំងអស់ និងដើម្បីរៀបចំនូវប្រព័ន្ធកែច្នៃសំរាម និងបង្កើតឱ្យមានកន្លែងចាក់សំរាមដែលមានអនាម័យ និងគោរពតាមស្តង់ដារដែលតម្រូវ។ លើសពីនេះទៀត វាក៏ត្រូវការចាំបាច់ផងដែរក្នុងការអប់រំប្រជាជនទាំងឡាយ អ្នកជំនួញ និងពាណិជ្ជកម្មនានាអំពីការស្តុកទុកសំណល់ត្រឹមត្រូវ ហើយជំរុញលើកទឹកចិត្តពួកគេឱ្យចូលរួមក្នុងការប្រើប្រាស់សេវាកម្មប្រមូលសំរាម។

ប្រព័ន្ធគ្រប់គ្រងសំណល់ដែលមានលក្ខណៈល្អប្រសើរមួយនឹងចូលរួមចំណែកទៅលើការអភិវឌ្ឍក្រុងបៃតង ហើយនឹងធ្វើឱ្យទីក្រុងកាន់តែទាក់ទាញច្រើនដល់ប្រជាជន ព្រមទាំងភ្ញៀវទេសចរនាពេលបច្ចុប្បន្ន និងនាពេលអនាគត។ បន្ថែមលើសពីនេះ ការអភិវឌ្ឍបៃតង អាចពង្រឹងដល់ទីក្រុងបន្ថែមទៀតដោយការប្រើប្រាស់សំណល់ទៅជាធនធាន និងជាឱកាសមុខជំនួញមួយផ្សេងទៀត ដូចជាតាមរយៈការលក់នូវវត្ថុធាតុកែច្នៃពីសំរាម (ឧទាហរណ៍ ដែកថែប ជីកំប៉ុស្ដិ៍ជាដើម) ហើយតាមរយៈគម្រោងស្តីអំពីការកែច្នៃសំណល់ទៅជាថាមពល (waste-to-energy) ឧទាហរណ៍ការផលិតអគ្គិសនីតាមការដុតសំរាម រឺកន្លែងផលិតជីវឧស្ម័ន។

## ការដឹកជញ្ជូន

ជារៀងរាល់ថ្ងៃ មានឡានប្រភេទកុងទីន័រចំនួន ៣០០គ្រឿងបើកបរកាត់ក្រុងបាវិត និងឡានប្រភេទទ្រុងចំនួន ៧០០គ្រឿងដឹកអ្នកធ្វើការទៅ នឹងមកពីកន្លែងធ្វើការរបស់ពួកគេ។ ហើយការធ្វើចរាចរណ៍របស់រថយន្តទាំងនេះ គឺនៅលើផ្លូវក្នុងក្រុងដែលមានលក្ខណៈតូចចង្អៀត ដែលបង្កទៅជាការកកស្ទះចរាចរណ៍ និងសំឡេងកងរំពង ហើយឡានប្រភេទទ្រុងគឺមានលក្ខណៈចាស់ និងមិនមានស្តង់ដារពេញលេញ បង្កឱ្យមានការបំពុលបរិយាកាស និងគ្រោះថ្នាក់ចរាចរណ៍ជាច្រើន។

វាទាមទារឱ្យរដ្ឋបាលក្រុងបាវិតក្នុងការគ្រប់គ្រងចរាចរណ៍ឱ្យកាន់តែប្រសើរជាងមុន និងមានការវិនិយោគលើផ្លូវថ្នល់។ ក្នុងបរិបទក្រុងបៃតង កត្តានេះរួមបញ្ចូលនូវផ្លូវក្រវ៉ាត់ក្រុងដើម្បីកាត់បន្ថយការកកស្ទះចរាចរណ៍ក្នុងក្រុង ជាមួយនឹងប្រព័ន្ធដឹកជញ្ជូនសាធារណៈមួយដើម្បីការធ្វើដំណើររបស់បុគ្គលិក/កម្មករ។ នៅក្នុងតំបន់កណ្តាលក្រុង គួរតែមានប្រព័ន្ធដឹកជញ្ជូនសាធារណៈល្អប្រសើរដូចជា រថយន្តប្រើអគ្គិសនី ផ្លូវសម្រាប់ជនពិការ ផ្លូវសម្រាប់អ្នកជិះកង់ និងផ្លូវថ្មើរជើង និងតំបន់គ្មានការបើកបរយានយន្ត។

## ការបំពុលខ្យល់

ដោយសារក្រុងបាវិត មានផ្លូវជាតិនៅចំកណ្តាលក្រុង ហើយដែលតភ្ជាប់ជាមួយប្រទេសវៀតណាម ក្រុងបាវិតមានបញ្ហាដ៏ចម្បងគួរឱ្យកត់សម្គាល់មួយ គឺការបំពុលខ្យល់ដែលបង្កដោយការធ្វើចរាចរណ៍របស់ឡានប្រភេទកុងទីន័រធំៗដែលរង់ចាំនៅផ្លូវម្ខាងទៀតដែលកំពុងចាំការត្រួតពិនិត្យដើម្បីឆ្លងកាត់ព្រំដែន។ ក្រុងនេះមានផ្លូវលំតិចតួច ហើយរួមទាំងតំបន់សេដ្ឋកិច្ចពិសេស និងតំបន់កាស៊ីណូទាំងអស់ សុទ្ធតែពឹងផ្អែកលើផ្លូវជាតិមួយនេះ សម្រាប់អ្នកធ្វើការ និងបុគ្គលិកប្រើប្រាស់ផ្លូវពីកន្លែងធ្វើការទៅកន្លែងស្នាក់នៅរបស់ពួកគេ កត្តានេះបង្កជាបញ្ហានៃការបំពុលបរិយាកាសកាន់តែធ្ងន់ធ្ងរឡើងៗ។ វាជាតម្រូវការបន្ទាន់មួយក្នុងការបង្កើតផ្លូវឆ្លងកាត់ផ្សេងៗទៀតដែលកំពុងស្ថិតក្រោមការសាងសង់ ដែលអាចជួយកាត់បន្ថយបន្ទុកចរាចរណ៍ទំនិញធ្ងន់ៗឱ្យឆ្ងាយពីមណ្ឌលក្រុងបាវិត ហើយដូចនេះជាការជួយដោះស្រាយបញ្ហាបានមួយភាគ។

## ២.៣. សកម្មភាពអាទិភាព

| ល.រ | ឈ្មោះគម្រោង | បរិយាយពីមូលហេតុដែលជាគម្រោងអាទិភាព និងអត្ថប្រយោជន៍ផ្នែកសង្គម សេដ្ឋកិច្ច និងបរិស្ថានរបស់ក្រុង |
|---|---|---|
| ១ | អភិវឌ្ឍន៍ប្រព័ន្ធលូ (ទឹកភ្លៀង និងទឹកកខ្វក់) ក្នុងក្រុង | ការពារក្រុងពីជំនន់ទឹកភ្លៀង និងទឹកកខ្វក់។ បញ្ចៀសការហូរចូលនៃទឹកកខ្វក់ទៅក្នុងចរន្តទឹក ដូចជាចរន្តទឹកសម្រាប់ប្រើប្រាស់ផលិតទឹកស្អាត។ |
| ២ | អភិវឌ្ឍន៍ស្ថានីយប្រព្រឹត្តិកម្មទឹកកខ្វក់ | ប្រព្រឹត្តិកម្មទឹកកខ្វក់ ទៅដល់កម្រិតស្តង់ដារបរិស្ថានដែលអាចទទួលយកបានមុននឹងបញ្ចេញចោលទៅក្នុងធម្មជាតិ ឬប្រើប្រាស់សម្រាប់ជាកសិកម្ម |
| ៣ | រៀបចំបំពាក់ប្រព័ន្ធគ្រប់គ្រងសំណល់ (ការគ្រប់គ្រងខ្សែសង្វាក់ផ្គត់ផ្គង់សំរាម ទាំងមូលនិងទីលានចាក់សំរាមស្របតាមស្តង់ដាបច្ចេកទេសដែលអាចកាត់បន្ថយបរិមាណសំរាម) | ផ្សព្វផ្សាយចំណេះដឹងសាធារណៈដល់ប្រជាពលរដ្ឋអំពីផលប៉ះពាល់នៃសំរាមទៅលើបរិស្ថាន និងការទុកដាក់ ការញែកសំរាមឱ្យបានត្រឹមត្រូវតាមបច្ចេកទេស។ ក្រុងនឹងមានសេវាប្រមូលសំរាមបានល្អប្រសើរជាងមុន (ញឹកញាប់ និងទាន់ពេលវេលា)។ ការបង្កើតនូវទីលានចាក់សំរាមដែលសមស្រប ជាមួយនឹងបច្ចេកទេសញែក និងកែច្នៃសំរាម។ បង្កើត និងអនុវត្តក្របខ័ណ្ឌច្បាប់ និងបទប្បញ្ញត្តិនៃការចោលសំរាម។ |
| ៤ | កែលម្អ និងពង្រីកបណ្តាញផ្លូវថ្នល់ | កែលម្អនូវប្រព័ន្ធដឹកជញ្ជូនសាធារណៈ ជាពិសេសនៅម៉ោងចេញ/ចូល ធ្វើការ។ កាត់បន្ថយបានការកកស្ទះចរាចរណ៍។ កែលម្អការដឹកជញ្ជូនទំនិញតាមដងផ្លូវដែលអាចកាត់បន្ថយការចំណាយលើការដឹកជញ្ជូនរបស់ក្រុមហ៊ុន។ |
| ៥ | សិក្សាពីលទ្ធភាពនៃការបង្កើតប្រភពថាមពលកកើតឡើងវិញ | មានភ្លើងអគ្គិសនីប្រើប្រាស់គ្រប់គ្រាន់សម្រាប់ក្រុង ក៏ដូចជាសម្រាប់តំបន់ឧស្សាហកម្ម។ |
| ៦ | រៀបចំតំបន់ទេសចរណ៍ និងសន្តិសុខសណ្តាប់ធ្នាប់ | - អភិរក្សទួលបុរាណ ព្រៃសហគមន៍ និងកែលម្អបឹង ព្រែកឱ្យក្លាយទៅជាតំបន់ទេសចរណ៍ដើម្បីទាក់ទាញភ្ញៀវជាតិ និងអន្តរជាតិ<br>- ពង្រឹងសន្តិសុខសុវត្ថិភាពជូន ភ្ញៀវជាតិ និងអន្តរជាតិ |
| ៧ | បំពាក់បច្ចេកទេសប្រសិទ្ធភាពថាមពលនៃខ្សែសង្វាក់ផលិតកម្មក្នុងតំបន់សេដ្ឋកិច្ចពិសេស | ការអនុវត្តខ្សែសង្វាក់ផលិតកម្មក្នុងតំបន់សេដ្ឋកិច្ចពិសេស មានភាពល្អប្រសើរជាងមុនដែលជួយដល់និរន្តរភាពបរិស្ថាន |
| ៨ | ការគ្រប់គ្រងសំរាម ទឹកកខ្វក់ និងអនាម័យនៅតាមរោងចក្រក្នុងតំបន់សេដ្ឋកិច្ចពិសេស | ការអនុវត្តខ្សែសង្វាក់ផលិតកម្មក្នុងតំបន់សេដ្ឋកិច្ចពិសេស មានភាពល្អប្រសើរជាងមុនដែលជួយដល់និរន្តរភាពបរិស្ថាន |
| ៩ | រៀបចំផែនការមេប្រើប្រាស់ដីរបស់ក្រុង (សាងសង់) | កែលម្អឱ្យមានភាពប្រសើរឡើងនៃតំបន់ សម្រាប់វិស័យឧស្សាហកម្ម កសិកម្ម និងតំបន់លំនៅឋាន |
| ១០ | រៀបចំការគ្រប់គ្រងប្រព័ន្ធផ្គត់ផ្គង់ទឹកស្អាត | - ពង្រឹងគុណភាពទឹកស្អាត ធានាតម្លៃសមរម្យ<br>- ពង្រីកបណ្តាញទឹកស្អាតឱ្យបានប្រើប្រាស់គ្រប់ភូមិក្នុងក្រុង |

*ប្រភព៖ ការប្រឹក្សាយោបល់ជាមួយរដ្ឋបាលក្រុងបាវិត*

## ២.៤. ព័ត៌មានស្ថិតិសេដ្ឋកិច្ចសង្គម

| សន្ទស្សន៍ | ទិន្នន័យ (២០១៥) |
|---|---|
| ចំនួនប្រជាជន (នាក់) | ៣៩.៧៤៧ |
| ដង់ស៊ីតេប្រជាជន (នាក់/គ.ម២) | ២៤២,៧ |
| អត្រាភាពក្រីក្រ (បទបង្ហាញពីសិក្ខាសាលា) (ភាគរយ) | ១១,៩% |
| ផ្ទៃក្រឡា (គ.ម២) | ២០៦,៦៩ |
| អត្រាអ្នកចេះអក្សរ (បទបង្ហាញពីសិក្ខាសាលា) (ភាគរយ) | ៩៨,៩៨% |
| វិស័យសេដ្ឋកិច្ចសំខាន់ៗ | រោងចក្រ កាស៊ីណូ ដឹកជញ្ជូននិង កសិកម្ម |
| បំណែងចែកការងារតាមវិស័យផ្សេងៗ (ភាគរយ) | |
| - កសិកម្ម | ៣៦,១% |
| - ផលិតកម្ម | ០,២% |
| - សេវាកម្ម | ៦៣,៧% |
| ចំណាកស្រុក (ទៅក្រៅប្រទេស) (នាក់) | ៤១៨ |
| មធ្យមភាគទោចក្រយានយន្តក្នុងផ្ទះ (គ្រឿង) | ០,៩ |
| ចំនួនប្រជាជនដែលជាប់បំណុល(ធនាគារ ឬមីក្រូហិរញ្ញវត្ថុ) (នាក់) | ៣.៣៥១ |
| ចំនួនផ្ទះនៅសំណង់អនាធិបតេយ្យ/លំនៅឋានខុសច្បាប់ (ខ្នងផ្ទះ) | ៦៩ |
| ចំនួនផ្ទះដែលទទួលឥទ្ធិពលពីខ្យល់ព្យុះ (ខ្នងផ្ទះ) | ១ |
| ចំនួនផ្ទះដែលទទួលឥទ្ធិពលពីទឹកជំនន់ (ខ្នងផ្ទះ) | ០ |
| ចំនួនផ្ទះដែលទទួលឥទ្ធិពលពីភាពរាំងស្ងួត (ខ្នងផ្ទះ) | ០ |
| ភាគរយផ្ទះដែលសេវាកម្មប្រមូលសំរាមអាចចូលទៅដល់ (ភាគរយ) | ៨% |
| ភាគរយផ្ទះដែលមានលទ្ធភាពទទួលបានសេវាអនាម័យ (ភាគរយ) | ៦៧,២% |
| ភាគរយផ្ទះដែលមានប្រព័ន្ធទឹកតាមបំពង់ទុយោ (ភាគរយ) | ១០,០១% |
| ភាគរយផ្ទះដែលមានភ្លើងប្រើប្រាស់ (ភាគរយ) | ៦៣,៨២% |
| ចំនួនសំរាមក្នុងមួយថ្ងៃ (តោន) | ២០ តោន |


ស្វាយរៀង



ស្វាយរៀង



ក្រុងសួង

# ក្រុងសួង

## ២.១. សេចក្ដីផ្ដើម

ក្រុងសួង ជាក្រុងកសិកម្មតូចមួយនៅក្នុងខេត្តត្បូងឃ្មុំ ដែលបានបង្កើតឡើងនៅចុងឆ្នាំ២០០៨ នេះហើយត្រូវបានចាត់ទុកជាក្រុងនៅឆ្នាំ២០១៤។ ក្រុងសួង មានទីតាំងនៅចន្លោះរវាងខេត្តកំពង់ចាម និងប្រទេសវៀតណាម។ ខេត្តត្បូងឃ្មុំត្រូវបានបង្កើតឡើងបន្ទាប់ពីការបំបែកខេត្តកំពង់ចាមជាពីរ ដោយព្រះរាជក្រឹត្យចុះថ្ងៃទី ៣១ ខែធ្នូ ឆ្នាំ២០១៣។

ក្រុងសួងមានការពិបាកក្នុងការទាក់ទាញការវិនិយោគថ្មីៗ ជាពិសេសនៅក្នុងវិស័យទេសចរណ៍ និងកំពុងមានបញ្ហាប្រឈមពីរសំខាន់ៗដែលគេត្រូវពិចារណា ។ បញ្ហាទីមួយគឺ “លំហូរចេញនូវធនធានមនុស្ស” ជាបន្តបន្ទាប់ ពោលគឺប្រជាជនក្នុងក្រុងដែលមានសមត្ថភាព និងទទួលបានការបណ្ដុះបណ្ដាលខ្ពស់ ចាកចេញពីស្រុកកំណើតនេះដើម្បីទៅស្វែងរកឱកាសការងារដែលល្អប្រសើរជាងនេះ ហើយបញ្ហាទីពីរគឺ “ការខ្វះខាតនៃតំបន់ទេសចរណ៍សំខាន់ៗសម្រាប់ផ្សារភ្ជាប់ជាមួយនឹងបណ្ដាក្រុងផ្សេងៗទៀត និងជាមួយរាជធានីភ្នំពេញ។ ទីប្រជុំជនក្រុងសួងជាតំបន់ថ្មីសន្លាង ផ្ដល់ភាពងាយស្រួលក្នុងការរៀបចំផែនការអភិវឌ្ឍទីក្រុងស្របទៅតាមគោលការណ៍នៃទីក្រុងនិរន្តរភាព ដែលនេះជាលក្ខណៈពិសេសប្លែកពីគេ បើប្រៀបធៀបទៅនឹងក្រុងដទៃទៀតក្នុងប្រទេសកម្ពុជាដែលមានការអភិវឌ្ឍទៅមុនហើយនោះ។ កត្តានេះក៏ជាបច្ច័យល្អដែរសម្រាប់ក្រុងនេះក្នុងការរៀបចំជាសំណើកម្មវិធី/គម្រោងទាក់ទាញការវិនិយោគបៃតងថ្មីៗក៏ដូចជាការទាក់ទាញក្នុងវិស័យទេសចរណ៍។

ក្រុងសួងមានប្រជាពលរដ្ឋរស់នៅតិចតួចនៅឡើយ ហើយត្រូវបានចាត់ថ្នាក់ថាជាទីក្រុងមួយមានកំណើនប្រជាជនថេរ (ដោយគ្មានការផ្លាស់ប្ដូរណាគួរឱ្យកត់សម្គាល់) ដោយសារតែការធ្វើចំណាកស្រុក។ គេអាចរំពឹងថានឹងមានលំហូរចូលនៃប្រជាពលរដ្ឋពីតំបន់ផ្សេងៗមកក្នុងក្រុងសួង ដោយសារតែឱកាសថ្មីដែលផ្ដល់ដោយក្រុងថ្មីនេះ ប៉ុន្តែចំនួននេះនឹងត្រូវបានប៉ះប៉ូវជាមួយចំនួនអ្នកក្រុងសួងដែលចាកចេញពីក្រុងដើម្បីស្វែងរកឱកាសល្អប្រសើរជាងនេះ ព្រោះក្រុងនេះមានគុណសម្បត្តិជាយុទ្ធសាស្ត្រតិចតួចណាស់ក្នុងការបង្កើតនូវប្រភពការងារ ដែលជានាទុកចិត្តបាន និងយូរអង្វែង។

តារាង៖ ស្ថិតិប្រជាសាស្ត្រសំខាន់ៗនៃក្រុងសួង (ស្ថិតិសេដ្ឋកិច្ចសង្គមនៃក្រុងសួង ឆ្នាំ២០១៧)

| ស្ថិតិប្រជាសាស្ត្រ | ២០១៣ | | ២០១៤ | ២០១៥ | ២០១៦ |
|---|---|---|---|---|---|
| ចំនួនប្រជាជន (នាក់) | ៣៦.៩៨៤ | | ៣៧.២៥៥ | ៣៩.០១០ | ៣៨.៦៥០ |
| អត្រាកំណើនប្រចាំឆ្នាំ (គិតជាភាគរយ) | ៣,២ | | ០,៧ | ៤,៧ | -០,៩ |
| ចំនួនស្ត្រី (នាក់) | ១៩.១៥៧ | | ១៩.១៧៧ | ២០.២៤០ | ២០.០៤១ |
| សមាមាត្រស្ត្រីធៀបនិងបុរស (ក្នុងចំណោមបុរស១០០នាក់) | ១០៧,៥ | | ១០៦,១ | ១០៧,៨ | ១០៧,៧ |
| ចំនួនគ្រួសារ (គ្រួសារ) | ៨.០៧៤ | | ៨.២៩៨ | ៨.៣៨១ | ៨.៣៧៨ |
| ទំហំគ្រួសារជាមធ្យម (នាក់) | ៤,៦ | | ៤,៥ | ៤,៧ | ៤,៦ |

## ២.២. ការវិភាគតាមវិស័យ សម្រាប់ការអភិវឌ្ឍទីក្រុងនិរន្តរភាព

### កសិកម្ម និងពាណិជ្ជកម្ម

កសិកម្ម គឺជាវិស័យសេដ្ឋកិច្ចសំខាន់ចម្បងបន្ទាប់ពីវិស័យអាជីវកម្មនៅក្រុងសួង។ ក្រុងសួងជាក្រុងដែលមានដីផ្តល់ទិន្នផលខ្ពស់ មានជាតុអាកាសល្អ និងហានិភ័យទាបក្នុងការជួបគ្រោះរាំងស្ងួត និងទឹកជំនន់។ បច្ចុប្បន្នផ្ទៃដីកសិកម្មភាគច្រើនគ្របដណ្តប់ដោយចំការកៅស៊ូ ហើយក្រុងនេះ ស្ថិតក្នុងចំណោមផលិតករនាំមុខខាងផ្នែកទិន្នផលគ្រាប់ស្វាយចន្ទី និងម្រេច ។ ស្រូវ គឺជាដំណាំសំខាន់មួយទៀត រួមជាមួយទីតាំងរបស់ខ្លួននៅលើផ្លូវជាតិលេខ ៧ ជិតក្រុងកំពង់ចាមនិងជិតព្រំប្រទល់ជាមួយវៀតណាម ក្រុងសួងមានសក្តានុពលល្អក្នុងការក្លាយជាទីតាំងស្នូលសម្រាប់ ការផលិត ការរក្សាទុក ការធ្វើទីផ្សារ និងការធ្វើពាណិជ្ជកម្មផលិតផលកសិកម្ម ព្រមទាំងសម្រាប់ផ្គត់ផ្គង់ឧបករណ៍ និងសេវាកម្មដល់វិស័យនេះ តួយ៉ាងដូចជាគ្រឿងយន្តសម្រាប់ធ្វើកសិកម្មជាដើម។

បញ្ហាប្រឈមខ្លះ ក្នុងចំណោមបញ្ហាប្រឈមទាំងឡាយនាពេលបច្ចុប្បន្នដែលត្រូវដោះស្រាយ រួមមាន៖ ការចំណាយខ្ពស់លើការធ្វើកសិកម្មដែលនៅតែផ្អែកលើបច្ចេកទេសចាស់ គុណភាពប្រព័ន្ធធារាសាស្ត្រមានកម្រិត ផលចំណេញដែលទទួលបានដោយពួកឈ្មួញកណ្តាលបានធ្វើឱ្យតម្លៃទាបសម្រាប់កសិករ និងកង្វះខាតទីផ្សារដែលមានការរៀបចំត្រឹមត្រូវនិងបង្កលក្ខណៈងាយស្រួលដល់ផលិតករ អ្នកផ្គត់ផ្គង់ និងអ្នកទិញអាចជួបគ្នាបាន។ បន្ថែមពីលើនេះទៀត គឺការធ្លាក់ចុះនៃតម្លៃទីផ្សារអន្តរជាតិ ការប្រកួតប្រជែងពីផលិតផលនាំចូល និងផលប៉ះពាល់នៃការប្រែប្រួលអាកាសធាតុ។

ដំណោះស្រាយឆ្លើយតបនឹងបញ្ហាប្រឈមខាងលើរួមមាន៖ កិច្ចខិតខំប្រឹងប្រែងដើម្បីបង្កើនទិន្នផលកសិកម្ម ការធ្វើពិពិធកម្មប្រភេទដំណាំផ្សេងៗ (ដើម្បីបន្ថយភាពងាយរងគ្រោះដោយសារការប្រែប្រួលតម្លៃទីផ្សារនិងបម្រែបម្រួលអាកាសធាតុ) និងការស្តារឱ្យប្រសើរឡើង កែលម្អ និងពង្រីកប្រព័ន្ធធារាសាស្ត្រ។ វាជាកិច្ចការចាំបាច់ក្នុងការពង្រឹងតួនាទីរបស់ក្រុងសួងឱ្យទៅជាទីផ្សារសម្រាប់ផលិតផលកសិកម្ម និងសេវាកម្មពាក់ព័ន្ធនានា តួយ៉ាងតាមរយៈការបង្កើតយន្តការមួយដែលធ្វើការសម្របសម្រួលរវាងអ្នកផលិត អ្នកកែច្នៃ និងអ្នកទិញ ហើយត្រូវបង្កើនភាពទាក់ទាញរបស់ក្រុងសួងនៅក្នុងតំបន់ ។ ការអភិវឌ្ឍបន្ថែមទៀតនៃវិស័យនេះក៏តម្រូវឱ្យមានការខិតខំប្រឹងប្រែងកសាងសមត្ថភាពរបស់កសិករក្នុងក្រុងសួង និងភាគីសំខាន់ផ្សេងទៀតក្នុងដំណើរការទីផ្សារលើផ្នែកសំខាន់ៗជាក់លាក់ ឧទាហរណ៍ដូចជាផ្នែកប្រភេទដំណាំថ្មីនិងបច្ចេកទេសទំនើបៗក្នុងការធ្វើកសិកម្ម។

ការផ្តោតលើវិស័យកសិកម្ម/សេវាកម្មពាក់ព័ន្ធ និងផ្នែកពាណិជ្ជកម្ម ដោយគោរពតាមទស្សនវិស័យបង្កើតទីក្រុងនិរន្តរភាពមួយ និងការអភិវឌ្ឍដោយមិនប៉ះពាល់បរិស្ថាន វាអាចផ្តល់នូវឱកាសផ្សេងៗបន្ថែមទៀត ដែលអាចពង្រឹងមុខមាត់កិត្តិនាមរបស់ ទីក្រុងសួង និងផ្តល់ជាកំណើនសេដ្ឋកិច្ច ការងារ និងប្រាក់ចំណូល (រួមទាំងសម្រាប់អ្នកក្រីក្រនិងអ្នកដែលងាយរងគ្រោះ) និង ក្នុងពេលជាមួយគ្នានេះគាំពារធ្វើឱ្យបរិស្ថានប្រសើរឡើង។ ក្នុងចំណោមឱកាសទាំងនេះក៏រួមមានការនាំមកនូវការអនុវត្តផ្នែកកសិកម្មប្រកបដោយចីរភាពជាងមុនក្នុងការប្រើប្រាស់ទឹក ថាមពលហ្វូស៊ីលតិចតួច ឬមិនប្រើតែម្តង ទឹកថ្នាំសម្លាប់សត្វល្អិត និងជីគីមី (ឧទាហរណ៍ ការធ្វើកសិកម្មដោយប្រើជីសរីរាង្គ)។ ការអនុវត្តការងារកសិកម្មបែបនេះ នឹងជួយឱ្យមានការងារបន្ថែមទៀត កាត់បន្ថយផលប៉ះពាល់បរិស្ថាន ព្រមទាំងបង្កើតបានជាផលិតផលដែលអាចទទួលបានតម្លៃខ្ពស់ជាងមុននៅលើទីផ្សារ។ ទីផ្សារទាំងឡាយក្នុងទីក្រុង សម្រាប់ផលិតផលកសិកម្មអាចត្រូវបានរចនាឡើងដោយបច្ចេកវិជ្ជាដែលប្រើប្រាស់ថាមពលនិងទឹកឱ្យមានប្រសិទ្ធភាព ដូចជាការប្រើប្រាស់ថាមពលកកើតឡើងវិញ និងការកែច្នៃសំណល់សម្រាប់ប្រើប្រាស់ឡើងវិញ ហើយសំណល់សរីរាង្គអាចយកមកប្រើសម្រាប់ផលិតជាថាមពលឬជី (ជីកំប៉ុស្តិ៍)។ ការប្រើប្រាស់គ្រឿងយន្តកសិកម្ម និងយានយន្តដឹកជញ្ជូនក្នុងតំបន់អាចត្រូវបានកែលម្អដោយជម្រើសមិនប៉ះពាល់បរិស្ថាន ដូចជាប្រើប្រាស់ឧបករណ៍ ម៉ាស៊ីន និងយានយន្ត ដែលប្រើប្រាស់ប្រព័ន្ធអគ្គិសនី។ ការកសាងមុខមាត់ ខាងផ្នែកការពារបរិស្ថានបានល្អបែបនេះ អាចមានសារៈសំខាន់ចំពោះកិត្តិសព្ទក្រុងសួង នាពេលអនាគត ហើយក៏អាចធ្វើការទាក់ទាញអតិថិជនជាតិ និងអន្តរជាតិថ្មីៗ រួមទាំងវិនិយោគិនសាធារណៈនិងឯកជនបានថែមទៀតផង។

### សំណល់

ក្រុងសួង ក៏ដូចគ្នាជាមួយបណ្តាក្រុងភាគច្រើននៅក្នុងប្រទេសកម្ពុជាដែរ គឺមានប្រព័ន្ធ និងការគ្រប់គ្រងសំណល់មិនសូវមានប្រសិទ្ធភាព។ វាជាកិច្ចការចាំបាច់ដែលត្រូវធ្វើឱ្យប្រសើរឡើងដើម្បីជាប្រយោជន៍ដល់ប្រជាពលរដ្ឋ និងជាផ្នែកសំខាន់មួយនៃ

ការអភិវឌ្ឍទីក្រុងនិរន្តរភាព។ ក្រុងដែលទើបនឹងបង្កើតថ្មីនេះ មិនមានប្រព័ន្ធលូច្បាស់លាស់ទេ ហើយមានតែ១១% នៃគ្រួសារសរុប និង១៧% នៃផ្ទះសម្បែងទាំងអស់នៅក្នុងក្រុងដែលមានសេវាកម្មប្រមូលសំរាមទៅដល់។

បច្ចុប្បន្នទឹកកខ្វក់ហូរជ្រាបតាមដីចូលទៅក្នុងប្រឡាយ ហើយហៀរចូលក្នុងវាលស្រែ បង្កឱ្យមានបញ្ហា បរិស្ថាន និងសុខភាព។ ជាការឆ្លើយតប ក្រុងនេះមានបំណងបង្កើតប្រព័ន្ធគ្រប់គ្រងសំណល់រាវ (ទឹកកខ្វក់)ដែលអាចទៅដល់គ្រប់ផ្ទះសម្បែង កន្លែងធ្វើអាជីវកម្ម និងស្ថាប័នផ្សេងៗ ទាំងអស់អាចប្រើប្រាស់បំពង់បង្ហូរទឹកកខ្វក់ដែលប្រមូលសំណល់រាវចូលទៅក្នុងលូ និងមានប្រព័ន្ធប្រមូលទឹកកខ្វក់ទាំងនោះចូលទៅក្នុងរោងចក្រកែច្នៃ។ លើសពីនេះទៀត វាជាការចាំបាច់ក្នុងការសាបព្រួសចំណេះដឹងអំពីរបៀបគ្រប់គ្រងដំណើរការ និងថែរក្សាប្រព័ន្ធទឹកកខ្វក់ និងបង្កើនការយល់ដឹងជាសាធារណៈស្តីពីការគ្រប់គ្រងទឹកកខ្វក់។

ចំពោះសំណល់រឹង ក្រុង ទីប្រជុំជនក្រុងនេះត្រូវការបង្កើនកិច្ចសហប្រតិបត្តិការជាមួយក្រុមហ៊ុននិងដៃគូវិនិយោគ ផ្សេងៗទៀតដែលអាចបង្កើតការប្រមូលសំណល់រឹង ដែលមានប្រសិទ្ធភាព និងដែលគួរតែការគ្របដណ្តប់លើផ្ទៃទីក្រុងទាំងមូល ជាមួយនឹងប្រព័ន្ធកែច្នៃឡើងវិញនិងដីវាលចាក់សំរាមដែលការពារការច្រោះចូលទៅក្នុងដី ផ្លូវទឹក កាត់បន្ថយក្លិន និងមានចម្ងាយសមរម្យពីផ្ទះសម្បែងរស់នៅ កន្លែងធ្វើអាជីវកម្មនិងដីស្រែចំការ។ វាក៏សំខាន់ផងដែរក្នុងការកាត់បន្ថយការបោះចោលសំណល់ពាសវាលពាសកាលនៅកន្លែងសាធារណៈតាមរយៈ ការដាក់ធុងសំរាមជាដើម។ ចំពោះសំណល់រឹងក៏មានតំរូវការក្នុងការបង្កើតការយល់ដឹងក្នុងចំណោមប្រជាពលរដ្ឋនិងកន្លែងធ្វើអាជីវកម្មផ្សេងៗអំពីការគ្រប់គ្រងសំណល់ការប្រមូលសំណល់តាមប្រភេទ និងការបោះសំណល់ចោល។

ប្រព័ន្ធគ្រប់គ្រងសំណល់ដែលមានលក្ខណៈល្អប្រសើរឡើងនឹងធ្វើឱ្យក្រុងកាន់តែទាក់ទាញដល់ប្រជាពលរដ្ឋរស់នៅក្នុងក្រុងបច្ចុប្បន្ននិងអនាគត ក៏ដូចជាទាក់ទាញភ្ញៀវទេសចរ និងការធ្វើអាជីវកម្ម ឬពាណិជ្ជកម្មនៅក្នុងវិស័យនេះ។ ឱកាសនៃការធ្វើអាជីវកម្មបន្ថែមទៀតក្នុងការកែច្នៃសំណល់ទៅជាធនធានតួយ៉ាងដូចជាការលក់វត្ថុធាតុដើមដែលបានកែច្នៃឡើងវិញជាដើម (ឧទាហរណ៍ លោហៈធាតុ ជីកំប៉ុស្ដិ៍) និងតាមរយៈគម្រោងកែប្រែសំណល់ទៅជាថាមពលដូចជា ការផលិតអគ្គិសនីពីសំណល់ឡដុត សំណល់ឧស្ម័ន ឬជីវឧស្ម័នដែលរំលាយចេញរោងចក្រកែច្នៃទឹកកខ្វក់ ។

## ការដឹកជញ្ជូន

ក្រុងនេះ ខ្វះហេដ្ឋារចនាសម្ព័ន្ធជាមូលដ្ឋានទាក់ទងនឹងផ្លូវថ្នល់។ មានតែ ១៦% ប៉ុណ្ណោះនៃផ្លូវនៅក្នុងទីក្រុងសួងជាផ្លូវថ្នល់ ដែលមានការលំបាកក្នុងការធ្វើដំណើរពីភូមិមួយទៅភូមិមួយក្រៅពីតំបន់កណ្តាលក្រុង។ មានតម្រូវការចាំបាច់ក្នុងការកែលម្អ (ក្រាលកៅស៊ូ) ផ្លូវដែលនៅសេសសល់ និងបង្កើតប្រព័ន្ធដឹកជញ្ជូនសាធារណៈដែលតភ្ជាប់ភូមិទាំងអស់ទៅតំបន់កណ្តាលក្រុង។ ក្រៅពីនេះក៏មានជម្រើសក្នុងការប្រើប្រាស់ការដឹកជញ្ជូនដោយមិនប៉ះពាល់បរិស្ថាននៅក្នុងក្រុង ទីប្រជុំជនក្រុង ដូចជាការណែនាំឱ្យប្រើរថយន្តប្រើប្រាស់អគ្គិសនី (រួមបញ្ចូលប្រព័ន្ធដឹកជញ្ជូនរបស់សាលាក្រុង និងរថយន្តក្រុងសាធារណៈ) បង្កើតផ្លូវសម្រាប់អ្នកជិះកង់និងផ្លូវអ្នកថ្មើរជើង និងបង្កើនចំនួនតំបន់គ្មានរថយន្តចេញចូល។

## ២.៣. សកម្មភាពអាទិភាព

| ល.រ | ឈ្មោះគម្រោងអាទិភាព | បរិយាយពីមូលហេតុដែលជាគម្រោងអាទិភាព និង អត្ថប្រយោជន៍ផ្នែកសង្គម សេដ្ឋកិច្ច និងបរិស្ថានរបស់ក្រុង |
|---|---|---|
| ១ | អភិវឌ្ឍន៍កែលម្អទីលានចាក់សំរាមរបស់ក្រុង | អាចគ្រប់គ្រងបាននូវការចោលសំរាម ដែលមានគំរបការពារធម្មជាតិក្នុងរយៈពេលវែង កាត់បន្ថយផលប៉ះពាល់ជាអវិជ្ជមានដល់ចរន្តទឹក (ចរន្តទឹកទាំងខាងលើ និងខាងក្រោមដី) ដី ខ្យល់ បរិយាកាស និងបរិស្ថានទាំងមូល។ |
| ២ | អភិវឌ្ឍន៍ប្រព័ន្ធប្រមូល និងកែច្នៃសំរាមឱ្យមានប្រសិទ្ធភាពជាងមុន រួមមានទាំងការដាក់បន្ថែមធុងសំរាមតាមទីសាធារណៈ | កែលម្អនូវការគ្រប់គ្រងសំរាម និងការដាក់បន្ថែមនូវធុងសំរាមតាមទីសាធារណៈ។ គ្រប់គ្រងការចោលសំរាម ដូចជាការផ្លាស់ប្តូរផ្នត់គំនិតរបស់ប្រជាពលរដ្ឋក្នុងការចោលសំរាមពាសវាលពាសកាល។ សកម្មភាពនេះនឹងជួយដល់ការការពារបរិស្ថាន បង្កើនសណ្តាប់ធ្នាប់ក្នុងក្រុង និងលើកសម្រស់ក្រុងសួង។ |
| ៣ | អភិវឌ្ឍន៍ស្ថានីយប្រព្រឹត្តិកម្មទឹកកខ្វក់បែបមជ្ឈការ (ប្រព័ន្ធមេរួម) សម្រាប់តំបន់ក្រុង | ការពារបាននូវចរន្តទឹកក្រោមដី ពីការហូរចូលនូវទឹកកខ្វក់ដែលមានសារជាតុពុលដែលចុងក្រោយនឹងប៉ះពាល់ដល់ដំណាំកសិកម្ម ធនធានធម្មជាតិនិងសុខភាពមនុស្ស នៅពេលប្រើប្រាស់ទឹកក្រោមដីនោះ។ |
| ៤ | ដាក់/កែលម្អបណ្តាញលូរំដោះទឹកស្អុយ/ទឹកភ្លៀង | អាចគ្រប់គ្រងបាននូវទឹកកខ្វក់ មិនមានការកកស្ទះ មិនមានជំនន់ទឹកភ្លៀង កាត់បន្ថយការប៉ះពាល់ជាអវិជ្ជមានទៅលើបរិស្ថាន បង្កើនសុវត្ថិភាពជីវៈចម្រុះ។ |
| ៥ | បង្កើតវិធីសាស្ត្រគ្រប់គ្រងភក់សំណល់ពីបង្គន់ (ក្នុងនោះមានការប្រមូល ដឹកជញ្ជូន និងការធ្វើប្រព្រឹត្តកម្ម/ប្រើប្រាស់ឡើងវិញ) | កាត់បន្ថយការចាក់ចោលនូវសំណល់ភក់ពីបង្គន់ទៅក្នុងប្រឡាយ ស្រះ បឹងធម្មជាតិ។ កែលម្អបរិស្ថាន ជីវចម្រុះ សុខភាពសាធារណៈ និងការលើកកម្ពស់សោភណ្ឌភាពក្រុង។ |
| ៦ | បង្កើតទីធ្លាសាធារណៈ (មានសួន និងតំបន់កំសាន្តពហុគោលបំណង) | លើកកម្ពស់សោភ័ណភាពក្រុង និងសុខភាពសាធារណៈ ទាក់ទាញភ្ញៀវទេសចរ និងបង្កើនសេដ្ឋកិច្ចក្នុងក្រុង។ |
| ៧ | អភិវឌ្ឍន៍ទួលធម្មជាតិតាបេងទៅជារមណីយដ្ឋានអេកូទេសចរណ៍ | ជាតំបន់វប្បធម៌ប្រវត្តិសាស្ត្រ អាចស្រូប/បង្កើនការអភិវឌ្ឍសេដ្ឋកិច្ចមូលដ្ឋានក្នុងក្រុង។ |
| ៨ | ផ្សព្វផ្សាយពីស្ថាបត្យកម្មបុរាណខ្មែរ | រក្សានូវសំណង់អគារ ផ្ទះដែលមានលក្ខណៈស្ថាបត្យកម្មបុរាណខ្មែរ ឱ្យមានលក្ខណៈស្តង់ដារក្នុងការលើកកម្ពស់សោភ័ណភាពក្រុង និងទាក់ទាញ ទេសចរណ៍។ |
| ៩ | សាងសង់ផ្លូវកៅស៊ូ និងបេតុង នៅក្នុងតំបន់ក្រុង និងការបំពាក់អំពូលភ្លើង LED ដើរដោយថាមពលពន្លឺព្រះអាទិត្យ | បង្កើនសោភ័ណភាព សុខភាពសាធារណៈ ទាក់ទាញទេសចរណ៍បង្កើនសេដ្ឋកិច្ចមូលដ្ឋាន។ |
| ១០ | អភិវឌ្ឍន៍ទីផ្សារផលិតផលកសិកម្មក្នុងស្រុក ដើម្បីជំរុញកំណើនសេដ្ឋកិច្ចមូលដ្ឋាន និងបង្កើតការងារបៃតង | បង្កើនកំណើនសេដ្ឋកិច្ចមូលដ្ឋាន តាមរយៈផលិតផលកសិកម្ម ដែលមានសក្តានុពលប្រកួតប្រជែងរបស់ក្រុងសួង។ សកម្មភាពនេះនឹងជួយបង្កើនចំណូលប្រជាពលរដ្ឋមូលដ្ឋាន និងឱកាសការងារជាច្រើនប្រកបដោយចីរភាព។ |

*ប្រភព៖ ការប្រឹក្សាយោបល់ជាមួយរដ្ឋបាលក្រុងសួង*

## ២.៤. ព័ត៌មានស្ថិតិសេដ្ឋកិច្ចសង្គម

| សន្ទស្សន៍ | ទិន្នន័យ (២០១៦) |
|---|---|
| ចំនួនប្រជាជន (នាក់) | ៣៨.៦៥០ |
| ដង់ស៊ីតេប្រជាជន (នាក់/គ.ម²) | ៤៦៦,៧៩ |
| អត្រាភាពក្រីក្រ (បទបង្ហាញពីសិក្ខាសាលា) (ភាគរយ) | ១៤% |
| ផ្ទៃក្រឡា (គ.ម²) | ៨២,៨០ |
| អត្រាអ្នកចេះអក្សរ (បទបង្ហាញពីសិក្ខាសាលា) (ភាគរយ) | ៩៨% |
| វិស័យសេដ្ឋកិច្ចសំខាន់ៗ | ពាណិជ្ជកម្ម |
| បំណែងចែកការងារតាមវិស័យផ្សេងៗ (ភាគរយ) | |
| - កសិកម្ម | ៣៧,៨% |
| - ផលិតកម្ម | ១,១% |
| - សេវាកម្ម | ៦១,១% |
| អត្រាគ្មានការងារធ្វើ | ១,៩៤% |
| ចំណាកស្រុក (ទៅក្រៅប្រទេស) (នាក់) | ១.០០២ |
| មធ្យមភាគទោចក្រយានយន្តក្នុងផ្ទះ (គ្រឿង) | ០,៨ |
| ចំនួនប្រជាជនដែលជាប់បំណុល(ធនាគារ ឬមីក្រូហិរញ្ញវត្ថុ) (នាក់) | ១.៥៣៨ |
| ចំនួនផ្ទះនៅសំណង់អនាធិបតេយ្យ/លំនៅឋានខុសច្បាប់ (ខ្នងផ្ទះ) | ៦០ |
| ចំនួនផ្ទះដែលទទួលឥទ្ធិពលពីខ្យល់ព្យុះ (ខ្នងផ្ទះ) | ០ |
| ចំនួនផ្ទះដែលទទួលឥទ្ធិពលពីទឹកជំនន់ (ខ្នងផ្ទះ) | ០ |
| ចំនួនផ្ទះដែលទទួលឥទ្ធិពលពីភាពរាំងស្ងួត (ខ្នងផ្ទះ) | ០ |
| ភាគរយផ្ទះដែលសេវាកម្មប្រមូលសំរាមអាចចូលទៅដល់ (ភាគរយ) | ១៦,៦២% |
| ភាគរយផ្ទះដែលមានលទ្ធភាពទទួលបានសេវាអនាម័យ (ភាគរយ) | |
| ភាគរយផ្ទះដែលមានប្រព័ន្ធទឹកតាមបំពង់ទុយោ (ភាគរយ) | |
| ភាគរយផ្ទះដែលមានភ្លើងប្រើប្រាស់ (ភាគរយ) | ៩៨,៩% |
| ចំនួនសំរាមក្នុងមួយថ្ងៃ (តោន) | ១៣ តោន |


ក្រុងសួង

# វិធីសាស្ត្រនៃការសិក្សាស្រាវជ្រាវ និងវិភាគទិន្នន័យ

## វិធីសាស្ត្រ និងដំណើរការ នៃការសិក្សាស្រាវជ្រាវ

ការរៀបចំផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ទីក្រុងនិរន្តរភាព គឺជាផ្នែកមួយនៃកម្មវិធីអភិវឌ្ឍន៍ទីក្រុងបៃតង ដែលកំពុងអនុវត្តដោយមានការសហការជាដៃគូរវាងក្រុមប្រឹក្សាជាតិអភិវឌ្ឍន៍ដោយចីរភាព (ក.ជ.អ.ច.) ក្រសួងមហាផ្ទៃតាមរយៈអគ្គនាយកដ្ឋានរដ្ឋបាល និងវិទ្យាស្ថានអភិវឌ្ឍន៍បៃតងសកល (GGGI) ក្នុងគោលបំណងដើម្បីរួមចំណែកដល់រាជរដ្ឋាភិបាលកម្ពុជាក្នុងការអភិវឌ្ឍសេដ្ឋកិច្ចប្រកបដោយនិរន្តរភាព កាត់បន្ថយផលប៉ះពាល់អវិជ្ជមានលើបរិស្ថាន និងឆ្លើយតបទៅនឹងការប្រែប្រួលអាកាសធាតុ។

ដើម្បីឱ្យដំណើរការរៀបចំផែនការយុទ្ធសាស្ត្រទីក្រុងនិរន្តរភាព អាចប្រព្រឹត្តទៅបានប្រកបដោយបរិយាប័ន្ន មានប្រសិទ្ធភាព និងស្របទៅតាមផែនការ និងទិសដៅរបស់រាជរដ្ឋាភិបាលក្រុមការងារគ្រប់គ្រងគម្រោង (Program Management Unit - PMU) ត្រូវបានបង្កើតឡើងដោយមានសមាជិកចូលរួមមកពីស្ថាប័នដៃគូ អនុវត្តន៍គម្រោង ។វិធីសាស្ត្រ និងដំណើរការនៃការសិក្សាស្រាវជ្រាវ បានឆ្លងកាត់ការប្រឹក្សាយោបល់ទូលំទូលាយទាំងនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ជាមួយបណ្ដាក្រសួង មន្ទីរពាក់ព័ន្ធ អាជ្ញាធរក្រុង អង្គការដៃគូអភិវឌ្ឍន៍ អង្គការក្រៅរដ្ឋាភិបាលជាតិ និងអន្តរជាតិ វិស័យឯកជន វិស័យសិក្សាធិការ និងស្ថាប័នស្រាវជ្រាវ។ ដំណើរការនៃការរៀបចំផែនការយុទ្ធសាស្ត្រនេះ គឺមានរយៈពេល ១ឆ្នាំ ក្នុងឆ្នាំ ២០១៧ ក្នុងនោះរួមមាន៖

### ការជ្រើសរើសក្រុងគោលដៅ

ការជ្រើសរើសក្រុងគោលដៅ សម្រាប់ជាករណីសិក្សាស្រាវជ្រាវ និងវិភាគក្នុងការបង្កើតផែនការយុទ្ធសាស្ត្រនេះ គឺត្រូវបានធ្វើឡើងជាពីរដំណាក់កាល។ ដំណាក់កាលទី១ គឺការប្រឹក្សាយោបល់ជាមួយស្ថាប័នដៃគូអនុវត្តន៍នៅថ្នាក់ជាតិក្នុងនោះរួមមានក្រុមប្រឹក្សាជាតិអភិវឌ្ឍន៍ដោយចីរភាព ក្រសួងមហាផ្ទៃ និងអង្គការដៃគូអភិវឌ្ឍន៍ដែលពាក់ព័ន្ធ ហើយបានជ្រើសរើសក្រុងសក្ដានុពលចំនួន ៩ ជាគោលដៅ។ ដំណាក់កាលទី ២ គឺការប្រឹក្សាយោបល់ជាមួយស្ថាប័នថ្នាក់ក្រោមជាតិតាមរយៈការចុះទៅសិក្សាផ្ទាល់ (Scoping Study) នៅតាមក្រុងគោលដៅដែលបានកំណត់នៅក្នុងដំណាក់កាលទី ១ និងការវិភាគពីស្ថានភាពភូមិសាស្ត្រ និងរចនាសម្ព័ន្ធរដ្ឋបាលនៃក្រុងដែលជាគោលដៅ ហើយបានធ្វើចំណាត់ថ្នាក់អាទិភាពក្រុងសក្ដានុពលទាំង ៩ ក្នុងការរៀបចំផែនការយុទ្ធសាស្ត្រទីក្រុងនិរន្តរភាព។

លទ្ធផលពីការប្រឹក្សាយោបល់ទាំងនៅថ្នាក់ជាតិនិងថ្នាក់ក្រោមជាតិ ការវិភាគលើឯកសារដែលមានស្រាប់ និងការប្រើប្រាស់លក្ខខណ្ឌវិនិច្ឆ័យ ដែលបានបង្កើតឡើងដោយក្រុមអ្នកជំនាញការទីក្រុងនិរន្តរភាពនៃវិទ្យាស្ថានអភិវឌ្ឍន៍បៃតងសកល (GGGI) (ដូចសង្ខេបក្នុងតារាងខាងក្រោម) ដើម្បីធ្វើចំណាត់ថ្នាក់អាទិភាពក្រុងគោលដៅ និងដោយពិចារណាទៅលើទំហំការងារ និងថវិកាដែលមាន ក្រុមការងារគ្រប់គ្រងកម្មវិធីបានជ្រើសរើសក្រុងគោលដៅចំនួន ៧៖

- ក្រុងសៀមរាប
- ក្រុងបាត់ដំបង
- ក្រុងព្រះសីហនុ
- ក្រុងបាវិត
- ក្រុងសួង
- ក្រុងកែប
- ក្រុងកំពង់ចាម

| លក្ខខណ្ឌវិនិច្ឆ័យជ្រើសរើសក្រុងគោលដៅ | ពន្យល់បន្ថែម |
|---|---|
| សក្តានុពលចូលរួមចំណែកផ្នែកសេដ្ឋកិច្ចដល់ដំណើរការអភិវឌ្ឍជាតិ | សារៈសំខាន់នៃសកម្មភាពសេដ្ឋកិច្ច ដើម្បីរួមចំណែកដល់ការអភិវឌ្ឍសេដ្ឋកិច្ចជាតិ និងកាត់បន្ថយភាពក្រីក្រ។ |
| មានសារៈសំខាន់ផ្នែកភូមិសាស្ត្រសម្រាប់ការធ្វើតុល្យភាពនៃការអភិវឌ្ឍតំបន់ | ការអភិវឌ្ឍប្រកបដោយនិរន្តរភាពរបស់ក្រុង គឺមានសារៈសំខាន់ រួមចំណែកដល់តុល្យភាពនៃការអភិវឌ្ឍទីប្រជុំជនរបស់ប្រទេសទាំងមូល។ |
| ចំណាប់អារម្មណ៍ និងការប្តេជ្ញាចិត្តរបស់រដ្ឋបាល មូលដ្ឋាន | កម្រិតនៃចំណាប់អារម្មណ៍ និងការប្តេជ្ញាចិត្តរបស់រដ្ឋបាលមូលដ្ឋានក្នុងការអភិវឌ្ឍក្រុងបៃតង។ |
| កំណើនប្រជាជន | ការព្យាករអត្រាកំណើននៃប្រជាជនក្នុងក្រុង។ សម្ពាធនៃការកើនឡើងចំនួនប្រជាជនតម្រូវឱ្យមានដំណោះស្រាយ ដើម្បីគាំទ្រដំណើរការអភិវឌ្ឍប្រកបដោយនិរន្តរភាព ឆ្ពោះទៅរកការអភិវឌ្ឍដែលមានលក្ខណៈធំជាងមុន មានសមភាព និងនិរន្តរភាពនៃតំបន់ក្រុង។ |
| បញ្ហាសង្គម និងបរិស្ថានមានច្រើនដែលទាមទារឱ្យមានដំណោះស្រាយបន្ទាន់ | កម្រិតនៃបញ្ហាប្រឈមផ្នែកសង្គម និងបរិស្ថានរបស់ទីក្រុង ដែលនឹងប៉ះពាល់ដល់ការអភិវឌ្ឍទីក្រុងបៃតង ក្នុងករណីមិនមានការដោះស្រាយនាពេលអនាគតដ៏ខ្លី។ |
| បរិបទផ្នែកគោលនយោបាយ និងការរៀបចំស្ថាប័ននៅកម្រិតក្រុងសម្រាប់ការអភិវឌ្ឍបៃតង | កម្រិតនៃបរិបទគោលនយោបាយ និងការរៀបចំស្ថាប័ននៅកម្រិតក្រុង នឹងអំណោយផលដល់ការអនុវត្តគម្រោងកម្មវិធី ឬជាកត្តាហានិភ័យដល់ការអនុវត្តគម្រោងកម្មវិធី។ ការរៀបចំ ស្ថាប័នដែលមានលក្ខណៈគាំទ្រដល់គម្រោងកម្មវិធី គឺមានសារៈសំខាន់ ខ្លាំងដើម្បីធានាដល់ភាពជោគជ័យនៃការអភិវឌ្ឍទីក្រុងបៃតង។ |
| មានជំនួយគាំទ្រពីដៃគូអភិវឌ្ឍន៍ផ្សេងទៀត | កម្រិតនៃជំនួយគាំទ្រដល់ក្រុង ដែលទទួលបានពីដៃគូអភិវឌ្ឍន៍ អង្គការជាតិ និងអន្តរជាតិនានា។ |

## ការសិក្សា និងវិភាគលើឯកសារសំខាន់ៗដែលមានស្រាប់

ឯកសារសំខាន់ៗជាច្រើនដែលពាក់ព័ន្ធទៅនឹងការអភិវឌ្ឍ និងវិនិយោគហេដ្ឋារចនាសម្ព័ន្ធក្នុងក្រុងដែលបានប្រមូលពីបណ្តាក្រុងគោលដៅ រួមមានឯកសារសិក្សាលើការបង្កើតផែនការមេប្រើប្រាស់ដី (ប្លង់គោល) ផែនការអភិវឌ្ឍរយៈពេលវែងរបស់ខេត្ត និងក្រុង កម្មវិធីវិនិយោគបីឆ្នាំរំកិលរបស់ក្រុង ផែនការអភិវឌ្ឍតាមវិស័យនានា របាយការណ៍ប្រចាំឆ្នាំ ក៏ដូចជាគោលនយោបាយ គោលការណ៍ណែនាំ ផែនការយុទ្ធសាស្ត្រពាក់ព័ន្ធនានារបស់រាជរដ្ឋាភិបាល ក្នុងការអភិវឌ្ឍខេត្ត/ក្រុង ដូចជាផែនការកម្មវិធីប្រកួតប្រជែងទីក្រុងស្អាតជាដើម ត្រូវបានប្រមូល និងធ្វើការសិក្សាវិភាគលម្អិតដោយក្រុមអ្នកជំនាញផ្តោតទៅលើកាលានុវត្តភាព បញ្ហាប្រឈមក្នុងវិស័យអាទិភាព និងសក្តានុពលនៃការអភិវឌ្ឍបៃតងតាមបណ្តាក្រុងដែលជាគោលដៅអភិវឌ្ឍន៍និរន្តរភាព។

## ការប្រមូល វិភាគ និងផ្ទៀងផ្ទាត់ទិន្នន័យ និងការប្រឹក្សាយោបល់នៅថ្នាក់ក្រោមជាតិ

ដំណើរការនៃការប្រមូល និងវិភាគលើទិន្នន័យមូលដ្ឋាន និងការចុះអង្កេតលើស្ថានភាពភូមិសាស្ត្រ ជាក់ស្តែងរបស់ក្រុងនីមួយៗ ត្រូវបានធ្វើឡើងចំនួន២លើក ក្នុងនោះរួមមានការពិភាក្សា និងប្រឹក្សាយោបល់លម្អិតជាមួយអាជ្ញាធរមូលដ្ឋាន រួមមានរដ្ឋបាលខេត្ត និងក្រុង មន្ទីរតាមវិស័យពាក់ព័ន្ធ វិស័យឯកជនដូចជាតំណាងវិស័យឯកជនក្នុងតំបន់សេដ្ឋកិច្ចពិសេសនៅក្រុងបាវិត និងក្រុងព្រះសីហនុ និងអង្គការសង្គមស៊ីវិលនានានៅតាមមូលដ្ឋាន។ លទ្ធផលពីការវិភាគលើឯកសារពាក់ព័ន្ធដែលមានស្រាប់ ក៏ត្រូវបានធ្វើការផ្ទៀងផ្ទាត់ជាមួយអាជ្ញាធរមូលដ្ឋាននៃបណ្តាក្រុងគោលដៅនីមួយៗដើម្បីផ្តល់សុពលភាពទៅលើទិន្នន័យនៅក្នុងឯកសារទាំងនោះ ក៏ដូចជាដើម្បីឆ្លុះបញ្ចាំងពីការវិវត្តរបស់ក្រុង។

| បេសកកម្មនៅថ្នាក់មូលដ្ឋាន | រយៈពេល | គោលបំណង |
|---|---|---|
| ការសិក្សាពីស្ថានភាព និងបរិបទមូលដ្ឋាននៅក្រុងទាំង ៩ ( scoping study ) | ចាប់ពីខែ ធ្នូ ២០១៦ ដល់ខែកុម្ភៈ ២០១៧ | ដើម្បីស្វែងយល់ពីស្ថានភាពភូមិសាស្ត្រ សង្គម សេដ្ឋកិច្ច និងបរិបទទូទៅនៃក្រុងនីមួយៗ ក៏ដូចជាស្វែងយល់ពីរចនាសម្ព័ន្ធរដ្ឋបាល និងការគាំទ្រពី អាជ្ញាធរមូលដ្ឋាន ក្នុងដំណើរការរៀបចំផែនការយុទ្ធសាស្ត្រទីក្រុងនិរន្តរភាព។ |
| ការចុះសិក្សា និងអង្កេតនៅក្រុងគោលដៅទាំង៧ លើកទី១ | ១១-២១ កក្កដា ២០១៧ | ដើម្បីធ្វើការផ្ទៀងផ្ទាត់ទិន្នន័យមូលដ្ឋានដែលទទួលបានពីឯកសារជាមួយអាជ្ញាធរ ក្រុង និងដើម្បីរៀបចំជាតារាងទិន្នន័យជាក់លាក់សម្រាប់ការរៀបចំផែនការយុទ្ធសាស្ត្រ ទីក្រុងនិរន្តរភាព។ ការចុះសិក្សានេះក៏ដើម្បីធ្វើការពិគ្រោះយោបល់ជាមួយអាជ្ញាធរក្រុងនូវផែនការសកម្មភាពវិនិយោគអាទិភាព និងការកំណត់ទិសដៅ និងគោលបំណង។ |
| ការចុះសិក្សា និងអង្កេតនៅក្រុងគោលដៅទាំង៧ លើកទី២ | ១៤-២៥ សីហា ២០១៧ | ដើម្បីធ្វើការបង្ហាញនូវផែនសេចក្តីព្រាងផែនការយុទ្ធសាស្ត្រទីក្រុងនិរន្តរភាព ផ្ទៀងផ្ទាត់ទិន្នន័យជាលើកទី ២ ជាមួយអាជ្ញាធរ ក្រុង និងដើម្បីរៀបចំជាតារាងទិន្នន័យជាក់លាក់សម្រាប់ការរៀបចំផែនការយុទ្ធសាស្ត្រ ទីក្រុងនិរន្តរភាព។ ការចុះសិក្សានេះក៏ដើម្បីធ្វើការបង្ហាញនិងពិភាក្សាជាមួយអាជ្ញាធរក្រុងនូវផែនការសកម្មភាពវិនិយោគអាទិភាព ទិសដៅ និងគោលបំណង ដែលបានកំណត់។ |
| ការធ្វើបច្ចុប្បន្នភាពទិន្នន័យ | ត្រីមាសទី ២-៣ ឆ្នាំ២០១៩ | មុននឹងមានការអនុម័តជាផ្លូវការ វិទ្យាស្ថានអភិវឌ្ឍន៍បៃតងសកល និងនាយកដ្ឋានសេដ្ឋកិច្ចបៃតង បានធ្វើបច្ចុប្បន្នភាពទិន្នន័យនៅក្នុងសេចក្តីព្រាងទាំងមូល។ |

## សិក្ខាសាលាពិគ្រោះយោបល់នៅថ្នាក់ជាតិ និងវគ្គបណ្តុះបណ្តាលខ្លី

សិក្ខាសាលាពិគ្រោះយោបល់ថ្នាក់ជាតិ ត្រូវបានរៀបចំឡើងចំនួន ៣លើក ជាបន្តបន្ទាប់ដែលរួមបញ្ចូលនូវវគ្គបណ្តុះបណ្តាលខ្លីៗស្តីពីការអភិវឌ្ឍបៃតង និងវិធីសាស្ត្ររៀបចំផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍បៃតង។ ការរៀបចំសិក្ខាសាលាពិគ្រោះយោបល់ថ្នាក់ជាតិ គឺមានការចូលរួមពីពហុភាគីពាក់ព័ន្ធទាំងថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិដូចជាក្រសួង និងស្ថាប័នពាក់ព័ន្ធនៅថ្នាក់ជាតិ អាជ្ញាធរខេត្ត/ក្រុង និងមន្ទីរជំនាញតាមវិស័យនៅក្រុងដែលជាគោលដៅ អង្គការដៃគូអភិវឌ្ឍន៍ អង្គការសង្គមស៊ីវិល និងវិស័យឯកជន ដើម្បីឆ្លុះបញ្ចាំងពីលទ្ធផលវិភាគលើឯកសារ ទិន្នន័យមូលដ្ឋានក្រុង ទិន្នន័យតាមវិស័យដែលបានប្រមូល និងអនុសាសន៍ដែលបានស្នើឡើងដោយក្រុមអ្នកជំនាញការក្នុងការបង្កើតផែនការសកម្មភាពអភិវឌ្ឍន៍ទីក្រុងបៃតង។ សិក្ខាសាលាពិគ្រោះយោបល់ថ្នាក់ជាតិ ក៏បានផ្តល់ឱកាសដល់សិក្ខាកាមដែលបានចូលរួម ធ្វើការពិភាក្សា និងឆ្លុះបញ្ចាំងពីស្ថានភាពជាក់ស្តែងក្នុងការកំណត់អាទិភាពទៅលើផែនការសកម្មភាពអភិវឌ្ឍន៍ទីក្រុងបៃតង ដោយប្រើប្រាស់នូវឧបករណ៍វិភាគពហុលក្ខខណ្ឌវិនិច្ឆ័យ (Multi-Criteria Analysis) តាមរយៈការដាក់ពិន្ទុទៅតាមលក្ខខណ្ឌវិនិច្ឆ័យ (Evaluation Criteria) នីមួយៗ។

សិក្ខាសាលាពិគ្រោះយោបល់ថ្នាក់ជាតិ ក៏បានបញ្ចូលនូវវគ្គបណ្តុះបណ្តាលខ្លីៗក្នុងនោះរួមមានវិធីសាស្ត្រ រៀបចំផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ទីក្រុងបៃតង ការគ្រប់គ្រងសំណល់រឹង/រាវ ការចែករំលែកចំណេះដឹង និងបទពិសោធន៍ទាក់ទងនឹងការគ្រប់គ្រងចំណីផ្លូវសម្រាប់អ្នកថ្មើរជើង និងវិធីសាស្ត្រនៃការកំណត់អាទិភាពគម្រោង ឬផែនការសកម្មភាពដោយប្រើប្រាស់ឧបករណ៍វិភាគបែបសេដ្ឋកិច្ច ដូចជា ឧបករណ៍វិភាគពីផលចំណេញធៀបនឹងការចំណាយ (Cost-Benefit Analysis - CBA) ការវិភាគប្រសិទ្ធភាពនៃការចំណាយ (Cost-Effectiveness Analysis-CEA) និងការវិភាគពហុលក្ខខណ្ឌវិនិច្ឆ័យ (Multi-Criteria Analysis - MCA)។

| សិក្ខាសាលា | ពេលវេលា & ទីតាំង | គោលបំណង |
|---|---|---|
| សិក្ខាសាលាចាប់ផ្តើមកម្មវិធី និងវគ្គបណ្តុះបណ្តាលខ្លី - កម្មវិធីអភិវឌ្ឍន៍ទីក្រុងបៃតងនៅកម្ពុជា (ដំណាក់កាលទី ២) | ១៤-១៦ មិថុនា ២០១៧ ក្រុងបាត់ដំបង | - បង្ហាញអំពីកម្មវិធីគម្រោង និងដើម្បីទទួលបានចំណាប់អារម្មណ៍ និងការប្តេជ្ញាចិត្តរបស់ភាគីពាក់ព័ន្ធក្នុងការចូលរួមអនុវត្តកម្មវិធីគម្រោង<br>- ប្រមូលមតិនិងការយល់ឃើញដែលពាក់ព័ន្ធនឹងផែនការ និងវិធីសាស្ត្រការងាររបស់កម្មវិធី<br>- ផ្តល់វគ្គបណ្តុះបណ្តាលខ្លីដល់ភាគីពាក់ព័ន្ធអំពីទស្សនទានអភិវឌ្ឍន៍ទីក្រុងបៃតង និងវិធីសាស្ត្ររៀបចំផែនការយុទ្ធសាស្ត្រអភិវឌ្ឍទីក្រុងបៃតង។ |
| សិក្ខាសាលាពិគ្រោះយោបល់ថ្នាក់ជាតិ និងវគ្គបណ្តុះបណ្តាលខ្លី - កម្មវិធីអភិវឌ្ឍន៍ទីក្រុងបៃតងនៅកម្ពុជា (ដំណាក់កាលទី ២) | ៣០-៣១ សីហា ២០១៧ ក្រុងសៀមរាប | - បង្ហាញពីលទ្ធផលវិភាគថ្នាក់ជាតិទៅលើសក្តានុពលអភិវឌ្ឍន៍ក្រុងបៃតងនៅក្នុងប្រទេសកម្ពុជា<br>- បង្ហាញលទ្ធផលពីការវាយតម្លៃទិន្នន័យមូលដ្ឋានរបស់ក្រុង<br>- ពិភាក្សាអំពីចក្ខុវិស័យ ទិសដៅ និងគោលដៅតាមវិស័យសម្រាប់ក្រុងនីមួយៗ<br>- ផ្តល់វគ្គបណ្តុះបណ្តាលស្តីពីវិស័យអភិវឌ្ឍន៍ក្រុងជាក់លាក់ដល់មន្ត្រីសាលាក្រុង |
| សិក្ខាសាលាពិគ្រោះ យោបល់ថ្នាក់ជាតិ និងវគ្គបណ្តុះ បណ្តាលខ្លី - កម្មវិធី អភិវឌ្ឍន៍ ទីក្រុងបៃតងនៅកម្ពុជា (ដំណាក់កាលទី ២) | ១៥-១៦ វិច្ឆិកា ២០១៧ ក្រុងកំពង់ចាម | - បង្ហាញអំពីទិដ្ឋភាពទូទៅនៃសេចក្តីព្រាងផែនការយុទ្ធសាស្ត្រថ្នាក់ជាតិសម្រាប់ទីក្រុងដែលមាន សក្តានុពលបៃតង និងប្រមូលមតិត្រឡប់ពីអ្នកចូលរួម<br>- ផ្តល់ការបណ្តុះបណ្តាលអំពីការកំណត់អាទិភាពគម្រោងក្រុងបៃតង<br>- ពិភាក្សាអំពីសកម្មភាពអាទិភាពសម្រាប់ការអភិវឌ្ឍក្រុងដែលមានសក្តានុពលបៃតង<br>- បង្ហាញអំពីលទ្ធផលនៃការវិភាគរបស់ក្រុមការងាររបស់ធនាគារពិភពលោក (World Bank) ស្តីពីស្ថានភាពតំបន់ក្រុងភ្នំពេញ និងពិនិត្យលើឱកាសអភិវឌ្ឍន៍ទីក្រុងបន្ទាប់ដែលមានសក្តានុពល<br>- ចែករំលែកពីការវិភាគបរិបទសម្រាប់កំណែទម្រង់លើបញ្ហាចំណតនៅរាជធានីភ្នំពេញ |

## ការផ្ទៀងផ្ទាត់ទិន្នន័យ និងការផ្តល់សុពលភាពលើផែនការយុទ្ធសាស្ត្រ

ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ទីក្រុងនិរន្តរភាព ត្រូវបានព្រាងឡើងដោយប្រើប្រាស់នូវទម្រង់ផ្លូវការដែលទទួលបានពីទីស្តីការគណៈរដ្ឋមន្ត្រី និងផ្អែកលើលទ្ធផលពីការសិក្សាស្រាវជ្រាវ និងវិភាគទៅលើឯកសារគតិយុទ្ធដែលមានស្រាប់ ការវិភាគលើទិន្នន័យមូលដ្ឋានទិន្នន័យតាមវិស័យ ការចុះទៅអង្កេតនៅមូលដ្ឋានលើស្ថានភាពភូមិសាស្ត្រជាក់ស្តែង ការប្រឹក្សាយោបល់ជាមួយអាជ្ញាធរទាំងនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ដៃគូអភិវឌ្ឍន៍ និងស្ថាប័នក្រៅរដ្ឋាភិបាលនានាដែលពាក់ព័ន្ធ និងលទ្ធផលពីសិក្ខាសាលាពិគ្រោះយោបល់ថ្នាក់ជាតិជាមួយគ្រប់ភាគីពាក់ព័ន្ធ។

កិច្ចប្រជុំផ្តល់សុពលភាពលើផែនការយុទ្ធសាស្ត្រ ត្រូវបានរៀបចំឡើងនៅថ្ងៃទី១០ ខែកក្កដាឆ្នាំ២០១៨ ដោយមានអ្នកតំណាងមកពីក្រុងទាំង៧ តំណាងក្រសួងមហាផ្ទៃ និងក្រុមប្រឹក្សាជាតិអភិវឌ្ឍន៍ដោយចីរភាព។ សេចក្តីព្រាងផែនការយុទ្ធសាស្ត្រត្រូវបានបង្ហាញក្នុងអំឡុងពេលកិច្ចប្រជុំហើយអ្នកចូលរួមត្រូវបានចាត់ជាក្រុមដើម្បីពិនិត្យឡើងវិញនូវផ្នែកផ្សេងៗនៃផែនការ។ មតិយោបល់ដែលប្រមូលបានពីការប្រជុំត្រូវបានដាក់បញ្ចូលនៅក្នុងសេចក្តីព្រាងចុងក្រោយដែលបានឆ្លងកាត់ការត្រួតពិនិត្យឡើងវិញដោយក្រុមការងារគ្រប់គ្រងគម្រោង (PMU) មុនពេលដាក់ស្នើសុំការសម្រេចអនុម័តជាផ្លូវការពីរដ្ឋាភិបាល។



ក្រុងព្រះសីហនុ

# ពាក្យបច្ចេកទេស និងនិយមន័យ

## ពាក្យបច្ចេកទេស និងនិយមន័យ

| ភាសាខ្មែរ | ភាសាអង់គ្លេស | ការពន្យល់ |
|---|---|---|
| ការអភិវឌ្ឍប្រកបដោយចីរភាព / និរន្តរភាព | Sustainable development | សំដៅដល់ការអភិវឌ្ឍដែលនាំមកនូវការរីកចម្រើនសេដ្ឋកិច្ចសង្គមប្រកបដោយចីរភាពបរិស្ថាន ដោយផ្អែកលើតុល្យភាពនៃបង្គោលគ្រឹះ ៤ គឺសេដ្ឋកិច្ច សង្គម បរិស្ថាន និងវប្បធម៌។ |
| ការអភិវឌ្ឍបៃតង | Green growth | ការអភិវឌ្ឍដែលប្រើប្រាស់ធនធានធម្មជាតិប្រកបដោយចីរភាព រួមមាន ការងារបៃតង បរិស្ថានបៃតង ទឹកនិងអនាម័យ សេដ្ឋកិច្ច និងវិនិយោគ ទូរគមនាគមន៍ និងដឹកជញ្ជូន ឧស្សាហកម្ម និងថាមពលបៃតង ទេសចរណ៍បៃតង សន្តិសុខស្បៀង និងសុវត្ថិភាពចំណីអាហារ និងការប្រើប្រាស់ដីធ្លី។ |
| សេដ្ឋកិច្ចបៃតង | Green economy | ការអភិវឌ្ឍសេដ្ឋកិច្ចប្រកបដោយប្រសិទ្ធភាព ដោយឈរលើមូលដ្ឋាននៃការប្រើប្រាស់ធនធានធម្មជាតិ ចីរភាពបរិស្ថាន ការងារបៃតង បច្ចេកវិទ្យាបៃតង និងកំណែទម្រង់សេដ្ឋកិច្ច ដោយគិតគូរបន្ថែមលើការលើកទឹកចិត្ត ដូចជា ពន្ធបៃតង ហិរញ្ញវត្ថុបៃតង ពិសេសឥណទាន និងមីក្រូហិរញ្ញវត្ថុបៃតងជាដើម។ |
| ការងារបៃតង | Green jobs | សំដៅដល់សកម្មភាពរបស់បុគ្គលនីមួយៗដែលបម្រើការនៅក្នុងវិស័យនានាដែលទាក់ទងនឹងការអភិវឌ្ឍបៃតង ដោយទទួលបានប្រាក់ចំណូល ដូចជាឧស្សាហកម្មបៃតង ហេដ្ឋារចនាសម្ព័ន្ធបៃតង វិនិយោគបៃតង ទេសចរណ៍បៃតង សេដ្ឋកិច្ចបៃតង កសិកម្មបៃតង ដឹកជញ្ជូនបៃតង បច្ចេកវិទ្យាបៃតង។ |
| ឧស្សាហកម្មបៃតង | Green Industry | ផលិតកម្មស្អាតដែលប្រើប្រាស់បច្ចេកទេសបៃតង ថាមពលប្រកបដោយប្រសិទ្ធផល និងកាត់បន្ថយការប្រើប្រាស់ធនធានធម្មជាតិនៅក្នុងខ្សែសង្វាក់ ផលិតកម្មនៃសហគ្រាសខ្នាតតូចនិងមធ្យម ដើម្បីធានាបាននូវចីរភាពធនធានធម្មជាតិ ដោយអនុវត្តគោលការណ៍ផលិតកម្មនិងការប្រើប្រាស់ប្រកបដោយចីរភាព។ |
| ការដឹកជញ្ជូនបៃតង | Green transport | ហេដ្ឋារចនាសម្ព័ន្ធ និងមធ្យោបាយដឹកជញ្ជូនផ្លូវគោក ផ្លូវទឹក ផ្លូវអាកាស ទូរគមនាគមន៍ និងបណ្តាញថាមពលអគ្គិសនី ដែលជួយលើកកម្ពស់បរិស្ថានបៃតង ដូចជាអយស្ម័យយានរថយន្តក្រុង ផ្លូវនាវាចរណ៍ បណ្តាញខ្សែកាប អុបទិក ប្រព័ន្ធផ្គាយរណប និងបណ្តាញខ្សែបញ្ជូនអគ្គិសនី។ |
| បច្ចេកវិទ្យាបៃតង | Green technology | បច្ចេកវិទ្យា និងប្រព័ន្ធបច្ចេកទេសដែលមិនបង្កការខូចខាតដល់បរិស្ថាន ដូចជាបច្ចេកវិទ្យាកាត់បន្ថយឧស្ម័នផ្ទះកញ្ចក់ បច្ចេកវិទ្យាកាត់បន្ថយការសាយភាយសារធាតុបំពុលបរិស្ថាន បច្ចេកវិទ្យាដែលប្រើប្រាស់ថាមពលប្រកបដោយប្រសិទ្ធភាព បច្ចេកវិទ្យាអភិវឌ្ឍន៍ស្អាតសម្រាប់ការកែច្នៃឡើងវិញ និងប្រើប្រាស់ឡើងវិញ នូវធនធានដែលប្រើប្រាស់រួចហើយ។ |
| ថាមពលបៃតង | Green energy | ប្រសិទ្ធភាពថាមពល ជាពិសេសការផលិត និងការប្រើប្រាស់ប្រភពថាមពលកកើតឡើងវិញដូចជា កម្លាំងខ្យល់ ពន្លឺព្រះអាទិត្យ កម្លាំងទឹករលក ជីវឧស្ម័ន ជីវម៉ាស ជីវឥន្ធនៈ និងវារីអគ្គិសនី។ |

| | | |
|---|---|---|
| ថាមពលកកើតឡើងវិញ | Renewable Energy | ថាមពលកើតពីធនធានដែលត្រូវបានបំពេញឡើងវិញដោយធម្មជាតិដូចជាជីវម៉ាស ភាវីអគ្គិសនី កម្ដៅចេញពីផែនដី ពន្លឺព្រះអាទិត្យ ខ្យល់កម្ដៅមហាសមុទ្រ ចលនាទឹករលក និងចលនាទឹកជោរនោច។ |
| ប្រសិទ្ធភាពថាមពល | Energy efficiency | អនុបាត(ratio)ថាមពលចេញ ដែលមានអត្ថប្រយោជន៍របស់ប្រព័ន្ធមួយ ដែលបានមកពីដំណើរការ ឬសកម្មភាពបំប្លែង ធៀបទៅនឹងថាមពលចូលរបស់ប្រព័ន្ធនោះ។ |
| ការប្រែប្រួលអាកាសធាតុ | Climate change | ការប្រែប្រួលស្ថានភាពអាកាសធាតុដែលអាចកំណត់អត្តសញ្ញាណបាន(តាមរយៈការវិភាគស្ថិតិ)តាមរយៈការប្រែប្រួលតួលេខមធ្យម និងតួលេខអថេរនៃអាកាសធាតុ ហើយការប្រែប្រួលនោះបន្តកើតឡើងក្នុងរយៈពេលវែងជាច្រើនទសវត្សរ៍ឬយូរជាងនេះ។<br><br>ការប្រែប្រួលអាកាសធាតុ អាចបណ្ដាលមកពីដំណើរផ្ទៃក្នុងរបស់ធម្មជាតិកម្លាំងជំរុញពីខាងក្រៅ ការប្រែប្រួលរយៈពេលវែងនៃសមាសភាពបរិយាកាស ឬសកម្មភាពមនុស្ស ដូចជា ការប្រើប្រាស់ដី ការបញ្ចេញឧស្ម័នពីរោងចក្រ ជាដើម។ ក្នុងមាត្រា១នៃអនុសញ្ញាក្របខ័ណ្ឌសហប្រជាជាតិស្ដីពីការប្រែប្រួលអាកាសធាតុ បានឱ្យនិយមន័យការប្រែប្រួលអាកាសធាតុជា "ការប្រែប្រួលអាកាសធាតុដែលជាប់ទាក់ទងដោយផ្ទាល់ ឬដោយប្រយោលទៅនឹងសកម្មភាពមនុស្ស ដែលធ្វើឱ្យផ្លាស់ប្ដូរសមាសភាពបរិយាកាសពិភពលោក និងការបន្ថែមលើការប្រែប្រួលអាកាសធាតុដោយសារធម្មជាតិ ដែលសង្កេតឃើញក្នុងរយៈពេលប្រហាក់ប្រហែលគ្នា"។ អនុសញ្ញានេះ បញ្ជាក់ពីភាពខុសគ្នារវាងការប្រែប្រួលអាកាសធាតុពីសកម្មភាពមនុស្ស ដែលបណ្ដាលឱ្យផ្លាស់ប្ដូរសមាសភាពបរិយាកាស និងអថេរអាកាសធាតុពីធម្មជាតិ។ |
| ផលផ្ទះកញ្ចក់ | Greenhouse effect | បាតុភូតនៃកំណើនសីតុណ្ហភាពខ្យល់នៅក្នុងលំហបិទជិតដោយកញ្ចក់ ឬកៅស៊ូប្លាស្ទិកថ្លា ដែលអនុញ្ញាតឱ្យ*កាំរស្មីព្រះអាទិត្យ* ឆ្លងកាត់ចូល តែមិនអាចឱ្យកាំរស្មីដែលមានជំហានរលកវែង ឆ្លងកាត់ចេញវិញបាន។<br><br>ពាក្យនេះត្រូវបានយកមកប្រើ ដើម្បីសម្គាល់បាតុភូតស្រដៀងគ្នានេះ ដែលកើតមាននៅក្នុងបរិយាកាសផែនដី។ អ្នកប្រាជ្ញភាគច្រើនអះអាងថា កំណើនកម្ដៅគួរឱ្យកត់សម្គាល់ចាប់ពីដើមសតវត្សរ៍នេះ បណ្ដាលមកពីកំណើននៃ*ឧស្ម័នកាបូនិក ឧស្ម័នក្លរ៉ូភ្លុយអូរ៉ូកាបូ មេតាន ឌីអាសូតម៉ូណូអុកស៊ីត*។ល។ ដែលប្រៀបដូចផ្ទះកញ្ចក់ មានប្រភពពីសកម្មភាពមនុស្ស ពិសេសពីការដុត*ឥន្ធនៈហ្វូស៊ីល*។ នៅពេលដែល ស្រទាប់ឧស្ម័នផ្ទះកញ្ចក់នៅក្នុងបរិយាកាសកើនលើសពីកម្រិតធម្មជាតិ កម្ដៅ ដែលចាំងផ្លាតពីផែនដីទៅ ពុំអាចចេញទៅក្នុងបរិយាកាសស្រទាប់លើបាន ហើយចាំង ខ្វាតមកផែនដីវិញ ដែលជាមូលហេតុនៃកំណើនសីតុណ្ហភាពខ្យល់នៅក្នុងបរិយាកាសស្រទាប់ក្រោម។ |
| បន្សាំ | Adaptation | ដំណើរការសម្របខ្លួនទៅនឹងអាកាសធាតុបច្ចុប្បន្ន ឬរំពឹងទុកទៅនឹងឥទ្ធិពលនៃអាកាសធាតុនោះ។ |
| ភាពធន់ | Resilience | សមត្ថភាពនៃប្រព័ន្ធសង្គម-អេកូឡូស៊ីដើម្បីទប់ទល់នឹងព្រឹត្តិការណ៍គ្រោះថ្នាក់ ឬការរំខានណាមួយ ដែលអាចឆ្លើយតបឬចាត់ចែងឡើងវិញតាមវិធីដែលអាចរក្សាបាននូវមុខងារសំខាន់ៗ អត្តសញ្ញាណ និងរចនាសម្ព័ន្ធ ហើយដែលអាចរក្សាបាននូវសមត្ថភាពបន្សាំ ការរៀនសូត្រ និងច្នៃប្រតិដ្ឋ។ |
| ច្រករបៀងបៃតង | Green corridor | "ច្រករបៀងបៃតង" គឺសំដៅទៅលើទំនាក់ទំនងនៃការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធសាធារណៈតាមវិស័យក្នុងទីក្រុង ឬតំបន់ទីប្រជុំជន ឧទាហរណ៍ផ្លូវថ្នល់ សួនច្បារតាមដងផ្លូវ ជាដើម។ល។" |

| | | |
|---|---|---|
| ច្រករបៀងខៀវ | Blue corridor | ច្រករបៀងខៀវ សំដៅទៅដល់ការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធសាធារណៈនៅក្នុងទីក្រុង ឬតំបន់ទីប្រជុំជនទាំងឡាយណាពាក់ព័ន្ធទៅនឹងចរន្តទឹក និងលំហូរនៃទឹកទាំងទឹកក្រោមដី និងលើដី។ |
| ចំហាក ឬសេណារីយ៉ូ | Scenario | សេចក្តីអធិប្បាយដ៏សាមញ្ញ និងដែលគួរឱ្យជឿជាក់បាន ថាតើ នាពេលអនាគតប្រហែលវាអាចនឹងកើតឡើងដូចម្តេច ដោយផ្អែកលើភាពប្រទាក់គ្នា និងសង្គតិភាពផ្ទៃក្នុងនៃការសន្មតពីកម្លាំង ជំរុញ និងទំនាក់ទំនងសំខាន់ៗ។ ចំហាកអាចកើតចេញពីការព្យាករ ប៉ុន្តែជាញឹកញាប់ច្រើនតែផ្អែកលើព័ត៌មានបន្ថែមពីប្រភពដទៃទៀត ហើយជួនកាលរួមផ្សំនឹងការពណ៌នាសាច់រឿង។ |
| ធុរកិច្ចតាមទម្លាប់ចាស់ | Business As Usual (BAU) | ការព្យាករតាមទម្លាប់ធម្មតា ត្រូវបានធ្វើឡើងដោយផ្អែកលើការសន្មត ដែលការងារប្រតិបត្តិ និងគោលនយោបាយនៅតែដូចទៅនឹងអ្វីដែលមាននាពេលបច្ចុប្បន្ន។ ទោះបីជាចំហាកគោល អាចបញ្ចូលលក្ខណៈពិសេសរបស់ចំហាកតាមទម្លាប់ ធម្មតា (ឧទាហរណ៍ ការហាមឃាត់បច្ចេកវិទ្យា ណាមួយ) ក៏ចំហាកតាមទម្លាប់ធម្មតាគ្មានទម្លាប់ប្រតិបត្តិ ឬគោលនយោបាយខុសពីបច្ចុប្បន្នឡើយ។ |
| ឧស្ម័នកាបូនិក | Carbon dioxide ($CO_2$) | ឧស្ម័នក្នុងបរិយាកាសផែនដីដែលកើតឡើងដោយធម្មជាតិ និងដោយការដុតឥន្ធនៈហ្វូស៊ីល (ប្រេងកាត ឧស្ម័នធ្យូងថ្ម...) ការដុតជីវម៉ាស និងការប្រែប្រួលការប្រើប្រាស់ដី និងដំណើរការឧស្សាហកម្ម ហើយជាឧស្ម័នផ្ទះកញ្ចក់ចម្បងដែលបង្កឡើងដោយសកម្មភាពមនុស្ស និងមានឥទ្ធិពលមកលើតុល្យភាពនៃចំណាំងផ្លាតនៃរំភាយរស្មីព្រះអាទិត្យមកលើផែនដី។ |
| ឱអាសូតម៉ូណូអុកស៊ីត | Nitrous Oxide ($N_2O$) | ឧស្ម័នផ្ទះកញ្ចក់មួយប្រភេទក្នុងចំណោមឧស្ម័នផ្ទះកញ្ចក់ ទាំង៦ ដែលត្រូវកាត់បន្ថយក្រោមពិធីសារក្យូតូ ដែលមានប្រភពសំខាន់ពីសកម្មភាពមនុស្ស គឺពីវិស័យកសិកម្ម (ការគ្រប់គ្រងដីនិងលាមកសត្វ) ការធ្វើប្រព្រឹត្តិកម្មសំណល់រាវ ចំហេះឥន្ធនៈហ្វូស៊ីល និងដំណើរការឧស្សាហកម្មគីមី។ ឱអាសូតម៉ូណូអុកស៊ីត($N_2O$) ក៏ត្រូវបានបង្កើតឡើងដោយធម្មជាតិ ពីប្រភពជីវសាស្ត្រជាច្រើនផ្សេងទៀត នៅក្នុងដី និងទឹក ជាពិសេសសកម្មភាពមីក្រូជីវសាស្ត្រនៅព្រៃត្រូពិកសើម។ |

*ប្រភព៖ (១) សទ្ទានុក្រម ការប្រែប្រួលអាកាសធាតុ រៀបចំដោយ ក.ជ.អ.ច. ឆ្នាំ២០១៧ និង (២) ផែនការយុទ្ធសាស្ត្រស្តីពីការអភិវឌ្ឍបៃតង ឆ្នាំ២០១៣-២០៣០ រៀបចំដោយ ក.ជ.អ.ច. ឆ្នាំ២០១៣។ ប្រភពទាំងពីរអាចរកបានតាមរយៈគេហៈទំព័រ ក.ជ.អ.ច. ដូចខាងក្រោម៖ www.camclimate.org.kh*

GGGI